


Scanned by CamScanner

# ១

## ច្រកស្នេហា

ច្រកស្នេហា, ក្រុងហ៊ីតវែល

ជិតដល់ពេលដែលមេឃត្រូវគ្រប់ដណ្ដប់ដោយភាពងងឹត នៅផ្លូវភាគខាងត្បូងរបស់ក្រុងហ៊ីតវែល នឹងភ្លឺចិញ្ចែងចិញ្ចាច ដោយភ្លើងស្អាតត្រកាលភ្នែក ទីកន្លែងមួយនេះត្រូវហៅថា **ច្រកស្នេហា**។ អ្នកទេសចរនិងប្រជាជននៃប្រទេសសាក់ខារៀ នឹងតម្រង់ទៅរកច្រកនោះ បើត្រូវការភ្លក្សរសជាតិសេចក្ដីសុខពីការទេសចរណ៍រាត្រី ទាំងសុរា និងស្រីស្អាត។

បុរស អាចធ្វើជាម្ចាស់របស់មនុស្សស្រីបណ្ដោះអាសន្នបានស្របច្បាប់ ដើម្បីមិនឱ្យកើតការលួចលាក់លក់សេវកម្មផ្លូវភេទ ឬបង្ខាប់បង្ខំមនុស្សស្រីឱ្យធ្វើការការងារនេះ ដោយគ្មានក្ដីមេត្តា។

ប្រទេសសាក់ខារៀ មានច្បាប់ការពារស្ត្រីលក់សេវាកម្មផ្លូវភេទ អាជីពនេះនៅក្នុងប្រទេសនេះជាអាជីពសុចរិត មានសិទ្ធិនៅក្នុងការប្រើប្រាស់ប្រាក់



Scanned by CamScanner

ឧបត្ថម្ភនានារបស់រដ្ឋបាល ជាអាជីពដែលត្រូវបង់ពន្ធជូនរដ្ឋបាល ប៉ុន្តែមិនមែនគ្រប់កន្លែងដែលអនុញ្ញាតឱ្យស្ត្រីលក់សេវាកម្មផ្លូវភេទ ចេញមកដើរខាងក្រៅផ្តេសផ្តាសបាន ទោះស្របច្បាប់ តែត្រូវមានការការពារ ដើម្បីមិនឱ្យកើតទំនាក់ទំនងផ្តេសផ្តាស ហើយស្ត្រីដែលត្រូវការរកស៊ីអាជីពនេះត្រូវកំណត់ទីតាំង នៅក្នុងច្រកស្នេហាប៉ុណ្ណោះ។

ច្រកស្នេហា ជាកន្លែងសម្រាប់បុរសមករកសេចក្តីសុខបណ្តោះអាសន្ន។ រោងរបាំស្រាត ណៃត៍ក្លឹប និងសេចក្តីសុខជាច្រើនទៀត ផ្នែកកាមារម្មណ៍ ត្រូវយកផ្តុំនៅក្នុងច្រកស្នេហា។

ដូចជា រោងរបាំស្រាត ណាខាងដៀ ដែលជារោងរបាំស្រាតល្បីឈ្មោះនៅក្នុងចំណោមរោងរបាំស្រាតទាំងតូច ទាំងធំរាប់សិបកន្លែងនៅក្នុងច្រកនេះ។ ណាខាងដៀ ត្រូវចាត់ទុកជារោងរបាំស្រាតធំ ដែលស្វាគមន៍តែភ្ញៀវកាបូបធំៗប៉ុណ្ណោះ និងជារោងរបាំស្រាត ដែលថ្លៃសំបុត្រចូលទស្សនាមានតម្លៃខ្ពស់ តែសម្រស់ស្ត្រីក៏ស្អាតលេចធ្លោ គួរឱ្យគយគន់ សឹងតែដកភ្នែកចេញមិនបាន។

រោងរបាំស្រាគឺជាកន្លែងផ្តល់សេវាកម្ម ដែលអ្នកណាក៏ដឹងថា ស្រីរបាំនៅក្នុងនោះ មានការងារពិសេស គឺលក់សេចក្តីសុខផ្នែកផ្លូវភេទឱ្យបុរស ដែលថ្លៃសេវាកម្មគឺអាស្រ័យទៅតាមលំដាប់របស់ស្រីរបាំ។ ស្រីរបាំមានតម្លៃខ្ពស់ជាង





Scanned by CamScanner

ស្រីលក់ផ្លូវភេទ ដែលលក់សេចក្តីសុខផ្នែកផ្លូវភេទឱ្យបុរសតែមួយមុខគត់ ព្រោះពួកនាងលក់សេចក្តីសុខ ដែលមិនត្រឹមតែរឿងលើគ្រែឱ្យបុរសប៉ុណ្ណោះទេ។

ស្រីរបាំនៅណាខាងជៀ ល្បីឈ្មោះរឿងការប្រណិប័តន៍ និងកាយវិការលើគ្រែ ដែលធ្វើឱ្យបុរសដូចបានឡើងឋានសួគ៌ ទាំងដែលនៅមានជីវិតរស់។

"បងស្រី"

មនុស្សស្រីមាឌល្អិតត្រសុលទៅរកបងស្រី ក្នុងបន្ទប់សម្រាកផ្ទាល់ខ្លួនរបស់ សាន់នី។ នៅណាខាងជៀ ស្រីរបាំដែលមានអ្នកចិញ្ចឹម នឹងទទួលបានសិទ្ធិពិសេសឱ្យមាន បន្ទប់សម្រាកផ្ទាល់ខ្លួន តែត្រូវមានថ្លៃចាយវាយសម្រាប់ផ្នែកនេះបន្ថែម ដែលនាងទទួលបានសិទ្ធិនេះ។

ម្ចាស់ជីវិត របស់នាង នាងហៅគេបែបនោះ ធ្វើការនៅលើកោះ ស៊ី រ៉ូវើរ ដែលមនុស្សទូទៅហៅថា កោះចោរ។ នាងមិនធ្លាប់សួររឿងផ្ទាល់ខ្លួនរបស់គេ ព្រោះនាងតួនាទីត្រឹមប្រណិប័តន៍ ឱ្យគេមានសេចក្តីសុខ ហើយពេលគេទទួលបានវា ហើយក៏ចាកចេញទៅ។

ម្ចាស់ជីវិតរបស់ សាន់នី នឹងមក ណាខាជៀ ពីរ ឬបីខែម្តង ឬអាចយូរជាងនោះ តែនាងមិនធ្លាប់សួរនាំទៀតនោះឯង ថាគេបាត់ទៅណា ព្រោះវាជាមិនមែនជារឿង ដែលនាងត្រូវដឹងទៀតនោះឯង។ រឿងដែលនាងត្រូវដឹងគឺបង្វឹក



Scanned by CamScanner

ថ្វីដៃនៅលើគ្រែ ដើម្បីគេ។

"កុំខ្លាចអី" សាន់នី ឱនទៅលួងលោមប្អូនស្រី។

ម្ដាយរបស់ពួកនាងត្រូវបោក មកលក់ខ្លួននៅប្រកស្នេហា ទោះមានការការពារ ប៉ុន្តែយុត្តិធម៌ពណ៌ប្រផេះតែងតែមានចន្លោះប្រហោងជានិច្ច។ ស្រីអាស៊ីមាឌល្អិតម្នាក់ ត្រូវឱនក្បាល ព្រមធ្វើការដែលខ្លួនមិនពេញចិត្ត រហូតដល់បង្កើតបានកូនស្រីពីរនាក់ ដែលពួកនាងមិនដឹងទេថា អ្នកណាជាឪពុករបស់ខ្លួន។

ពួកនាងធំធាត់ក្នុងរោងរបាំស្រាតណាខាងដៀ ពេលម្ដាយចែកឋានម្ចាស់ ណាខាដៀ ឈ្មោះថា ឃែរ៉លេ និង អាដាំ ជាស្វាមីក៏មើលថែពួកនាង។ គុណស្រ័យរបស់ ឃែរ៉លេ និង អាដាំ ច្រើនណាស់ ពេលគ្រប់អាយុម្ភៃឆ្នាំ សាន់នីក៏ត្រូវសងគុណដោយរាងកាយ ធ្វើការដែលនាងមិនប្រាថ្នា ប៉ុន្តែនាងគ្មានសិទ្ធិជ្រើសរើស។ សាន់នី ត្រូវជ្រើសរើស រវាងការធ្វើជាស្រីរបាំស្រាតលើវេទិកាមុន ឬលក់ខ្លួនឱ្យភ្ញៀវមុន។

ទោះជាប្រាប់ថាជាការលក់សិល្បៈលើរាងកាយ ប៉ុន្តែវាជាសិល្បៈនៃកាមារម្មណ៍នៅលើគ្រែ។ វាគ្រាន់តែជាពាក្យថ្លៃថ្នូរ ហើយមិនថាជ្រើសរើសធ្វើជាស្រីរបាំមុន ឬលក់ខ្លួនមុន នាងត្រូវធ្វើការទាំងពីរនេះដដែល តែជាសំណាងល្អរបស់ សាន់នី យប់ដំបូង ដែលត្រូវឡើងវេទិកាក្នុងឋានៈជាស្រីរបាំ នាងត្រូវបាន



ជ្រើសរើសឱ្យប្រណិប័តន៍បុរសដែលមកពីកោះចោរម្នាក់នោះ។

បន្ទាប់ពីនោះ នាងត្រូវបំពេញតួនាទីជាស្រីលក់ខ្លួនពេញរូបរាង នាងក្លាយជាស្រីរបស់គេ និងជាសំណាងល្អបន្តិចបន្តួច គឺគេចិញ្ចឹមនាង ទើបនាងមិនចាំបាច់ឡើងរាំ និងទទួលភ្ញៀវផ្សេងទៀត តែពេលនេះមានបញ្ហាធំដែលត្រូវចាត់ការតាមដែលសតិបញ្ញារបស់នាងអាចធ្វើបាន។

"សាន់នី"

សាន់នី ងើបឈរ មានស្រីក្មេងមុខមាត់ស្រស់ស្អាតត្រសុលមកបៀត។

"សួស្តី អ្នកស្រី"

"សួស្តី សួស្តីនាងដែរ ធីណា"

ឃែរ៉ល គឺអ្នកស្រី ចំណែក អាដាំ គឺអ្នកប្រុស ហើយការដែល ឃែរ៉ល មកទីនេះ ព្រោះគោលបំណងពាក់ព័ន្ធនឹង ធីណា ដែលនាងមានអាយុគ្រប់ម្ភៃឆ្នាំនៅខែក្រោយនេះ។

"មានអីឱ្យនាងខ្ញុំបម្រើឬ អ្នកស្រី"

"អ្នកណាទៅហ៊ានប្រើស្រីរបស់លោក ម៉ារីស ទៅ"

ឃែរ៉ស និយាយដោយសំឡេងតូចដាក់ សាន់នី។ ឃែរ៉ល នឹកច្រណែន សាន់នី ណាស់ដែរ ដែលមិនចាំបាច់ទៅបម្រើប្រុសផ្សេង បន្ទាប់ពីក្លាយជារបស់



Scanned by CamScanner

លោក ម៉ារីស។

"ខ្ញុំសុំអនុញ្ញាតអង្គុយបានទេ?"

"អញ្ជើញអ្នកស្រី"

សាន់នី ដាក់បង្គុយលើសាឡុង បន្ទាប់ពី ឃែរ៉ល អង្គុយរួចរាល់ ដោយមាន ធីណា មកអង្គុយបៀត។ ប្អូនស្រីមុខស្រស់ឱបដៃបងស្រីណែនដៃ ដោយការភ័យខ្លាច ព្រោះនាងមិនធ្លាប់បិទបាំងរឿងការសងបំណុលដែលនាង និង ប្អូនស្រីត្រូវសង។

ទោះធ្លាប់និយាយជាមួយ ឃែរ៉ល ថានាងដោះបំណុលជំនួសប្អូនស្រី ប៉ុន្តែ ឃែរ៉ល បែរជាបដិសេធយ៉ាងទន់ភ្លន់។ ឃែរ៉ល ជាមនុស្សបែបនេះ ទន់ភ្លន់តែអាត្មានិយម និងត្រូវការប្រាក់ពីការលក់សេវាកម្មផ្លូវភេទរបស់ស្រីរបាំ នៅណាខាងដៀ។

ឃែរ៉ល មើលថៃស្រីរបាំរបស់ខ្លួនឱ្យស្អាតទាក់ភ្នែកទាក់ចិត្ត ដើម្បីទារថ្លៃពីបុរសដែលជាប់ចិត្តជាប់ថ្លើមនឹងស្រីរបាំ ដែលនាង និង ប្អូនស្រី មានបំណុលច្រើនណាស់ ត្រូវសងរោងរបាំស្រោតនេះ ហើយពេលនេះបំណុលរបស់នាងត្រូវកាត់កងទូទាត់ក្នុងពេលមួយខែៗ។

បំណុលដែល ឃែរ៉ល អាងថាជាថ្លៃចិញ្ចឹមមើលថៃ មិនត្រឹមតែពួកនាង





Scanned by CamScanner

ទេ ដែលត្រូវអាងបែបនេះ នៅមានស្រីៗ ស្ទើរតែទាំងអស់នៅណាខាងដៀ មិនបូកបញ្ចូលអ្នកដែលស្ម័គ្រចិត្តដើរមកសុំឱ្យជ្រើសរើស ដើម្បីធ្វើជាស្រីរបាំបម្រើកាមលោកីយ៍។

"ខ្ញុំមានរឿងត្រូវសុំអនុញ្ញាតពី សាន់នី"

"រឿងអី ?"

"ហ៊ឺ! នៅមានរឿងអីទៀត បើមិនមែនរឿងរបស់ ធីណា"

យៃវ៉ល មើល ធីណា ដោយខ្សែភ្នែកមានន័យ ខួរក្បាលស្រមើស្រមៃដល់រូបិយប័ណ្ណកំពុងតែហោះហើរ ព្រោះ សាន់នី ថាស្អាតហើយ ក្មេងស្រី ធីណា នេះកាន់តែធំ កាន់តែស្អាតជាប់ចិត្តជាប់ភ្នែក រូបរាងសម្បុរសម្បកស្អាតគ្មានអ្វីឱ្យទាស់។

ធីណា ត្រូវតែក្លាយជាស្រីរបាំដែលរកប្រាក់ឱ្យ ណាខាដៀ បានច្រើនជាប្រវត្តិសាស្ត្រ ជាពិសេសនៅយប់ដេញថ្លៃព្រហ្មចារីរបស់នាង ព្រោះអ្នកដែលធ្វើស្ថិតិបានគឺ សាន់នី ហើយ ធីណា នឹងក្លាយជាអ្នកបំបែកស្ថិតិនោះ។ យៃវ៉លគិតការពេញចិត្តពេញថ្លើម គិតថាខ្លួនឯងចំជាសំណាងល្អដែលរក្សាទុកពីរនាក់បងប្អូននៅ ណាខាដៀ។

"មានអីឬ ?"



Scanned by CamScanner

"នែ៎! សាន់នី នាងក៏ដឹងថា ធីណា អាយុជិតម្ភៃហើយ"

"ចា៎ ខ្ញុំដឹង"

"ពេលគ្រប់អាយុម្ភៃឆ្នាំ គឺត្រូវតែធ្វើការដោះបំណុល"

"ចា៎ អ្នកស្រី"

"ខ្ញុំគិតថា ធីណា អាចចង់ហ្វឹកហាត់ការងារ"

"កុំអាលអី អ្នកស្រី ខ្ញុំចង់រង់ចាំឱ្យ ធីណា មានអាយុគ្រប់ម្ភៃឆ្នាំសិន"

ឃៃរ៉ល ចងចិញ្ចើមដាក់ចម្លើយនោះ តែត្រូវទប់អារម្មណ៍ ទោះយ៉ាងណា ធីណា ត្រូវតែធ្វើការឱ្យ ណាខាងដៀ ប៉ុន្តែ សាន់នី ជាស្រីសំណព្វរបស់លោក ម៉ារីស ដូច្នេះហើយ ឃៃរ៉ល ត្រូវតែចិត្តត្រជាក់ និងរង់ចាំដោយការអត់ធ្មត់។

"ការហ្វឹកហាត់នឹងធ្វើឱ្យការធ្វើការបានស្រួល"

"ដោយសមត្ថភាពរបស់អ្នកបង្វឹក ដែលខ្ញុំក៏ធ្លាប់ទទួលបានការបង្វឹក ខ្ញុំជឿថា ធីណា ត្រូវតែទទួលបានការដុសខាត់ដែលសក្តិសមពេលដល់វេលា"

"តាមចិត្តនាងចុះ"

"អរគុណអ្នកស្រីដែលយល់"

"អ៊ូ! ខ្ញុំត្រូវតែយល់ហើយ ដែលម៉ោនិយាយនេះ មិនមែនថាចង់បង្ខំទេ គ្រាន់តែគិតថាពេលវាជិតមកដល់ហើយ បង្វឹកទុកមុន វាល្អចំពោះ ធីណា"





Scanned by CamScanner

"ចាំ អ្នកស្រី អរគុណម្តងទៀត សម្រាប់ក្តីមេត្តាដែលមានចំពោះ ធីណា"

"មិនបាច់ក្រែងចិត្តទេ សាន់នី ធីណា ខ្ញុំអាណិតស្រឡាញ់នាងដូចកូនដូចក្មួយរបស់ខ្ញុំ"

មានញាតិចាស់ទុំណាបង្គាប់បង្ខំឱ្យអ្នកដែលខ្លួនឯងប្រាប់ថា អាណិតស្រឡាញ់នាងដូចកូនដូចក្មួយ លក់ខ្លួន យករាងកាយទៅដោះដូរយកប្រាក់ដើម្បីផលប្រយោជន៍របស់ខ្លួនឯង។

"ចាំ អ្នកស្រី"

"ធីណា មិនបាច់ខ្លាចទេ ការហ្វឹកហាត់វាមិនគួរឱ្យខ្លាចទេ

កាយវិការ ទឹកមុខរបស់ ធីណា ធ្វើឱ្យ ឃែរ៉ល ត្រូវងាកទៅលួងលោម។ ឃែរ៉ល ផ្តោតសំខាន់ទៅលើការមើលថែស្រីរបាំណាស់។ ស្ត្រីដែលមានមុខមាត់ស្រស់ស្អាត ឃែរ៉ល នឹងរកវិធីក្រាលអនាគតឱ្យ ដោយការធ្វើឱ្យមានបំណុលមិនមែនសាម៉ីខ្លួន តែជាបំណុលដែលក្រុមគ្រួសារបង្ក។

ឃែរ៉ល មិនប្រើស្រីរបាំឱ្យធ្វើការទាល់តែគ្រើមដៃគ្រើមជើង តែនឹងផ្តល់ការមើលថែឱ្យស្អាតដូចកូនអ្នកមាន ដែលមានស៊ីមានចុក ចំណែកអ្នកដែលមានមុខមាត់មិនស្អាត និងមិនជាប់ជម្រើស ឱ្យធ្វើជាអ្នកបម្រើ មានការបែងចែកការងារគ្នាច្បាស់លាស់នៅ ណាខាដៀ។



Scanned by CamScanner

"ចាំ...ចាំ អ្នកស្រី"

ធីណា មិនហ៊ានប្រសព្វភ្នែកនឹងម្ចាស់ ណាខាដៀ ពេលមើលហើយក៏ប្រញាប់គេចភ្នែក ដោយអាការៈភ័យខ្លាច។

"បើអ៊ីចឹង ខ្ញុំទៅសិនហើយ"

ឃៃវ៉ល ញញឹមដាក់ពីរនាក់បងប្អូន ហើយងើបឈរ។

"ចាំ អ្នកស្រី អរគុណដែលមកសួរសុខទុក្ខ"

សាន់នី ទះស្មាប្អូនស្រី ហើយបេះដៃ ធីណា ចេញ ដើម្បីជូនដំណើរ ឃៃវ៉ល ដល់មុខបន្ទប់។

"បង សាន់នី"

ធីណា ឱបបងស្រីជាប់ មិនឱ្យរបេះដៃ។ សាន់នី មិនបានបិទបាំងរឿងបំណុល និងការចាំបាច់ដែលត្រូវធ្វើការដោះបំណុល។ ធីណា អាណិតបងស្រី តែក្នុងសំណាងអាក្រក់ក៏មានសំណាងល្អ ព្រោះបងស្រីទទួលបានការចិញ្ចឹមពី ម៉ារីស។ ការធ្វើជាស្រីរបស់បុរសម្នាក់នោះក៏មិនអាក្រក់អាក្រីអីដែរ បើធៀបនឹងការដែលបងស្រី ត្រូវធ្វើជារបស់កម្សាន្តអារម្មណ៍ត្រេកកាមរបស់បុរសចម្រុះមុខមាត់។





Scanned by CamScanner

"កុំខ្លាចអី ធីណា"

"បង សាន់នី ខ្ញុំខ្លាចណាស់"

"បងនឹងរកវិធីជួយ ធីណា ឱ្យបាន"

"បើការជួយខ្ញុំ ធ្វើឱ្យបងមានរឿង បងកុំជួយអី"

សាន់នី ឱបប្អូនស្រីណែនដៃ។ ធីណា ជាគ្រួសារតែម្នាក់គត់ ដែលនាងមាន ជាក្ដីស្រឡាញ់ និងជាសេចក្ដីសុខរបស់នាង ហើយនាងសច្ចារួចហើយថា ត្រូវតែការពារប្អូនស្រីឱ្យបាន ទោះត្រូវដោះដូរដោយជីវិតខ្លួនឯងក៏ដោយ។

សាន់នី ធ្វើខ្លួនជាម្ដាយរបស់ ធីណា ដែលជាប្អូនស្រីដែលទន់ភ្លន់ និងយកចិត្តទុកដាក់មើលថែប្អូនស្រី ឱ្យមានគំនិតល្អប្រពៃខុសពីនាង។ ពេល ធីណា មានក្ដីសុខ នាងក៏មានសេចក្ដីសុខ ស្នាមញញឹមស្រស់ស្រាយរបស់ប្អូនស្រី ជាអ្វីដែលនាងត្រូវរក្សាទុក រួមទាំងជីវិតរបស់ ធីណា ត្រូវតែល្អជាងនាងដែរ។ ប្អូនស្រីដ៏សែនបរិសុទ្ធ ចិត្តគំនិតប្រពៃ ទាំងទន់ភ្លន់ ទាំងផ្អែមល្ហែម ត្រូវតែគ្មានជីវិតប្រឡាក់ប្រឡូកក្នុងលោកីយ៍ គួរឱ្យខ្ពើមរអើម ដូចនាងកំពុងនៅ។

នាងព្យាយាមរកផ្លូវចេញរឿងរបស់ ធីណា ទុកមុនមួយឆ្នាំហើយ តែរកមិនទាន់ឃើញ។ ពេលវេលាបីខែទៀតដែលនៅសល់ នាងត្រូវតែធ្វើឱ្យបានសម្រេច មិនព្រមឱ្យប្អូនស្រីក្លាយជាស្រីរបាំស្រាតនៅ ណាខាដៀ ដាច់ខាត



Scanned by CamScanner

ព្រោះខ្លាចមិនសំណាងល្អ    មានមនុស្សប្រុសកក់ខ្លួនប្រាណរយៈពេលមួយឆ្នាំ ដូចនាង ព្រោះនាងមិនគិតថាខ្លួនឯងសំណាងល្អរហូត ថ្ងៃមួយ ម៉ារីស ធុញទ្រាន់ខ្លួនប្រាណរបស់នាងហើយ ចាប់អារម្មណ៍ស្រីរបាំថ្មី ពេលនោះ គេនឹងលុបចោលការទិញនាងផ្ដាច់មុខ នាងក៏ត្រូវទទួលភ្ញៀវផ្សេងទៀត។

ជីវិតដូចរស់នៅក្នុងនរកបែបនោះ នាងមិនព្រមឱ្យ ធីណា ជួបដាច់ខាត នាងមិនព្រមឱ្យប្អូនស្រីត្រូវប្រថុយ។ ធីណា មិនដូចនាង ប្អូនស្រីទាំងទន់ជ្រាយ និងផុយស្រួយ មិនអាចទទួលយករឿងបែបនោះបានទេ។

"បងគ្មានរឿងអីទេ ហើយបងត្រូវតែជួយ ធីណា ឱ្យបាន"

"បងសន្យាសិនម៉ោ"

ពេល ធីណា សុំការសន្យា សាន់នី ក៏អង្អែលថ្ពាល់ប្អូនស្រី ហើយឱនទៅថើបថ្នមៗ និងញញឹមស្រទន់ដាក់ មិនឱ្យប្អូនស្រីខ្វល់ខ្វាយ។

"បងសន្យា"

"ខ្ញុំរាងសប្បាយចិត្តបន្តិច"

"ទៅឃើញស្អីឬអត់ ?"

សាន់នី សួរ ព្រោះស្គាល់ប្អូនស្រីច្បាស់។ ធីណា អាចឃើញហេតុការណ៍អ្វីហើយ ទើបមានភាពខ្វល់ខ្វាយចំពោះរឿងរបស់នាងខ្លាំងយ៉ាងនេះ។





Scanned by CamScanner

"និយាយបានទេ?"

"និយាយម៉ោ"

ធីណា គ្មានអាថ៌កំបាំងចំពោះបងស្រី ពេលដកដង្ហើមធំ បន្ធូរអារម្មណ៍ហើយ ក៏សម្រេចចិត្តនិយាយ។

"ពីម្សិល ខ្ញុំឃើញមនុស្សត្រូវវ៉ៃ"

"ត្រូវវ៉ៃឬ?"

"ចាំ មែន ខ្ញុំចៃដន្យទៅឃើញនៅក្រោយ ណាខាដៀ បានឮគេនិយាយគ្នាថាអ្នកដែលត្រូវវ៉ៃនោះ រត់គេច ព្រោះមិនចង់ធ្វើជាស្រីរបាំ"

ឃៃរ៉ល និង អាដាំ ថ្នាក់ថ្នមស្រីរបាំ ដើម្បីផលប្រយោជន៍ក៏ពិតមែន ប៉ុន្តែសម្រាប់អ្នកដែលប្រឆាំង ពីរនាក់នោះនឹងចាត់ការដោយវិធីសាហាវ ដើម្បីមិនឲ្យយកធ្វើជាគំរូមិនល្អ ធ្វើឲ្យស្រីរបាំឯទៀត បង្កបញ្ហាឲ្យ ណាខាដៀ។

"មានអ្នកណាឃើញឯងឬអត់?"

"គ្មានទេ ខ្ញុំពួន"

"សំណាងល្អ ត្រូវតែប្រយ័ត្ន រឿងបែបនេះ កុំចូលទៅរវីរវល់"

សាន់នី បារម្ភពីប្អូនស្រីខ្លាំងណាស់ ទោះនាងមិនចូលចិត្ត ក៏ត្រូវតែអរគុណ ម៉ារីស ដែលគេព្រមចំណាយប្រាក់ប្រចាំខែឲ្យ ណាខាដៀ ដើម្បីបាន



Scanned by CamScanner

ស្នាក់នៅក្នុងបន្ទប់ធំ ដែលមានបន្ទប់ដេកពីរ ទើបនាងយកប្អូនស្រីមកនៅជាមួយបាន។

"ចាំ បងស្រី"

អ្នកណាចង់ថានាងអាត្មានិយម ក៏តាមតែគេទៅ ប៉ុន្តែនាងនិងប្អូនស្រីជួយខ្លួនឯងមិនទាំងបានផង តើចង់ចេញមុខធ្វើជាវីរនារី ចេះដឹងរឿងអ្នកដទៃម៉េចនឹងបាន។

"រឿងផ្សេង ឯងកុំគិតច្រើន បងនឹងរកវិធីជួយឲ្យបាន"

"ចាសបងស្រី"

"ហើយបងប្រាប់ម្តងទៀត ឯងត្រូវត្រៀមខ្លួនឲ្យរួចរាល់ ក្រែងលោត្រូវចេញពីទីនេះភ្លាមៗ"

សាន់នី មិនបារម្ភពីសុវត្ថិភាពខ្លួនឯង ដូចសុវត្ថិភាពរបស់ប្អូនស្រី។ ការដែលនាងបញ្ជូនប្អូនស្រីចេញពី ណាខាដៅ គឺត្រូវតែត្រៀមចិត្តសម្រាប់ខ្លួនឯងដែរ។

"ត្រូវទៅដែរឬ?"

"បើនៅទីនេះ គឺត្រូវធ្វើមុខរបរដូចបង"

"តែខ្ញុំចង់នៅជាមួយបង"



"ដល់វេលាត្រូវទៅ គឺត្រូវនៅឆ្ងាយគ្នាសិន បើឯងចេញពីទីនេះបាន បងនឹងរង់ចាំថ្ងៃដែលឯងមកជួយបង យល់ទេ"

"ខ្ញុំមិនយល់ប៉ុន្មានទេ តែខ្ញុំស្ដាប់បង្គាប់បង"

"ក្មេងល្អ ស្ដាប់បង្គាប់បងល្អហើយ ព្រោះបើមិនស្ដាប់បង្គាប់បង ឯងនឹងធ្វើឲ្យបងមិនសប្បាយចិត្ត"

"ខ្ញុំមិនធ្វើឲ្យបងមិនសប្បាយចិត្តទេ"

សាន់នី ប្រសព្វភ្នែកនឹងប្អូនស្រី រិះរកផ្លូវចេញនៃបញ្ហានេះ ហើយគំនិតមួយក៏ផុសថ្ពោលនៅក្នុងខួរក្បាល នាងដឹងថាជាវិធីដែលប្រថុយ និងមិនអាចទទួលបានជំនួយ ប៉ុន្ដែនាងចង់សាកល្បងម្ដង ក្រែងលោជោគជតាជួយនាង។

"បងស្រី"

សាន់នី កំពុងតែភ្លឹក នាងត្រូវរៀបចំលំដាប់គំនិតរបស់ខ្លួនឯង ហើយរង់ចាំការមកដល់របស់គេ។

"បងស្រី"

អាការៈស្ងប់ស្ងាត់របស់បងស្រី ធ្វើឲ្យ ធីណា ខ្វល់ខ្វាយ ទើបហៅហើយហៅទៀត និងអង្រួនតិចៗ។

"ហ៊ឺ? មានអីឬ?"

"បងអង្គុយភ្លឹក ខ្ញុំបារម្ភ"

"បងមានរឿងត្រូវគិត"

"បងកុំគិតច្រើនពេក"

"ត្រូវតែគិតច្រើន ព្រោះវាជារឿងពាក់ព័ន្ធនឹងឯង"

ធីណា មើលបងស្រីដោយការព្រួយបារម្ភ។ បងស្រីបារម្ភពីនាង នាងក៏បារម្ភពីបងស្រីដែរ បងស្រីជាក្រុមគ្រួសារតែម្នាក់គត់របស់នាង ទាំងបង និងជាម្ដាយ ទោះមានអាយុឆ្ងាយគ្នាមិនដល់ពីរឆ្នាំក៏ដោយ។

"ខ្ញុំបារម្ភពីបងដូចគ្នា"

"មិនបាច់បារម្ភពីបងទេ បងមើលថែខ្លួនឯងបាន"

"បងចេះបារម្ភពីខ្ញុំ"

"ព្រោះឯងមើលថែខ្លួនឯងមិនបានដូចបង"

សាន់នី មិនមែនជាមនុស្សរឹងមាំ ប៉ុន្តែនាងត្រូវតែធ្វើខ្លួនឲ្យរឹងមាំ បើនាងទន់ជ្រាយ ជីវិតរបស់នាងនិងប្អូនស្រីនឹងជួបស្ថានការណ៍អាក្រក់ជាងនេះ។

"បងកុំគិតច្រើន បើទៅជាឈឺ ខ្ញុំបារម្ភ"

"បងមិនបណ្ដោយឲ្យខ្លួនឯងឈឺទេ ទាល់តែបងជួយឯងបានសម្រេច"

"ខ្ញុំទៅមើលម្ហូបឲ្យបងសិន រង់ចាំខ្ញុំមួយភ្លែត"





Scanned by CamScanner

ធីណា ស្រវាឱបបងស្រី ហើយងើបដើរចេញទៅ។ តួនាទីសំខាន់របស់ធីណា គឺរៀបចំម្ហូបអាហារឲ្យបងស្រី។ សម្រាប់មនុស្សស្រីនៅ ណាខាដៀ ដែលមានអ្នកចិញ្ចឹម រឿងម្ហូបអាហារ ការហូបចុក ត្រូវបែងចែកលំដាប់តាមរយៈតម្លៃបន្ទប់ស្នាក់នៅរបស់ស្រីរបាំនោះ។

**ម៉ារីស ឃើញភាពធូរទ្រូងដែល សាន់នី បង្ហាញឲ្យឃើញ ដូចនាងកំពុង** ទន្ទឹងរង់ចាំការមកដល់របស់គេ តែគេមិនសូវច្បាស់ប៉ុន្មាន ព្រោះនាងជាស្រីលក់ខ្លួនឆ្មើងឆ្មៃ ដែលព្រមដេកជាមួយគេព្រោះការចាំបាច់ ទោះរាងកាយរបស់នាងព្រមឲ្យគេ ប៉ុន្តែនោះមកពីបទពិសោធរឿងលើគ្រែដ៏ជោគជាំ ដែលគេយកវាមកល្បួងរាងកាយរបស់នាងប៉ុណ្ណោះ តែបេះដូងរបស់នាង មិនព្រមចុះញ៉មគេ។

ម៉ារីស សប្បាយនឹងការចាប់នាងសង្កត់នៅលើគ្រែ អាការៈចិត្តមិនយល់ព្រម តែរាងកាយបដិសេធមិនបានរបស់នាង ធ្វើឲ្យគេភ្លើតភ្លើន ហើយគ្រប់ពេលដែលឆៀងមករកនាង ទោះនាងស្វាគមន៍គេដោយមារយាទដ៏ប្រពៃ គឺមកពីនាងធ្វើតាមតួនាទី មិនធ្លាប់ធ្វើឲ្យគេដឹងថានាងនឹកគេ និងចង់ជួបគេដល់ថ្នាក់ញ៉រខ្លួនដូចដែលស្រីផ្សេងមានអាការៈ នេះអាចជាហេតុផលមួយ ដែលធ្វើឲ្យគេមិនទាន់ធុញទ្រាន់នាង។



Scanned by CamScanner

"លោក ម៉ារីស"

តាមធម្មតាពេលជួបគ្នា បន្ទាប់ពីឱនគំនាប់ដើម្បីធ្វើការគោរពគេតាមទំនៀមទម្លាប់នៃការប្រណិប័តន៍ខ្លួនរបស់ ណាខាដៀ ហើយ សាន់នី មិនដើរមករកគេមុន បើគេមិនបង្គាប់ង្ហំ តែម្តងនេះនាងដើរលឿនស្លេវតែម្តង មករកគេមកឈរនៅចំពោះមុខគេ ឲ្យគេលូកដៃទៅឱបចង្កេះរបស់នាង។

នាងក្រាញបន្តិច តែបន្ទាប់មកក៏ព្រមទន់ភ្លន់ ត្រសុលមករក ទើបគេទម្លាក់ភ្នែកចុះ លាក់ពន្លឺម៉្យាងនៅក្នុងកែវភ្នែករបស់ខ្លួនឯង។ សាន់នី ប្រហែលត្រូវការអ្វីម៉្យាងពីគេ នាងអាចទាមទារសុំរបស់ថ្លៃៗ ដូចដែលមនុស្សស្រីនៅណាខាដៀ ត្រូវការ។

*អស់ពេលសាងរូបភាពហើយឬយ៉ាងម៉េច!*

គេនឹកភាពប្លែកៗរបស់នាង ទើបព្រមចំណាយប្រាក់ដើម្បីធ្វើឲ្យនាងក្លាយជាស្រីរបស់ខ្លួនឯងតែម្នាក់ មិនចាំបាច់បម្រើភ្ញៀវផ្សេងទៀត។

"សួស្តីសំណព្វចិត្ត"

គេចាប់ចង្ការរបស់នាងភ្ញើយ ហើយឱនទៅថើបជញ្ជក់បបូរមាត់ទន់ល្មើយថើបនាងខ្លាំងៗ ដោយមិនខ្វល់ពីខ្សែភ្នែករបស់អ្នកដទៃ ខណៈដែល សាន់នីចង់រុញច្រានគេចេញ ប៉ុន្តែស្មារតីរបស់នាងបញ្ជាការ ឲ្យព្រមធ្វើតាមចិត្តគេ បើ





Scanned by CamScanner

នាងត្រូវអង្វរករគេ។

*ប្លែកណាស់!*

បុរសដែលចូលមកក្នុងនេះ ក្នុងនាម ម៉ារីស មានចេតនាថើបនាង ហើយគេក៏បានចម្លើយ ថាមានអ្វីម្យ៉ាងប្រែប្រួល ទើបដកបបូរមាត់ចេញឲ្យឆ្ងាយពីបបូរមាត់ទន់ល្មើយទាំងលំបាក មាត់របស់នាងផ្អែម ថើបប៉ុន្មានដងក៏មិនធ្លាប់ធុញទ្រាន់ ហើយឈ្ងោកទៅពិនិត្យមើលបបូរមាត់ញ័រទទ្រើតរបស់នាងដោយការពេញចិត្ត។

"នាងសប្បាយចិត្ត ដែលបានជួបខ្ញុំឬយ៉ាងម៉េច"

"អឺ...ចាស"

សាន់នី ត្រូវឆ្លើយយកចិត្តគេសិន និងឱបក្រសោបគេណែនដៃ គេក៏ងាកទៅបក់ដៃឲ្យមនុស្សរបស់ខ្លួនទៅរកសេចក្តីសុខ ចំណែកគេមិនចាំបាច់ជ្រើសរើសស្រីណាទៀតទេ ព្រោះគេមានមនុស្សស្រីជារបស់ខ្លួនឯងហើយ។

"លោក ម៉ារីស"

ម៉ារីស ងាកទៅមើល ឃែរ៉ល ដែលដើរលឿនស្លេវ ញញឹមពព្រាយមករាក់ទាក់។ គេមើលម្ចាស់ ណាខាដៀ ដោយដៃនៅតែឱបចង្កេះរបស់ សាន់នី។

"សុំទោសផង ដែលមិនបានចេញទៅទទួល"

ឃៃរ៉ល ជាប់រវល់ទទួលភ្ញៀវវីអាយភីផ្សេងទៀត ប៉ុន្តែសម្រាប់ ម៉ារីស គេគឺជាភ្ញៀវលំដាប់ស៊ុបពើវីអាយភីរបស់នាង ព្រោះក្រៅពីគេចំណាយលុយច្រើនហើយ នៅចិត្តទូលាយដាក់កូនចៅ ឲ្យសិទ្ធិជ្រើសរើសស្រីរបាំទៅបម្រើ។ ការបង្ហាញខ្លួនរបស់ ម៉ារីស មានន័យដល់ប្រាក់ដែលនឹងហូរចូល រោងរបាំស្រោតមួយនេះ។

"មិនអីទេ"

ឃៃរ៉ល មិនធ្លាប់ដឹងទេថា ម៉ារីស ធ្វើការអ្វីនៅលើកោះចោរ តែតំណែងរបស់គេនៅទីនោះប្រហែលមិនមែនតំណែងតូចតាច គេអាចស្និទ្ធស្នាលនឹងម្ចាស់កោះចោរ ជីសាស់ ស៊ី រ៉ូវើ ក៏ថាបាន ឬមិនអីចឹង គឺត្រូវតែធ្វើការជិតមនុស្សសំខាន់ណាម្នាក់នៅលើកោះចោរ។

"តែនាងខ្ញុំក៏ប្រញាប់ប្រញាល់មកទទួលលោក ម៉ារីស"

"បាទ"

ម៉ារីស ងាកទៅថើបសៀតផ្ការបស់មនុស្សស្រីនៅក្នុងរង្វង់ដៃ សាន់នី ក៏ងើយមើលមុខគេ កែវភ្នែករបស់នាងកាចបែបមនុស្សហ្លួងហែងខ្លួន ទាំងដែលត្រូវគេចាត់ការ ឡើងស៊ាំទៅហើយ ប៉ុន្តែមើលទៅនាងដូចទើបតែនឹកឃើញ ទើបកំហឹងនៅក្នុងកែវភ្នែកមួយគូនោះ វារលាយបាត់។





Scanned by CamScanner

តែមមាត់របស់ ម៉ារីស ញោចចេញជាស្នាមញញឹម គេគិតមិនខុសដែលមករកសេចក្តីសុខនៅទីនេះ បន្ទាប់ពីការសម្រាករបស់គេ មុនត្រឡប់ទៅកោះស៊ីរ៉ូវីរិញ យប់នេះត្រូវតែជាយប់ដែលមានសេចក្តីសុខខ្លាំង គេសង្ឃឹមបែបហ្នឹង សង្កេតមើល សាន់នី ហើយ និងរង់ចាំឲ្យនាងបង្ហាញពីតម្រូវការ។

"មិនត្រឹមតែនាងខ្ញុំទេដែលទន្ទឹងរង់ចាំលោក ម៉ារីស សាន់នី ក៏ទន្ទឹងរង់ចាំលោករាល់ថ្ងៃដែរ"

"មែនឬ?"

ម៉ារីស ឱនមកសួរមនុស្សស្រីនៅក្នុងរង្វង់ដៃ ធ្វើឲ្យ សាន់នី នឹកស្អប់ ឃៃរ៉ល មួយរំពេច។ ឃៃរ៉ល និយាយស្តីយកចិត្តយកថ្លើម ម៉ារីស យ៉ាងណាក៏អញ្ជើញ តែមិនគួរទាញនាងចូលទៅពាក់ព័ន្ធ។

*បើយើងបដិសេធ គេច្បាស់ជាខឹង!*

នាងធ្លាប់ធ្វើខ្លួនឲ្យ ម៉ារីស ខឹង ដោយការគិតបែបល្ងង់ខ្លៅថា គេខឹងហើយនិងមួម៉ៅ ដើរចេញពី ណាខាដៀ តែកំហឹងរបស់ ម៉ារីស ដូចអណ្តាតភ្លើង គេយកវាមកជះលើរាងកាយរបស់នាង ធ្វើឲ្យនាងសឹងតែវារចុះពីគ្រែតែម្តង។

"ប្រហែលមិនពិតទេដឹង"

គេនិយាយដោយសំឡេងមួយៗ ប៉ុន្តែមានឥទ្ធិពលចំពោះជតាជីវិតរបស់



Scanned by CamScanner

សាន់នី មួយរំពេច ព្រោះត្រូវ យ៉ៃរ៉េល ងាកខ្ទាប់មកសម្លក់សម្លឹងមុខ។

"អ៎...ពិត"

នាងត្រូវព្រមចុះចាញ់ ឲ្យស្ថានកាណ៍ដែលកើតឡើង។ នាងមិនបានស្ថិតនៅឋានៈដែលខ្លួនឯងអាចធ្វើឫក្រអឺតក្រទមដាក់គេបាន ជាពិសេសនៅពេលនេះ ដែលកំពុងតែប្រថុយសុំជំនួយពីគេ នាងមិនសង្ឃឹមមួយរយភាគរយទេថាគេជួយ ប៉ុន្តែនាងមានជម្រើសមិនច្រើន ទោះត្រូវលុតជង្គង់អង្វរករគេ ក៏នាងត្រូវតែធ្វើ ដើម្បីប្អូនស្រី។

"អ៊ីចឹង ប្រាប់នៅចំពោះមុខ យ៉ៃរ៉េល ឲ្យខ្ញុំបានឮច្បាស់ថានាងនឹកខ្ញុំ"

សាន់នី សម្លឹងមើលកែវភ្នែកមុខស្រួចរបស់គេ នាងខឹង ហើយអាការៈចង់ព្រួសភ្លើងដាក់គេ មិនមែននឹក ធ្វើឲ្យ ម៉ារីស ចង់សើច ប៉ុន្តែគេនៅតែធ្វើទឹកមុខធម្មតា ដូចមើលមិនឃើញថានាងកំពុងតែក្ដៅក្នុងទ្រូងដោយភ្លើងទោសៈ។

"ខ្ញុំគិតថា..."

"ខ្ញុំចង់ស្ដាប់ ពៅព្រលឹង"

ម៉ារីស ឱនមកប្រមៀលប្រមុះនឹងថ្ពាល់រលោង នាងក៏លើកដៃទ្រានដើមទ្រូងរបស់គេ រិះតែរុញចេញទៅហើយ ប៉ុន្តែគ្រប់គ្រងខ្លួនឯងបានទាន់ពេលវេលា ទើបខ្ទាំអាវរបស់គេជាប់។





Scanned by CamScanner

"ខ្ញុំនឹកលោក"

"អូខេ ខ្ញុំជឿនាង នាងប្រហែលនឹកខ្ញុំខ្លាំងដល់ថ្នាក់ចង់ដោះអាវរបស់ខ្ញុំ"

នាងក្រមុំចង់ស្ទប់មុខគេខ្លាំងណាស់ រឿងគួរឲ្យខ្មាសបែបនេះ ម៉ារីស នៅនិយាយចេញមកបាន មនុស្សដូចគេសមតែត្រូវកាត់អណ្តាតចោល នាងមិនមែនជាមនុស្សស្រីត្រេកកាមដល់ថ្នាក់ហ្នឹងទេមិនបានគិតរឿងដោះខោអាវចេញពីរាងកាយមាំមួនរបស់គេនៅចំពោះមុខអ្នកដទៃ ឬមិននៅចំពោះមុខអ្នកណាក៏ដោយ។

"ចាសលោក ម៉ារីស"

"ប្រហែលមកពីខ្ញុំខានមករកនាងយូរ ទើបរាងកាយរបស់នាងត្រូវការខ្ញុំខ្លាំងដល់ថ្នាក់លាក់វាមិនជិត"

សាន់នី ប្រឹងទប់ទោសៈ មុខឡើងក្រហមងាំង ធ្វើឲ្យ ម៉ារីស នឹកក្នាញ់ថ្ពាល់ក្រហមព្រោះកំហឹងរបស់មនុស្សស្រីនៅក្នុងរង្វង់ដៃ។ សាន់នី ជាមនុស្សស្រី ដែលកាន់តែខឹងកាន់តែស្អាត នាងជារបស់លេងរើបម្រះបាន ដែលធ្វើឲ្យជីវិតរបស់គេមានរស្មី ហើយក៏មិនសោកស្តាយកម្ទេចប្រាក់ ដែលជះទៅលើយ៉ៃរ៉ល ដើម្បីទិញយកសេចក្តីសុខពី សាន់នី។

"ចាសលោក ម៉ារីស"



Scanned by CamScanner

"អ៊ីចឹងយើងចូលបន្ទប់នៅខាងក្រោម ហើយនៅជាមួយគ្នាក្នុងនោះតែពីរនាក់ល្អទេ"

"យើងឡើងទៅបន្ទប់ខាងលើមិនបានឬ"

បន្ទប់ដែលគេចំណាយប្រាក់ជួលឲ្យនាងស្នាក់នៅក្នុង ណាខាដៀ អាចបើកទទួលគេបាន ហើយនាងត្រូវការនាំគេឡើងទៅខានលើឲ្យលឿនបំផុតដើម្បីរកវិធីចរចានឹងគេ។

"នាងត្រូវការខ្ញុំខ្លាំងដល់ថ្នាក់នេះឬ ពៅព្រលឹង"

នាងចង់ទះកំផ្លៀងគេឲ្យបាក់.ក ដោយសាររឿងដែលគេព្រួសចេញមក ប៉ុន្តែនាងត្រូវព្រមធ្វើជាស្រីត្រេកកាមនៅចំពោះមុខ យៃវ៉ល ព្រោះក្រៅពីធ្វើឲ្យ យៃវ៉ល ពេញចិត្តហើយ ក៏ធ្វើឲ្យ ម៉ារីស ពេញចិត្តដែរ។

"ចាស ខ្ញុំចង់នៅជាមួយលោកតែពីរនាក់ស្ទើតែទ្រាំមិនបានទៅហើយ"

"នាងនឹងបានវា ពៅព្រលឹង"





Scanned by CamScanner

# ២

## ស្រីលើគ្រែ

"ហ៊ឺ! កុ..."

សាន់នី គ្មានឱកាសនិយាយឱ្យចប់ប្រយោគ ពេលដែលចូលមកក្នុងបន្ទប់សម្រាករីអាយធី ម៉ារីស ក៏ត្រូវចាប់កញ្ចឹង.ក ឱនមកថើបជញ្ជក់បបូរមាត់។ ទោះដឹងថាការមកទីនេះរបស់គេ មិនធ្លាប់ចប់ត្រឹមសម្លឹងមុខ រាក់ទាក់ហើយលា តែនាងត្រូវការនិយាយជាមួយ នៅក្នុងបន្ទប់ផ្ទាល់ខ្លួន។

"កុ...កុំ ហ៊ឺ!"

នាងមានឱកាសដកដង្ហើមចូល ប៉ុន្តែគ្មានឱកាសនិយាយដដែល និងពេលបានដកដង្ហើមចូលហើយ បបូរមាត់ទន់ល្មើយក៏ត្រូវគ្រប់គ្រងម្តងទៀត។

"អ៊ា..." សាន់នី ថ្ងូរថ្ងូរដោយសំឡេងពីរោះ។

ការថើបរបស់ ម៉ារីស មានអានុភាពខ្លាំងក្លាប៉ុនណា នាងដឹងច្បាស់ព្រោះមិនធ្លាប់បម្រះចេញពីចំណងប្រាថ្នារបស់គេបានសម្រេចសូម្បីតែម្តង និង

តែត្រេកត្រអាលនឹងការថើបរបស់គេ ឈ្លក់វង្វេង ងប់ងល់ក្នុងរង្វង់ដៃរបស់គេ។

ហើយពេលគេគ្រប់គ្រងនាង ភាពផ្អែមល្ហែមគឺការបញ្ជាក់ថារាងកាយរបស់នាងប្រាថ្នាការគ្រប់គ្រងរបស់គេដូចគ្នា។ ការខិនមកថើបនាង ប្រហែលធ្វើឱ្យគេរួយក ទើបលើកនាង ឱ្យហើបជើង។

នាងកម្រើកខ្លួនមិនបាន ទ័លបញ្ញា នឹងរាំង ម៉ារីស ពេលគេមានដៃពីរប៉ុន្តែហាក់ដូចមានដៃដប់ រើមរវាមលើខ្លួនប្រាណរបស់នាង ទាំងដែលកំពុងតែពនាងជាប់នឹងរាងកាយ ខណៈដែលដៃទាំងពីររបស់នាងឱបករបស់គេ។

គេគិតតែថើប ធ្វើឱ្យនាងផ្សាបបបូរមាត់ ប៉ុន្តែភាពផ្សាក្តៅនោះ នាំមកនូវភាពក្តៅគគុកនៅក្នុងខ្លួន ដែលត្រូវភ្ញោចឱ្យនាងកើតតម្រូវការចំពោះគេ។ នាងទន់ខ្លួន ជ្រប់មុខនឹងប្រឡោះកអ្នកកំលោះ ពេលគេដកបបូរមាត់ចេញ។

"ទីនេះ"

នាងយល់ន័យរបស់គេ។ នាងត្រូវការឡើងទៅបន្ទប់ដេក ប៉ុន្តែគេបែរជាគិតថា នាងត្រូវការឱ្យគេគ្រប់គ្រងដល់ថ្នាក់ទ្រាំលែងបាន។ ម៉ារីស ជ្រើសរើសទីនេះឱ្យនាងបម្រើគេ បន្ទប់ទទួលភ្ញៀវវីអាយភីដែលអាចទាញវាំងនន ហើយមើល តាមកញ្ចក់ទៅវេទិកាសម្តែងរបាំស្រោតបាន ប៉ុន្តែអ្នកនៅខាងក្រៅ មិនអាចមើលតាមកញ្ចក់មកខាងក្នុង។



"មិន...មិនមែន"

"នាងនឹកខ្ញុំមិនអីចឹង ?"

ម៉ារីស សួរដោយសំឡេងកាច។ គេដូចមនុស្សចិត្តល្អ ចិត្តទូលាយ ប៉ុន្តែនាងបែរជាគ្មានអារម្មណ៍ថាគេចិត្តល្អ មានអ្វីម្យ៉ាងដែលគួរឱ្យខ្លាចនិងគ្រោះថ្នាក់បង្កប់នៅក្នុងខ្លួនរបស់គេ ទោះគេជាបុរសសម្បូរស្នេហ៍ ប៉ុន្តែនាងនៅតែគិតថាគេមិនមែនជាមនុស្សប្រុសដែលមនុស្សស្រីសមគួរនឹងនៅជិត។

"កុ...កុំ អ៊ាំ..."

នាងត្រូវចាប់ដាក់ទៅលើសាឡុង បែរមុខទៅរកបង្អែក ដៃទាំងពីរទ្រាននឹងបង្អែកសាឡុង ដោយ ម៉ារីស ត្រសុល មកបៀត ដៃទាំងពីរ លូកទៅក្នុងអាវរបស់នាង។

"កុំអី និយាយ!"

ដៃរបស់គេ មិនត្រឹមតែប្រចាប់ ដើម្បីភ្ញោចអារម្មណ៍របស់នាងប៉ុណ្ណោះទេ ពេលដែលសួរដើម្បីឈ្លេចយកចម្លើយ គេក៏ប្រចាប់ខ្លាំងៗ ធ្វើឱ្យនាងឈឺ។

"មិនមែនទីនេះ"

"តែខ្ញុំត្រូវការនាងទីនេះ និងឥឡូវនេះ"

គេប្រកាស ដូចមនុស្សស៊ាំនឹងការចេញបញ្ជា ហើយចុចបូតុងឱ្យរាំងនន



Scanned by CamScanner

ទាញបិទ ការសម្ដែងរបាំស្រាត កំពុងតែដំណើរការ ការសម្ដែងនៅលើវេទិកា សុទ្ធតែស្រីរបាំ រាងរៅស្អាត មានដើមទ្រូង មានចង្កេះ កំពុងតែរាំរែក ទាក់ទាញអារម្មណ៍ និងដោះសម្លៀកបំពាក់លើរាងកាយម្ដងមួយៗ។ របាំស្រាតរបស់ណាខាដៀ មិនត្រឹមតែជាការរាំរែក គ្រលែងខ្លួនទៅមក តាមចង្វាក់ភ្លេង ដោះសម្លៀកបំពាក់ ទាល់តែអស់ ហើយចប់ តែរបាំស្រាតនៅទីនេះ មានសម្រស់ដ៏ស្រស់ស្អាត ការធ្វើកាយវិការរបស់រាងកាយដ៏ល្វត់ល្វន់ និងទាក់ទាញ តាមរយៈការហ្វឹកហាត់ រាំដើម្បីភ្ញោចតណ្ហា និងធ្វើឱ្យអ្នកទស្សនាកើតអារម្មណ៍ក្ដៅគគុកតាំងពីចាប់ផ្ដើមដោះស្រោមដៃម្ល៉េះ។

"អ៊ំា..."

"ល្អ សំឡេងថ្ងូចថ្ងូរពីរោះរបស់នាង ខ្ញុំចូលចិត្តស្ដាប់"

អ្នកកំលោះចាប់មុខរបស់នាងឱ្យបែរមករក ហើយឱនទៅថើបជញ្ជក់បបូរមាត់ ដៃក៏មមាញឹកនឹងការគ្រប់គ្រងដើមទ្រូងទ្រលុកទ្រលន់ដែលបិទបាំងដោយអាវ ដែល សាន់នី បដិសេធគេមិនបាន ព្រោះមានកម្លាំងតិចជាង ហើយគេក៏មិនអនុញ្ញាតឱ្យធ្វើបែបនោះដែរ។

គេដកបបូរមាត់ចេញ ហើយចាប់បង្វែរមុខរបស់នាងទៅរកវេទិកា។

"ស្រមើស្រមៃថានាងនៅលើនោះទៅ"





Scanned by CamScanner

នាងខ្ទាំបង្អែកសាឡុងខ្លាំងៗ ពេលអណ្ដាតគ្រើមរបស់ម៉ារីស គ្រវាសក្នុងរន្ធត្រចៀក បន្ទាប់មក គេក៏អូសមុខសង្ហា ទៅរកប្រឡោះក។

"នាងក៏ត្រូវការខ្ញុំ ពៅព្រលឹង"

គេត្រសុលទៅរក នាងក៏អែនថយក្រោយ សង្កត់ជង្គង់នឹងពូកសាឡុង ឱ្យគេលូកដៃម្ខាងចូលទៅក្នុងខោក្នុង សាច់ស្ដើង បន្ទាប់មកក៏ចាប់ទាញវាទាល់តែរហែក ខណៈដែលសំពត់ ត្រូវលើកដើម្បីចេញឱ្យផុតពីផ្លូវរបស់គេ។

អ្នកកំលោះគ្រប់គ្រងនាងដោយភាពក្ដៅគគុក ឱ្យនាងស្រែកថ្ងូចថ្ងូរ ខ្ទាំម្រាមដៃទាល់តែរឹង ឡើងសស្លេក ការប្រាថ្នា ត្រូវភ្ញោចឱ្យជ្រួលច្រាល់ នៅក្រោមភាពព្រៃផ្សៃដ៏ក្ដៅគគុករបស់ ម៉ារីស។

"តបស្នងខ្ញុំ"

បញ្ជារបស់គេ គឺរឿងដែលនាងមិនអាចព្រងើយកន្តើយបាន សាន់នី ត្រូវធ្វើចលនារាងកាយដើម្បីតបស្នងភាពក្ដៅគគុកដែលគេត្រូវការ។

"សប្បាយទេ"

ម៉ារីស ប្រែខ្លួន ងើបអង្គុយលើសាឡុង ធ្វើឲ្យនាងត្រូវអង្គុយច្រកគៀរនៅលើភ្លៅរបស់គេ។ ពេលនេះ សាន់នី ដកដង្ហើមដង្ហក់ សំងំនៅក្នុងរង្វង់ដៃរឹងមាំ



Scanned by CamScanner

ខណៈដែលសំណួររបស់គេគួរឲ្យទះ ប៉ុន្តែនាងគ្មានឱកាសបានឆ្លើយ ព្រោះបបូរមាត់ទន់ល្មើយកំពុងតែធ្វើម្ហូបៗដូចត្រីកំភ្លាញដើម្បីដកដង្ហើមចូលឲ្យពេញស្ងួត។

"ណេថ្លីយ ខ្ញុំបានចម្លើយហើយ ខ្ញុំគិតថានាងគួរតែសប្បាយនឹងវា"

គេអង្អែលភ្លៅដែលលាក់នៅក្រោមសំពត់ ខណៈនោះដៃម្ខាងទៀត ក៏ចុចតេឡេ បើកទូរទស្សន៍ខ្នាតធំដែលព្យួរជាប់នឹងជញ្ជាំង។ បើមិនទស្សនាការសម្តែងរបាំនៅលើវេទិកាតាមបង្អួច ដែលជាកញ្ចក់ប្រភេទពិសេស គឺអាចទស្សនាការសម្តែងរបាំស្រោត តាមទូរស្សន៍បាន។

ការកម្សាន្តដែលត្រូវរៀបចំសម្រាប់ទទួលភ្ញៀវ អាចនិយាយបានថាសម្បូរបែបតែម្តង ក្រៅពីការកម្សាន្តហើយ ការរក្សាភាពផ្ទាល់ខ្លួនរបស់ភ្ញៀវ ក៏ត្រូវអនុវត្តយ៉ាងតឹងរ៉ឹង បុគ្គលិកដែលមានតួនាទីជាអ្នករត់តុ ទោះឃើញភ្ញៀវនិងស្រីរបាំកំពុងធ្វើអីក៏ដោយ ក៏ត្រូវឈ្ងោកមុខឈ្ងោកមាត់ បំពេញតួនាទីរបស់ខ្លួនឯងតែប៉ុណ្ណោះ។

ការងើយមុខមើលភ្ញៀវគឺជារឿងគ្មានមារយាទ ការសម្លឹងភ្ញៀវក៏ជារឿងគ្មានមារយាទដូចគ្នា ហើយនៅតែជាច្បាប់ដែលត្រូវអនុវត្តយ៉ាងតឹងរ៉ឹងរបស់រោងរបាំស្រោត ណាខាដៀ ដែរ។ មិនត្រឹមតែជាការទស្សនាការរាំរបាំស្រោតប៉ុណ្ណោះ





Scanned by CamScanner

ទេ ភ្ញៀវដែលត្រូវការមានសេចក្ដីសុខជាមួយស្រីរបាំក៏អាចធ្វើបានភ្លាមៗ ដោយមិនចាំបាច់ឡើងបន្ទប់ ឬរកកន្លែងស្ងាត់។

សាន់នី សំណាងល្អខ្លះ ដែលម្ចាស់ជីវិតរបស់នាងមិនមែនជាបុរសដែលចូលចិត្តធ្វើរឿងបែបនោះនៅចំពោះភ្នែកអ្នកដទៃ តែគេក៏មិនមែនជាសុភាពបុរសសម្រាប់នាង ម៉ារីស ប៉ះពាល់នាងដូចនាងជារបស់ តែគេក៏មិនខុស ព្រោះគេចំណាយប្រាក់ទិញជីវិតរបស់នាងបណ្ដោះអាសន្ន។

ពេលណាដែលគេធុញទ្រាន់ ហើយការទិញលក់ត្រូវបញ្ចប់ នាងក៏ត្រូវប្ដូរដៃគូលើគ្រែ ទោះមិនចង់ធ្វើក៏ដោយក៏នាងមិនអាចជ្រើសរើសបាន ប៉ុន្តែមុនដល់ពេលវេលានោះ នាងអាចមានជម្រើស សុំត្រឹម ធីណា មិនរស់នៅទីនេះទៀត នាងមិនបារម្ភពីអ្វីទៀតនោះទេ សូម្បីតែខ្លួនឯង។

"ដកដង្ហើមមិនទាន់ឬយ៉ាងម៉េច"

ម៉ារីស ចាប់ចង្កា ភ្ញើយមុខរបស់នាង ហើយបានឃើញពន្លឺ ដែលដូចមានអាថ៌កំបាំងអ្វីម្យ៉ាងនៅក្នុងភ្នែករបស់នាង ហើយវាក៏ធ្វើឲ្យគេចម្លែកចិត្តជាខ្លាំង។ ស្រីម្នាក់នេះដូចប្រស្នា ហើយគេនៅស្វែងរកចម្លើយសម្រាប់ខ្លួននាងមិនដែលបាន។

"កើតអី ?"



Scanned by CamScanner

គេមានន័យដល់ភាពភ្លឹកភ្លាំង   នៅក្នុងកែវភ្នែករបស់នាងអម្បាញ់មិញ ប៉ុន្តែ សាន់នី បែរជាយល់ថាគេសួរពីអាការៈហត់នឿយរបស់នាង។

"ខ្ញុំហត់"

គេសម្លឹងមើលកែវភ្នែករបស់នាង ពេលខ្លះ សាន់នី មានអារម្មណ៍ភ័យខ្លាចភាពមុតស្រួចនៅក្នុងកែវភ្នែករបស់គេធ្វើឲ្យនាងខ្លាច។កែវភ្នែករបស់គេដូចអាចទម្លុះចូលទៅគាស់កកាយអារម្មណ៍របស់នាងបាន    អារម្មណ៍ដែលនាងព្យាយាមលាក់វាបានជិត។

*ភាពគួរឲ្យខ្លាច!*

សាន់នី  គ្រាន់តែជាមនុស្សស្រីម្នាក់ប៉ុណ្ណោះ  ទោះនាងរឹងមាំយ៉ាងណាការការពារខ្លួនឯងក៏ពិបាកធ្វើដែរ  នាងបង្កើតក្រោះទឹកកក  បិទបាំងខ្លួនឯងតែងតែប្រាប់ខ្លួនឯងថានាងត្រូវតែមិនខ្លាច នាងត្រូវធ្វើជាបង្គោលឲ្យប្អូនស្រី។

**ស្មាទាំងពីររបស់នាង ពន់រែកបន្ទុកដ៏ធ្ងន់ធ្ងរ ស្មាតូចស្ដើង ប៉ុន្តែនាងធ្វើ**ខ្លួនស្ដើងដូចរាងកាយមិនបាន  នាងត្រូវព្យាយាមកាត់គ្រប់យ៉ាងដែលពាក់ព័ន្ធនឹងខ្លួនឯងចេញ ហើយផ្ដោតសំខាន់ទៅលើរឿងរបស់ប្អូនស្រី។



មានឬដែលនាងមិនស្រមើស្រមៃ   ដល់ការបង្កើតគ្រួសារជាមួយបុរស



Scanned by CamScanner

ម្នាក់ដែលនាងស្រឡាញ់ មានឬដែលនាងមិនចង់រស់នៅដោយមានសេរីភាព អាចជ្រើសការរកស៊ីធ្វើការដោយខ្លួនឯងបាន ប៉ុន្តែនៅក្នុងការពិត នាងធ្វើបែប នោះមិនបាន នាងត្រូវប្រើរាងកាយដើម្បីដោះដូរនឹងការមានខ្យល់ដង្ហើមរស់នៅ បន្ត និងធ្វើតួនាទីការពារប្អូនស្រី។

"ហត់កាយឬហត់ចិត្ត?"

សំណួររបស់ ម៉ារីស ចាក់ចូលទៅក្នុងបេះដូងរបស់នាង។ សាន់នី ងាក មុខចេញ ការហត់នឿយដែលនាងត្រូវបិទបាំង ព្រោះដឹងថារករង្វង់ដៃរបស់ នរណាម្នាក់ដែលឱបលួងលោមនាងមិនបាន បើនាងទន់ជ្រាយឲ្យប្អូនស្រី ឃើញ ធីណា នឹងកាន់តែខ្លាច។

សាន់នី មិនបន្ទោសម្ដាយដែលធ្វើឲ្យនាងនិងប្អូនស្រីត្រូវមានជីវិតបែប នេះ បើជ្រើសរើសបាន ម្ដាយប្រហែលប្រាថ្នារបស់តែមួយគត់ដូចនាង ប៉ុន្តែ គាត់ជ្រើសរើសមិនបាន ហើយគាត់ក៏ប្រឹងប្រែងអស់ពីសមត្ថភាព រឹងមាំ ព្រមរង ការជិះជាន់ ប្រមាថមើលងាយ ដើម្បីមានឱកាសបានចិញ្ចឹមនាងនិងប្អូនស្រី។

នាងបន្ទោសក្ដីស្រឡាញ់ដ៏ធំធេងរបស់ម្ដាយអ្នកផ្ដល់កំណើតឲ្យម្ដេចនឹង បានទៅ ប៉ុន្តែរឿងគ្រប់យ៉ាងវាកាន់តែសាហាវទៅៗ ព្រោះភាពអាត្មានិយមរបស់ មនុស្ស។ ឃែរ៉ល និង អាដាំ ប៉ងដួសដងយកផលប្រយោជន៍ពីពួកនាងបីនាក់

ម្ដាយកូន ពេលអ្នកម្ដាយលែងនៅ នាងធ្វើបានត្រឹមតែឈ្ងោកមុខឈ្ងោកមាត់ ព្រមទទួលដើម្បីសុវត្ថិភាពរបស់ប្អូនស្រី។

នាងព្រមលក់ព្រហ្មចារី ដើម្បីទិញពេលវេលា ប៉ុន្តែនាងគ្មានអារម្មណ៍ថា ខ្លួនឯងបាត់បង់កិត្តិយស នាងធ្វើមិនមែនព្រោះនាងសប្បាយ នឹងក្លិនផ្កាប លោកិយ៍ ឬឈ្លក់វង្វេងនឹងភ្លើងពណ៌ នាងធ្វើដើម្បីជីវិតរបស់ខ្លួនឯងនិងប្អូនស្រី បានរស់នៅបន្តទៅវិញទេ។ គ្មានអ្នកណាអាចប្រមាថមើលងាយកិត្តិយសរបស់ នាងបាន ព្រោះវាមាននៅក្នុងខ្លួនរបស់នាងទាំងអស់។

មនុស្សដែលគ្មានកិត្តិយស គឺមនុស្សដែលឃើញលុយជាព្រះជាម្ចាស់ ព្រមធ្វើគ្រប់យ៉ាងដើម្បីវា សូម្បីតែការកេងចំណេញនិងលក់ជីវិតមនុស្សលោក ដូចគ្នា។

សាន់នី បង្ហាញភាពរឹងមាំរបស់នាងតាមរយៈកែវភ្នែក ដូចនាងកំពុង លើកទឹកចិត្តខ្លួនឯង។

ម៉ារីស ចាប់ចង្ការរបស់នាង គេត្រូវការសម្លឹងមើលកែវភ្នែកស្រទន់មួយគូ នោះ ដើម្បីផ្ចិតយកអ្វីម្យ៉ាងនៅក្នុងនោះ ហើយឱនទៅរក នាងក៏បិទភ្នែក ព្រម ចុះចាញ់តម្រូវការរបស់គេ តាមដែលគេដួសដងវាពីនាង ហើយបន្ទាប់ពីនោះ នាងនឹងរកវិធីបញ្ចុះបញ្ចូលគេ ដើម្បីសុំជំនួយពីគេ។





Scanned by CamScanner

...

"**សេត ទៅណា**?"

ព្រះអង្គម្ចាស់ ហ្លាវៀន សម្លឹង ឃីអាឃីហ្វ បន្ទាប់ពីចប់ការប្រជុំសំខាន់ វ៉េនដហ្វ ក៏ធ្វើដំណើរត្រឡប់ទៅក្រុងអាឡិចសានដេវិញភ្លាម។ សម្រាប់ វ៉េនដហ្វ ទ្រង់មិនងឿងឆ្ងល់នោះទេ ព្រោះម្នាក់នោះមានអ្វីម្យ៉ាងដែលគួរឲ្យចាប់អារម្មណ៍ ជាងការអង្គុយផឹកប្រាន់ឌី បន្ទាប់ពីចប់ប្រជុំ រង់ចាំនៅក្រុង អាឡិចសានដេ។

"ត្រឡប់ទៅវិញហើយ"

"មិនបានត្រឡប់ទៅកោះចោរ?"

ព្រះអង្គម្ចាស់ដឹងថា សេត មិនបានធ្វើដំណើរត្រឡប់ទៅកោះ ស៊ី រ៉ូវើ ព្រោះឧទ្ធម្ភាគចក្ររបស់ សេត ធ្វើដំណើរចេញពីក្រុង សេនថាម៉ារ៉ា សំដៅក្រុង ហ៊ីតវ៉េល។

"ទៅសម្រាក"

"សម្រាក? ក្នុងបនស្រី?"

ព្រះអង្គម្ចាស់ ហ្លាវៀន សួរត្រង់ៗ ទើប ឃីអាឃីហ្វ ក្អកគ្រហែមតិចៗ ព្រោះសួរត្រង់ដូចធ្វើដំណើរទៅជាមួយ សេត ដោយខ្លួនឯងបែបនេះ តើគេ បដិសេធម្ដេចបាន។



Scanned by CamScanner

"គួរហៅថា រោងរបាំស្រោត"

ឃើអាឃើហ្វ កែខែឲ្យត្រឹមត្រូវ ព្រោះរោងរបាំស្រោត និងបនស្រី មាន ដំណាក់កាលនៃការចូលទៅប្រើប្រាស់សេវាកម្មខុសគ្នា។

"ខុសគ្នាពីបនស្រីត្រង់ណា ?"

"គឺត្រង់ពាក្យហៅ និងតម្លៃដែលត្រូវចំណាយ"

"ប៉ុន្តែវាទៅដោយគោលបំណងតែមួយ"

"ដឹងហើយ"

"មួយរយៈនេះដូច សេត ទៅទីនោះញឹកញាប់"

ព្រះអង្គម្ចាស់នៅតែជាបុរសប៉ិនសង្កេត រឿងខិលខូចនិងមនុស្សប្រុសគឺ ជារឿងដែលពិបាកញែកចេញពីគ្នា ហើយ សេត ក៏បដិសេធការមានដំណាក់ ស្រីកំណាន់ ទាំងដែលអាចធ្វើបាន ប៉ុន្តែមើលទៅ សេត ប៉ប៉ុកនឹងរឿងស្រី នៅក្នុងរោងរបាំស្រោត ណាខាដៀ ខ្លាំងជាពិសេស។

មនុស្សស្រីបើប្រើការធម្មតាៗគឺគ្មានបញ្ហាអីទេ ប៉ុន្តែបើផ្តោតសំខាន់ទៅ លើពួកនាងពេលណា បញ្ហានឹងកើតឡើងភ្លាម។ មនុស្សស្រីគឺជាភេទដែលត្រូវ តែប្រុងប្រយ័ត្ន ព្រោះពួកនាងអាចជាជនបង្កប់របស់នរណាម្នាក់ ដែលបញ្ជូនមក ក៏ថាបាន ទើបការការពារគឺជារឿងល្អ។





Scanned by CamScanner

"ឯងពុញទ្រាន់នឹងផឹកជាមួយខ្ញុំតែពីរនាក់ឬយ៉ាងម៉េច អម្ចាស់ ?"

"តែពីរនាក់ ?"

ព្រះអង្គម្ចាស់ ហ្គាវៀន ជ្រួញចិញ្ចើម ខណៈដែល ឃីអាឃីហ្វ មើលទៅជុំវិញខ្លួន ឃើញថាមានអង្គរក្សជាងដប់នាក់ឈរប្រចាំការនៅក្នុងបន្ទប់នេះ។

"ខ្ញុំមានន័យថាតែយើងពីរនាក់"

"ខ្ញុំគ្រាន់តែសង្ស័យ សេត ងប់ងល់នឹងស្រីម្នាក់នោះខ្លាំង"

"ប្រហែលហ្នឹង"

"ជួយមើលគេផង មនុស្សប្រុសពេលខ្លះក៏ល្ងង់បាននឹងរឿងដែលមិនសមជារឿង ជាពិសេសរឿងមនុស្សស្រី"

"ទទួលរាជ្យបញ្ជាព្រះអង្គម្ចាស់"

ឃីអាឃីហ្វ ឱនគំនាប់ ទទួលបញ្ជាពីព្រះអង្គម្ចាស់ ហ្គាវៀន។ បើមើលស្រីដែល សេត ទៅពាក់ព័ន្ធជាមួយ គ្រាន់តែជាការរកសេចក្ដីសុខបណ្ដោះអាសន្ន គឺមិនបង្កឲ្យកើតបញ្ហាអីនោះទេ។

"ខ្ញុំមិនត្រូវការឲ្យមានរឿងមិនល្អកើតឡើង"

"ខ្ញុំដឹង ខ្ញុំក៏សង្ឃឹមបែបនោះ"

"សេត អាចសប្បាយ ប៉ុន្តែការសប្បាយ បើដោះដូរដោយបញ្ហា វាមិន



Scanned by CamScanner

សមាមាត្រទេ"

ព្រះអង្គម្ចាស់និយាយដូចមិនយកចិត្តទុកដាក់ ប៉ុន្តែវាគឺជាការយកចិត្តទុកដាក់ ដោយឋានៈរបស់ពួកគេ គ្រប់រឿងត្រូវតែចាត់ការ ឲ្យមានរបៀប រួមទាំងរឿងរបស់មនុស្សស្រីដែរ។ ការធ្វើដំណើរទៅច្រកស្នេហា បើមិនទៅដើម្បីសេពស្នេហាគឺប្រហែលមិនយកខ្លួនទៅបៀត។

សេត មិនធ្លាប់ សេពស្នេហាជាប់គ្នារយៈពេលយូរបែបនេះទេ គេមានទំនាក់ទំនងនឹងមនុស្សស្រីប្ដូរមុខជារឿយៗ ហើយក៏ទៅច្រកស្នេហាខ្លះ បើសេត នៅក្នុងឋានៈជាកំលោះនៅលីវ ដែល សេត នៅទំនេរយូរមកហើយ គួរតែជិតពីរឆ្នាំ តែមិនឃើញថាចង់មានគូស្នេហ៍ថ្មី ហើយនៅឧស្សាហ៍ទៅច្រកស្នេហាពេលទំនេរទៀត។

ភ្នែកត្រចៀករបស់ព្រះអង្គម្ចាស់ ហ្គារៀន ហៅថាម្ចាស់ក៏បាន ទ្រង់មានអង្គភាពពត៌មានរហ័ស សម្ងាត់ ទុកសម្រាប់ប្រើការ សូម្បីតែរឿងសាច់ញាតិនិងមនុស្សជិតខ្លួន ក៏មិនអាចឲ្យរំលងពីភ្នែកបាន ទោះមិនបានតាម សេត ទៅដល់ ណាខាដៀ ប៉ុន្តែទ្រង់នៅតែត្រូវបានរាយការណ៍ថា សេត ទៅទីនោះជាប្រចាំមុនពេលត្រឡប់ទៅកោះ ចោរ។

"ឯងខ្លាចអីឬអម្ចាស់ ?"





Scanned by CamScanner

"ខ្ញុំមិនបានខ្លាចស្អីទាំងអស់"

ប៉ុន្តែព្រះអង្គម្ចាស់ ហ្គាវៀន មិនត្រូវការធ្វើរឿងធុញទ្រាន់ចិត្ត ស្ថានការណ៍របស់ប្រទេស សាក់ខាវៀ នៅពេលនេះ ទោះមានស្ថេរភាពជាងមុន ប៉ុន្តែនៅតែត្រូវមានការគ្រប់គ្រង ឲ្យបានដិតដល់ ពួកឧទ្ទាមដែលបំបែកក្រុមទៅហើយគ្មានន័យថា គ្មានអ្នកលួចប្រមូលផ្តុំកម្លាំងមនុស្ស អ្នកដែលមានជំនឿងប់ងល់នៅតែអាចសេសសល់ និងរស់នៅជាមួយប្រជាជនធម្មតា មនុស្សស្រីគឺភេទដែលពួកគេត្រូវប្រុងប្រយ័ត្ន បើសេពសុខផ្នែករាងកាយ ហើយគ្មានការភ្ជាប់ទំនាក់ទំនងជ្រាលជ្រៅខាងផ្លូវចិត្ត ក៏មិនមែនជាបញ្ហាដែលត្រូវចាប់អារម្មណ៍ ប៉ុន្តែបើវាផ្ទុយពីនោះ ហើយមនុស្សស្រីដែលថានោះ ជាមនុស្សរបស់ពួកឧទ្ទាម វិធីតែមួយគត់ដែលព្រះអង្គម្ចាស់ ហ្គាវៀន ប្រគល់ឲ្យគឺ **សេចក្តីស្លាប់។**

"ខ្ញុំនិយាយខុស សូមអភ័យទោស ខ្ញុំចង់មានន័យថាឯងប្រហែលមិនត្រូវការធ្វើរឿងរំខានចិត្ត"

"ឧបមាដែលវាធ្ងន់ធ្ងរដល់ថ្នាក់ សេត លង់ស្នេហ៍នាង ហើយនាងជាមនុស្សរបស់ពួកឧទ្ទាម ឯងដឹងមែនទេ ថាត្រូវចាត់ការយ៉ាងណា"

"សម្លេះនាង"

ឃីអាឃីហ្វ មានបុគ្គលិកលក្ខណៈទន់ភ្លន់ជាងបណ្តាបងប្អូនទាំងអស់



Scanned by CamScanner

ប៉ុន្តែនៅក្នុងភាពទន់ភ្លន់របស់គេ គ្រាន់តែជារូបភាពបោកប្រាស់ភ្នែកប៉ុណ្ណោះ ព្រោះភ្នែករឹងកំព្រឹស និងដាច់ខាតរបស់ យីអាយីហ្វ ក៏មិនចាញ់អ្នកណា។

"ហ្នឹងហើយ តែខ្ញុំមិនគិតថាវាធ្ងន់ធ្ងរដល់ថ្នាក់នោះទេ"

"ឬទោះ សេត ប្រាកដប្រជានឹងស្រីនោះ ក៏ប្រហែលពិបាកដដែល"

"បើមានពាក់ព័ន្ធនឹងរាជ្យវង្ស បើមានឱកាសរៀបការ ព្រោះស្នេហា ចាត់ទុកថាជារឿងល្អ ប៉ុន្តែបើស្នេហានោះមានន័យដល់មនុស្សស្រីដែលអាស្រ័យ នៅក្នុងច្រកស្នេហា ឯងគិតថាយើងនឹងមើលមុខបុព្វបុរសរបស់រាជ្យវង្សដោយ របៀបណា"

ស្ត្រីដែលត្រូវជ្រើសរើសដើម្បីធ្វើជាសមាជិករាជ្យវង្ស គឺគួរមានកិត្តិយស និងមានគុណសម្បត្តិ ដែលរឿងនេះ សេត ក៏ដឹង ហើយព្រះអង្គម្ចាស់ ក៏មិនគិត ដែរថា សេត ជ្រើសរើសមនុស្សស្រីនៅក្នុងច្រកស្នេហាធ្វើជាគូជីវិត។

"វាមិនអាចទេ"

"តែខ្ញុំមិនគិតថា សេត ស្រឡាញ់អ្នកណានៅពេលនេះ ភ្នែករបស់វានៅ តែគ្មានស្នេហា"

សេត កំពុងសប្បាយនឹងមនុស្សស្រីដែលត្រូវចិត្តខ្លាំងជាពិសេស ជាការ ត្រូវចិត្តដែលមានរយៈពេលយូរ ធ្វើឲ្យព្រះអង្គម្ចាស់ ហ្គារៀន មានចំណាប់





Scanned by CamScanner

អារម្មណ៍។

"សូមព្រះអង្គម្ចាស់ទុកព្រះទ័យ បើមានរឿងអីកើតឡើង និងចាំបាច់ត្រូវចាត់ការឲ្យដាច់ស្រឡះ ទូលបង្គំនឹងចាត់ការមុនពេលដល់ដៃរបស់ទ្រង់"

ព្រះអង្គម្ចាស់ងក់ក្បាល ទទួលយកការជានានោះ។ ទ្រង់មិនបានផ្ដោតខ្លាំងទៅលើរឿងនេះក៏ពិតមែន ប៉ុន្តែត្រូវតែមានការសន្និដ្ឋាន ដើម្បីត្រៀមខ្លួនទទួលយកលទ្ធផលដែលអាចនឹងកើតឡើង រឿងដែលមិនគិតថានឹងកើត នៅពេលខ្លះ វាក៏អាចកើតឡើងបាន។

"ខ្ញុំសង្ឃឹមថាយើងនឹងមិនធ្វើបែបនោះ"

"ជឿចុះ បើ សេត ភ្លាត់ស្នៀត សេត ត្រូវតែបន្ទោសខ្លួនឯង"

"ឯងព្រមឲ្យរឿងបែបហ្នឹងកើតឡើងឬយ៉ាងម៉េច?"

"ខ្ញុំគ្រាន់តែគិត ប៉ុន្តែខ្ញុំគិតដូចឯង អម្ចាស់ សេត កំពុងតែសប្បាយ ប៉ុន្តែមិនបានប្រាកដប្រជាអីទេ"

ព្រះអង្គម្ចាស់ ហ្គាវៀន ជិបប្រាន់ឌីនៅក្នុងដៃ វាគឺជាការបញ្ចប់ការសន្ទនាពាក់ព័ន្ធនឹង សេត អ្នកដែលធ្វើដំណើរចាកចេញពីក្រុង សេនថាម៉ារ៉ា ប៉ុន្តែមិនបានត្រឡប់ទៅផ្ទះរបស់ខ្លួនភ្លាមៗ។

"ចុះឯង អម្ចាស់?"



Scanned by CamScanner

"ខ្ញុំយ៉ាងម៉េច"

"ឯងត្រូវការទៅសម្រាកខ្លះឬអត់"

"ខ្ញុំមិនគិតថាធ្វើដំណើរទៅច្រកស្នេហា"

ឃីអាឃីហ្វ ញាក់ស្មាបន្តិច បើព្រះអង្គម្ចាស់ ហ្គាវៀន ត្រូវការធ្វើដំណើរទៅទីនោះ គេនឹងជូនដំណឹងទៅ សេត ឲ្យប្រាប់មនុស្សរបស់ ណាខាដៀ ដើម្បីត្រៀមចាំទទួលភ្ញៀវពិសេស។

"ស្មានថាចាប់អារម្មណ៍"

"ខ្ញុំគ្មានតម្រូវការចំពោះមនុស្សស្រីនៅពេលនេះទេ គ្រាន់តែត្រូវការផឹកស្វាត់ៗ"

នេះគឺជាបញ្ជាដោយប្រយោលដែលមិនអនុញ្ញាតឲ្យ ឃីអាឃីហ្វ បបួលនិយាយបន្ត ប៉ុន្តែមានតួនាទីផឹកប្រាន់ឱកំដរព្រះអង្គម្ចាស់បែបស្វាត់ៗ និងល្ងឹងល្ងើយប្លែកៗ។

"ប្រយ័ត្ន"

សាន់នី ជួយគ្រាហ៍បុរសមាឌធំ ចូលបន្ទប់សម្រាករបស់នាង។ ម៉ារីស ទាំងផឹក និងសេពសុខពីរាងកាយរបស់នាង ធ្វើឲ្យនាងហត់នឿយ ទម្រាំតែគេ





Scanned by CamScanner

ព្រមឡើងមកបន្ទប់ជាមួយ ក៏ផឹកច្រើនដល់ថ្នាក់នាងគិតថាថ្ងៃនេះ ប្រហែលនិយាយគ្នាមិនដឹងរឿងទេ តែគេដេកនៅទីនេះ នាងគិតថានៅមានពេលវេលាស្អែកមួយថ្ងៃទៀតសម្រាប់ការនិយាយគ្នា។

"នាងគិតថាខ្ញុំស្រវឹង ?"

អ្នកដែលផឹកអស់ច្រើនដល់ថ្នាក់ស្រវឹងអួទីនួទៅហើយ ប៉ុន្តែ សាន់នី មិនធ្លាប់ឃើញថាមនុស្សស្រវឹងណា ព្រមទទួលស្គាល់ថាខ្លួនឯងស្រវឹង។

"ចាសខ្ញុំគិត"

នាងឆ្លើយតបតាមត្រង់ ព្រោះគិតថាគេស្រវឹង ថ្ងៃស្អែកភ្ញាក់ឡើង គេត្រូវតែចាំអីមិនបាន ថាបាននិយាយអីជាមួយនាងខ្លះ។

"អុ! នេះលោក!"

សេត មានមាឌធំណាស់ គ្រាហ៍គេក៏លំបាកសឹងស្លាប់ទៅហើយ ពេលគេផ្តួលខ្លួនទៅលើកម្រាលបែបនេះ ខ្លួននាងក៏ត្រូវទាញទៅជាមួយ ស្ថានការណ៍ស្ងប់ ពេលគេប្រែខ្លួនដេកផ្ងារ នាងក៏លូកដៃទៅទ្រក្បាលរបស់គេ ជួយមិនឲ្យវាទង្គិចនឹងកម្រាល។

គេប្រើខ្សែភ្នែកមនុស្សស្រវឹងខ្លាំងរបស់គេ មើលភ្នែករបស់នាង នាងក៏ដកដៃចេញពីក្បាលរបស់មនុស្សស្រវឹង ពេលឃើញថាគេដេកស្ងៀម និងគិតតែ



Scanned by CamScanner

សម្លឹងនាង មិនរើបម្រះដូចអម្បាញ់មិញ។

"ខ្ញុំមិនស្រវឹង"

"ចាស មិនស្រវឹងក៏មិនស្រវឹង"

"នាងមិនជឿខ្ញុំឬ?"

គេកំពុងតែរករឿងឈ្លោះច្បាស់ណាស់ នាងមិនបណ្តោយឲ្យគេនិយាយ ហើយរង់ចាំឱកាសបបួលគេចូលបន្ទប់ដេក គេបែរជាមកដេកសន្ទឹងនៅក្នុងបន្ទប់អង្គុយលេងបែបនេះ មានឱកាសដែល ធីណា អាចបើកទ្វារចេញពីបន្ទប់ដេកមួយទៀត មកឃើញនាងនិងគេ។

ធីណា និង សេត មិនធ្លាប់ជួបគ្នា តែគេដឹងថានៅក្នុងបន្ទប់នេះ នាងនៅជាមួយប្អូនស្រី មិនដឹងក៏មិនបាន ព្រោះគេជាអ្នកចំណាយប្រាក់ ដើម្បីទិញភាពផ្ទាល់ខ្លួនឲ្យនាង ប៉ុន្តែពេលដែលគេមករកនាង ធីណា នឹងនៅក្នុងបន្ទប់ដេក ហើយពេលគេត្រឡប់ទៅវិញ ទើបនាងហៅប្អូនស្រីចេញពីបន្ទប់។

"ម៉េចក៏លោកដឹង?"

"ដឹងត្រឹមខ្ញុំដឹងទៅបានហើយ"

"ងើបបានទេ ខ្ញុំអៀវលោកមិនរួចទេ"

"ងើបទៅណា"





Scanned by CamScanner

គេលើកដៃអង្អែលថ្ពាល់របស់នាង នៅក្រោមការប៉ះពាល់របស់ម្រាមដៃរឹងកំព្រឹស គឺសាច់រលោង ដែលគេជាប់ចិត្ត។

"ចូលទៅដេកក្នុងបន្ទប់"

"ដេកត្រង់នេះក៏បាន"

"មិនបានទេ"

"បាន ដេកជាមួយគ្នាមក"

គេទាញនាងឲ្យទៅដេកលើខ្លួន សាន់នី ក៏ងើបក្បាលមើល ហើយធូរទ្រូង ដែលបន្ទប់ដេករបស់ប្អូនស្រីនៅតែបិទ ធីណា ប្រហែលជាដេកលក់ទៅហើយ តែបើបានឮសំឡេងប្លែកៗ ខ្លាចថាប្អូនស្រីចេញមកមើល។

"ងើបឡើង"

"មិនចង់ងើប"

ក្រៅពីមិនងើបហើយ សេត នៅជ្រលើមដោយការលូកដៃចូលក្នុងអាវរបស់នាង ច្របាច់ដើមទ្រូងទ្រលុកទ្រលន់ដែលគេចាប់ញីកញាប់នៅរាត្រីនេះ។

"ចូលទៅក្នុងបន្ទប់សិន"

"ខ្ញុំចង់បាននាងនៅត្រង់នេះនិងឥឡូវនេះ"

គេប្រាប់ដោយសំឡេងស្អក និងចាប់ក្បាលរបស់នាងសង្កត់ ហើយថើប



Scanned by CamScanner

ជញ្ជក់បបូរមាត់ក្រពុំឡើងស្រៀវស្រើប សាន់នី ក៏ភ្លេចខ្លួនថើបគេវិញឱ្យទាល់តែបាន។ គេថើបនាង ហើយចាប់អាវ ទាញឡើងលើ តាមដោយការរុញខ្លួនរបស់នាងឡើងទៅដែរ ធ្វើឱ្យដើមទ្រូងទ្រលុកទ្រលន់ស្ថិតនៅលើមុខរបស់គេ។

បន្ទាប់ពីថើបជញ្ជក់បបូរមាត់ សេត ក៏ឈ្មុលមុខនឹងដើមទ្រូងទាំងសងខាង ក្លិនក្រអូបចេញពីស្បែកក្រមុំ ធ្វើឱ្យគេដកដង្ហើមចូលឱ្យខ្លាំងៗ។ គេស៊ីនាងច្រើនដងហើយ ប៉ុន្តែសាច់ទន់ល្មើយរបស់នាងនៅតែទាក់ទាញនិងភ្ញោចអារម្មណ៍របស់គេបានល្អខ្លាំងណាស់។

"លោក ម៉ារីស អុំ!"

គេបឺតជញ្ជក់ខ្លាំងៗ ដូចឃ្លើសចិត្ត ដែលត្រូវនាងហាមប្រាម ទើបសាន់នី ត្រូវយល់ព្រម ព្រោះបើនាងជំទាស់ចិត្តគេ អាចនឹងមានរឿងផ្សេងកើតឡើង។

"ធ្វើឱ្យខ្ញុំ សាន់នី"

គេប្រាប់ដោយសំឡេងស្អកដោយការប្រាថ្នា សាន់នី ក៏ឡើងច្រកគៀរលើភ្លៅរឹងមាំ លើកខ្លួនបន្តិច ដើម្បីទាញខ្សែក្រវាត់និងប្រឡេះឡេវខោរបស់គេ ហើយទម្លាក់ខ្លួនទៅរក ដើម្បីប៉ះពាល់គេដោយបបូរមាត់ ផ្គាប់ផ្គន់ឱ្យគេទទួលបានការពេញចិត្ត។





Scanned by CamScanner

"អំា...សាន់នី ល្អ"

នាងក្រមុំប៉ះពាល់គេដោយដៃនិងមាត់ រាងកាយរឹងមាំរបស់គេមានក្លិនក្រអូបស្អាត និងគួរឱ្យប្លែកដែលនាងគ្មានអារម្មណ៍ថាខ្ពើមរអើមដែលត្រូវប៉ះពាល់គេ នាងបម្រើគេទាល់តែមានបញ្ជាឱ្យគ្រប់គ្រងនោះឯង ដែលនាងជៀសពីវាមិនផុត បន្ទាប់ពីគិតថា គេអាចប្តូរចិត្ត ចូលទៅបន្តនៅក្នុងបន្ទប់ដេក តួនាទីរបស់នាង គឺធ្វើតាមបញ្ជារបស់គេ។

នាងលើកខ្លួន ទាញអាវមកបិទ ទោះអាវក្នុងត្រូវប្រឡេះទំពក់ក៏ដោយ ដៃទាំងពីរទ្រានលើដើមទ្រូងធំទូលាយ ហើយទម្លាក់ខ្លួនដើម្បីគ្រប់គ្រងគេ។

ដៃរបស់ សេត លូកចូលទៅក្នុងអាវ ច្របាច់ដើមទ្រូងណែនក្បុំទាំងពីរដោយអារម្មណ៍ឈ្លក់វង្វេង គេប្រហែលចូលចិត្តវាខ្លាំង។ នាងខ្ទឹបបបូរមាត់ ការរំលាយរាងកាយជាមួយគេ មិនថាពេលណាក៏ដោយ វានៅតែលំបាកដូចកាលលើកដំបូងជានិច្ច។

"ទម្លាក់ខ្លួនម៉ោ សាន់នី"

ដូចគេមិនត្រូវការអត់ធ្មត់តទៅទៀត សាន់នី ក៏ទម្លាក់ខ្លួនទៅរក ទាល់តែអាចគ្រប់គ្រងគេបានទាំងអស់តាមដែលគេត្រូវការ ហើយនាងក៏ដកដង្ហើមដង្ហក់រាងកាយលើសពីពេញចិត្ត ទទួលយកគេ នៅក្នុងភាពកក់ក្តៅរបស់នាង។



Scanned by CamScanner

"នាងក្ដៅណាស់"

គេគ្រហឹមដូចមនុស្សមមើ ហើយនាងក៏គិតថា គេស្រវឹងដល់ថ្នាក់ត្រូវភាពត្រេកកាមបាំងមុខ នាងគេចវេះពីវាលែងបានទៀតហើយ វិធីតែមួយដែលធ្វើបានគឺប្រញាប់ ធ្វើឱ្យវាឆាប់ចប់ ប៉ុន្តែដូចជោគជតាមិនកាន់ជើងនាង ត្រូវដៃរបស់គេច្របាច់ដើមទ្រូងកាន់តែខ្លាំង។

គេកំពុងតែស្រវឹង ប៉ុន្តែនាងនៅមានស្មារតី និងបានឮសំឡេងទ្វារ ទើបងាកទៅមើល និងបក់ដៃ ទោះខ្មាសប្អូនស្រី តែយ៉ាងហោចណាស់នៅលើខ្លួនរបស់នាង ក៏មានសម្លៀកបំពាក់ ហើយសាឡុង ក៏បាំងភ្នែករបស់ ធីណា ដែលប្អូនស្រីត្រូវតែមើលឃើញដៃរបស់នាង ព្រោះទ្វារបន្ទប់ដេកត្រូវបិទជិត។

"លោកជាមនុស្សក្បាលរឹង"

"ខ្ញុំបានឮ"

នាងគ្រលែងចង្កេះ ដើម្បីគ្រប់គ្រងគេតាមចង្វាក់ប្រាថ្នា ដែលធ្វើឱ្យគេពេញចិត្ត។ នាងខ្មាស នាងអៀន នាងមានអារម្មណ៍មិនល្អជាខ្លាំង ដែលប្អូនស្រីរិះតែចេញមកឃើញពេញភ្នែកទៅហើយ សំណាងល្អដែលខ្លួនប្រាណរបស់នាង និងគេ នៅតែមានសម្លៀកបំពាក់។



"គឺលោករឹងពិតមែន"



Scanned by CamScanner

"ខ្ញុំមិនបានមកដើម្បីស្ដាប់នាងរអ៊ូទេ"

"ខ្ញុំដឹងថាលោកមកដើម្បីសេពសុខ"

"អ៊ីចឹងនាងគួរធ្វើឱ្យខ្ញុំមានសេចក្ដីសុខ"

បញ្ចារបស់ម្ចាស់ជីវិតត្រូវតែបានការតបស្នងនាងគ្រលែងត្រគាកនៅលើរាងកាយរបស់គេ បន្ទាប់មក ក៏ត្រូវចាប់សង្កត់ ហើយគេជាអ្នកចាត់ការ ដោយការគ្រលែងត្រគាកខ្លាំងៗដើម្បីឱ្យដល់ចិត្តខ្លួនឯង ឱ្យនាងថ្ងូចថ្ងូរដោយភ្លេចខ្លួន ហើយពេលគេនិងនាង ទៅដល់គោលដៅនៃសេចក្ដីសុខ ក៏ត្រូវគេលើកបីចូលទៅក្នុងបន្ទប់ដេក។



Scanned by CamScanner

# ៣

## ភ្លើងប្រាថ្នា

ទិដ្ឋភាពនៅក្នុងបន្ទប់ដេករបស់ សាន់នី វាគ្រាន់តែជាបន្ទប់ដែលនាងផ្ដល់ខ្លួនដេកពីមួយថ្ងៃទៅមួយថ្ងៃដោយគ្មានន័យ ពេលនេះវាបែរជាពោរពេញទៅដោយភាពក្ដៅគគុក នៅក្នុងបន្ទប់ដែលបើកម៉ាស៊ីនត្រជាក់ ត្រជាក់ស្រេង ប៉ុន្តែរាងកាយរបស់នាងជោកដោយញើស។

ភាពត្រជាក់របស់សីតុណ្ហភាពនៅក្នុងបន្ទប់ និងសីតុណ្ហភាពក្ដៅគគុកចេញពីរាងកាយរបស់អ្នកកំលោះ ធ្វើឱ្យនាងរងាផង ក្ដៅផង បាតដៃដែលសង្កត់ដើមទ្រូងរបស់គេឡើងរឹង ម្រាមដៃ ស ស្ទើរតែកប់បាត់នឹងសាច់ដុំរឹងមាំដូចទឹករលកស្អាត នៅលើរាងកាយមាំមួន។

មិនថាជាសាច់ដុំទ្រូង ឬសាច់ដុំពោះរបស់គេ សុទ្ធតែរឹងដូចក្ដាកី ឬតាមពិតទៅ សេត ដែលនាងស្គាល់ ក្នុងនាមលោក ម៉ារីស រឹងមាំសព្វសាច់នោះឯង។ នាងដឹងថា គេជាបុរសដែលមានរូបរាងសង្ហា មិនមែនសង្ហាខ្លាំងបែបខ្លង់ខ្ពស់ តែគេជាបុរស ដែលមានបុគ្គលិកលក្ខណៈក្ដៅគគុកនិងគ្រោះថ្នាក់ គេជាបុរស





Scanned by CamScanner

សិចស៊ី ស្រីរបាំនៅ ណាខាដៀ សុទ្ធតែចូលចិត្តគេ ចង់ធ្វើជាជម្រើសរបស់គេ ប៉ុន្តែគេជ្រើសរើសនាង ប្រាក់របស់គេការពារនាងពីបុរសផ្សេង ហើយទោះនាងខ្ពើមរអើមអាជីពដែលកំពុងធ្វើ ប៉ុន្តែយ៉ាងហោចណាស់ ការមានទំនាក់ទំនងលើគ្រែជាមួយ សេត តែម្នាក់ វាល្អជាង ឡើងគ្រែជាមួយមនុស្សប្រុសចម្រុះមុខ។

"អ៊ឺ..."

គេចាប់មុខរបស់នាងជាប់ ហើយងើបអង្គុយ ព្រមទាំងចាប់រាងកាយរបស់នាងឱ្យមកនៃបនិត្យជាមួយ កែវភ្នែកគឃ្លើន ពោរពេញទៅដោយភ្លើងប្រាថ្នាដែលបង្កប់ដោយអារម្មណ៍ប្រឆាំងដែលនាងមាន តែមិនអាចតតាំងនឹងព្យុះប្រាថ្នាបាន ធ្វើឱ្យគេឈ្លក់វង្វេងនឹងការប្រសព្វភ្នែកជាមួយនាង។

សាន់នី ជាមនុស្សស្រីដែលស្អាតសព្វសាច់ ស្លៀកពាក់ក៏ស្អាត ស្រាតក៏ស្អាតមុខមាត់ស្រស់ស្រទន់របស់នាងស្អាតមិនសមនឹងធ្វើអាជីពជាស្រីរបាំនៅណាខាដៀ ធ្វើឱ្យខ្សែភ្នែករបស់គេសម្លឹងមើលនាងតាំងពីវិនាទីដំបូងដែលបានឃើញនាង។

ម្រាមដៃញ័រៗដែលគេចាប់ ពេលនាងគ្រលែងត្រគាកដើម្បីកម្ចាយអារម្មណ៍ចេញពីខ្លួន ទឹកមុខឆ្មើងឆ្មៃនិងខ្សែភ្នែកសោកសៅ ធ្វើឱ្យគេហៅ យ៉េរ៉ូលឱ្យមកជួប និងសម្រេចចិត្តទាញនាងទម្លាក់ពីវេទិការបាំស្រាតដោយប្រាក់ដែល



Scanned by CamScanner

គេមាន។

នាងមិនទាន់ដោះសម្លៀកបំពាក់ផង ក៏ត្រូវគេទាញមកឱប។ គេនៅចងចាំរាត្រីដំបូងដែលបានគ្រប់គ្រងនាង ទាំងដែលមិនធ្លាប់ចាំរាត្រីដំបូងជាមួយស្រីណា ប្រហែលមកពីមួយរយៈនេះគេមានតែនាងម្នាក់ មិនត្រឹមតែមួយរយៈនេះទេ តាំងពីបាននាងលើកដំបូង គេក៏មិនធ្លាប់ប្តូរសជាតិ ទៅលេបត្របាក់ស្រីណាទៀត។

*ជិតពីរឆ្នាំហើយ យើងទ្រាំស៊ីបង្អែមចានដដែលៗបានដោយរបៀបណា!*

"ថ្ងូរឱ្យខ្លាំងៗ"

"មិន...មិន...អ៊ាំ..."

សេត ញញឹមឃោរឃៅ ប្រហែលមកពីអាការៈតតាំងរបស់នាងនោះឯងដែលធ្វើឱ្យគេគ្មានអារម្មណ៍ធុញទ្រាន់នាង ពេលនាងបដិសេធ គេក៏ចាត់ការរាងកាយរបស់នាងដោយភាពមាំមួនរបស់គេ យ៉ាងខ្លាំងក្លា ធ្វើឱ្យនាងថ្ងូចថ្ងូរដោយសំឡេងញ័រ។

សម្បុរស ហាក់ដូចទឹកដោះគោរបស់នាងឡើងក្រហម ឈាមនៅក្នុងខ្លួនជ្រួលច្របល់ដោយភាពក្តៅគគុក ក្រៅពីនេះ មាត់និងដៃរបស់គេ ដែលបបោសអង្អែលសព្វសាច់សស្អាត ក៏ធ្វើឱ្យកើតស្នាមក្រហម កន្ទួល ដោយសារស្បែក





Scanned by CamScanner

របស់នាងស្តើងពេកហើយ។ គេជាប់ចិត្តនាង ហើយគេកំពុងតែពិចារណា ដល់ការទិញខ្លួននាងពីរោងរបាំស្រាត ណាខាដៀ ជារៀងរហូត។

គេនឹងទុកនាងនៅលើគ្រែដោយគ្មានអារម្មណ៍ធុញទ្រាន់ បានមួយឆ្នាំពីរទៀតឬអត់ បើវាអាចមានរយៈពេលវែងដល់ថ្នាក់នោះ ការទិញខ្លួននាងចេញពីទីនេះ ចាត់ទុកថាសមាមាត្រ ប៉ុន្តែគេអាចធុញទ្រាន់នាងមុនពេលវេលា ព្រោះមិនទាន់កាត់ចិត្តពីនាងបាន ទើបគេមិនរហេករហាន់នឹងទិញនាងចេញពីទីនេះ។

បើគេសម្រេចចិត្តចរចាទិញនាងពី ឃៃរ៉ូល ពេលណា ខេរ៉ូលច្បាស់ជាកោគេមិនដាក់ទឹក ប៉ុន្តែគេព្រមចំណាយនៅក្នុងតម្លៃដែលសក្តិសមប៉ុណ្ណោះ។

អ្នកកំលោះឱបរឹតរាងតូចស្តើងណែនដៃ ឱ្យដើមទ្រូងធំហួសមាឌរបស់នាង ពិតនឹងដើមទ្រូងធំទូលាយ។

គេគ្រហឹមនៅដើមកដោយពេញចិត្តនឹងភាពទន់ល្មើយដែលត្រដុសនឹងរាងកាយនននលគក រឹងមាំរបស់គេ បបូរមាត់របស់គេបឺតជញ្ជក់បបូរមាត់ក្រពុំឱ្យនាងបើបគេវិញ ព្រោះបើនាងបដិសេធ គេនឹងញ៉ោះដោយការបើបខ្លាំងៗទាល់តែបបូរមាត់ចង់ដាច់សាច់។

បបូរមាត់ទាំងពីរនែបនិត្យគ្នា ពេលដែល សេត ចាប់ត្រគាករបស់នាង ហើយគ្រប់គ្រងចង្វាក់ប្រាថ្នា ទាល់តែរាងកាយរបស់នាងកន្ត្រាក់ដោយសេចក្តី



Scanned by CamScanner

សុខ គេក៏បន្ថែមចង្វាក់ដើម្បីឱ្យខ្លួនឯងទៅតាមនាង និងថើបខ្លាំងៗ ហើយឱបកាន់តែណែន កំលុងពេលពន្លៃងភាពក្តៅគគុកចូលទៅក្នុងខ្លួននាង។

"នាងមានការអីនិយាយជាមួយខ្ញុំ ?"

សេត ថយទៅអង្គុយផ្អែកនឹងក្បាលគ្រែ ខណៈដែល សាន់នី អស់កម្លាំងកំហែងដកដង្ហើមដង្ហក់ដាក់ដើមទ្រូងរបស់គេ ទើបធ្វើឲ្យគេអាណិត ឱបរឹតនាងជាប់ទ្រូង ខណៈដែលដៃម្ខាងទៀត អង្អែលរាងកាយស្រឡៅស្រឡូន ឲ្យនាងសំងំនៅបែបនោះ ដោយនៅតែមិងមាំងនឹងសំណួររបស់គេ។

អារម្មណ៍របស់នាងនៅតែវិលវល់ក្នុងអន្លង់ប្រាថ្នា ទាញខ្លួនឯងចេញមកវិញមិនបាន។ សេត សួរហើយថើបថ្ពាសរបស់នាង អង្អែលរាងកាយនននលគកដែលទន់ដូចចាហួយ រង់ចាំឲ្យនាងឆ្លើយសំណួររបស់គេ។ គេដឹងថានាងមានរឿងចង់និយាយជាមួយគេ ទើបចាត់ការនាងខ្លាំង ដោយការបបួលនាងធ្វើរឿងក្តៅគគុកជាច្រើនដង។

*ចង់គួរឲ្យញ៉ោះធ្វើអី!*

គេពេញចិត្តពេញថ្លើម ការញ៉ោះនាងគឺជាសេចក្តីសុខមួយរបស់គេរង់ចាំទាល់តែនាងស្ងួតខ្លួន ទើបទាញភួយមកដណ្តប់ឲ្យទាំងពីរនាក់។

"អឺ...លោក ម៉ារីស"





Scanned by CamScanner

"បាទ ពៅព្រលឹង"

គេភ្ញើយចង្ការបស់នាង ឱនទៅថើបបបូរមាត់ទន់ល្មើយ សាន់នី ក៏ងាកមុខចេញ ដោយគ្មានចេតនាគេចនោះទេ ប៉ុន្តែខ្លាចគេថើបហើយ មិនបាននិយាយសាច់ការ ទាស់ត្រង់ថា សេត មិនព្រមឲ្យគេច គេសង្កត់កញ្ចឹង.ករបស់នាង ហើយថើបខ្លាំងៗ ធ្វើឲ្យនាងទន់ខ្លួនល្វកម្ដងទៀត។

"ខ្ញុំអនុញ្ញាតឲ្យនាងនិយាយជាមួយខ្ញុំដប់ប្រាំនាទីប៉ុណ្ណោះ ពៅព្រលឹង ហើយខ្ញុំនឹងធ្វើរឿងដែលខ្ញុំនិងនាងចូលចិត្តដូចគ្នាបន្ត"

សាន់នី យល់ពីសម្ដីរបស់គេ គេត្រូវការសេពសុខរាងកាយរបស់នាងទៀត ពេលវេលាដប់ប្រាំនាទីធ្វើឲ្យនាងត្រូវពិចារណា និយាយសាច់ការជាមួយគេ ឲ្យបានច្បាស់លាស់បំផុត។

"ខ្ញុំចង់សុំជំនួយពីលោក ម៉ារីស រឿងប្អូនស្រីរបស់ខ្ញុំ"

"នាងគិតថាខ្ញុំជួយស្អីនាងបាន"

"ខ្ញុំចង់សុំឱកាសឲ្យប្អូនស្រីរបស់ខ្ញុំ មានជីវិតរស់នៅខុសពីខ្ញុំ មិនបាច់លក់ជីវិត ដើម្បីបានរស់នៅបន្ត"

នាងងើយមុខមើលគេដោយទឹកភ្នែករលីងរលោង តែមិនមែនព្រោះត្រូវការប្រើទឹកភ្នែកទាមទារការចាប់អារម្មណ៍ពីគេនោះទេ នាងកំពុងតែអាម៉ាស់



Scanned by CamScanner

ចំពោះជោគជតារបស់ខ្លួនឯងប៉ុណ្ណោះ។

"មានអីកើតឡើង សាន់នី ?"

"ពេលគ្រប់អាយុម្ភៃឆ្នាំ ពីណា ត្រូវធ្វើការដូចខ្ញុំដើម្បីដោះបំណុលឲ្យណាខាដៀ ខ្ញុំមិនចង់ឲ្យប្អូនស្រីមានជីវិតដូចខ្ញុំ លោក ម៉ារីស ជួយខ្ញុំបានទេ ហើយខ្ញុំនឹងធ្វើគ្រប់យ៉ាង ជាការសងគុណតាមដែលលោកត្រូវការ"

"នាងមានស្អីមកដោះដូរនឹងខ្ញុំទៀត ?"

នាងក្រមុំភាំង នាងគ្មានអ្វីដោះដូរនឹងគេទៀតទេ ព្រហ្មចារីរបស់នាង គេបានវាទៅហើយ មិនបានយកទៅហ្រ្វីៗ តែគេត្រូវដេញថ្លៃ ដោយប្រាក់ដែលធ្វើឲ្យ ឃៃរ៉ល និង អាដាំ ញញឹមរីកមុខពព្រាយ នាងគ្មានអ្វីនៅសេសសល់ទៀតទេ នាងគ្មានអ្វីទៀតទេ ក្រៅពីខ្យល់ដង្ហើម។

"ខ្ញុំគ្មានស្អីឲ្យទេ ក្រៅពីពាក្យសន្យាថាខ្ញុំនឹងស្តាប់បង្គាប់ ខ្ញុំនឹងព្រមធ្វើគ្រប់យ៉ាង ដែលលោកត្រូវការ ដើម្បីជាការសងគុណ"

នាងមិនប្រសព្វនិយាយការអង្វរករក៏មិនពូកែទៀតទើបអង្វរករគេដោយចិត្តស្មោះ តាមដែលខ្លួនឯងអាចបញ្ចេញមកបាន។

"ខ្ញុំនឹងគិតមើល"

"ខ្ញុំបានចម្លើយពេលណា..."





Scanned by CamScanner

បើយូរពេក អាចនឹងមិនទាន់ពេលជួយប្អូនស្រី ធ្វើឲ្យនាងខ្វល់ខ្វាយចិត្ត ព្រោះមានឱកាសតិចណាស់ដែល ម៉ារីស ព្រមជួយនាង។

"ពេលខ្ញុំព្រមឆ្លើយ"

"លោក ម៉ារីស..."

"តួនាទីរបស់នាងគឺបម្រើខ្ញុំ សាកធ្វើឲ្យខ្ញុំយល់ស្របដោយខ្លួនឯងទៅ សាន់នី ពាក្យសន្យាដែលប្រាប់ថានាងនឹងព្រមធ្វើគ្រប់យ៉ាងឲ្យខ្ញុំពេញចិត្ត នាងធ្វើវាបានល្អប៉ុណ្ណា"

នាងតានតឹងចិត្តខ្លាំងណាស់ ប៉ុន្តែត្រូវតែព្រមធ្វើគ្រប់យ៉ាងដែលគេបញ្ជា ដើម្បីឲ្យគេព្រមចិត្តទន់ ជួយនាំប្អូនស្រីរបស់នាង ចេញពីនរកមួយនេះ។

**សាន់នី អង្វរករគេដើម្បីប្អូនស្រី ហើយនាងក៏ធ្វើឲ្យរាងកាយរបស់គេ** ស្ទើរតែឈ្លក់សេចក្ដីសុខស្លាប់នឹងភាពទន់ភ្លន់របស់នាង។ នាងធ្វើឲ្យគេដឹងថា នាងពេញចិត្តនឹងប្រណិប័តន៍គេ ការអង្វរកររបស់នាង សេត អាចធ្វើវាបានយ៉ាងស្រួល។

នាងព្រមឲ្យប្អូនស្រីចាកចេញពីទីនោះ ប៉ុន្តែខ្លួនឯង ត្រូវនៅទីនោះបន្ត បើថ្ងៃមួយគេធុញទ្រាន់នាង ឈប់ចិញ្ចឹមនាង គឺមានន័យថានាងត្រូវយកមុខ



Scanned by CamScanner

មាត់ស្រស់ស្អាត និងរាងកាយផ្អែមល្ហែមរបស់នាង ទៅធ្វើជារបស់កម្ចាយអារម្មណ៍ឲ្យប្រុសផ្សេងអីចឹងឬ។

អ្នកកំលោះចងចិញ្ចើម គេកើតអារម្មណ៍ហួងហែង ស្រីមុខស្រស់ដែលគេឱបពេញមួយរាត្រីកន្លងមក គេមិនទាន់ឲ្យចម្លើយដល់នាង និងចាកចេញពេលដែលនាងដេកលក់ គេត្រូវត្រឡប់ទៅកោះ ចោរ ព្រោះមានការងារត្រូវធ្វើ តែគេមិនភ្លេចសំណូមពររបស់នាង គ្រាន់តែមិនគិតនឹងឆ្លើយប្រាប់នាងភ្លាមៗ។ គេជាប់ចិត្តនាង ចិញ្ចឹមមើលថែនាង ប៉ុន្តែវាត្រូវតែបែងចែកឲ្យជ្រះស្រឡះពីការជួយប្អូនស្រីរបស់នាង គេនឹងពិចារណារឿងនេះ ហើយសម្រេចចិត្តម្តងទៀត ប៉ុន្តែមុខមាត់ស្រស់ស្រទន់ ដែលមើលមកគេដោយការអង្វរករ ធ្វើឲ្យគេកម្ចាត់រឿងនេះចេញពីខួរក្បាលបានយ៉ាងលំបាក។

"ម្ចាស់តូច"

សេត ងាកទៅ តាមសំឡេងហៅ គេគឺជាម្ចាស់តូចនៃកោះ ចោរ ឬកម្រង កោះ ស៊ី រ៉ូវើ។ ឪពុករបស់គេគឺ ជីសាស់ ស៊ី រ៉ូវើ ប្រមុខកោះ ចោរ។ សៃស្រឡាយរបស់គេមិនធម្មតា ព្រោះម្តាយរបស់គេគឺព្រះនាង យៃតទ្រីណា ម៉ាលខៃសេនតេ ដែលជាប្អូនស្រីរបស់ព្រះអង្គម្ចាស់ ខាឡូម៉ាន់ ម៉ាលខៃសេនតេ ប្រមុខប្រទេសសាក់ខារៀ។





Scanned by CamScanner

"មានការអី ?"

"មានទូកចូលដែនទឹករបស់យើង"

សេត ងើបឈរភ្លាម ពេលនេះគេស្លៀកខូវប៊យតែមួយប៉ុណ្ណោះ រាងកាយវែងលើទទេស្អាត ស្បែករបស់គេពណ៌ទង់ដែងស្អាត ហើយទោះរៀបចំខ្លួនមិនសូវល្អ ក៏រស្មីនៃភាពជាអ្នកដឹកនៅតែសាយភាយចេញពីរាងកាយរបស់គេ។

"អាណា!"

"តាមដែលត្រួតពិនិត្យ គឺជាទូកដែលមកពី ខាសេ"

កោះ ចោរ ជាតំបន់ដែលត្រូវហាមប្រាម ឬទោះមិនមែនជាតំបន់ដែលត្រូវហាមប្រាម ការចូលទៅជិតដែនទឹករបស់ប្រទេសអ្នកដទៃ ដោយគ្មានការរាយការណ៍ជាមុន មិនមែនជារឿងដែលត្រូវធ្វើ។

"សង្ឃឹមថាជាពួកមិនដឹងខ្យល់អី ព្រោះបើវាមានចេតនា ខ្ញុំនឹងយកឈាមរបស់វាមកលាងជើង"

កែវភ្នែករបស់ សេត ឡើងរឹងកំព្រឹស ទូកជាច្រើនគ្រឿងត្រូវការចង់សាកនឹងកោះ ចោរ ហើយពួកវាក៏ត្រូវបញ្ចប់ជីវិត ព្រោះភាពល្ងង់ខ្លៅ។

"អញ្ជើញម្ចាស់តូច"

កូនចៅជំនិតរបស់ សេត អញ្ជើញគេឲ្យចុះទូកលឿន គេក៏លោតចុះភ្លាម



Scanned by CamScanner

ដោយមិនរារែក ដោយបញ្ឈប់ការនឹករឭកដល់ការអង្វរកររបស់ សាន់នី ព្រោះត្រូវចេញទៅបំពេញភារកិច្ច។

**សាន់នី ចាប់ផ្ដើមខ្វល់ខ្វាយចិត្ត ទាំងដោយដឹងថានាងមិនគួរខឹង ម៉ារីស** ទោះគេមិនជួយក៏ដោយ ប៉ុន្តែនៅតែអត់ខឹងមិនបាន ខឹងនាងគុំកួន ការព្រួយបារម្ភចំពោះប្អូនស្រី វាជ្រួលច្រាល់នៅក្នុងទ្រូង ការបាត់ដំណឹងសូន្យឈឹងរបស់ ម៉ារីស ធ្វើឲ្យនាង ច្បាស់ពីចម្លើយរបស់គេហើយ។

នាងក៏មិនបាននៅស្ងៀម រិះរកផ្លូវផ្សេងដែរ ប៉ុន្តែភាពងងឹតនៅតែគ្របដណ្ដប់ មានមនុស្សស្រីជាច្រើន ដែលព្យាយាមរត់គេច ពេលគេចមិនរួច ក៏ត្រូវទទួលទោស។ នាងមិនត្រូវការប្រថុយបែបនោះ ព្រោះការដាក់ទោស គឺជាទោសដ៏ធ្ងន់ធ្ងរសម្រាប់មនុស្សស្រី បើនាងសម្រេចចិត្តខុស នាងនឹងស្ដាយក្រោយមួយជីវិត។

នាងអង្គុយភ្លឹក មើលទៅក្រៅបង្អួច តែមិនឃើញស្រមោលអីផ្សេងក្រៅពីរូបភាពនៅក្នុងអាគារ ណាខាដៀ។ ភាពតានតឹងនោះធ្វើឲ្យនាងរលីងរលោងទឹកភ្នែក ក្រៅពីនេះ នាងនៅអស់សង្ឃឹមចំពោះបុរសដែលគិតថាគេជាក្ដីសង្ឃឹមចុងក្រោយរបស់នាង។





Scanned by CamScanner

"បងសាន់នី"

នាងក្រមុំប្រញ៉ាប់លើកដៃជូតទឹកភ្នែកដែលរលីងរលោង ព្រោះមិនអាចឲ្យប្អូនស្រីឃើញភាពទន់ជ្រាយរបស់ខ្លួន វានឹងកាន់តែធ្វើឲ្យ ធីណា តានតឹងតាម។

"ខ្ញុំចូលមករំខានឬអត់?"

ធីណា ដើរចូលទៅក្នុងបន្ទប់ដេករបស់បងស្រី សាន់នី ក៏ងាកទៅញញឹមដាក់ ទើបហ៊ានដើរទៅរក។

"មានអីឬអត់?"

"ដល់ពេលញ៉ាំអាហារថ្ងៃត្រង់ហើយ"

"បងមិនទាន់ឃ្លាន"

នាងគិតច្រើនដល់ថ្នាក់លេបអីមិនចូល។ ធីណា ដាក់បង្កួយលើសាឡុងស្រវាចាប់ដៃរបស់បងស្រី ដែលត្រូវមើលថែសុខភាពរាងកាយរបស់បងស្រីឲ្យបានល្អបំផុត។

"បើបងមិនញ៉ាំ ខ្ញុំក៏មិនញ៉ាំ"

"បើរឹងដាក់បងមិនបានទេ"

"ខ្ញុំបារម្ភពីបងហ្នឹងណា៎"



Scanned by CamScanner

សាន់នី ត្រូវបុះញ៉មឲ្យប្អូនស្រីព្រោះបើបដិសេធការទទួលទានអាហារ ធីណា នឹងរឹងទទឹង ត្រូវទ្រាំអត់ឃ្លានព្រោះតែនាង ដូច្នេះហើយនាងមិនអាចអាត្មានិយមបានទេ។

"បងព្រមញ៉ាំក៏បាន"

"អ៊ីចឹង ទៅញ៉ាំអាហារថ្ងៃត្រង់ ខ្ញុំរៀបចំដាក់លើតុរួចហើយ"

ធីណា ងើបឈរ ហើយទាញដៃបងស្រីឲ្យងើបតាម នាំគ្នាដើរចេញពីបន្ទប់ដេក សំដៅកន្លែងទទួលភ្ញៀវ ដែលជាប់នឹងផ្ទះបាយ។

...

**"ម្ចាស់តូច" គ្រីស ឱនគំនាប់ចៅហ្វាយ។**

សេត ត្រូវធ្វើដំណើរទៅបរទេសជាមួយ ព្រះអង្គម្ចាស់ ខាឡូម៉ាន់ និង រ៉េនដហ្វ ហើយគេត្រូវចាត់ការរឿង ធីណា ឲ្យរួចរាល់មុនពេលធ្វើដំណើរ ព្រោះបើត្រឡប់មកវិញចាំចាត់ការ អាចនឹងយឺតពេលក៏ថាបាន ហើយបើគេជួយប្អូនស្រី សាន់នី មិនទាន់ នាងច្បាស់ជាដាក់បណ្ដាសាគេតាមកែវភ្នែកស្រទន់របស់នាងមិនខាន។ អ្នកកំលោះ មានអារម្មណ៍ល្អបន្តិច ពេលនឹកដល់ស្រីមុខស្រស់ រាងកាយផ្អែមល្ហែមដូចទឹកឃ្មុំ ដែលគេចូលចិត្តស្រង់ក្លិន ពីសាច់ទន់ល្មើយសព្វសាច់តែម្ដង។





Scanned by CamScanner

"ទៅចាត់ការរឿងរបស់ ធីណា នៅ ណាខាដៀ"

"ចាត់ការបែបណាម្ចាស់តូច ?"

"ការពារមិនឲ្យនាងឡើងសំដែងរបាំស្រាត ហើយហាមប្រុសផ្សេងទៅទាក់ទងនាង"

"បាទម្ចាស់តូច"

សេត ចេញពីកោះ ចោរ ហើយ ត្រូវធ្វើដំណើរទៅក្រុង សេថាម៉ារ៉ា។ គេចង់ចាត់ការរឿងនេះផ្ទាល់ ព្រោះចង់ឃើញមុខមាត់ស្រស់ស្អាត តែក្រអើតក្រទមរបស់ សាន់នី ប៉ុន្តែពេលខ្លះតម្រូវការរបស់គេ ក៏ត្រូវផ្អាក ព្រោះការងារសំខាន់ជាង។

"ឯងធ្វើដំណើរទៅក្រុង ហ៊ីតវែល ថ្ងៃនេះ និងចាត់ការឲ្យរួចរាល់"

"បាទម្ចាស់តូច"

"សុំអនុញ្ញាត"

សំឡេងគោះទ្វារបន្លឺឡើង តាមដោយសំឡេងអង្គរក្សជំនិត ដែលសុំការអនុញ្ញាតហើយបើកទ្វារដើរចូលមកបន្ទប់ដែល សេត និង គ្រីស កំពុងសន្ទនាគ្នា។

"ម្ចាស់តូច រថយន្តរៀបចំរួចរាល់ហើយ នៅសល់ពេលពីរនាទីប៉ុណ្ណោះ"



Scanned by CamScanner

"បញ្ញា គ្រីស"

"ទទួលបញ្ជាម្ចាស់តូច"

ជាទំនៀមទម្លាប់របស់ សេត នៅក្រោមបង្គាប់បញ្ជារបស់គេ បន្ទាប់ពីបញ្ជាឲ្យប្រតិបត្តិការងារ គឺត្រូវតែមានការបញ្ជាក់ ហើយកូនចៅក៏ត្រូវទទួលបញ្ជាមុនពេលចេញប្រតិបត្តិតួនាទី។សេតដែលថ្ងៃនេះពាក់គ្រ័រហ្សេទំនើបពណ៌ខ្មៅមួយតួខ្លួន ដើរសំដៅរថយន្តដើម្បីធ្វើដំណើរទៅប្រាសាទដែលជាដំណាក់របស់ព្រះអង្គម្ចាស់ ហ្គាវៀន។

"អញ្ជើញម្ចាស់តូច"

ទ្វាររថយន្តត្រូវបើក សេត ឡើងទៅអង្គុយ សង្ឃឹមថាស្រីស្រស់របស់គេនឹងពេញចិត្តចំពោះក្តីមេត្តាដែលគេប្រគល់ឲ្យ នាងគួរតែរំភើប ជាខ្លាំង ដែលគេមិនបដិសេដការអង្វរកររបស់នាង ទាំងដែលគេមិនបាច់ចាប់អារម្មណ៍ក៏បាន។ គេតានតឹងបន្តិចពេលនឹកដល់ សាន់នី ធ្វើឲ្យរាងកាយរបស់គេ មានតម្រូវការ ប៉ុន្តែគេមិនគិតថាយកទៅកម្ចាយជាមួយស្រីផ្សេង គេអត់ធ្មត់ ហើយត្រឡប់មកវិញនឹងចាត់ការនាងឲ្យណាណើ។



"មិនពិត!"



Scanned by CamScanner

សាន់នី ស្ទុះទៅរកប្អូនស្រី ប៉ុន្តែបុរសមាឌដំបងដែល ឃៃរ៉ល នាំមកជាមួយ ចូលមកពាំង។ ឃៃរ៉ល កំពុងតែរីកមុខពព្រាយ ព្រោះខ្លួននិងស្វាមី បានចំណូលពីការលក់ ធីណា ឲ្យ ម៉ារីស។ ពីរនាក់បងប្អូននេះ មានស្ម៊ីល្អទៅ ទើប ម៉ារីស ម៉ៅយកទៅមើលថៃ ទាំងពីរតែម្តង។

"នេះជារឿងពិត សាន់នី"

ឃៃរ៉ល ដឹងថា សាន់នី មិនពេញចិត្ត ប៉ុន្តែការពេញចិត្តឬមិនពេញចិត្តរបស់ សាន់នី មិនសំខាន់សម្រាប់ ឃៃរ៉ល។

"ត្រូវតែមិនពិត"

នាងនៅតែនៅនិយាយរអ៊ូៗ បាត់បង់ការគ្រប់គ្រងមួយខណៈ។ នាងជាមនុស្សស្រីដែលគ្រប់គ្រងស្មារតីបានល្អជានិច្ច ប៉ុន្តែវាកំពុងតែយ៉ាប់យ៉ឺន ព្រោះភាពអស់សង្ឃឹមដែលកំពុងលុកលុយនៅក្នុងទ្រូង។ នាងមិនបានអង្វរករឲ្យ ម៉ារីស ជួយចញ្ចឹមប្អូនស្រីរបស់នាងម្នាក់ទៀត នាងត្រូវការឲ្យគេនាំ ធីណា ចេញពី ណាខាដៅ។

"បង សាន់នី"

សំឡេងញ័រទទ្រើតរបស់ ធីណា ចាក់បេះដូងរបស់នាង ឲ្យចេញឈាម ប៉ុន្តែនាងមិនអាចចូលទៅរកប្អូនស្រីរបស់ខ្លួនបាន ព្រោះ ឃៃរ៉ល គ្រវីដៃចេញ



Scanned by CamScanner

បញ្ជាឲ្យបុរសមាឌដំបងក្រុមនោះ នាំ ធីណា ចេញពីបន្ទប់។

"ខ្ញុំមិនចង់ទៅ បង សាន់នី"

"ធីណា!"

"កុំមករវល់អី សាន់នី" ឃៃរ៉ល ហាមាត់ដាស់តឿន ដោយសំឡេងស្រទន់ ប៉ុន្តែវាជាការគំរាមដល់ សាន់នី មិនព្រមឈប់ នាងនិងប្អូនស្រីនឹងមានបញ្ហា។

"ធីណា នៅក្មេងណាស់ ឃៃរ៉ល"

"ក្មេងស្អី កាលនាងក៏អាយុប៉ុណ្ណឹងដែរ ខ្ញុំនឹងនាំ ធីណា ទៅដុសខាត់ស្បែកឲ្យកាន់តែស្អាត រង់ចាំទទួលលោក ម៉ារីស"

"គេមកពេលណា?"

នាងក្តាប់ដៃណែន ភាពត្រេកាមរបស់មនុស្សប្រុស គឺជារឿងពិត ពេលខ្លះខុសពីការស្មាន ព្រោះគេមិនចេះស្តាប់ស្តល់ដល់ថ្នាក់គួរឲ្យខ្ពើមរអើម។

"លោក ម៉ារីស មិនបានជូនដំណឹង" ឆ្លើយតាមត្រង់ នាងទទួលបានប្រាក់ពីមនុស្សរបស់ ម៉ារីស ដែលមកចាត់ការរឿងនេះជំនួសចៅហ្វាយ ប៉ុន្តែនាងត្រូវតែត្រៀមខ្លួន ធីណា ឲ្យរួចរាល់។

"មានន័យថាគេមិនទានមកមែនទេ?"



"មែនហើយ ហើយក៏គ្មានការកំណត់មកដែរ"



Scanned by CamScanner

ចង់ប្រាប់ថា ជាអាការៈធូរទ្រូងក៏បាន ព្រោះបើ ម៉ារីស មកទីនេះនៅយប់នេះ ដើម្បីគ្រប់គ្រងប្អូនស្រីរបស់នាង នាងច្បាស់ជាឆ្កួត ។ នាងស្អប់គេ នាងចង់ខ្វាចមុខសង្ហារបស់គេឲ្យខ្ទេចខ្ទី។

មនុស្សជួជាតិ!

"នាងពីរនាក់បងប្អូនសំណាងល្អ"

ឃែរ៉ល បូញមាត់បូញ.កនិយាយជាមួយ សាន់នី ខណៈដែលនាងក្រមុំបានតែញញឹមចុងមាត់ ឡកឡឺយនៅក្នុងចិត្ត។ បងនិងប្អូនដែលត្រូវដេកជាមួយមនុស្សប្រុសតែម្នាក់ ហើយថាសំណាងល្អអីចឹងឬ វាគួរឲ្យខ្ពើមរអើមទៅវិញទេ។

បេះដូងរបស់ សាន់នី ស្ទើរតែគាំង ពេលងាកទៅមើលប្អូនស្រីធ្វើបានត្រឹមតែតាមមើល ដោយការឈឺចាប់។

"មានន័យថា ជីណា នៅមានសុវត្ថិភាព"

"នាងនិយាយស្អី សាន់នី ?"

"អត់មានទេ"

បើ ម៉ារីស មិនទាន់មក អីចឹង ជីណា នៅតែមានសុវត្ថិភាពពីដៃមនុស្សល្មោភម្នាក់នោះ យ៉ាងហោចណាស់ក៏ជាសុវត្ថិភាពរយៈពេលខ្លី អាចពន្យារពេលបានបន្តិចទៀត។



Scanned by CamScanner

"នាងគួរតែរំភើបនឹងទឹកចិត្តទូលាយរបស់ ម៉ារីស សាន់នី"

"ចាស ឃែរ៉ល"

ការប្រកែកតវ៉ានឹង ឃែរ៉ល គឺជារឿងរបស់មនុស្សល្ងង់ ដូច្នេះហើយ នាងបានត្រឹមតែអ៊ឺអើតាម ខណៈដែលបេះដូង តវ៉ាប្រកែកប្រណាំងនឹងសម្ដីរបស់ស្រីកំណាចម្នាក់នោះ។

"លោក ម៉ារីស និងមើលថែនាងទាំងប្អូនស្រីនាង សំណាងល្អណាស់ដែលពួកនាងទាំងពីរមិនបាច់ធ្វើការលើវេទិកា និងបម្រើភ្ញៀវផ្សេងទៀត តែគួរឲ្យស្ដាយដែលពួកនាងមិនបានប្ដូរសជាតិ"

"ប្ដូររសជាតិ ?"

"រឿងលើគ្រែនោះអី មនុស្សប្រុសម្នាក់ៗឲ្យអារម្មណ៍មិនដូចគ្នាទេ"

ឃែរ៉ល លើកដៃខ្ទប់មាត់សើច ដែលចម្លើយនេះ ធ្វើឲ្យ សាន់នី មានអាការៈអន្ទឹមអន្ទម ដោយការខ្ពើមរអើម។ បើនាងចូលចិត្តប្រហែលមានសេចក្ដីនឹងការបានប្ដូរដៃគូលើគ្រែ ប៉ុន្តែនាងគ្មានចំណង់ចំណូលចិត្តបែបហ្នឹង។

"ចាស ឃែរ៉ល"

"ខ្ញុំទៅចាត់ការរឿង ធីណា ត្រៀមទុកសម្រាប់លោក ម៉ារីស សិន"



"ចាស ឃែរ៉ល"



Scanned by CamScanner

"ខ្ញុំដាស់តឿននាងម្តងទៀត សាន់នី ធ្វើខ្លួនស្តាប់បង្គាប់ បើនាងហ៊ានបង្កបញ្ហា ខ្ញុំនឹងមិនចិត្តល្អដាក់នាងដូចរាល់ដងទេ នាងហួងហែងប្អូនស្រី ខ្ញុំយល់ ប៉ុន្តែនាងដឹងហើយថា នាងនិងប្អូនស្រីត្រូវដឹងពីបំណុលដែលម្តាយរបស់នាងជំពាក់ខ្ញុំ"

យ៉ៃរ៉ល និយាយដោយសំឡេងស្រទន់ ប៉ុន្តែគ្រប់ពាក្យសម្តីគឺជាការគំរាមកំហែង ដែល សាន់នី បានត្រឹមតែក្តាប់ដៃណែន ខ្ទាំទាល់តែក្រចកមុតសាច់បាតដៃ ប៉ុន្តែ នាងមិនឈឺ កន្លែងដែលឈឺគឺបេះដូង។

(**គ្រប់យ៉ាងរៀបរយហើយ ម្ចាស់តូច**)

សេត បានទទួលការរាយការណ៍ពី គ្រីស ព្រោះគេមិនបាននៅក្នុងប្រទេស ទើបឲ្យ គ្រីស ចាត់ការ យកប្រាក់ទៅការពារ ធីណា សិន ហើយពេលគេត្រឡប់ទៅវិញ នឹងចាត់ការដោយខ្លួនឯង ថានឹងធ្វើយ៉ាងណាចំពោះពីរនាក់បងប្អូននោះ ហើយបើចង់យក ធីណា ចេញពី ណាខាដៀ គេត្រូវយក សាន់នី មកជាមួយ។

ស្រីមុខស្រស់ម្នាក់នោះជារបស់គេ រាងកាយទន់ល្មើយ ក្រអូបរបស់នាងក៏ជារបស់គេ គេមិនព្រមឲ្យប្រុសផ្សេងប៉ះពាល់នាង មិនឲ្យជាន់ដានរបស់គេជា



Scanned by CamScanner

ដាច់ខាត ពេលនេះគេមិនទាន់ធុញទ្រាន់ ហើយគេក៏មិនត្រូវការឲ្យមានរឿងបែប នោះកើតឡើងដែរ។

"ឯងទៅដែរទេ សេត ?"

វែនដហ្វ សួរបញ្ជាក់។ ពួកគេធ្វើដំណើរចេញពីប្រទេសសាក់ខាវៀ ដើម្បី មកចូលរួមប្រជុំសំខាន់លំដាប់ពិភពលោក ដែលរៀបចំនៅប្រទេសបារាំង។

"ទៅណា ?"

"ផឹក"

វែនដហ្វ និងព្រះអង្គម្ចាស់ ហ្គាវៀន ចុះទៅផឹកនៅក្នុងក្លឹប ដែលជាការ ផឹកដើម្បីបន្ធូរអារម្មណ៍ ពួកគេត្រូវការសុរា តែមិនត្រូវការនារី។

"ផឹកតែម្យ៉ាង ?"

"អឺ"

"មួយរយៈនេះរក្សាខ្លួនរក្សាប្រាណណាំ វែនដហ្វ"

"មានន័យពីស្អី ?"

"ហួងហែងខ្លួនជាពិសេស"

សេត ត្បុកសួរដោយមិនប្រាកដប្រជា ការចង់បានចម្លើយដែលច្បាស់ លាស់ពី វែនដហ្វ គឺជារឿងពិបាក យ៉ាងហោចណាស់ គឺទាល់តែ វែនដហ្វ ព្រម





Scanned by CamScanner

បើកចំហ។

"ចុះឯង ?"

"ខ្ញុំយ៉ាងម៉េច ?"

"អស់លុយប៉ុន្មានហើយ ទៅលើស្រីនៅ ណាខាជៀ"

រ៉េនជហ្វ ត្បកសួរ ដោយសំឡេងស្មើ ដែលក្រៅពីមិនឆ្លើយសំណួររបស់សេត ហើយ នៅរូងយកអាថ៌កំបាំងទៀត។

"ខក់ៗ"

"កើតអី"

"ឈប់និយាយៗ"

សេត យករួចខ្លួនងាយៗ។ គេជាប់ចិត្តនឹង សាន់នី ប៉ុន្តែគ្មានអនាគតវែងឆ្ងាយសម្រាប់នាង គេចិញ្ចឹមនាង ដោយធ្វើកិច្ចសន្យាមិនលើសពីពីរឆ្នាំប៉ុណ្ណោះ។

**ធីណា យំខ្សឹកខ្សួល ចង់ជួបបងស្រី ប៉ុន្តែ យែរ៉ល ប្រាប់ថាមិនអាចជួប**បាន ព្រោះត្រូវត្រៀមខ្លួនចាំទទួលលោក ម៉ារីស។

"ឈប់យំទៅ ធីណា បើមិនចង់ឲ្យបងស្រីរបស់នាងមានបញ្ហា"

ឃៃវ៉ល ធុញទ្រាន់នឹងភាពទន់ជ្រាយរបស់ក្មេងស្រីម្នាក់នេះ។ បើនាងស្អាតដូចពីរនាក់បងប្អូន នាងនឹងប្រើសម្រស់របស់ខ្លួន រកសេចក្ដីសុខឲ្យបុរសៗឲ្យណាណី ព្រោះថ្នាក់នាងមិនស្អាតផង នៅអាចលួចលាក់ឡើងគ្រែជាមួយប្រុសផ្សេងនៅក្រោយខ្នងស្វាមីបានជានិច្ច។

នាងស្រឡាញ់ អាដាំ ប៉ុន្តែក៏ត្រូវការភាពរំភើបញាប់ញ័រនៅក្នុងជីវិតសេចក្ដីសុខបណ្ដោះអាសន្ន ធ្វើឲ្យឈាមរបស់នាងជ្រួលច្របល់ សុំត្រឹម អាដាំ ចាប់មិនបាន គឺគ្រប់គ្រាន់ហើយ។

នាងត្រួតពិនិត្យរាងកាយនននលគករបស់ ជីណា នៅក្នុងអាងទឹក ដែលមានស្រីបម្រើបីនាក់ជួយដុសខាត់ស្បែក។

"នាងនេះស្អាត ទោះមិនស្អាតដូចបងស្រី តែក៏ស្អាតខ្លាំងណាស់"

ធ្លាប់គិតថា ជីណា គួរតែស្អាតជាងនេះ ប៉ុន្តែសម្រស់ប៉ុណ្ណឹង គឺគ្រប់គ្រាន់ហើយដែលធ្វើឲ្យមនុស្សប្រុសឈ្លក់វង្វេង ថ្នាក់លោក ម៉ារីស ដែលជាប់ចិត្តជិតអារម្មណ៍នឹង សាន់នី រយៈពេលយូរនៅបញ្ជូនមនុស្សឲ្យមកចំណាយប្រាក់កក់ជីណា។ មនុស្សប្រុសគឺបែបនេះហ្នឹងឯង ទោះស្រីមុនស្អាត ល្អយ៉ាងណា ក៏មិនអាចទ្រាំស៊ីរបស់ដដែលៗបានយូរដែរ។

"អ្នកស្រី ឃៃវ៉ល កុំធ្វើអីបង សាន់នី"





Scanned by CamScanner

ធីណា ចាប់អារម្មណ៍តែសម្ដីមុននេះរបស់ ឃៃរ៉ល ដោយមិនត្រូវការឲ្យបងស្រីមានបញ្ហាព្រោះតែខ្លួន ទើបប្រឹងទប់សំឡេងអណ្ដឺតអណ្ដកឡើងមុខក្រហម។

"អ៊ីចឹងធ្វើខ្លួនស្ដាប់បង្គាប់ដាក់ខ្ញុំទៅ"

"ចាស ខ្ញុំនឹងស្ដាប់បង្គាប់"

"ល្អណាស់"

ធីណា ជាក្មេងលង់នៅក្នុងខ្សែភ្នែករបស់ ឃៃរ៉ល ខណៈដែល សាន់នី ឆ្លៀវឆ្លាត ដោយមិនអាចមើលដឹងទេថា សាន់នី កំពុងគិតអី។

"ខ្ញុំនឹងឲ្យគេបង្រៀននាង ពីរឿងនានា ដែលត្រូវប្រណិប័តន៍លោក ម៉ារីស"

"លោក ម៉ារីស ជាស្វាមីរបស់បង សាន់នី"

"ស្វាមីស្អី បងស្រីរបស់នាងគ្រាន់តែជាស្រីលើគ្រែរបស់លោក ម៉ារីស តែប៉ុណ្ណោះ លោក ម៉ារីស ធុញទ្រាន់ពេលណា នឹងត្រូវទាត់ក្បាលចោល"

ធីណា ស្រទប់ាំងកាំងនឹងប្រយោគនោះ ហើយងាកទៅមើលស្រីបម្រើដែលឈ្ងោកមុខឈ្ងោកមាត់ធ្វើការរបស់ខ្លួន ដោយគ្មានអ្នកណាព្រមប្រសព្វភ្នែកជាមួយនាង អ្នកដែលនៅជុំវិញខ្លួននាង មានតែមនុស្សគួរឲ្យខ្លាច ជា



Scanned by CamScanner

ពិសេស ឃៃវ៉ល។ នាងចង់ទៅរកបងស្រី តែបើ ឃៃវ៉ល មិនអនុញ្ញាតគឺមិនអាចធ្វើបាន នាងត្រូវតែធ្វើជាក្មេងស្តាប់បង្គាប់ ដែលជូនកាលបើនាងស្តាប់បង្គាប់ ឃៃវ៉ល អាចព្រមឲ្យនាងទៅជួបបងស្រីក៏ថាបាន។





Scanned by CamScanner

# ៤

## ព្យុះអារម្មណ៍

សេត នឹកភាពទាក់ទាញរបស់ស្រីសាច់ផ្អែមរបស់គេ ទើបប្រឹងប្រែងធ្វើការមិនដកដៃរយៈពេលមួយសប្ដាហ៍កន្លងមកនេះ ហើយត្រូវតែបានរង្វាន់ជាការតបស្នងភាពហត់នឿយរឿងការងារ និងទឹកចិត្តដែលគេមានចំពោះនាង នាងត្រូវតែទទួលខុសត្រូវផ្ដល់រង្វាន់ឱ្យគេ។ អ្នកកំលោះញាត់ញៀតឱ្យ សាន់នី ជាអ្នកផ្ដល់រង្វាន់ឱ្យ ព្រោះគេត្រូវការពីនាង មិនមែនពីអ្នកដទៃ។

នៅតាមផ្លូវធ្វើដំណើរទៅរោងរបាំស្រាត ណាខាងដៀ គេស្រមើស្រមៃដល់ភាពស្រៀវស្រើប ដែលគេនិងនាងធ្វើជាមួយគ្នា។

បបូរមាត់របស់ សេត មានស្នាមញញឹមកំណាច។ ការបាននៅក្នុងខ្លួនរបស់ សាន់នី គឺអារម្មណ៍មានសេចក្ដីសុខកម្រិតកំពូលរបស់គេ។ មិនធ្លាប់មានស្រីណា ធ្វើឱ្យគេជាប់ចិត្តបានដូច សាន់នី។

សេត ចុះពីឡាន និងត្រូវគ្រប់គ្រងខ្លួនឯង មិនឱ្យរត់ទៅរកនាងដូចព្យុះ។



Scanned by CamScanner

*បេះធ្វើខ្លួនជាកូនក្មេងទៅកើត សេត!*

អ្នកកំលោះសួរខ្លួនឯងនៅក្នុងចិត្ត ខណៈនោះ ឃៃរ៉ល ក៏ម្ទីម្នាចេញមកទទួល ព្រោះគេមិនបានជូនដំណឹងជាមុនថានឹងមក។

"លោក ម៉ារីស"

ឃៃរ៉ល បន្ទន់ខ្លួន ធ្វើការគោរព អ្នកដែលមើលមកខ្លួន ដែលតាមធម្មតា បើឃើញខ្សែភ្នែកបែបនេះហើយ នាងត្រូវតែប្រញាប់នាំ សាន់នី មកឱ្យបន្ទាន់។

"លោក ម៉ារីស មកមិនប្រាប់ជាមុន ទើបនាងខ្ញុំមិនបានចេញមកទទួល សូមអភ័យទោសផង"

"មិនអីទេ ខ្ញុំទៅបន្ទប់សម្រាក"

"អញ្ជើញលោក ម៉ារីស នាងខ្ញុំនាំដំណើរ"

ឃៃរ៉ល ចង់នាំដំណើរ ម៉ារីស ទៅបន្ទប់សម្រាកវីអាយភី ដែលតាមធម្មតា ឱ្យបុគ្គលិកនាំផ្លូវក៏បាន ប៉ុន្តែគេគឺជាភ្ញៀវសំខាន់។

"ប្តូរបន្ទប់?"

ពេលមកដល់បន្ទប់ដេក គេក៏ចងចិញ្ចើម ខណៈដែល ឃៃរ៉ល លើកដៃបិទមាត់ គិតថាលោក ម៉ារីស មានចំណង់ចំណូលចិត្តពិសេស ត្រូវការពីរនាក់បងប្អូននៅលើគ្រែតែមួយ។





Scanned by CamScanner

"ចាំ ត្រូវប្ដូរមកបន្ទប់នេះ ព្រោះត្រូវនៅបំបែកគ្នា"

យ៉ៃរ៉ុល យល់ន័យពីសំណួររបស់ សេត ខុសពីអ្វីដែលម្ចាស់សំណួរត្រូវការបញ្ជាក់។ យ៉ៃរ៉ុល យល់ថា សេត សង្ស័យ ពេលគេចំណាយប្រាក់ដើម្បីទិញសេរីភាពរបស់ ជីណា ពីរនាក់បងប្អូនគឺត្រូវនៅបំបែកគ្នាដើម្បីងាយស្រួលក្នុងការប្រណិបតន៍គេ ទើបអធិប្បាយ ព្រោះគេប្រហែលគិតថាពីរនាក់នោះត្រូវនៅជាមួយគ្នាក្នុងបន្ទប់ចាស់។

"អញ្ជើញលោក ម៉ារីស សុំឱ្យមានសេចក្ដីសុខខ្លាំង"

យ៉ៃរ៉ុល បើកទ្វារបន្ទប់ឱ្យ ហើយពេលគេចូលទៅក្នុងបន្ទប់ ក៏ជួយទាញទ្វារបិទ ផ្ដល់ភាពងាយស្រួលឱ្យគេពេញទី។

"សួ...សួស្ដី"

ជីណា ញ៉័រខ្លួនទទ្រើត អង្គុយលើសាឡុង តែពេលឃើញអ្នកចូលមក ក៏ស្ទុះងើបឈរ សម្លឹងមើលគេ និងបន់ស្រន់សុំឱ្យខ្លួនឯងកុំឱ្យល់គនៅពេលនេះ។

គេច្បាស់ជាខឹងមិនខាន!

បើធ្វើឱ្យគេខឹង យ៉ៃរ៉ុល នឹងដាក់ទោសនាងនិងបងស្រី។ នាងខ្លាចគេក្រៅពីនេះ នៅជឿថា គេជាស្វាមីរបស់បងស្រីទៀត។ នាងធ្លាប់ឃើញពួកគេនៅ



Scanned by CamScanner

ជាមួយគ្នាពេញភ្នែកនៅកណ្ដាលបន្ទប់ ទោះឃើញមួយភ្លែតក៏ដោយ ប៉ុន្តែគេមានទំនាក់ទំនងជ្រាលជ្រៅនឹងបងស្រីរបស់នាង។ គេជាបងថ្លៃ ប៉ុន្តែនាងត្រូវមានស្វាមីតែម្នាក់ជាមួយបងស្រីអ៊ីចឹងឬ នាងគិតថាវាមិនត្រឹមត្រូវទេ ប៉ុន្តែនាងខ្លាចការគំរាមរបស់ ឃៃរ៉ល និងមិនត្រូវការឱ្យបងស្រីមានបញ្ហាព្រោះតែខ្លួន បងស្រីការពារនាងពេញមួយជីវិតទៅហើយ នាងមិនព្រមឱ្យបងស្រីអំពល់ទុក្ខដោយសារនាងទៀតទេ។

"ខ្ញុំគិតថាប្រហែលមានអ្វីម្យ៉ាងភ្លាំងភ្លាត់"

សេត សម្លឹងមើលមុខក្មេងស្រីនៅចំពោះមុខ នាងខ្លាចគេឡើងញ័រខ្លួន គិតតែពីគេចមុខគេចមាត់ មិនព្រមមើលចំ ត្រឹមគេ ងាកខ្លួនបន្តិច នាងក៏ទន់ជង្គង់ សម្រូតខ្លួនអង្គុយលើសាឡុងវិញ។

"សុំ...សុំទោស ខ្ញុំខ្លាច"

"ខ្លាចអ្នកណា ខ្លាចខ្ញុំ?"

"ចាំ ខ្លាច"

ធីណា មិនចេះកុហក ពេល សេត ដើរទៅរក នាងខ្លាចគេខ្លាំងណាស់ ចង់រត់គេចចេញពីគេ ប៉ុន្តែមិនអាចទៅណាបាន នាងត្រូវនៅក្នុងបន្ទប់នេះ ដើម្បីបម្រើគេតាមបញ្ជារបស់ ឃៃរ៉ល។





Scanned by CamScanner

"សុំទោស! ខ្ញុំសុំទោស"

"នាងបិទមាត់ទៅ ខ្ញុំជាមនុស្សប៉ិនធុញទ្រាន់ ខ្ញុំត្រូវដាស់តឿនទុកមុន"

សេត ដាក់បង្គុយលើសាឡុង រក្សាគម្លាត ឆ្ងាយពីនាងតាមដែលគេអាចធ្វើបាន ដើម្បីការពារមិនឱ្យក្មេងស្រីម្នាក់នេះតាំងបេះដូង។

"បិទមាត់ហើយលោកកុំខឹងខ្ញុំ ខ្ញុំខ្លាចហើយ"

"ខ្លាចហើយត្រូវនិយាយឱ្យស្តាប់គ្នាយល់ ខ្ញុំមិនចូលចិត្តមនុស្សដែលនិយាយមិនចេះស្តាប់គ្នា យល់ទេ"

"ចាំ យល់ហើយ ខ្ញុំនឹងធ្វើតាមលោកនិយាយគ្រប់យ៉ាង ប៉ុន្តែលោកកុំធ្វើអីបងស្រីខ្ញុំ"

"បងស្រីនាង សាន់នី ?"

នាងងក់ក្បាលបញ្ជាក់ សេត ដឹងហើយថា នាងជាអ្នកណា នាងគឺប្អូនស្រីរបស់ សាន់នី ឃែរ៉ល នាំគេមកទីនេះ ព្រោះគិតថាគេនឹងឡើងគ្រែជាមួយនាង។

"ហើយហេតុអីខ្ញុំត្រូវដាក់ទោស សាន់នី ?"

"ឃែរ៉ល ប្រាប់"

ក្មេងម្នាក់នេះល្ងីល្ងើចូលដល់ថ្នាក់ល្ងង់ តែក៏គួរឱ្យស្រឡាញ់ ជាភាពគួរឱ្យស្រឡាញ់បែបកូនក្មេង មិនមែនបែបស្រីក្រមុំ ដែលមានភាពទាក់ទាញ ចាប់



Scanned by CamScanner

ចំណាប់អារម្មណ៍របស់គេបាន។

មុខមាត់របស់ សាន់នី ផុសថ្កោលនៅក្នុងគំនិតរបស់ សេត ត្រូវតែជាស្រីពេញក្រមុំ ឆ្មាសឆ្មើមតិចៗ តែមិនដល់ថ្នាក់កំណាច ស្រីក្បាលរឹងបែបនោះទៅវិញទេដែលមានមន្តស្នេហ៍ និងអាចទាក់ទាញចំណាប់អារម្មណ៍ពីគេបាន មិនមែនមនុស្សស្រីដែលធំតែខ្លួន តែគំនិតកូនក្មេងដូច ធីណា។

"យ៉ែរ៉ល ប្រាប់អីខ្លះដល់នាង ?"

សេត មិនបង្វែរបង្វៀង មើលតាមអត្តចរិតរបស់ ធីណា ហើយ គេគ្រាន់តែសួរត្រង់ៗ នាងក៏ព្រមប្រាប់គ្រប់រឿង ខុសពី សាន់នី ដែលត្រូវតែមានល្បងទម្រាំបានចម្លើយ ប៉ុន្តែការសន្ទនានឹង សាន់នី ធ្វើឱ្យគេទទួលបានសេចក្តីសុខព្រោះគេអាចឆ្លៀតឱកាសលូកលាន់នាងដែរនៅពេលនោះ នាងតែងតែបង្ហាញអាការៈឆ្មាសឆ្មើម មុខមាត់មិនយល់ព្រម ប៉ុន្តែរាងកាយទោទន់ទៅតាមការដុតរបស់គេ ភាពមានព្រលឹងព្រលះរបស់នាង ធ្វើឱ្យគេកាន់តែចង់ឃើញមុខនាងស្ទើរដាច់ខ្យល់ ប៉ុន្តែគេត្រូវនិយាយជាមួយ ធីណា ឱ្យស្តាប់គ្នាយល់សិន ចាំទៅរក សាន់នី។

"បើខ្ញុំមិនព្រមដេកជាមួយលោក ខ្ញុំនិងបងស្រី នឹងត្រូវដាក់ទោស"

"ដាក់ទោសបែបណា ?"





Scanned by CamScanner

"ការដាក់ទោសនៅទីនេះមានច្រើនវិធី តែដែលធ្ងន់ធ្ងរបំផុត គឺបញ្ជូនខ្ញុំ និងបងស្រី ទៅឱ្យមនុស្សរបស់ ឃៃរ៉ល រំលោភបំពាន លោក ម៉ារីស"

ចម្លើយរបស់ ធីណា ធ្វើឱ្យ សេត ទៅជាឆ្ងល់ចុងច្រមុះ រឿងបែបនេះអាចយកមកគំរាមអ្នកដទៃបានដែរឬ វាគឺជារឿងថោកទាប អីចឹងតើបានជាក្មេងស្រីល្ងីល្ងើនេះ ខ្លាចម្ល៉េះ។

"នាងចង់ឡើងគ្រែជាមួយខ្ញុំឬអត់ ?"

ធីណា គ្រវីក្បាលភ្លាម ជាការពិតដែលគេសង្ហា នាងមិនធ្លាប់ឃើញបុរសណាសង្ហាដូចគេ ប៉ុន្តែគេគឺជាបងថ្លៃរបស់នាង។

"លោកជាបងថ្លៃរបស់ខ្ញុំ"

"បងថ្លៃ ?"

"ចាំ គឺលោកជាស្វាមីរបស់បង សាន់នី"

"បងស្រីរបស់នាងបានព្រួចប្រាស់ជាស្រែកគ្រីត"

សេត ញញឹមចុងមាត់ សាន់នី មិនព្រមទទួលគេជាស្វាមីនោះទេ គេកំពុងតែគិតដល់រឿងមួយ ដោយទឹកមុខលាក់កំណួច គេអាចប្រាប់រឿងនេះដល់នាង ដើម្បីឱ្យគេបានឃើញទឹកមុខខឹងសម្បាលាយទ្បំអឹមអៀនរបស់ សាន់នី។

"ឬថាមិនមែនតែលោកមានស្អីៗជាមួយបង សាន់នី ហើយ ហើយលោក



Scanned by CamScanner

ក៏មើលថែបង សាន់នី បានល្អ បើមិនដោយសារលោក បង សាន់នី ត្រូវទៅធ្វើរឿងបែបនោះជាមួយមនុស្សប្រុសផ្សេងច្រើននាក់ទៀត"

"នាងចង់គិតអីចឹងក៏តាមចិត្ត"

សេត គ្រវីដៃ ក្មេងស្រីល្ងីល្ងើម្នាក់នេះ ប្រហែលមិនចង់ឡើងគ្រែជាមួយគេ ព្រោះនាងមើលមកគេដោយការភ័យខ្លាច។

"យើងត្រូវឡើងគ្រែជាមួយគ្នាមែនឬ ?"

"នាងគិតថាម៉េច ?"

"បើយើងមានស្អីៗគ្នា បង សាន់នី ច្បាស់ជាខូចចិត្ត ព្រោះលោកជាស្វាមីរបស់បង សាន់នី តែបើខ្ញុំមិនព្រម ឃែរ៉ល នឹងដាក់ទោសខ្ញុំនិងបងស្រី ខ្ញុំខ្លាច"

ធីណា ញ័រខ្លួនទៀតហើយ សេត ធុញទ្រាន់ដែលនាងគិតតែមានអាការៈបែបនេះ ប៉ុន្តែគេក៏មានការហេតុផលឱ្យនាងបាន ដោយហេតុផលតែមួយគត់គឺក្មេងស្រីល្ងីល្ងើម្នាក់នេះ ជាប្អូនស្រីរបស់ សាន់នី។

"អីចឹងនាងមិនបាច់ខ្លាចទេ យើងនឹងមិនឡើងគ្រែជាមួយគ្នា ព្រោះខ្ញុំមិនមែនជាមនុស្សដែលគ្មានគំនិតដល់ថ្នាក់ដេកជាមួយមនុស្សស្រីដែលជាបងប្អូននឹងគ្នា"

"លោកនិយាយមែនឬ ?"



"មែន"

"លោកជាមនុស្សល្អដល់ហើយលោកបងថ្លៃ"

ខ្សែភ្នែកភ័យខ្លាចរបស់ ធីណា ប្រែប្រួលភ្លាម មើលមកហាក់ដូចគេជាវីរៈបុរស ធ្វើឱ្យ សេត ដកដង្ហើមធំ ទោះពេលនេះនាងអាយុម្ភៃឆ្នាំ យៃវ៉ល គួរតែឱ្យធ្វើការងារផ្សេង មិនមែនបង្គាប់បង្ខំក្មេង ដែលខួរក្បាលមិនទាន់ធំពេញលក្ខណៈឱ្យមកធ្វើរឿងបែបនេះ។

"តែរឿងដែលយើងមិនឡើងគ្រែជាមួយគ្នា នាងត្រូវបិទមាត់ឱ្យជិត កុំប្រាប់អ្នកណា ព្រោះវាអាចធ្វើឱ្យនាងមានគ្រោះថ្នាក់"

ដើម្បីបង្ការមិនឱ្យមានភាពថ្លោះធ្លោយកើតឡើង បើគេមិននៅទីនេះ គេមិនដឹងទេថា នឹងមានរឿងអ្វីកើតឡើងខ្លះ ប៉ុន្តែបើគេមិនបញ្ជាការ ក្មេងស្រីម្នាក់នេះ ច្បាស់ជាប្រាប់ យៃវ៉ល គ្រប់រឿងដូចដែលប្រាប់គេនៅពេលនេះ។

"ត្រូវកុហកឬ?"

"ដើម្បីជីវិតនាងនិងបងស្រី ធ្វើឬមិនធ្វើគឺតាមចិត្តនាង"

"ធ្វើ ខ្ញុំធ្វើ"

ធីណា សន្យាភ្លាម ដើម្បីខ្លួនឯងនិងបងស្រី។ នាងសម្រេចចិត្តហើយថា នឹងស្តាប់បង្គាប់ សេត ព្រោះគេគឺជាមនុស្សដែលនាងជឿហើយថា នឹងជួយនាង



Scanned by CamScanner

និងបងស្រីបាន គេគឺជាទីពឹងពាក់របស់នាងនិងបងស្រី។

"ហ្នឹងហើយគឺអ្វីដែលនាងគួរធ្វើ"

"ចាំ លោកបងថ្លៃ"

"ហៅខ្ញុំដូចដែលបងស្រីរបស់នាងហៅទៅបានហើយ"

សេត ព្រឹសម្បុរដែលត្រូវហៅថាលោកបងថ្លៃ គេនិង សាន់នី មានទំនាក់ទំនងផ្លូវកាយក៏ពិតមែន ប៉ុន្តែវាមិនស្ថិតនៅក្នុងទំនាក់ទំនងដែលហៅថាស្វាមីភរិយា។

"ចាំ លោក ម៉ារិស"

"ខ្ញុំនឹងនៅទីនេះមួយសន្ទុះ ហើយទៅរកបងស្រីនាង ទៅលេងស្អីក៏ទៅៗហាមរំខានខ្ញុំ"

សេត បក់ដៃដេញ ធីណា។ គេនឹងនៅក្នុងបន្ទប់នេះសិន បើប្រញាប់ប្រញាល់ចេញទៅ ខ្លាច ឃែរ៉ល គិតថា ធីណា មើលថែគេមិនបានល្អ ហើយអាចរករឿងដាក់ទោសនាងនៅក្រោយខ្នងគេ ចំណែក ធីណា ក៏ស្ទុះចូលទៅក្នុងបន្ទប់ដេក ទុកឱ្យគេអង្គុយនៅក្នុងបន្ទប់ទទួលភ្ញៀវ តាមតម្រូវការ។







Scanned by CamScanner

ជាច្រើនទៀត ឡូកឡំ។ នាងមិនបានត្រួតពិនិត្យអារម្មណ៍របស់ខ្លួនឯងឱ្យច្បាស់លាស់ ប្តូកវាបញ្ចូលគ្នា ហើយហៅថាទោសៈ។ នាងអង្វរករផងនោះ ហើយយ៉ៃវ៉េល ក៏មកប្រាប់ថា ម៉ារីស នៅក្នុងបន្ទប់ជាមួយ ជីណា។

ក្មេងស្រីដ៏គួរឱ្យស្រឡាញ់របស់នាង តើភ័យខ្លាចគេយ៉ាងណាទៅ ប៉ុន្តែក៏មានគំនិតមួយទៀតថា ទោះប្អូនស្រីមិនដឹងខ្យល់អី មានការភ័យខ្លាច ក៏បុរសដែលជំនាញរឿងលើគ្រែលំដាប់កំពូលដូច ម៉ារីស នឹងមានវិធីធ្វើឱ្យ ជីណា ព្រមតាម។

នាងដែលរឹងមាំជាងប្អូនស្រី នៅចុះចាញ់គេ រាងកាយបដិសេធតម្រូវការរបស់គេមិនបាន។

សាន់នីរលីងរលោងទឹកភ្នែកប៉ុន្តែត្រូវខាំបបូរមាត់មិនព្រមឱ្យទឹកភ្នែកហូរ អាម៉ាស់ ដែលត្រូវក្លាយជារបស់មនុស្សប្រុសតែម្នាក់ជាមួយប្អូនស្រី។ ជោគជតាលេងកំប្លែងនឹងជីវិតរបស់ពួកនាងពេកឬអត់ បេះដូងរបស់នាងត្រូវច្របាច់ខ្លាំងៗ ដោយមិនអាចចូលទៅក្នុងបន្ទប់ដេកបាន គិតតែអង្គុយនៅក្នុងបន្ទប់អង្គុយលេង ទោះប្រាប់ខ្លួនឯងថា ម៉ារីស មិនមករកនៅយប់នេះ ហើយគេអាចមិនមករកនាងទៀត។

នាងមិនបន្ទោស ជីណា បើ ម៉ារីស ជាប់ចិត្តប្អូនស្រីរបស់នាងដល់ថ្នាក់



Scanned by CamScanner

លុបចោលការការពារនាង នឹងធ្វើឱ្យនាងក្លាយជាស្រីសាធារណៈសម្រាប់ភ្ញៀវដែលមានប្រាក់ទាំងឡាយរបស់ ណាខាដៀ ប៉ុន្តែនាងបន្ទោសភាពត្រេកកាមរបស់គេ ដែលគេមិនខ្វល់ពីអារម្មណ៍របស់នាង។

"ខ្ញុំគ្រាន់តែជាស្រីរបាំ"

មនុស្សស្រីដែលគេទុកសម្រាប់កម្សាយតម្រូវការផ្នែកផ្លូវកាយ ឃែរ៉លនៅនិយាយឱ្យនាងបានឮញឹកញាប់ថា គួរពឹងដល់ក្ដីមេត្តា និងចិត្តទូលាយរបស់ ម៉ារីស ដែលធ្វើឱ្យនាងមិនបាច់ក្លាយជាមនុស្សស្រី ដែលភ្ញៀវអាចនាំទៅណាមកណាបានតាមអំពើចិត្ត ហើយមិនបាច់ពន់មុខឡើងទៅរាំស្រោតនៅលើវេទិកា។

មនុស្សស្រីនៅ ណាខាដៀ មិនមែនគ្រប់គ្នាសុទ្ធតែបង្ខំចិត្តធ្វើអាជីពនេះជាងពាក់កណ្ដាលមានសេចក្ដីសុខដែលបានធ្វើការនៅណាខាដៀ បានបង្អួតរូបរាងដ៏ស្រស់ស្អាត និងបានបម្រើបុរស ប៉ុន្តែនាងមិនស្ថិតនៅក្នុងក្រុមនោះ។

"បងសុំទោស ធីណា ដែលការពារឯងមិនបាន"

នាងលើកដៃស្ទាបទ្រូង ឈឺចាប់ដែលមិនអាចការពារប្អូនស្រីបាន ទាំងដែលព្យាយាម ស៊ូកប៉ាន់បុគ្គលិកនៅក្នុង ណាខាដៀ ប៉ុន្តែគ្មានអ្នកណាហ៊ានទទួល យកប្រាក់របស់នាង ដើម្បីជួយនាំប្អូនស្រីចេញពីទីនេះ នាងធ្វើឱ្យប្អូនស្រី





Scanned by CamScanner

អស់សង្ឃឹម ទាំងដែលបានសន្យាហើយថា នឹងជួយឱ្យបានសម្រេច។

ទឹកភ្នែក ហូរម្តងទៀតហើយ នាងព្រិចភ្នែកញាប់ស្នេក បណ្តេញវាទៅត្រឡប់ទៅកាន់កន្លែងដើមវិញ ពេលនោះទ្វារបន្ទប់របស់នាងក៏ត្រូវបើក ហើយអ្នកដែលដើរចូលមកបានឃើញភាពសោកសៅ និងអាការៈដូចមនុស្សអស់សង្ឃឹមចំពោះជីវិតនៅក្នុងខ្សែភ្នែករបស់នាងល្មម។

ស្រីក្បាលរឹងកំពុងតែសោកសៅឬនេះ!

ពេលឃើញគេ នាងក៏ងើបឈរ រកកល់ចង់ដួលបន្តិច ប៉ុន្តែក៏ត្រូវពើងទ្រូង។ នាងបាញ់ខ្សែភ្នែកមិនពេញចិត្តដាក់គេ ដែលធ្វើឱ្យ សេត យល់ពីគំនិតរបស់នាងភ្លាម ពេលនាងមើលមកដោយខ្សែភ្នែកចោទប្រកាន់។

"ពៅព្រលឹង"

នាងក្រមុំមានអារម្មណ៍ខ្ពើមរអើម ពេលគិតថាគេឡើងគ្រែជាមួយប្អូនស្រីរបស់នាងយូររាប់ម៉ោង ហើយមកហៅនាងថាជាពៅព្រលឹងរបស់គេ។

"មនុស្សបោកទាប"

"ស្អីដែលធ្វើឱ្យនាងស្វាគមន៍ខ្ញុំដោយសម្តីគ្រោតគ្រាតបែបហ្នឹង"

នាងប្លែកខុសពីធម្មតា ដូចបាត់បង់ការគ្រប់គ្រងខ្លួនឯង ថែមទាំងឈានជើងថយក្រោយ គេចពីគេ និងលើកដៃជូតទឹកភ្នែកទៀតផង។



Scanned by CamScanner

ទឹកភ្នែកដែលនាងមិនអនុញ្ញាតឱ្យគេបានឃើញ គិតថាខ្លួនឯងកំពុងខឹងខ្លាំង និងមិនចង់ឱ្យគេប៉ះពាល់ខ្លួនប្រាណ។

"លោកដឹងច្បាស់ហើយ"

នាងថយទៅឈរនៅក្រោយសាឡុង សេត ក៏ដើរឃើតៗទៅរក ត្រឹមសាឡុងមួយប៉ុណ្ណោះដែលពាំងមុខ បើគេត្រូវការគ្រប់គ្រងនាង វាការពារនាងពីគេមិនបានទេ។

"ខ្ញុំធ្វើស្អី ?"

សេត ធ្វើជាសួរ ក្នុងពេលដែលចង់គិតច្រើន ពូកែញាត់ញៀតការចោទប្រកាន់ឱ្យគេ អ៊ីចឹងគេអឺអើតាមតម្រូវការរបស់នាងទៅ។

"ខ្ញុំខុសដែលសុំអង្វរមនុស្សខុស"

"រឿងប្អូនស្រីនាង ?"

សំណួររបស់គេ ប្រហែលចាក់ដោតបេះដូង ព្រោះភ្នែករបស់នាងឡើងក្រហមងាំង សរសៃឈាមនៅក្នុងភ្នែកដែលគេមើលឃើញ ព្រោះនាងប្រឹងទប់ទឹកភ្នែក។

"មនុស្សថោកទាប!"

នាងគំហ៊កដាក់គេ ឈឺចាប់បេះដូងខ្លាំងណាស់ ចាប់តាំងពីថា ធីណា





Scanned by CamScanner

ត្រូវចាប់បំបែក នាងក៏ដេកមិនដែលលក់សូម្បីតែមួយយប់ ព្រោះតែងតែគិតដល់ប្អូនស្រី ហើយក៏លង់លក់ព្រោះរាងកាយល្វើយ។

"ខ្ញុំគិតថានាងសប្បាយចិត្តដែលខ្ញុំផ្តល់ជំនួយដល់នាង"

"ជួយឬ?"

នាងចង់ស្រែកដាក់មុខគេ គេហ៊ាននិយាយយកគុណសម្បត្តិដាក់ខ្លួនឯងផង ទាំងដែលញាត់ញៀតភាពអាប់យសឱ្យនាងនិងប្អូនស្រី។

"នាងអង្វរករខ្ញុំដោយខ្លួនឯងទេពៅព្រលឹង នាងមិនគួរណាភ្លេច"

"ខ្ញុំអង្វរករឱ្យលោកនាំ ធីណា ចាកចេញពីទីនេះ មិនមែនឱ្យលោកទិញប្អូនស្រីរបស់ខ្ញុំធ្វើជាស្រីលើគ្រែម្នាក់ទៀត!"

នាងដកដង្ហើមដង្ហក់រាងកាយជ្រមិលថយក្រោយបន្ទាប់ពីបំផ្ទុះអារម្មណ៍ដាក់គេ មួយមកពីរាងកាយរបស់នាងសន្សំភាពនឿយហត់ ដោយការសម្រាកមិនគ្រប់គ្រាន់ច្រើនយប់ពេក។

"លែងខ្ញុំ!"

រាងកាយរបស់នាងត្រូវឱបក្រសោបដោយរង្វង់ដៃរឹងមាំ ដោយការដែលសេត ស្ទុះមកក្រសោប ព្រោះខ្លាចនាងដួល។

"នាងទំនើងពេកហើយ សាន់នី"

គេរឹតចង្កេះរបស់នាងកាន់តែណែន ឱ្យនាងឈរផ្អែក នឹងដើមទ្រូងដែលត្រឹមគេឱប រាងកាយរបស់នាង ក៏កប់ទៅក្នុងដើមទ្រូងគ្មានបេះដូងរបស់គេទៅហើយ។

នាងឈឺចាប់ នាងគ្មានផ្លូវស៊ូ ហើយនាងទ្រាំទទួលរឿងដែលកើតឡើងស្ទើរតែមិនបាន។

អ្នកកំលោះឱនទៅរក ផ្ទឹបថ្ពាល់គ្រើម នឹងថ្ពាល់រលោង ចង់ចិត្តអាក្រក់ដាក់នាងជាងនេះ ដើម្បីជាការដាក់ទោស ប៉ុន្តែស្ថានភាពរបស់នាងធ្វើឱ្យគេមិនអាចធ្វើចិត្តរឹងដាក់បានដល់ថ្នាក់នោះ គេចង់អធិប្បាយរឿងទាំងអស់ឱ្យនាងស្តាប់។

គេមិនធ្លាប់មានចរិតបែបហ្នឹង ប៉ុន្តែគេចង់ប្រាប់នាង ប្រាប់នាងឱ្យអស់ ដើម្បីឱ្យនាង ឈប់សោកសៅ នាងស្គមជាងមុន ហើយវាក៏ធ្វើឱ្យគេមួម៉ៅ ហើយការដែលគេត្រដុសថ្ពាល់ខ្លួនឯងនឹងថ្ពាល់របស់នាងតិចៗ ដូចឆ្មាបបោសអង្អែល គឺជាយកចិត្តយកថ្លើមនាងដោយប្រយោល គេបង្ហាញកាយវិការនោះដោយមិនដឹងខ្លួន ហើយ សាន់នី ក៏មិនដឹងដែរថា កំពុងតែត្រូវគេលួងលោម។

"ខឹងដល់ថ្នាក់ចង់ខ្យល់គទៅហើយឃើញទេ"

"វាជារឿងរបស់ខ្ញុំ"





Scanned by CamScanner

នាងគំហ៊កដាក់ ប៉ុន្តែសំឡេងឮខ្សាវៗដោយគ្មានកម្លាំងកំហែង។ បេះដូងរបស់នាងត្រូវចាក់សុះអស់ ព្រោះប្អូនស្រីត្រូវពង្រាត់ពីទ្រូង និងត្រូវគេញាំញីទៅហើយ។

"រឿងរបស់នាង តែខ្ញុំចង់រវល់ហ្នឹងណា៎ ធ្វើយ៉ាងម៉េចទៅ"

"រឿងរបស់ខ្ញុំ" នាងនៅតែបង្ហាញពីគោលជំហរខ្លួនឯង តែសំឡេងវាគ្មានទម្ងន់ និងដើម្បីបង្កើតលំនឹងឱ្យខ្លួនឯង ទើបនាងគក់គេ ប៉ុន្តែកម្លាំងវាតិចខ្លាំងណាស់។

"កេះខ្ញុំធ្វើអី"

"ខ្ញុំគក់!"

"ឱ្យគក់សាថ្មី"

សេត ប្រាប់ដោយចិត្តទូលាយ ប៉ុន្តែអ្នកស្ដាប់បែរជាឆ្ងលចុងច្រមុះកាន់តែខ្លាំង។ នាងមិនចង់នៅជិតគេ រង្វង់ដៃរបស់គេគួរតែធ្វើឱ្យនាងខ្ពើមរអើម តែក្លិនដែលសុំនឹងច្រមុះ ភាពកក់ក្ដៅរបស់គេ ធ្វើឱ្យនាងមានអារម្មណ៍ផ្ទុយពីនោះ និងធ្វើឱ្យនាងអស់សង្ឃឹមខ្លួនឯង ដែលមិនម៉ឺងម៉ាត់។

យើងគួរស្អប់គេ!

គេធ្វើបាបនាងដោយឈាមត្រជាក់បំផុត នាងអង្វរករគេ បើគេត្រូវការឱ្យ



Scanned by CamScanner

នាងលុតជង្គង់ ក៏នាងសុខចិត្តធ្វើ ដើម្បីឱ្យប្អូនស្រីមានសុវត្ថិភាព ប៉ុន្តែគេបែរជាបោកប្រើការប្រាថ្នារបស់នាង  នាងប្រណិបត្តន៍ដោយការយកចិត្តយកថ្លើមសង្ឃឹមថាគេពេញចិត្តនិងព្រមជួយ  នាងនឹងចងចាំជំនួយរបស់គេពេញមួយជីវិត ដែលគេជួយមែននោះឯង ប៉ុន្តែមិនមែនជាវិធីដែលនាងគិត គេទិញយកប្អូនស្រីរបស់នាង ទោះមិនត្រូវប្រណិបត្តន៍ប្រុសផ្សេង ក៏ត្រូវប្រណិបត្តន៍គេ។

នាងទាញប្អូនស្រីពីនរកលោកីយ៍នេះមិនបានសម្រេច  នាងហត់នឿយនឹងជោគជតាដែលចិត្តអាក្រក់ដាក់នាងខ្លាំងណាស់ នាងត្រូវមកជួបនឹងមនុស្សអាត្មានិយមបែបនេះទៀត ទើបគ្មានកម្លាំងតស៊ូ។

"មិនគក់"

"ពិបាកយកចិត្តណាស់"

"មិនបាច់ម៉ោយកចិត្តខ្ញុំទេ  លោកប្រហែលមានសេចក្ដីសុខខ្លាំងដែលបានបោកខ្ញុំ"

នាងសួរគេដោយការឈឺចាប់  សំឡេងញ័រៗ  ដែលនាងមិនធ្លាប់បង្ហាញភាពទន់ជ្រាយឱ្យគេឃើញបានច្បាស់ដូចនៅពេលនេះ។

"ខ្ញុំបោកស្អីនាង"

"បានហើយ ខ្ញុំមិនចង់និយាយពីរឿងនេះទៀតទេ"





Scanned by CamScanner

នាងឈឺចាប់ខ្លាំងណាស់ នាងមិនហ៊ានសួរគេទេថា ធីណា យ៉ាងម៉េចហើយ នាងចង់ឃើញប្អូនស្រីដោយផ្ទាល់ភ្នែក ធីណា កំពុងភ័យខ្លាចឬអត់។

"បើមិននិយាយ ប្រហែលនិយាយស្តាប់គ្នាមិនបាន"

"លោកទៅវិញទេដែលនិយាយមិនចេះស្តាប់គ្នា"

"និយាយម៉ោ សាន់នី"

គេអង្អែលដៃរលោង ពេលត្រូវនាងវាសចេញ គេក៏អង្អែលទៀតដោយមិនញញើត ព្រោះគេមានកម្លាំងច្រើនជាងនាង។

"ខ្ញុំមិននិយាយ"

"នាងជ្រើសរើសដោយខ្លួនឯងទេ"

នាងក្រមុំ ខាំមាត់ទាល់តែឈឺ នាងជ្រើសរើសដោយខ្លួនឯង ជ្រើសរើសមានសង្ឃឹមចំពោះគេ ហើយគេក៏កម្ទេចក្តីសង្ឃឹមរបស់នាងឱ្យខ្ទេចខ្ទី។

"ខ្ញុំមិនចង់និយាយជាមួយលោក"

បន្ទាប់ពីចង់អធិប្បាយ សេត ក៏មានភាពក្រអឺតក្រទមចំពោះខ្លួនឯងដែរ គេកើតមក ដោយមានអំណាចពេញដៃ ហើយអ្វីដែល សាន់នី ប្រឆាំងនឹងគេ ក៏ធ្វើឱ្យគេចង់យកឈ្នះ គេទន់ដាក់នាងច្រើនពេកហើយនៅក្នុងអារម្មណ៍របស់គេ ប៉ុន្តែនាងបដិសេធឱកាសនោះ ក្នុងពេលដែលនាងមិនត្រូវការ គេក៏មើលមិន



Scanned by CamScanner

ឃើញការចាំបាច់ដើម្បីអធិប្បាយឱ្យនាងយល់ នាងចង់សោកសៅ ទ្រោមចិត្ត ព្រោះចរិតមិនចេះស្តាប់អ្នកដទៃរបស់នាង គេនឹងបណ្តោយឱ្យនាងសោកសៅតាមចិត្ត ប៉ុន្តែទោះសោកសៅ ក៏នាងត្រូវប្រណិបត្តន៍គេ។

"អ្ហឹ!អា!"

សាន់នី នៅតែព្យាយាមក្រាញននៀលដាក់ សេត ទោះត្រូវគេថើបឡើងទន់ខ្លួនទៅហើយ តែនៅតែប្រើកណ្តាប់ដៃរបស់នាង គក់ខ្នងរបស់គេ ទាស់ត្រង់សេត មានអារម្មណ៍ដូចត្រូវកេះប៉ុណ្ណោះ។ គេស្រង់យកក្លិនរបស់នាងដោយវិធីដុត ដែលភ្ញោចឱ្យរាងកាយរបស់នាង ទោរទន់តាមគេ។ រាងកាយរបស់នាងននលគក សម្លៀកបំពាក់រាយប៉ាយលើកម្រាលក្បែរគ្រែ ដោយសភាពមិនល្អប៉ុន្មាន នាងប្រឆាំងនឹងគេ ក៏ត្រូវគេតបតវិញដោយត្រូវគេចាប់ហែកសម្លៀកបំពាក់ដោយភាពព្រៃផ្សៃ និងគ្មានក្តីមេត្តា ឱ្យរាងកាយននលគកក្តៅគគុករបស់គេនៃបនិត្យនឹងរាងកាយរបស់នាង។

សំឡេងថ្ងូចថ្ងូរតវ៉ារបស់នាងត្រូវលេបត្របាក់។ គេមានវិធីគ្រប់គ្រងរាងកាយរបស់នាង សាន់នី មិនធ្លាប់យកឈ្នះតម្រូវការរបស់គេបានសូម្បីតែម្តង ហើយគេក៏មិនធ្លាប់បង្គាប់បង្ខំនាងដែរ ប៉ុន្តែគេនឹងធ្វើឱ្យរាងកាយរបស់នាង



ព្រមទោរទន់តាមគេដោយអស់ផ្លូវគេចវេះ។

"ឆ្នាសខ្លាំង ត្រូវដាក់ទោសដឹងទេ"

"គេខ្សឹបដាក់បបូរមាត់ដែលចូលចិត្តថើបខ្លាំងៗ ថើបញាក់ញី ទាល់តែបបូរមាត់របស់នាងក្រហមជាំ និងហើម ប៉ុន្តែនាងទាមទារការអាណិតពីគេមិនបាន។ គេភ្ញើយចង្ការរបស់នាង ទ្រោបទៅលើ និងថើបនាងទៀតហើយ ឱ្យស្មារតីរបស់នាងរត់ខ្ចាត់ខ្ចាយមិននៅក្នុងខ្លួន។ សាន់នី ខឹងខ្លួនឯង ដែលមិនអាចប្រឆាំងនឹងការប្រាថ្នាចំពោះគេបាន ភាពរឹងមាំរបស់នាង ត្រូវបំបាក់បន្តិចម្តងៗ ហើយនាងក៏មិនមែនជាគល់ឈើនៅលើគ្រែដែរ។ នាងដឹងថាគេពង្វក់ឱ្យនាងគ្រប់គ្រងរាងកាយខ្លួនឯងមិនបាន ឱ្យនាងតបស្នងគេដូចមនុស្សស្រីគ្មានកេរ្តិ៍ខ្មាស ឱ្យនាងទាមទារឱ្យគេគយគន់រាងកាយរបស់នាង ហើយនាងក៏តបស្នងតម្រូវការរបស់គេ ដែលធ្វើឱ្យគេបានទៅដល់គោលដៅនៃសេចក្តីសុខ។

"នាងត្រូវការខ្ញុំ"

"មិន...ត្រូវការ"

"ស្រីឆ្នាសមាត់រឹង"

គេប្រដេញបបូរមាត់លើបបូរមាត់ទន់ល្មើយ បបោសអង្អែលតិចៗ ហើយបឺតជញ្ជក់ខ្លាំងៗ បន្ទាប់មកក៏ជ្រែកអណ្តាតចូលទៅក្នុងប្រអប់មាត់របស់



Scanned by CamScanner

នាង ដែលធ្វើឱ្យនាងភ្ញាក់កន្ត្រាក់ ស្រវាឱបគេណែនដៃ។

"ហ៊្នឹងហើយពៅព្រលឹង តបស្នងខ្ញុំ ស្រីឆ្នាស"

គេសរសើរនាង ហើយថើបនាងទៀត ដោយមិនប្រញាប់ប្រញាល់ ចង់ចំណាយពេលនៅក្នុងការដុតរាងកាយរបស់នាង។ គេនឹងដេកនៅទីនេះជាមួយស្រីលើគ្រែដ៏ស្រស់ស្អាតរបស់គេ លេបត្របាក់នាង ឱ្យសក្តិសមនឹងការស្រេកឃ្លានរបស់គេ។ គេមិនដោះដូរសេចក្តីសុខរាងកាយជាមួយស្រីណា ព្រោះរវល់តែនឹកដល់មុខមាត់ស្រស់ស្អាត ក្រអឺតក្រទម របស់មនុស្សប៉ិនងរង៉ក់ ថែមទាំងប៉ិនគិតច្រើន គិតផ្តេសផ្តាស ដែលគេកំពុងឱប។

"អ៉ា!"

នាងភ្ញាក់ ត្រសុលទៅរកលង្វែកទ្រូងធំទូលាយ គេដឹងថាអាការៈឆ្នាសឆ្មើមរបស់នាងត្រូវគេរំលាយអស់ទៅហើយ។ សេត ជាមនុស្សប្រុសដែលមានទំនុកចិត្តចំពោះខ្លួនឯង តែគេមិនចាំបាច់អី យកអាការៈទោរទន់របស់នាងមកនិយាយ ដើម្បីយកឈ្នះ និងធ្វើឱ្យនាងអាម៉ាសមុខ គេជាសុភាពបុរសនៅផ្នែកដែលគួរធ្វើ។

គេស្ទាបអង្អែលរាងកាយនននលគក ហើយថើបនាង ដោយការស្រេកឃ្លាន ស្បែករបស់នាងរលោង ម៉ដ្ឋខៃ គេប្រាប់ខ្លួនឯង ភាពទាក់ទាញរបស់នាង





Scanned by CamScanner

រកកន្លែងឱ្យទាស់គ្មាន។

គេឱ្យពិន្ទុនាងខ្ពស់ជាងការពិតឬអត់ក៏មិនដឹង ប៉ុន្តែបើគេមានពិន្ទុមួយរយនៅក្នុងដៃ នឹងប្រគល់ឱ្យនាង លើសមួយរយ។

អណ្តាតក្តៅរបស់គេ បបោសអង្អែលរាងកាយរបស់នាងឱ្យទន់ល្ហុក ដល់ថ្នាក់គ្រប់គ្រងខ្លួនឯងមិនបាន។

"អ្ហឺ!!"

ដៃទាំងពីររបស់នាងខ្ទាំសក់របស់គេ គេកំពុងតែស្រុះរាងកាយរបស់នាង ដោយអណ្តាត មិនបានធ្វើឱ្យនាងឈឺចាប់ តែផ្តាប់ផ្តន់រាងកាយរបស់នាងធ្វើឱ្យនាងស្រៀវស្រើបរហូត ភ្នែករបស់នាងគឃ្លើន ដោយតម្រូវការដែលត្រូវដុតឱ្យពុះ។

រាងកាយរបស់នាង ត្រូវគេគ្រប់គ្រងទាំងអស់ សេត ក៏ឡើងទ្រោបពីលើពេលនាងឱបរឹតគេ គេក៏ពេញចិត្តនឹងការតបស្នងនោះ ឱនថើបថ្ពាសរបស់នាងថ្មមៗ។

"ពេលមិនរឹងក្បាលគឺគួរឱ្យស្រឡាញ់"

គេនិយាយរអ៊ូៗដាក់ខ្លួនឯង តែបើ សាន់នី មិនឆ្មាសឆ្មើមបែបនេះប្រហែលទាក់ទាញចំណាប់គេមិនបាននោះទេ។ គេប្រើម្រាមដៃអង្អែលថ្ពាល់



Scanned by CamScanner

រលោង ហើយគ្រប់គ្រងភាពកក់ក្ដៅរបស់នាង ឱ្យនាងស្រវ៉ាឱបរឹតគេណែនដៃ។

សាន់នី ទទួលដឹងព្រាលៗ នាងចុះចាញ់គេទៀតហើយ ទើបបានត្រឹមតែជ្រប់មុខនឹងប្រឡេះកមាំមួន ឱ្យគេឱបក្រសោប ខណៈដែលគេលុតជង្គង់លើគ្រែគ្រលែងត្រគាក ដើម្បីជ្រៀតជ្រែកខ្លួនឯងចូលមកក្នុងខ្លួននាងឱ្យកាន់តែជ្រៅ។

"អ៊ំា...ម៉ារីស"

គេបានឮនាងហៅឈ្មោះគេ ប៉ុន្តែ សេត មិនពេញចិត្តជាខ្លាំង ព្រោះចង់ឱ្យនាងហៅគេដោយឈ្មោះពិតច្រើនជាងតែណ្ហើយចុះពេលដល់វេលាសក្ដិសមនាងអាចនឹងបានហៅវា ឬមិនអីចឹង ប្រហែលគ្មានឱកាស ព្រោះគេអាចធុញទ្រាន់នាងមុនពេល ដោយមិនដឹងទេថាគេកំពុងតែឈ្លក់វង្វេងនឹងការបានធ្វើជាផ្នែកមួយនៅក្នុងរាងកាយរបស់នាង។

អ្នកកំលោះគ្រប់គ្រងនាងដូចព្យុះបោកបក់ និងឈ្លក់វង្វេង អាការៈរបស់គេ នៅឆ្ងាយពីពាក្យថាធុញទ្រាន់ រាងកាយរបស់នាងដែលតបស្នងគេ ស្រេកឃ្លានការបំពេញបន្ថែមពីគេ សំឡេងថ្ងូចថ្ងូរដ៏ពិរោះ កាន់តែភ្ញោចឱ្យ សេត ស្រឡាញ់នាងកាន់តែខ្លាំង និងក្ដៅគគុក ដើម្បីនាំនាងនិងគេទៅកាន់គោលដៅនៃសេចក្ដីសុខជាមួយគ្នា។





Scanned by CamScanner

# ៥

## អរុណក្តៅគគុក

មនុស្សស្រីរាងតូចច្រឡឹង ដែលគេរំខានពេលវេលាដេកពួនដល់មេឃទៀបភ្លឺ កំពុងឆុងកាហ្វេនៅក្នុងផ្ទះបាយ ដែលក្លិនរបស់វា ធ្វើឱ្យ សេត ត្រូវដើរទៅរក ហើយពេលពិនិត្យរាងកាយរបស់នាង ក៏មានអារម្មណ៍ប្លែកៗ ដែលមានមនុស្សស្រីម្នាក់កំពុងមមាញឹកនឹងរៀបចំអាហារពេលព្រឹកនៅក្នុងផ្ទះបាយ និងដឹងថានាងរៀបចំឱ្យគេដែរ។

សេត ដើរទៅឈរពីក្រោយ ដោយមិនបានគិតអីច្រើន ពេលលូកដៃទៅឱបចង្កេះតូចស្តើង ឈ្មុលមុខនឹងប្រឡោះក.សខ្ចី។ សក់ពណ៌ខ្មៅស្អាតហាក់ដូចសរសៃសូត្រ ដែលគេចូលចិត្តម្វរលេងនឹងម្រាមដៃ ត្រូវក្រសោបចង ជើងសក់ដែលលម្អកញ្ជ្រឹង.ករ៉េះៗ ធ្វើឱ្យនាងមើលទៅសិចស៊ី និងគួរឱ្យស៊ីខ្លាំងណាស់ ហើយគេក៏អត់មិនបាន នឹងឱនទៅបឺតជញ្ជក់សាច់ត្រង់នោះ។

សាន់នី ចង់រុញគេចេញ ប៉ុន្តែដឹងច្បាស់ថាខ្លួនឯងគួរធ្វើយ៉ាងណា ដើម្បី



Scanned by CamScanner

រស់។ ការប្រឆាំងនឹងគេ នៅពេលនេះ វាមិនកើតប្រយោជន៍អីទេ ព្រោះបើគេលុបចោលការការពារនាង និង ធីណា ពួកនាងពីរនាក់បងប្អូននឹងមិនត្រឹមតែទទួលត្មៀវម្នាក់ទេ ដូច្នេះហើយ ទើបឱ្យគេថើបជញ្ជក់តាំងពីសាច់.ក មកដល់ថ្កាល់ម៉ដ្ឋខែ។

"ធ្វើអីឱ្យខ្ញុំញ៉ាំ ?"

"អាហារពេលព្រឹកស្រួលៗ"

នាងអាចកុម្ម៉ង់អាហារពេលព្រឹកបាន ប៉ុន្តែនាងចង់ធ្វើទទួលទានដោយខ្លួនឯង និងត្រូវធ្វើឱ្យគេដែរ ដើម្បីកុំឱ្យមើលទៅអាក្រក់ពេក។

"លោកផឹកកាហ្វេពេលព្រឹកទេ ?"

"ផឹក"

គេចាប់នាងបង្វែរឱ្យបែរមុខមករកភ្លើយចង្កាហើយឱនទៅថើបបបូរមាត់ជ្រៀតជ្រែកអណ្តាតចូលទៅក្នុងប្រអប់មាត់ទន់ល្មើយ ហើយនាងក៏ជំទើតជើងដើម្បីបង្កភាពងាយស្រួលឱ្យគេ។

សេត គ្រហឹមនៅដើមកដោយការពេញចិត្តនឹងការតបស្នងរបស់នាង ហើយលើកនាងឱ្យហើបជើង ដាក់ទៅលើតុរៀបចំអាហារ នាងក៏ទ្រានដៃ នឹងដើមទ្រូងរងឹមាំ ប៉ុន្តែពេលប្រសព្វភ្នែកគ្នាហើយ នាងក៏បានដឹងថា សេត មិន





Scanned by CamScanner

ត្រូវការត្រឹមតែថើបប៉ុណ្ណោះទេ។

"ខ្ញុំនឹងស៊ីនាងមុនអាហារពេលព្រឹក"

សាន់នី ជាស្រីលើគ្រែរបស់គេ ដូច្នេះហើយនាងត្រូវយកចិត្តយកថ្លើមគេ។ សំពត់ដែលនាងស្លៀក ត្រូវទាញទម្លាក់ តាមដោយខោក្នុងសាច់ស្តើង ឱ្យគេស្ទាបអង្អែលរាងកាយ ដាស់តម្រូវការរបស់នាង ដោយមិនប្រញាប់ប្រញាល់និងគ្រប់គ្រងភ្លាមៗ។

"អាំ..."

គេទ្រានដៃនឹងតុ រុញជើងស្រឡូនចេញពីគ្នា ហើយសម្រូតខ្លួនដើម្បីថើបរាងកាយក្រអូបប្រហើរតាំងពីលើដល់ក្រោម ឱ្យនាងថ្ងូចថ្ងូរ បន្លឺសំឡេងនៅក្នុងផ្ទះបាយ ទាល់តែគេពេញចិត្តនោះឯង ហើយពេលគេងើបឈរវិញ រាងកាយរបស់នាងក៏ត្រៀមសម្រាប់ការគ្រប់គ្រងរបស់គេ។ គេត្រួតពិនិត្យនាង ហើយក្រសោបមុខរបស់នាងមកថើបជញ្ជក់បបូរមាត់ សាន់នី ក៏បិទភ្នែក បណ្តោយឱ្យរាងកាយតបស្នងគេតាមចិត្ត។

"អុំ!"

នាងឧទាន ព្រោះកៅស៊ូត្រូវទាញចេញពីសក់ ខណៈនោះ សេត ក៏ត្រសុល មកឈរនៅត្រង់ប្រឡោះជើង ថើបជញ្ជក់បបូរមាត់របស់នាងបណ្តើរ



Scanned by CamScanner

ជ្រងសក់របស់នាងបណ្ដើរ។

"សក់នាងស្អាតណាស់"

"លោកចូលចិត្តឬ"

គេឱនថើបសៀតផ្ការបស់នាង ហើយចាប់សក់វែង មកថើប ស្រង់ក្លិន។ គេចូលចិត្តស្រីសក់វែង ខ្លួនតូចល្អិតស្រួលបី ស្បែកស ដើមទ្រូងធំ ចង្កេះតូច ត្រគាកសាយ ដៃជើងក៏ស្រឡូន ដែល សាន់នី មានគ្រប់យ៉ាងដែលគេចូលចិត្ត។

"ចូលចិត្ត មិនថាមានអីកើតឡើងក៏ដោយ ហាមកាត់សក់"

សក់វែងរំសាយពេញខ្នងបែបនេះ បើនាងកាត់ចោល ទម្រាំវាដុះវែងបែប នេះម្ដងទៀត គឺត្រូវចំណាយពេល។ សាន់នី ជាស្រីសិចស៊ី ពេលនាងគ្រលែង ត្រគាកលើខ្លួនរបស់គេ សក់វែងរំសាយក៏យោលយោកបបោសអង្អែលរាងកាយ ស្រស់ស្អាតដែរ។

"ចាំ លោក ម៉ារីស"

នាងត្រូវឆ្លើយយកចិត្តយកថ្លើមគេ។

សេត ចាប់ត្រគាករបស់នាង និងត្រសុលទៅរកឱ្យនាងខ្ទាំស្នាធំទូលាយ ខណៈដែលបបូរមាត់ទន់ល្មើយត្រូវគេគ្រប់គ្រងម្ដងទៀត ដោយរាងកាយរបស់ គេ គ្រលែងទៅរកនាង ដើម្បីស្វែងរកភាពផ្អែមល្ហែមដែលលាក់នៅក្នុងខ្លួនតូច





Scanned by CamScanner

ប្រទ្បីងនោះ។

"អឺ...នាងល្អបំផុត ពៅព្រលឹង"

គេនិយាយរអ៊ូៗដាក់បបូរមាត់ទន់ល្មើយ ដោយមានអារម្មណ៍ពិសេស រាងកាយរបស់ សាន់នី បង្កើតសេចក្ដីសុខឱ្យគេបានជាងស្រីទាំងឡាយ ទាំងដែលនាងមិនពេញចិត្ត។

"ឈឺឬ?"

គេខ្សឹបសួរ ព្រោះអាការៈពេបមាត់ស្បែបរបស់នាង។ គេវាសសក់ចេញពីមុខស្រស់ស្អាត សាន់នី ក៏ងក់ក្បាល ហើយគេក៏ចាប់មុខរបស់នាងសង្កត់នឹងស្មាធំទូលាយ។ រាងកាយរបស់នាងត្រូវគេរានទន្ទ្រានអស់រយៈពេលជាច្រើនម៉ោង ទើបការត្រូវគេគ្រប់គ្រងនាពេលព្រឹក ធ្វើឱ្យនាងឈឺចាប់ខ្លះដែរ។

"ទ្រាំបន្តិចទៅ ខ្ញុំត្រូវការនាង"

នាងធ្វើអ្វីបានទៅ ក្នុងពេលដែលគេត្រូវការ គឺមានតែយល់ព្រមឱ្យគេគ្រប់គ្រង ទាល់តែពេញចិត្តប៉ុណ្ណោះ។

**ដោយសារមានសម្ពាធ ទើប សាន់នី ត្រូវយល់ព្រម ត្រូវអត់ធ្មត់ ទប់អារម្មណ៍ ហើយការបានជួប ម៉ារីស ញឹកញាប់ ធ្វើឱ្យនាងឃើញថាខ្លួនឯងកំពុង**



Scanned by CamScanner

តែឈឺចាប់ បេះដូងឈឺជាខ្លាំង គ្រប់ពេលដែលនៅក្នុងរង្វង់ដៃរបស់គេ ទារុណទារាដោយភាពវេទនា ពេលគេត្រឡប់ទៅវិញ ហើយនាងគិតថាគេក៏ធ្វើបែបនេះដាក់ ធីណា។

នាងអត់ធ្មត់ធ្វើខ្លួនស្តាប់បង្គាប់ដាក់គេ ឆ្មាសឆ្មើមដាក់គេនៅពេលខ្លះ ពេលដែលភ្លេចខ្លួន គឺសង្ឃឹមថា ថ្ងៃមួយគេព្រមឱ្យនាងជួបប្អូនស្រី នាងចង់ឃើញដោយផ្ទាល់ភ្នែក ថា ធីណា យ៉ាងម៉េចយ៉ាងម៉ា។

នាងដកដង្ហើមធំ ពេលអង្គុយលើសាឡុងក្បែរបង្អួចក្នុងបន្ទប់ដេក បង្អួចដែលមើលទៅខាងក្រៅមិនឃើញអ្វី ក្រៅពីណាខាដៀ ព្រោះវាគឺជាទិដ្ឋភាពនៅក្នុងណាខាដៀនោះឯង។ នាងរង់ចាំថា យៃវ៉ល អនុញ្ញាតឱ្យនាងទៅជួបប្អូនស្រីតាមការអង្វរករពេលណា ប៉ុន្តែរកឱកាសនោះមិនទាន់បាន។

ស្ថានភាពរបស់អ្នករង់ចាំ វាលំបាកណាស់ ប៉ុន្តែរឿងមួយដែលធ្វើបាន គឺត្រូវអត់ធ្មត់។ នាងលាក់ខ្លួនឯងនៅក្នុងសម្បក រុំដោយពាក្យថា **អត់ធ្មត់** ធ្វើខ្លួនដូចមនុស្សគ្មានមាត់គ្មានសំឡេង ដើម្បីរង់ចាំ ហើយ សេត ក៏មកទាន់ ឃើញអាការៈសោកសៅរបស់នាងម្តងទៀត។

គេដើរមកដាក់បង្អុយពីក្រោយ ស្រវាឱបចង្កេះ ធ្វើឱ្យនាងភ្ញាក់ព្រើត ហើយព្រមផ្អែកខ្លួនទៅពិតនឹងដើមទ្រូងធំទូលាយ។ គេមកទីនេះញឹកញាប់ ថ្ងៃ





Scanned by CamScanner

ខ្លះ ត្រូវចំណាយពេលហោះហើរទៅមកដូចបក្សី នោះមកពីអាការៈដូចមនុស្សជិតស្លាប់របស់ សាន់នី។

គេគ្មានពាក្យសម្ដីដែលល្អជាងនេះ នាងមិនមាត់មិនក នាងស្ដាប់បង្គាប់ដូចតុក្កតាដែលត្រូវដាក់ប្រូក្រាម ដូចនាងហត់នឿយចំពោះការដែលត្រូវប្រឆាំងនឹងគេ។

អ្នកកំលោះ ឱនមកថើបថ្ពាល់គ្រើម នឹងថ្ពាល់របស់នាង ដោយនៅស្ងៀមបែបនោះ។

"យើងទៅរកប្អូនស្រីរបស់នាងល្អទេ"

នាងក្រមុំបែរមុខមករកភ្លាម។ គេបានឮពី ឃៃរ៉ល ថា សាន់នី ត្រូវការជួបប្អូនស្រី ប៉ុន្តែការសម្រេចចិត្តគឺស្ថិតនៅលើគ្រែ ឃៃរ៉ល នៅដាក់សំណើគួរឱ្យខ្ពើមឱ្យគេរកសេចក្ដីសុខដោយការនាំពីរនាក់បងប្អូនឡើងគ្រែជាមួយ។

"ទៅ"

"អីចឹងញញឹមដាក់ខ្ញុំជាការដោះដូរសិនម៉ោ"

សាន់នី ចងចិញ្ចើម ខណៈដែល សេត អង្គុយមើលនាងមួយសន្ទុះទាមទារស្នាមញញឹមពីនាង ប៉ុន្តែនាងគ្មានហេតុផលអីដែលត្រូវញញឹមដាក់គេ។

"ខ្ញុំប្រាប់ឱ្យញញឹម មិនមែនធ្វើមុខកាច"

"ខ្ញុំញញឹមមិនបានទេ"

"អីចឹងមិនបាច់ទៅ"

"ឈប់!"

នាងបោះបង់ឱកាសនេះមិនបាន ពេលគេប្រុងងើបចេញពីសាឡុង ក៏ស្រវាឱបជាប់។

"ខ្ញុំញញឹម"

"អីចឹងញញឹមម៉ោ"

សេត អង្អែលថ្ពាល់រលោង ភាពមានព្រលឹងព្រលះរបស់នាង រសាត់ទៅបាត់បន្តិចម្តងៗ នោះហើយដែលធ្វើឱ្យគេមួម៉ៅជាខ្លាំង។

"ខ្ញុំសុំពេលមួយភ្លែត"

"វាពិបាកណាស់ឬយ៉ាងម៉េច"

នាងសម្លក់សម្លឹងគេ ទោះជាអាការៈឆ្មាសឆ្មើមតិចតួច ប៉ុន្តែ សេត ពេញចិត្ត ព្រោះធ្វើឱ្យគេ នឹកដល់ពេលដែលនាងរឹងទទឹងដាក់គេ ហើយព្យាយាមយកឈ្នះគេ ប៉ុន្តែត្រូវចាញ់គេដដែល។



"ព្រោះខ្ញុំគ្មានហេតុផលអីឱ្យញញឹម"



Scanned by CamScanner

"ញញឹមដាក់ខ្ញុំហ្នឹងអី"

"ខ្ញុំមិនចង់ញញឹមដាក់លោក"

"ហើយនាងចង់ធ្វើអីខ្ញុំ"

សេត មានអារម្មណ៍ល្អ ប៉ុន្តែ សាន់នី មិនចង់ប្រមាថអារម្មណ៍របស់បុរសម្នាក់នេះ គេធ្វើខ្លួនចិត្តទូលាយដាក់នាង ប៉ុន្តែពេលដែលកាច គឺគួរឱ្យខ្លាចខ្លាំងណាស់។

"យូរទៀតទេ ?"

គេប្រែដៃ មើលនាឡិកា ទើប សាន់នី លើកដៃក្រសោបមុខរបស់អ្នកដែលបង្ហាញអាការៈធុញទ្រាន់ ហើយញញឹមដាក់។

"នាងញញឹមឬញញ្ញចង្អូម"

"ខ្ញុំញញឹម"

"ញញឹមឱ្យស្អាត ចេះទេ ញញឹមស្រស់ដូចដែលប្អូនស្រីរបស់នាងចូលចិត្តញញឹម"

បន្ទាប់ពីព្យាយាមញញឹមដាក់គេ នាងក្រមុំក៏បិទមាត់ភ្លាម ហើយញ្ញេញចង្អូមដាក់គេ ហើយពេលគេងើប នាងក៏ប្រវេប្រវាស្រវាចាប់អាវរបស់គេជាប់ព្រោះគិតថា គេខឹង។



Scanned by CamScanner

"អុំ!"

សេត លើកនាងបី ហើយឱនថើបបបូរមាត់ទន់ល្មើយខ្លាំងៗ នាងក៏ស្រវាឱបករបស់គេ ដែលពេលខ្លះ គេក៏ធ្វើឱ្យនាងកក់ក្តៅក្នុងបេះដូង។

"ណ្ហើយចុះ ខ្ញុំចាត់ទុកថាអម្បាញ់មិញនាងញញឹមដាក់ខ្ញុំទៅចុះ"

"អរគុណ"

យ៉ាងហោចណាស់ គេមិនផ្អាកការនាំនាងទៅរកប្អូនស្រី។ នាងមានអារម្មណ៍ថា នាងគួរអរគុណគេ ពេលគេថើបថ្ពាល់ ហើយអូសមករកបបូរមាត់ នាងក៏ព្រមឱ្យថើប ព្រោះខ្លាចគេប្តូរចិត្ត និងចាត់ទុកថាជាការអរគុណចំពោះគេទៅចុះ។

**ព្រោះចេញមកជាមួយ សេត ទើបគ្មានអ្នកណាហ៊ានរាំង សាន់នី ជាង** នោះទៅទៀត នៅមានបុគ្គលិកមកមើលថៃ នាំនាងនិងគេ ដើរទៅបន្ទប់របស់ ធីណា ដែលនៅផ្នែកម្ខាងទៀតពីបន្ទប់របស់នាង។

"ចេញទៅចុះ"

ពេលដឹកដៃនាងមកដល់មុខបន្ទប់របស់ ធីណា ហើយ សេត ក៏ចេញបញ្ជាដាក់បុគ្គលិករបស់ ណាខាដៀ ហើយគេក៏បើកទ្វារចូលទៅខាងក្នុង បន្ទាប់





Scanned by CamScanner

ពីគោះបីដង ហើយ សាន់នី ឃើញប្អូនស្រីអង្គុយលើសាឡុង។

"បងសាន់នី"

ពីរនាក់បងប្អូនរត់ទៅឱបគ្នា ចំណែក សេត ងាកទៅបិទទ្វារ ចាក់សោរ ដើម្បីកុំឱ្យមានអ្នកណាមករំខាន បន្ទាប់មកក៏ដើរទៅដាក់បង្អុយលើសាឡុង។

"សួស្តីលោក ម៉ារីស" ធីណា ថើបថ្ពាល់បងស្រីហើយងាកទៅរាក់ទាក់អ្នកកំលោះ តាមមារយាទ។ នាងនិងគេ ជួបគ្នាញឹកញាប់ ប៉ុន្តែគេមិនធ្លាប់ប៉ះពាល់នាងពេលចូលមកដល់ហើយតែងតែនិយាយដាក់នាងដោយប្រយោគដដែល...

'ទៅលេងនៅកន្លែងណាក៏ទៅៗ'

ដូចនាងជាកូនក្មេងដែលគេមិនចង់និយាយរក ហើយគេក៏អង្គុយអានសៀវភៅ ឬមិនអីចឹងក៏អង្គុយធ្វើនេះធ្វើនោះ ដែល ធីណា មិនដឹងទេថា គេធ្វើអ្វីតាមរយៈទូរសព្ទដៃ បន្ទាប់មក គេក៏ចេញពីបន្ទប់របស់នាង។ ការបានជួបគ្នាញឹកញាប់ ហើយគេមិនរំលោភបំពានរាងកាយរបស់នាង ធ្វើឱ្យនាងរសាយការភ័យខ្លាច ដែលមានចំពោះគេ។

ប៉ុន្តែ សាន់នី បែរជាមើលឃើញថា ប្អូនស្រីរបស់ខ្លួនទុកចិត្ត ម៉ារីស គ្មានការភ័យខ្លាច ក្រៅពីញញឹមស្រស់ស្រាយដាក់ នោះហើយដែលធ្វើឱ្យនាងឈឺ



Scanned by CamScanner

ឆៀបក្នុងទ្រូង ប៉ុន្តែនាងឈឺចាប់ធ្វើអី ឬនាងឈឺចាប់ព្រោះបារម្ភពីប្អូនស្រី។

ធីណា ស្លូតបូតពេកហើយ ហើយម្ចាស់ជីវិតនៅចំពោះមុខក៏សង្ហាណាស់ដែរ គេមានមន្តស្នេហ៍យ៉ាងកំណាច ធីណា អាចលង់រូបសម្រស់របស់គេ។

"បងសាន់នី"

សំឡេងរបស់ប្អូនស្រី ធ្វើឱ្យនាងភ្ញាក់ស្មារតី ហើយងាកទៅឃើញ ធីណា ដែលញញឹមពព្រាយដាក់ ទើបបញ្ជោឱ្យខ្លួនឯងឈប់គិតពីរឿងផ្សេង នាងគួរតែសប្បាយចិត្តនឹងទិដ្ឋភាពដែលកើតឡើងនៅចំពោះមុខ។

"សុខសប្បាយទេ ?"

"ខ្ញុំសុខសប្បាយណាស់"

ពីរនាក់បងប្អូនដាក់បង្គុយលើសាឡុងតែមួយ សាន់នី ក៏ត្រួតពិនិត្យប្អូនស្រីស្ទាបអង្អែលមុខអង្អែលរាងកាយខណៈដែលសេតលួចមើលដោយមិនមាត់មិនក។ ក្រមុំទាំងពីរមានអាយុខុសគ្នាបន្តិចបន្តួចប៉ុណ្ណោះ ប៉ុន្តែ សាន់នី មានភាពជាមនុស្សចាស់ទុំពេកហើយ។

"ឱ្យបងត្រួតពិនិត្យសិន"

"ខ្ញុំក៏ចង់ត្រួតពិនិត្យបងដែរ"

"មិនបានទេ បងជាបង"





Scanned by CamScanner

"ខ្ញុំសុខសប្បាយពិតមែន"

ប្អូនស្រីលួងលោម។ ធីណា សប្បាយចិត្ត ព្រោះមិនបាច់បម្រើមនុស្សប្រុសតែមួយជាមួយបងស្រី។ នាងគោរព ម៉ារីស ពេលនេះ កាន់តែសរសើរគេ និងចាត់ទុកគេជាបងថ្លៃរបស់ខ្លួនឯង ទោះត្រូវគេបញ្ជាហាមហៅគេថា លោកបងថ្លៃក៏ដោយ។

"សុខសប្បាយមែនទេ"

"ចាំ សុខសប្បាយ"

ធីណា រិះតែតវ៉ាទៅហើយដែលបងស្រីសួរសំណួរដដែលៗ ប៉ុន្តែនាងជ្រើសរើសឆ្លើយតបដើម្បីឱ្យបងស្រីសប្បាយចិត្តព្រោះនាងសប្បាយចិត្តណាស់ដែលបានឃើញបងស្រី។

"ញ៉ាំឆ្អែតដេកលក់ស្រួលមែនទេ"

"ចាំ បងសាន់នី មិនល្អតែមួយប៉ុណ្ណោះ"

"ស្អី ?"

"ខ្ញុំនឹកបង"

ធីណា ចាប់ដៃបងស្រី ផ្អឹបនឹងថ្ពាល់ ត្រដុសនឹងបាតដៃនោះថ្នមៗ ហើយងើយមុខមកញញឹមស្រស់ដាក់។



Scanned by CamScanner

"ខ្ញុំសប្បាយចិត្តដល់ហើយដែលបានជួបបង"

"បងក៏សប្បាយចិត្ត"

"យើងបាននៅជាមួយគ្នាវិញពេលណា?"

បន្ទប់ដេកមួយទៀត ដែលធ្លាប់ជាបន្ទប់របស់ ធីណា នៅទំនេរ ធីណា មិនចង់នៅម្នាក់ឯង នាងចង់នៅជាមួយបងស្រីដូចកាលមុន។

"រង់ចាំសិន"

"ចាំ ខ្ញុំនឹងរង់ចាំ បង សាន់នី ខ្ញុំចង់ឱ្យយើងទាំងពីរបាននៅជាមួយគ្នាដូចមុនវិញ ខ្ញុំសន្យាថា នឹងមិនរំខានបងនិងលោក ម៉ារីស ទេ"

"ឯងមិនបានរំខានទេ ឯងក៏មានសិទ្ធិដូចគ្នា"

ធីណា ខ្លាចថាខ្លួនឯង ក្លាយជាឆ្អឹងទទឹងករវាងបងស្រីនិងបងថ្លៃ ប៉ុន្តែ សាន់នី បែរជាយល់ថា ប្អូនស្រីក្រែងរអែងចិត្ត និងមិនចង់ចូលទៅជ្រៀតជ្រែករវាងនាងនិង ម៉ារីស។

"ខ្ញុំគ្មានសិទ្ធិដូចបងស្រីទេ បន្ទប់នោះជាបន្ទប់របស់បង"

"គ្មានអីដែលជារបស់បងទេ ធីណា"

សាន់នី ឆ្លើយប្រាប់ដោយភាពសោកសៅ ហើយប្រញាប់សម្រួលអារម្មណ៍ដោយការបបួលប្អូនស្រីនិយាយរឿងផ្សេង ពេលបានជួបគ្នា នាងក៏ចង់



និយាយរឿងដែលធ្វើឱ្យ ធីណា មិនបាច់គិតច្រើនព្រោះតែនាង។

**សាន់នី ដេកឱបខ្លួនកំប្រោនៗនៅលើគ្រែ ព្រោះដេកមិនលក់ ចេះតែ** បម្រះទៅបម្រះមក ជាច្រើនដង ហើយទោះប្រឹងបិទភ្នែកយ៉ាងណា ក៏ដេកមិនលក់ដដែល។

"ឯការឬ?"

នាងមិនអាចបង្ខំខ្លួនឯងបានទៀត ទើបងើបអង្គុយ លូកដៃទៅបើកអំពូលភ្លើងនៅក្បាលគ្រែ។សប្តាហ៍នេះម៉ារីសមកទីនេះនិងដេកជាមួយនាងបួនថ្ងៃជាប់គ្នាពួកគេសម្ងំនៅក្នុងបន្ទប់ជាមួយគ្នាពេលយប់នាងក៏ត្រូវហត់នឿយនៅក្នុងរង្វង់ដៃរបស់គេ ហើយលង់លក់ក្នុងលង្វែកទ្រូងជំទូលាយ។

មុននេះ នាងធ្លាប់ដេកលក់ដំណាលគ្នា ប៉ុន្តែការគ្មានគេ បែរជាបន្ថែមអារម្មណ៍វេទនាឱ្យនាង ឬព្រោះមុននេះ នាងមានប្អូនស្រីដេកនៅបន្ទប់ក្បែរ ប៉ុន្តែពេលនេះនៅក្នុងបន្ទប់នេះ មានតែនាងម្នាក់ប៉ុណ្ណោះ។

"ធ្វើយ៉ាងម៉េចទៅទើបដេកលក់?"

នាងឱបជង្គង់ សួរខ្លួនឯង ហើយក៏អត់ពាលខឹង ម៉ារីស មិនបាន ព្រោះតែគេដែលធ្វើឱ្យនាងមានអាការៈប្លែកៗ។ ការដេកលក់នៅក្នុងរង្វង់ដៃរបស់គេ



Scanned by CamScanner

ជាប់គ្នាជាច្រើនយប់ ធ្វើឱ្យនាងសុាំ ក្រៅពីនេះ គេនៅមករកនាងញឹកញាប់ទាំងដែលកាលមុន ពីរឬបីខែទើបមកម្តង។

នាងមើលទៅជុំវិញបន្ទប់ ដែលត្រូវតុបតែយ៉ាងប្រណិត ប៉ុន្តែភាពវិចិត្ររបស់នាង លាបទៅដោយថ្នាំពិស។ បន្ទប់នេះ ធ្លាប់មានស្រីផ្សេងគ្រប់គ្រង បន្ទប់នេះអាចរបស់ស្រីរបាំនៅណាខាងៅ ដែលពេញចិត្តនិងមិនពេញចិត្តធ្វើជាតុក្កតាមានជីវិតរបស់បុរសអ្នកមាន។

"ឯងត្រូវតែដេក"

នាងបញ្ជាខ្លួនឯង ហើយផ្តួលខ្លួនដេក ទាញភួយឃ្លុំជិតក្បាល ប៉ុន្តែនៅតែបម្រះទៅបម្រះមក បន្ទាប់មកក៏ងើបអង្គុយ។

"ឬត្រូវផ្អាកផឹកកាហ្វេនៅពេលព្រឹក"

នាងផឹកកាហ្វេមួយព្រឹកមួយកែវ ប៉ុន្តែជាតិកាហ្វេអ៊ីនវាមករំខាននាងដល់ពេលនេះផងឬ ប៉ុន្តែគិតទៅៗ មិនសមនោះទេ ទោះនាងមិនផឹកកាហ្វេ ក៏ត្រូវព្រមទទួលស្គាល់ការពិតថានាងដេកមិនលក់ដដែល។

"ព្រោះតែស្អី"

នាងមិនហ៊ានពិនិត្យបេះដូងខ្លួនឯង វាជាយុទ្ធសាស្ត្រការពារខ្លួនឯងដែលនាងបង្កើតឡើង នាងធ្វើជាព្រងើយកន្តើយចំពោះអារម្មណ៍ខ្វល់ខ្វាយ





Scanned by CamScanner

ដែលមិនសុំនេះ។

"យើងមិនបានកើតអីទេ"

ប៉ុន្តែការនិយាយដាក់ខ្លួនឯងដូចមនុស្សឆ្កួត គឺជាការបញ្ជាក់ថានាងមានបញ្ហា។ នាងផ្តួលខ្លួនដេកម្តងទៀត ប្រឹងបិទភ្នែក ដេកឱ្យលក់ ហើយក៏ចង់ទៅរកប្អូនស្រី ប៉ុន្តែការចេញពីបន្ទប់ ដោយគ្មានការអនុញ្ញាត គឺមិនបាននោះទេ បន្ទប់នេះ ប្រៀបដូចគុក ពេលថ្ងៃ នាងអាចចេញពីបន្ទប់បាន ប៉ុន្តែត្រូវមានការកំណត់ទំហំនិងពេលវេលា ពេលយប់ ចេញបាន គឺទាល់តែមាន សេត ឬព្រោះជាបញ្ជារបស់ ឃៃរ៉ល ប៉ុណ្ណោះ។

**សាន់នី ដឹងថាម្ចាស់ជីវិតរបស់នាងមក ហើយក្រៅពីនាង ធីណា ក៏ត្រូវ** ស្វាគមន៍គេដែរ ប៉ុន្តែជាការស្វាគមន៍នៅក្នុងបន្ទប់វីអាយភី នៅផ្ទែកសម្តែង។

ឃៃរ៉ល ឱ្យអ្នកបម្រើ យកសម្លៀកបំពាក់ស្អាតមកឱ្យ ហើយអ្នកបម្រើក៏នៅបម្រើនាង តុបតែងខ្លួនដោយការផ្ចិតផ្ចង់ ហើយពេលសាច់ក្រណាត់ស្តើងត្រូវយកមកបំពាក់លើរាងកាយរបស់នាង វាមើលទៅមិនសិចស៊ី តែឱ្យអារម្មណ៍ទាក់ទាញ ដែលធ្វើឱ្យនាងកាន់តែគួរឱ្យមើល ធ្វើឱ្យ ឃៃរ៉ល ដែលដើរចូលមកពិនិត្យរបៀបរៀបរយអត់មិនបាននឹងរិភាគ។



Scanned by CamScanner

"ព្រោះតែស្អាតបែបនេះឯង ទើបលោក ម៉ារីស កាត់ចិត្តមិនបាន"

ឃែរ៉ល និយាយដូចច្រណែន ប៉ុន្តែ ឃែរ៉ល ច្រណែនសម្រស់របស់ សាន់នី មែន។ បើ ឃែរ៉ល កើតមកស្អាតបែបនេះ ប្រហែលជាល្អ ពេញមួយតួខ្លួន របស់ សាន់នី មិនចាំបាច់ចំណាយប្រាក់ ធ្វើការវះកាត់ បន្ថែមសម្រស់ដូចស្រីរបាំឯទៀតក្នុងណាខាដៀ ប៉ុន្តែចិត្តច្រណែនរបស់ ឃែរ៉ល មិនមែនជាការច្រណែនដើម្បីបំផ្លាញ ព្រោះ សាន់នី អាចរកប្រាក់ឱ្យនាងបាន ហើយក្រៅពីនេះ សាន់នី ក៏មិនធ្លាប់ធ្វើឱ្យឈឺក្បាលដូចស្រីរបាំមួយចំនួន ដែលក្រៅពីទទួលភ្ញៀវហើយ នៅលួចមានទំនាក់ទំនងនឹងបុគ្គលិកនៅក្នុងណាខាដៀទៀតផង។

មានជាច្រើននាក់ ដែលជម្រត់គ្នា ហើយត្រូវចាប់បាន ពេលរត់មិនរួច គឺត្រូវទទួលទោស ធ្វើឱ្យណាខាដៀ ត្រូវបាត់បង់ស្រីរបាំ ដែលអាចរកប្រាក់បាន ព្រោះបន្ទាប់ពីដាក់ទោស ស្រីរបាំដែលទ្រាំនឹងភាពអាម៉ាស់លែងបាន ទៅជាឡប់សតិ ឬមិនអីចឹងសម្លាប់ខ្លួន។

"ចាំ ឃែរ៉ល"

សាន់នី ឆ្លើយតបដោយភាពស្លូតបូត មិនចង់ប្រកែកប្រណាំងនឹង ឃែរ៉ល ព្រោះមិនអាចឈ្នះ ក្រៅពីនេះនឹងធ្វើឱ្យ ឃែរ៉ល មិនពេញចិត្ត។ ឃែរ៉ល មិនបានចិត្តល្អដូចអកប្បកិរិយាដែលបង្ហាញឱ្យឃើញក្រៅពីនេះនៅដឹងទៀតថា





Scanned by CamScanner

ត្រូវធ្វើយ៉ាងណាឱ្យនាងព្រម ដោយមិនធ្លាប់រអៀសចិត្ត ដែលយក ជីណា មក គំរាមនាង។

"ថ្នាក់បានប្អូនស្រីរបស់នាងទៅហើយ នៅតែជាប់ចិត្តនាងមិនព្រម ដោះលែង"

"ចាំ យៃវ៉ល"

"តែល្អ ព្រោះធ្វើឱ្យខ្ញុំមានចំណូល"

ក្រៅពី យៃវ៉ល បានចំណូលហើយ សាន់នី ក៏បានចំណូលដូចគ្នា គុណសម្បត្តិរបស់ យៃវ៉ល ក៏មានខ្លះដែរ ប្រាក់ថ្លៃខ្លួនត្រូវឱ្យដោយការវេរចូលបញ្ជីជាប្រចាំរៀងរាល់ខែ ប៉ុន្តែ សាន់នី មិនធ្លាប់ដកវាយកមកចាយវាយ ព្រោះវាគឺជាលុយស្មោកគ្រោក ប៉ុន្តែនាងត្រូវទទួលយកវា ព្រោះវាគឺជាប្រាក់ថ្លៃខ្លួន ដែលនាងត្រូវទទួលបាន។

"ថ្ងៃនេះ លោក ម៉ារីស ជូនដំណឹងជាមុន ហើយឱ្យនាងចេញទៅទទួល"

"ចាំ យៃវ៉ល"

"កុំធ្វើឱ្យលោក ម៉ារីស ខឹង"

យៃវ៉ល បញ្ជាក់ ព្រោះដឹងចរិតរបស់ សាន់នី ថានៅពេលខ្លះ ពេលដែលខឹង គឺឆ្នាសខ្លាំងណាស់ ប៉ុន្តែដែល យៃវ៉ល គ្មានឱកាសដាក់ទោស ព្រោះមិន



Scanned by CamScanner

ធ្លាប់បានទទួលការប្តឹងពី ម៉ារីស។

"ចូលទៅរកលោក ម៉ារីស ទៅ សាន់នី"

យ៉ៃរ៉ល ដឹកដៃ សាន់នី មកចាំទទួលលោក ម៉ារីស ថង់មាសថង់ប្រាក់របស់ យ៉ៃរ៉ល ហើយពេលឃើញគេ ក៏និយាយដាក់នាងដោយពាក្យពេចន៍ពីរោះពិសា ប្រាប់ឱ្យនាងដើរទៅរក នាងក៏ព្រមធ្វើតាម ដោយប្រាប់មិនត្រូវទេថាមានអារម្មណ៍យ៉ាងណាដែលបានជួបគេ តែនាងគ្មានអារម្មណ៍ថារើសអើង។

"លោក ម៉ារីស បាត់មុខបាត់មាត់ សាន់នី រអ៊ូនឹករាល់ថ្ងៃ"

សេត បានស្តាប់ប្រយោគបែបនេះពី យ៉ៃរ៉ល ឡើងចាំទៅហើយ ហើយគិតថាភ្ញៀវឯទៀតក៏បានឮប្រយោគបែបនេះដូចគ្នា។

"នាងនឹកខ្ញុំមែនឬ"

អ្នកកំលោះស្រវាឱបចង្កេះអ្នកដែលដើរមករក និងមើលនាងដោយខ្សែភ្នែកម៉ក់ៗ។ ថ្ងៃនេះ សាន់នី ស្អាតខ្លាំងណាស់ ការពិតទៅនាងស្អាតគ្រប់ពេលដែលជួបគ្នាប៉ុន្តែមកពីខានជួបនាងច្រើនថ្ងៃទើបធ្វើឲ្យគេមានអារម្មណ៍ដូចឃ្លានខ្លាំង ឃ្លានមែនទែន ដល់ថ្នាក់ចង់ចាប់នាងស៊ីនៅត្រង់នេះ។

គេភ្ញើយចង្ការបស់នាងសួរនាំជាការលេងសើចហើយគ្រប់ពេលដែលគេ



សួរបែបនេះ នាងក៏លួចសម្លក់សម្លឹងគេ តែម្ដងនេះ នាងមានអាការៈដូចមនុស្ស ខ្លាច ព្យាយាមធ្វើខ្លួនឱ្យនឹងធឹង មិនឆ្លើយសំណួរគេ ប៉ុន្តែថ្ពាល់ឡើងក្រហមនោះ គឺជាចម្លើយដែលបញ្ជាក់ច្បាស់។

"អូខេ ខ្ញុំបានចម្លើយហើយ"

គេឱនទៅថើបថ្ពាល់រលោង ឱ្យនាងផ្អឹបថ្ពាល់នឹងដើមទ្រូងធំទូលាយ ខណៈដែលបាតដៃធំក្រាស់ ស្ទាបអង្អែលត្រគាកសាយរបស់នាង។

"លោកម៉ារីស ចង់ទស្សនាការសម្ដែងសិនទេ"

"ក៏ល្អដែរ"

គេទទួលយកសំណើរបស់ ឃៃវ៉ល ខណៈនោះក៏មូលសក់របស់ សាន់នី លេង ដែលនាងទម្លាក់វាពាក់កណ្ដាល ចំណែកពាក់កណ្ដាលទៀតលើកចង ដែលប្រវែងរបស់វា ជិតដល់កំប៉េះគូទឯណោះ។

"អញ្ជើញលោក ម៉ារីស"

សេត ឱបចង្កេះរបស់នាង នាំដើរចូលទៅខាងក្នុងជាមួយ រហូតដល់ បន្ទប់វីអាយភី ទើបដាក់បង្អុយលើសាឡុង ហើយទាញនាងឱ្យអង្គុយលើភ្លៅនៅ ចំពោះមុខ ឃៃវ៉ល។

"លោក ម៉ារីស ហៅភេសជ្ជៈអីដែរ ?"



Scanned by CamScanner

ឃែរ៉ល សួរដើម្បីយកចិត្តយកថ្លើមភៀរវីអាយភីរបស់ខ្លួន ព្រោះ ម៉ារីស ជាមនុស្សដែលពិបាកចូលទៅដល់ ប៉ុន្តែគេមិនស្និត មិនកំណាញ់ មិនរើងច្រើន ឬទាមទារសេវាកម្មដល់ថ្នាក់ធ្វើឱ្យឈឺក្បាល។

"ប្រាន់ឌី"

"នាងខ្ញុំនឹងចាត់ការជូន"

ពេល ឃែរ៉ល ដើរចេញពីបន្ទប់វីអាយភី សេត ក៏ចាប់សក់របស់អ្នកនៅលើភ្លៅមកស្រង់ក្លិនចូលឱ្យពេញសួត ហើយសម្លឹងមុខ អ្នកដែលធ្វើខ្លួនមិនត្រូវ។

"មុខខ្ញុំប្រែប្រួលឬ?"

សាន់នី មានអារម្មណ៍ភ័យៗ ទាំងដែលនាងនិងគេស្និទ្ធស្នាលគ្នាលើសអារម្មណ៍នោះទៅហើយ ប៉ុន្តែខ្សែភ្នែករបស់គេ នៅតែធ្វើឱ្យនាង ព្រឺរងា។

"ថី?"

"សម្លឹងអីក៏សម្លឹង"

"ចង់សម្លឹង"

នាងមិនចង់ឱ្យគេសម្លឹង សេត កាន់តែសម្លឹង ទើប សាន់នី ងាកមុខចេញ ប៉ុន្តែត្រូវគេចាប់មុខឱ្យបែរមកវិញ ហើយងើយទៅថើបជញ្ជក់បបូរមាត់ ដែលដំបូងនាងគក់ស្មារបស់គេ តែបន្ទាប់មក ក៏ត្រូវសហការ។





Scanned by CamScanner

"ឆ្នាសណាស់ ត្រូវតែដាក់ទោស"

គេថើបជញ្ជក់បបូរមាត់របស់នាងកាន់តែខ្លាំង សាន់នី ក៏ត្រសុលមករក ទើបព្រលែងកដៃ ដើម្បីឱបក្រសោបនាង។

"អុំ! សុំអភ័យទោសលោក ម៉ារីស"

"មិនអីទេ"

ឃៃវ៉ល នាំបុគ្គលិកដើរចូលមក ចេញបញ្ជាឱ្យដាក់ភេសជ្ជៈនៅលើតុ ដែលមានប្រាន់ឱសម្រាប់ត្បៀវសំខាន់ និងទឹកក្រូចសម្រាប់ សាន់នី។

"នាងខ្ញុំមិនរំខានទេ អញ្ជើញលោក ម៉ារីស តាមសម្រួល"

សេត ងក់ក្បាល ឃៃវ៉ល ក៏ដើរសំដៅទ្វារ ដោយលួចងាកមកមើលពេល បែរខ្លួនដើម្បីទាញទ្វារបិទ ឃើញត្បៀវរបស់ខ្លួន ឱនថើប សាន់នី ទៀតហើយ។ កាយវិការរបស់គេ បញ្ជាក់ឱ្យឃើញថា នៅជាប់ចិត្តជាប់ថ្លើមខ្លាំង ដែលវាគឺជា រឿងល្អ ព្រោះចំណូលដែលនឹងទទួលបាន។

"មិនផឹកទេឬ?"

"នាងបញ្ចុកខ្ញុំទៅ"

សេត ចុចបើកវាំងនន ដើម្បីមើលការរបាំស្រាត។ ណាខាដៀធ្វើការ សម្តែងបានស្អាត បើមើលជាការកម្សាន្ត វាគឺជាសិល្បៈមួយប្រភេទ។ សាន់នី



Scanned by CamScanner

ខ្ទីបបបប្ដូរមាត់ ព្រោះត្រូវគេបើបឡើងបបូរមាត់ញ៉រទទ្រើតទៅហើយ ហើយឱនទៅចាក់ប្រាន់ឌីដាក់កែវ លើកយកមកបញ្ចុកគេ។

"អញ្ជើញលោក ម៉ារីស"

"ខ្ញុំចង់ផឹកពីមាត់របស់នាង"

គេទាញកែវពីដៃរបស់នាង ដើម្បីបញ្ចុក សាន់នី មិនចង់ផឹក តែក្នុងពេលដែលគេត្រូវការ ទើបនាងយល់ព្រម ហើយពេលផឹករួច ក៏ត្រូវគេបើបបបូរមាត់ដួសដងយកប្រាន់ឌីពីមាត់របស់នាង ទើបរបាំស្រោតនៅលើវេទិកាមិនត្រូវបានទទួលការចាប់អារម្មណ៍ពី សេត ដូចការបង្ហាប់ឱ្យស្រីស្អាតនៅលើភ្លៅ បញ្ចុកប្រាន់ឌីគេបែបដល់មាត់ដល់អណ្ដាត។



# ៦

## របស់បញ្ចាំចិត្ត

*គេជាមនុស្សរោគចិត្ត តែនាងត្រូវអត់ធ្មត់នឹងគេឱ្យបាន!*

សេត នាំនាងប្តូរកន្លែង ទៅអង្គុយលើសាឡុងមួយទៀត ដែលសម្រាប់មើលវេទិកាសម្តែងរបាំស្រាត ដោយដៃទាំងពីររបស់គេក៏ដោះខោអាវចេញពីរាងកាយរបស់នាងបណ្តើរៗ ដែរ។

រ៉ូបតួខាងលើត្រូវទាញបូចេញពីគ្នា ហើយគេក៏វាសវាចេញពីស្មា លូកដៃមកក្រសោបដើមទ្រូងក្រពុំ ប្រចាប់វា ខណៈនោះក៏ថើបថ្ពាល់រលោងដែរ។

"ហ៊ឺ! ក្តិចឬ"

សាន់នី ខ្ទាំខ្នងដៃរបស់គេនឹងក្រចក។ គេចង់មើលរបាំ ក៏មើលទៅហេតុអីចាំបាច់មើលបណ្តើរ បបោលអង្អែលនាងបណ្តើរធ្វើអី។

"អត់ទេ បៃដន្យ វាប៉ះត្រូវ"

នាងដោះសា និងផ្តេកក្បាលនឹងដើមដៃរបស់គេ ខណៈនោះក៏ខ្ទាំដើមដៃ



Scanned by CamScanner

របស់គេដែរ ដែលម្តងនេះមិនបានចៃដន្យ តែព្រោះត្រូវគេប្រចាប់ដើមទ្រូងឱ្យរាងកាយញ័រទទ្រើត

"ចូលចិត្តឬ"

នាងក្រមុំមិនឆ្លើយ ប៉ុន្តែរាងកាយរបស់នាងលាតត្រដាងទាំងអស់ ថាការប៉ះពាល់របស់ សេត កំពុងរំខានការគ្រប់គ្រងខ្លួនឯងរបស់នាង។ គេចាប់ដៃដែលខ្ទាំខ្ទងដៃរបស់គេ មកថើប។

"ដៃតូចតែមួយ"

គេត្រដាងបាតដៃទ្រាបលើបាតដៃតូចស្តើង ឯដៃម្ខាងទៀតក៏រានទន្ទ្រានដើមទ្រូងណែនក្បុំមិនព្រមឈប់។ អារម្មណ៍ក្តៅគគុករបស់នាងត្រូវគេដុតឱ្យផ្ទុះខណៈនោះ ក៏បន្ថែមភាពទន់ភ្លន់ប្លែកៗ ឱ្យនាងដែរ ឱ្យថ្ពាល់ឡើងក្រហមងាំងតែប្រឹងត្រសុលទៅរកដើមទ្រូងជំទូលាយ។

"កដៃតូចតែមួយ"

សេត និយាយដូចរអ៊ូៗ និងពន្លែងបាតដៃចេញពីដើមទ្រូងក្រពុំ ហើយមួយសន្ទុះក្រោយមក នាងក៏មានអារម្មណ៍ដល់ភាពត្រជាក់ដែលប៉ះកដៃ។

"អុំ!"

សាន់នី ភ្ញាក់ព្រើត ទាញដៃចេញ តែត្រូវគេចាប់កដៃជាប់។ សេត បំពាក់





Scanned by CamScanner

កងដៃនឹង.កដៃរបស់នាង វាជាកងដៃពាក់លេង មានម៉ូតគួរឱ្យស្រឡាញ់ សម នឹង.កដៃរបស់នាង ពាក់ហើយស្អាតមែនទែន កាន់តែមើលទៅទន់ភ្លន់ ហើយគេ ក៏ចូលចិត្តពេលឃើញវានៅលើ.កដៃរបស់នាង។

"ខ្ញុំឱ្យ"

"អ៎!...ចាំ"

"ប៉ុណ្ណឹង ?"

សាន់នី នៅតែស្រឡាំងកាំងនឹងកងដៃដែលត្រូវបំពាក់ជាប់.កដៃ ទើប ឆ្លើយតបហាក់ដូចមនុស្សមមើ ព្រោះស្មានមិនដល់ទេថា ទទួលវាពីគេ។

"អឺ...ខ្ញុំ"

"ទើបរដាក់រដុប"

"ខ្ញុំភ្ញាក់ផ្អើល"

"ភ្ញាក់ផ្អើលស្អី ?"

បំពាក់កងដៃឱ្យនាងរួចរាល់ គេក៏លើកដៃនាងថើបព្នដុប ហើយដាក់ដៃ លើភ្លៅរបស់នាង បន្ទាប់មកច្របាច់ដើមទ្រូងណែនក្បំ។

"គឺ...គឺ...ហ៊ឹ!"

នាងក្រមុំឆ្លើយតបយ៉ាងលំបាក ព្រោះត្រូវច្របាច់ដើមទ្រូងខ្លាំងៗ ភ្លោច



Scanned by CamScanner

ចំណុចខ្សោយ ឱ្យនាងគ្រលែងត្រគាកលើភ្លៅរបស់គេ។

"ឆ្លើយប្រាប់ខ្ញុំម៉ោ សាន់នី"

"ភ្ញាក់...ភ្ញាក់ផ្អើលដែលទទួលបានកាដូ"

"អ៊ីចឹងហើយ នាងត្រូវសងគុណខ្ញុំ"

សេត លើកខ្លួននាងឡើង ទាញឈុតក្នុងចេញពីត្រគាកមូលក្លំ នាងក៏ជួយលើកជើង ដើម្បីឱ្យគេទាញវាឱ្យផុតពីរាងកាយ។

"រក្សាឱ្យបានល្អ"

ពេលត្រូវគេចាប់សង្កត់ខ្លួនចុះ សាន់នី ក៏ភ្ញាក់កន្ត្រាក់ ខ្ទាំដៃរបស់គេទាំងខាង ព្រោះគេជ្រែកភាពមហិមាចូលទៅក្នុងរាងកាយរបស់នាង។

"នេះហើយ ភាពកក់ក្តៅដែលខ្ញុំត្រូវការ"

គេដង្ហោយរកការគ្រប់គ្រងនាង តែត្រូវខាំធ្មេញទប់អារម្មណ៍ដែលគេមិនចង់ព្រមទទួលស្គាល់ថា វាជាការនឹករឭក ដើម្បីធ្វើការ ធ្វើការ និងធ្វើការ ប៉ុន្តែពេលមានពេលទំនេរ គេក៏ហាមការនឹករឭកនេះមិនបាន ត្រូវស្រូតដំណើរមករកនាងទៀតឱ្យទាល់តែបាន ហើយក៏បានត្រៀមខ្លួន ដើម្បីការចរចាទិញនាងពីណាខាដៀ ដែរ។

"រាំរបាំលើខ្លួនខ្ញុំ សាន់នី"





Scanned by CamScanner

ដៃទាំងពីររបស់គេចាប់ចង្កេះតូចស្ដើង ឱ្យរេរាំលើរាងកាយរឹងមាំ ដោយចង្វាក់ស្នេហាដែលធ្វើឱ្យនាងស្ទើរតែដាច់ខ្យល់។

"អ៎ា..."

"ពៅព្រលឹង ម៉ោឱ្យខ្ញុំឱបឱ្យណែនៗ"

គេទាញនាងមកឱប នាងក៏ផ្ដួលខ្លួនទៅរក និងឱ្យគេនាំផ្លូវ នាំនាងឆ្លងព្យុះប្រាថ្នាដ៏ក្ដៅគគុក ខ្យល់ដង្ហើមក៏ដង្ហក់ រាងកាយធ្វើចលនាជាបន្តបន្ទាប់ ទាល់តែបែកញើសជោកខ្លួន ប៉ុន្តែ សេត នៅតែថើបថ្ពាល់របស់នាងខ្សឹតៗ មិនខ្ពើមរអើមគ្រាប់ញើសដែលផុសពេញមុខ ញើសនាងច្រើនយ៉ាងនេះ ក្លិននៅតែក្រអូបទៀតឬ។

*នេះជាបញ្ហាលោកាវិនាសស្អីទៅ!*

សេត ត្រូវធ្វើដំណើរត្រឡប់ទៅកោះ ស៊ីរ៉ូវើ ជាបន្ទាន់ ព្រោះមានទូរសព្ទពីអ្នកម្ដាយជាទីស្រឡាញ់ ហើយពេលនេះទិដ្ឋភាពភូមិគ្រឹះដ៏ស្ដឹមស្ដែនៅលើកោះចោរ មានមនុស្សស្រីពីរនាក់ម្ដាយកូន អង្គុយឱបគ្នាយំខ្សឹកខ្សួលលើសាឡុង។

"សេត"

សេត ដើរទៅរកម្ដាយ ព្រះនាង ឃែតទ្រីណា ក៏ចុះពីសាឡុង ដើរមកឱបស្វាគមន៍កូនប្រុស។ ស្វាមីរបស់ព្រះនាងមិននៅលើកោះ ដោយធ្វើដំណើរទៅ



Scanned by CamScanner

បរទេស ដែលជារឿងល្អ ព្រោះបើ ជីសាស់ នៅទីនេះ អាចនឹងមានការសួរ ចម្លើយដែលតឹងរ៉ឹងកើតឡើង។

"សួស្តីអ្នកម៉ាក់ អ្នកម៉ាក់ស្អាតដល់ហើយ"

សេត ថើបថ្ពាល់ម្តាយ ហើយគ្រាហ៍ទ្រង់ទៅអង្គុយលើសាឡុង និងមើល ពីរនាក់ម្តាយកូន ណេដា ដែលជាកូន និង វ៉េននី ជាម្តាយ។

"នាងមានផ្ទៃពោះឬ?"

សេត មិនអូសបន្លាយវែងឆ្ងាយ ដាក់បង្គុយលើសាឡុងហើយសួរត្រង់ៗ ខណៈដែល ណេដា មិនហ៊ានមើលមុខគេចំ ទាំងដែលមុននេះនាងយំទឹកភ្នែក ទឹកសម្បោររឿងមានផ្ទៃពោះដាក់ព្រះនាង យៃតទ្រីណា។ ពីរនាក់ម្តាយកូនសុំ ឡើងមកលើកោះចោរដោយហេតុផល ដែលព្រះនាងមិនអាចបដិសេធបាន ដោយមកដល់កាលពីម្សិល ហើយថ្ងៃនេះព្រះនាងក៏ហៅមកជួបម្តងទៀត ដើម្បី បាននិយាយតទល់នឹង សេត។

"អឺ...ចា៎"

"មានផ្ទៃពោះជាមួយអ្នកណា?"

គេសួរដោយកាយវិការរំភើយ អ្នកដែលនិយាយស្តីចេះចុះមុននេះ ទៅជា និយាយមិនចេញ។ ទោះគេមើលទៅ រំភើយយ៉ាងណាក៏ដោយ ប៉ុន្តែកែវភ្នែក





Scanned by CamScanner

របស់គេមិនបានបង្ហាញឱ្យឃើញពីអារម្មណ៍នោះ។

"មានផ្ទៃពោះជាមួយខ្ញុំ ?"

ពេល ណេដា ឆ្លើយមិនចេញ គេក៏សួរឱ្យ។ មិនមែនថាគេមិនដឹងរឿងត្រួសៗពីម្ដាយ ប៉ុន្តែមានចេតនា សួរសំណួរឱ្យនាងឆ្លើយ។

"អឺ....ចាំ...ចាំ"

"មានប៉ុន្មានខែ ?"

សេត នៅតែព្រងើយកន្តើយ សួរនាំដូចបបួលនិយាយ ខណៈដែលព្រះនាង ឃែតទ្រីណា អង្គុយស្ដាប់ដោយមិនមាត់មិនក ទុកឱ្យកូនប្រុសជាអ្នកចាត់ការដោយផ្ទាល់។

"ពីរ...ពីរខែ"

"ពីរខែ ?"

គេសួរបញ្ជាក់ម្ដងទៀត ណេដា ក៏ច្របាច់ដៃម្ដាយខ្លាំងៗ ទើប វែននី ងាកមកមើលមុខកូនស្រី បាញ់ខ្សែភ្នែកដាក់គ្នា ដោយគេចមិនផុតពីខ្សែភ្នែករបស់ សេត។

"ចាំ លោក សេត"

"ច្បាស់ហើយ ?"



Scanned by CamScanner

"ចាំ ច្បាស់ហើយ"

សេត ងាកទៅចាប់ដៃម្ដាយ លើកថើប។ គេត្រូវមកអង្គុយស្ដាប់រឿងគ្មានប្រយោជន៍ គឺព្រោះពីរនាក់ម្ដាយកូននេះដែលមិនសំខាន់ចំពោះជីវិតរបស់គេ។

"ខ្ញុំឱ្យនាងឆ្លើយម្ដងទៀត"

"ខ្ញុំសុំបញ្ជាក់ថាខ្ញុំមានផ្ទៃពោះជាមួយលោក សេត មែន"

ណេដា ព្យាយាមគ្រប់គ្រងសំឡេងមិនឱ្យញ័រ សេត ក៏អង្គុយស្ដាប់ដោយមិនមាត់មិនក ទឹកមុខនៅតែពព្រាយ ធ្វើឱ្យ ណេដា មិនអាចសន្និដ្ឋានបានទេថាគេនឹងយល់ព្រមទទួលខុសត្រូវនាងឬអត់។

"បញ្ជាក់មាំដល់ហើយ"

"ព្រោះកូននៅក្នុងផ្ទៃជារបស់លោក សេត"

"ខ្ញុំការពារបានល្អ"

"វាមានឱកាសភ្លាត់ស្នៀតបាន"

"នាងឈ្មោះអី ?"

"ណេដា"

នាងមានកំហឹងតិចតួចដែល សេត ចាំមិនបាន ទោះនាងនិងគេធ្លាប់មានទំនាក់ទំនងគ្នាត្រឹមម្ដង ប៉ុន្តែគេគួរតែចាំនាងបានខ្លះ។





Scanned by CamScanner

"ខ្ញុំចាំមិនបាន យើងជួបគ្នានៅឯណា?"

"កំពង់ផែក្រុង ហ៊ីតវែល"

"ពេលណា?"

"រដូវក្តៅកាលពីពីរឆ្នាំមុន"

"ពីរឆ្នាំមុន ហើយខ្ញុំឡើងគ្រែជាមួយនាងពេលនោះឬ?"

"ចាំ៎ មែន លោក សេត និងនាងខ្ញុំចូលសណ្ឋាគារជិតកំពង់ផែក្រុង ហ៊ីតវែល មនុស្សរបស់លោក សេត ប្រាប់ថាលោកត្រូវការមនុស្សស្រី ប៉ុន្តែត្រូវលាក់ទុករឿងនេះជាសម្ងាត់"

"នាងមានការចងចាំល្អណាស់"

"ខ្ញុំគ្មានថ្ងៃភ្លេចទេ ទោះត្រឹមតែម្តងដែលយើងមានទំនាក់ទំនងគ្នាក៏ដោយ"

"អូខេ ចាត់ទុកថាបានចម្លើយច្បាស់លាស់ហើយអ្នកម៉ាក់ រយៈពេលយូរដល់ថ្នាក់ហ្នឹង បើនាងមានផ្ទៃពោះជាមួយខ្ញុំមែន កូនកើតរត់លេងបានទៅហើយ"

ណេដា ទើបតែងដឹងខ្លួនថា ភ្លាត់ស្មៀតពេលបានឮចម្លើយនេះឯង នាងចំជាល្ងង់ខ្លៅ ទាំងដែលទន្ទេញចាំពេលវេលាហើយថានឹងឆ្លើយឱ្យស្រដៀងនឹង



Scanned by CamScanner

អាយុភគ៌របស់នាងបំផុត។

"ចាំ សេត"

"អ្នកម៉ាក់ចាត់ការដោយខ្លួនឯង ឬឱ្យខ្ញុំចាត់ការ?"

**ព្រះនាង យៃតទ្រីណា ចាត់ការរឿង ណេដា និង វែននី ដោយផ្ទាល់** ព្រោះបើឱ្យ សេត ចាត់ការ ទ្រង់ខ្លាចចិត្តកូនប្រុស ដោយបញ្ជូនពីរនាក់ម្ដាយកូន ចេញពីកោះចោរ និងដាក់ឈ្មោះចូលបញ្ជីបុគ្គលដែលគ្មានឱកាសបានឡើង មកកោះចោរមួយជីវិត ទោះនៅក្នុងឋានៈជាកម្មករ ក៏គ្មានឱកាសដែរ។

កោះចោរ រើសកម្មករមកធ្វើការជាប្រចាំ ទាំងបណ្ដោះអាសន្ន និងពេញម៉ោង ដែល ណេដា និង វែននី នឹងមិនទទួលបានឱកាសនោះ ព្រះនាង យៃតទ្រីណា មានក្ដីមេត្តាណាស់ទៅហើយ ណេដា មានផ្ទៃពោះផង មិនចង់ធ្វើទារុណកម្មធ្ងន់ធ្ងរ។

"ម៉ាក់ខ្លាចខ្ញុំចាត់ការធ្ងន់ធ្ងរឬ?"

ព្រោះឪពុកនិងម្ដាយមានគេដែលជាទារយាទតែម្នាក់គត់ទើបបុរសមាឌធំ តែងតែម៉ិកម៉ូក់ដាក់ម្ដាយ ដែលពេលនេះគេដេកលើសាឡុងវែង។

"ទោះយ៉ាងណាក៏គួរឱ្យអាណិត"





Scanned by CamScanner

"មនុស្សគួរឱ្យអាណិតមិនធ្វើខ្លួនបែបនេះទេម៉ាក់"

"នាងកំពុងមានផ្ទៃពោះ"

"មានផ្ទៃពោះជាមួយអ្នកណាក៏មិនដឹង តែបែរជាញាត់ញៀតឱ្យខ្ញុំ"

សេត មេត្តាចំពោះអ្នកដែលសមគួរនឹងទទួលបានក្តីមេត្តាពីគេប៉ុណ្ណោះ។ ព្រះនាង ឃែតទ្រីណា ដឹងច្បាស់ពីចរិតបែបនេះ ដែលកូនប្រុសទទួលបានពី ជីសាស់ ស៊ី រ៉ូវើ ដែលជាឪពុក។

ជីសាស់ កាលនៅក្មេង គឺបែបនេះឯង សម្បកក្រៅមើលទៅរីករាយ ចិត្តទូលាយ ប៉ុន្តែគេមានភាពកំណាចឃោរឃៅដែលស្មានមិនដល់លាក់នៅក្នុងខ្លួន។

"នាងប្រហែលគ្មានជម្រើស"

"នាងឆ្លោយមានផ្ទៃពោះច្រើនជាង ហើយត្រូវការអ្នកទទួលខុសត្រូវ នាងគិតខុស ព្រោះខ្ញុំមិនព្រមឱ្យញាត់ញៀតជាឪពុករបស់កូននាងងាយៗទេ"

"នាងប្រហែលត្រូវការទីពឹងពាក់"

"នាងធ្វើដោយខ្លួនឯងទេ បើនាងសុំមកធ្វើការនៅលើកោះដើម្បីចិញ្ចឹមកូន ខ្ញុំនឹងផ្តល់ជំនួយ ប៉ុន្តែមនុស្សបែបហ្នឹង ខ្ញុំមិនទុកនៅជិតខ្លួនទេ ខ្លាចក្លាយជាពស់ពិស បង្កបញ្ហាឱ្យខ្ញុំនាពេលអនាគត"



Scanned by CamScanner

ណោដា ត្រូវទទួលខុសត្រូវចំពោះរឿងរបស់នាងដោយខ្លួនឯង គេមិនដាក់ទោសធ្ងន់ល្អប៉ុនណាទៅហើយ។

"នោះមកពីកូនមានមន្តស្នេហ៍"

សេត ចាប់ដៃម្តាយមកថើប។

"ខ្ញុំដឹងខ្លួនថាខ្ញុំសង្ហា"

"ហើយកូនក៏ចិត្តទូលាយចំពោះការប្រើរាងកាយរបស់កូនដែរ"

សេត អស់សំណើច។ អ្នកម្តាយជាទីស្រឡាញ់របស់គេ គឺជាស្ត្រីទន់ភ្លន់ពេលស្តីបន្ទោសឱ្យគេម្តងៗ ក៏ធ្វើដោយភាពទន់ភ្លន់ដែរ។

"ម៉ាក់ស្តីឱ្យខ្ញុំឬ"

"កូនគិតថាម៉េច"

"ម៉ាក់ប្រហែលស្តីឱ្យខ្ញុំរឿងខិលខូច"

"ម៉ាក់បារម្ភពីកូន"

ពេលនេះ សេត មិនទាន់ថ្លោះធ្លោយ តែថ្ងៃមួយអាចនឹងថ្លោះធ្លោយបានរឿងបែបនេះ មានទំនុកចិត្តពេកក៏មិនមែនថាជារឿងល្អ ព្រះនាង ឃែតទ្រីណាក៏មានចក្ខុវិស័យដូចគ្នា។

"ខ្ញុំមិនធ្លោយទេម៉ាក់ ម្យ៉ាងទៀតពេលនេះខ្ញុំក៏មិនបានទាក់ទងស្រីផ្សេង





Scanned by CamScanner

យូរហើយដែរ"

ណេដា ចូលមកក្នុងជីវិតរបស់គេម្ដងទៀត នៅកំលុងពេលដែលគេបញ្ឈប់ការធ្វើខ្លួនខិលខូចទៅហើយ។ នាងអាចគិតថា គេអាចខិលខូចដល់ថ្នាក់ភ្លេចពេលវេលាដែលបានជួបនាងទេដឹង។ ដេកជាមួយមនុស្សស្រី ទោះមិនបានយកចិត្តទុកដាក់យ៉ាងណាក៏ដោយ ក៏មិនអាចភ្លេចងាយៗដូចដើរទៅទិញរបស់នៅស៊ុបពើម៉ាឃីត។

ណេដា ត្អូញត្អែរថានាងក្រីក្រ ត្រូវការឱ្យកូនសុខសប្បាយ ជាពាក្យដោះសាដែលគួរឱ្យខ្ពើមរអើម ទោះក្រីក្រ ក៏គ្មានសិទ្ធិ បង្ករឿងថោកទាបបែបហ្នឹងដែរ សំណាងល្អហើយដែលគេនៅលីវ បើគេមានក្រុមគ្រួសារវិញ គ្រួសាររបស់គេនឹងមានបញ្ហាឱ្យតាមជម្រះ។

"មែនឬ?"

"បាទម៉ាក់"

សេត មានមនុស្សស្រីតែម្នាក់គត់នៅពេលនេះ គឺ សាន់នី ត្រឹមនឹកដល់មុខក្រអឺតក្រទមរបស់នាង រាងកាយរបស់គេ ក៏មានកម្លាំងព្រឺសភ្លាម។

"សេត ម៉ាក់មានសំណួរ"

"បាទ ម៉ាក់"



Scanned by CamScanner

"កូនមិនគិតថារៀបការទេឬ?"

"កូនរង់ចាំឱ្យ រ៉េនដហ្វ រៀបការសិន"

សេត ទាញបងប្អូនជីដូនមួយមកធ្វើជាក្រោះការពារ។ គេមិនទាន់ចង់បំពេញតួនាទីជាស្វាមីឱ្យស្រីណាទាំងអស់ ហើយបើគេចង់រៀបការ គេត្រូវតែឈប់ទាក់ទងនឹង សាន់នី។ ពេលមានភរិយា គេត្រូវតែស្មោះត្រង់ចំពោះនាង ហើយគេក៏មិនទាន់ត្រូវការបញ្ឈប់ទំនាក់ទំនងជាមួយ សាន់នី ដែរ។

"សេត ការរៀបការមិនមែនជារឿងគួរឱ្យខ្លាចទេកូន"

"ខ្ញុំដឹង តែខ្ញុំចង់រៀបការពេលដែលខ្ញុំអួខេ ហើយខ្ញុំនឹងរៀបការ ទាល់តែពេលដែលខ្ញុំជួបមនុស្សស្រីដែលខ្ញុំពេញចិត្តបញ្ឈប់ត្រឹមនាង"

"តាមចិត្តកូន"

ព្រះនាង ឃែតទ្រីណា អង្អែលថ្ពាល់កូនប្រុសដោយក្ដីស្រឡាញ់។ ទ្រង់មិនប្រសព្វប្រកែកប្រណាំង ធ្វើបានត្រឹមតែញញឹមពព្រាយ មិនថាជាស្វាមីឬកូនប្រុស ទ្រង់មិនធ្លាប់យកឈ្នះសម្ដីរបស់ពួកគេបានសូម្បីតែម្ដង។

"មានអីកើតឡើង ?"

សាន់នី ស្ទុះងើបឈរ ពេលមានសំឡេងឡូឡា និងសំឡេងក្អុងក្អាំងនៅ





Scanned by CamScanner

ខាងក្រៅហើយក៏ឮខ្លាំងទៅៗទើបបើកទ្វារចេញមកមើលឃើញបុរសមាឌដំបងមួយក្រុមឈរត្រៀបត្រា។

"រំខានឬ?"

ឃៃរ៉ល ដើរវែកបុរសមួយក្រុមនោះចេញមក ដែលក្រៅពី សាន់នី ហើយស្រីរបាំនៅក្នុងបន្ទប់ផ្សេងទៀត ក៏បើកទ្វារចេញមកមើលដែរ។

"ខ្ញុំគ្រាន់តែសង្ស័យ ឃៃរ៉ល"

"សុំអភ័យទោសផង ដែលរំខានអ្នកទាំងអស់គ្នា"

ឃៃរ៉ល ញញឹមពព្រាយ និយាយដាក់ស្រីរបាំ ដែលចេញមកឈរត្រៀបត្រានៅមុខបន្ទប់ ដែលនៅបរិវេណនេះ មានបន្ទប់ដែលមានស្រីរបាំ ជាម្ចាស់បីបន្ទប់ប៉ុណ្ណោះ ព្រោះតម្លៃចិញ្ចឹមមើលថែដែលមនុស្សប្រុសចំណាយដើម្បីពួកនាងមានចំនួនមិនច្រើនទេ។

"ភ័យឬ សាន់នី"

"អត់ទេ"

"គ្មានរឿងអីទេ មិនបាច់ភ័យទេ"

មិនអាចទៅរួចទេដែលគ្មានរឿង ប៉ុន្តែ ឃៃរ៉ល និយាយបែបនេះហើយ គឺត្រូវតែយល់តាមហ្នឹង។ ឃៃរ៉ល នៅតែញញឹម ប៉ុន្តែជាស្នាមញញឹមដែល



Scanned by CamScanner

ប្រាសចាកការពិត។

"អីចឹងល្អហើយ សុំអភ័យទោសម្តងទៀតដែលរំខាន"

"មិនអីទេអ្នកស្រី"

"អញ្ជើញអ្នកទាំងអស់គ្នាចូលទៅខាងក្នុងវិញទៅ"

សាន់នី មើលមនុស្សស្រីម្នាក់ដែលត្រូវចោមរោម ប៉ុន្តែទោះសង្ស័យ ក៏នាងដឹងថាត្រូវធ្វើខ្លួនយ៉ាងណា គឺថយក្រោយចូលទៅក្នុងបន្ទប់បិទទ្វារដោយបេះដូងលោតដុកដាក់នឹងរូបភាពដែលឃើញ ទោះបុរសមួយក្រុមនោះឈរបាំង ប៉ុន្តែនាងនៅតែមើលឃើញថាស្រីម្នាក់នោះ ត្រូវរ៉ៃឡើងបែកឈាមទៅហើយ។

"មនុស្សជ្រួជាតិ"

សាន់នី អាណិតជោគជតាជីវិតរបស់មនុស្សស្រីដូចគ្នា ស្រីរបាំម្នាក់នោះប្រហែលជាមនុស្សម្នាក់ទៀត ដែលមិនព្រមធ្វើការនេះ។

"ធ្វើចិត្តឱ្យត្រជាក់ សាន់នី"

នាងលើកដៃស្ទាបទ្រូង ភ័យខ្លាចចំពោះហេតុការណ៍ដែលកើតឡើង នាងចង់ជួយស្រីម្នាក់នោះ ប៉ុន្តែតើធ្វើអីបានទៅ បើខ្លួនឯងនាងជួយមិនបានផង។

"ជូនពរឱ្យនាងសំណាងល្អ"





Scanned by CamScanner

សំណាងល្អរបស់មនុស្សម្នាក់ៗ មិនដូចគ្នា ពេលខ្លះ សេចក្ដីស្លាប់គឺអាច ជាសំណាងល្អសម្រាប់អ្នកខ្លះក៏ថាបាន។

**ឈ្មោះរបស់នាងគឺ សនយ៉ា ដែលត្រូវមនុស្សប្រុសមាឌធំៗ វ៉ៃធ្វើបាប** ទាល់តែបែកឈាមយ៉ាងសាហាវឃោរឃៅ ហើយត្រូវបោះចូលទៅក្នុងបន្ទប់ឃុំឃាំង។ ទោះវាមិនមែនជាគុក ប៉ុន្តែក៏ដូចគុក បានត្រឹមតែស្រែកថ្ងូចថ្ងូរ ប៉ុន្តែ ឃែរ៉ល បែរជាឈរមើលដោយទឹកមុខគ្មានក្ដីមេត្តា មើលការដាក់ទណ្ឌកម្មដោយការឱ្យកូនចៅប្រុសៗប្រាំមួយនាក់រំលោភបំពាននាង។

"ស្រីបិសាច"

កែវភ្នែករបស់ សនយ៉ា ក្រហមងាំង មុខដែលធ្លាប់តែស្រស់ស្អាត ត្រូវវ៉ៃបែកឈាម ក្រៅពីនេះ រាងកាយក៏ត្រូវចាត់ការដោយគ្មានក្ដីមេត្តានិងសាហាវព្រៃផ្សៃ។ វាគឺជារឿងព្រៃផ្សៃបំផុត នៅក្នុងជីវិតរបស់មនុស្សស្រី ពេលដែលត្រូវបោះចូលបន្ទប់ឃុំឃាំង បានត្រឹមតែនាំរាងកាយគ្មានកម្លាំងកំហែងរបស់ខ្លួនងើបអង្គុយ ឱបជង្គង់នៅកៀនជញ្ជាំងប៉ុណ្ណោះ។

នាងចងចាំរូបភាពរបស់ ឃែរ៉ល នៅក្នុងឋានៈជាស្រីបិសាច ស្រីជួជាតិដែលរកស៊ីលើគំនរទុក្ខរបស់មនុស្សស្រីដូចគ្នា។ តំណក់ទឹកភ្នែករបស់ សនយ៉ា



Scanned by CamScanner

ហួរដល់ថ្នាក់គ្មានអីឱ្យហូរទៀតស្មារតីក៏រលត់ព្រោះត្រូវដេកជាមួយមនុស្សប្រុស ម្តងដល់ទៅប្រាំមួយនាក់។

"ស្រីបិសាច យ៉ៃរ៉ល មីបិសាច!"

នាងងាកឆ្វេងងាកស្តាំ ខ្ទាំម្រាមដៃឡើងក្រងង់ មិននៅសល់ទៀតទេ រូបភាពជាស្រីរបាំដ៏ស្រស់ឆើតឆាយ។ នាងជួបស្នេហ៍នឹងបុរសនៅក្រៅ ណាខាដៀ នៅថ្ងៃដែលគេចូលមកកម្សាន្តនៅទីនេះ។ នាងត្រូវការចេញពី ច្រកស្នេហា ដើម្បីទៅរស់នៅខាងក្រៅជាមួយគេ។

គេមានឱកាសមកកម្សាន្តនៅ ណាខាដៀ ព្រោះដើរតាមចៅហ្វាយ។ មួយរាត្រីដែលបាននៅជាមួយគ្នា នាងក៏ឈ្លក់វង្វេងនឹងគេ ប៉ុន្តែនាងក៏ត្រូវភ្ញៀវ ដែលមកកម្សាន្តផ្តល់ការចិញ្ចឹមមើលថែបន្ទាប់ពីនោះ ។ នាងមិនចង់បង្ខំចិត្តខ្លួន ឯងដេកជាមួយអ្នកដទៃ នាងត្រូវការតែគូស្នេហ៍របស់នាងប៉ុណ្ណោះ។

សនយ៉ា រត់គេច ប៉ុន្តែត្រូវចាប់បាន និងត្រូវដាក់ទណ្ឌកម្ម។

"មីបិសាច យ៉ៃរ៉ល អញមិនព្រមចាញ់ឯងទេ!"

សនយ៉ា នឹងត្រូវឃុំឃាំងនៅក្នុងបន្ទប់នេះរយៈពេលបីខែ ហើយបើនាង មិនទាន់ស្លាប់ នឹងត្រូវបញ្ជូនឱ្យទៅធ្វើការងារចាស់ ប៉ុន្តែបើស្លាប់ យ៉ៃរ៉ល នឹងឱ្យ គេនាំសាកសពរបស់នាងចេញពីបន្ទប់ ដែលនាងមិនអាចរង់ចាំឱ្យដល់បីខែ។





Scanned by CamScanner

សនយ៉ា លូកហោប៉ៅសំពត់ យកដែកកេះតូច ដែលដាក់ជាប់ខ្លួន ដោយគ្មានអ្នកណាសង្កេតឃើញ ព្រោះពួកវារវល់តែមានសេចក្ដីសុខនឹងការ ញាំញីរាងកាយរបស់នាង។ នាងកេះដែកកេះ ហើយផ្ទៀងកមើលអណ្ដាតភ្លើង បន្ទាប់មកក៏ងើបឈរ ដែលក្នុងបន្ទប់នេះមានគ្រឿងសង្ហារឹមតិចតួច ប៉ុន្តែវាអាច ឱ្យនាងដុតបាន។

"ទីនេះត្រូវតែឆេះសន្ធោរសន្ធៅដោយភ្លើងស្អាតៗ"

កែវភ្នែករបស់នាងដូចមនុស្សឡប់សតិទៅហើយ ហើយ សនយ៉ា ក៏ធ្វើ ឱ្យបន្ទប់ដែលត្រូវឃុំឃាំងនាង មានអណ្ដាតភ្លើង មិនយូរប៉ុន្មាន ភ្លើងក៏ឆាបឆេះ សន្ធោសន្ធៅពេញរោងរបាំស្រោត ណាខាដៀ។



Scanned by CamScanner

# ៧

## សេរីភាពដែលដង្ហោយរក

នៅក្នុងរោងរបាំស្រោត ណាខាដៀ កំពុងតែចលាចលភ្លើងឆេះយ៉ាងសន្ធោសន្ធៅ ព្រះការតុបតែងដោយក្រណាត់ពណ៌ស្រស់ៗនោះគឺជាប្រភពភ្លើង ឃៃរ៉ល និង អាដាំ កំពុងតែឆ្លុតនឹងរឿងដែលកើតឡើង ព្រោះវាបញ្ជាក់ថាពីរនាក់ប្ដីប្រពន្ធមិននៅសេសសល់អី បើមិនអាចគ្រប់គ្រងភ្លើងបាន។

សាន់នី ក៏កំពុងតែឆ្លុតដូចគ្នា ប៉ុន្តែនាងនៅមានស្មារតី បើកទូយកកាបូបស្ពាយ ដែលរក្សាទុកសៀវភៅធានាគារនិងឯកសារផ្ទាល់ខ្លួននានា មកពាក់ជាប់នឹងខ្លួន ហើយបើកទ្វារចេញពីបន្ទប់។

ភាពចលាចលដែលកើតឡើង ទោះជាកន្លែងដែលស្គាល់ច្បាស់ ប៉ុន្តែពេលនេះជារឿងលំបាកដែលនឹងនាំខ្លួនឯង ចេញទៅបានស្រួល។

ខណៈដែលអ្នកដទៃនាំគ្នារកផ្លូវរត់ចេញ នាងក្រមុំ បែរជារត់សំដៅផ្លូវដែលជាប់នឹងបន្ទប់ម្ខាងទៀត ដើម្បីទៅរកប្អូនស្រី ដោយមិនបានគិតពីសុវត្ថិភាព





Scanned by CamScanner

ខ្លួនឯង ព្រោះនាងបារម្ភពី ធីណា ខ្លាចប្អូនស្រីភ័យ រត់ចូលទៅក្នុងភ្នក់ភ្លើង។

ភ្លើងកំពុងឆេះសន្ធោសន្ធៅ ផ្សែងនិងអណ្តាតភ្លើងហុយទ្រលោម នាងនាំខ្លួនឯងចូលទៅខាងមុខជារឿយៗ ដោយមិនព្រមឈប់ បើមិនជួបប្អូនស្រី ប៉ុន្តែសំណាងល្អ ដែលនាងនិង ធីណា គិតដូចគ្នា ប្អូនស្រីក៏រត់មកផ្លូវនោះ ដើម្បីទៅរកបងស្រី។

"បង សាន់នី!"

"ធីណា!"

ពីរនាក់បងប្អូន ស្រវាឱបគ្នា។ ពេលឃើញបងស្រី ធីណា ក៏អណ្តើតអណ្តកមួយរំពេច ប៉ុន្តែរវល់តែឱបល្ហួងលោមប្អូនស្រីមិនបានទេនៅពេលនេះ។

"យើងឆាប់ចេញទៅ ធីណា"

ប្អូនស្រីងក់ក្បាល ធូរទ្រូងដែលបានជួបមុខបងស្រី និងឃើញបងស្រីមានសុវត្ថិភាព ព្រោះបើឃើញបងស្រីកើតអី នាងមិនដឹងទេថាខ្លួនឯងនឹងរស់នៅបន្តយ៉ាងណា។

"ចាបង សាន់នី"

"តោះទៅ ធីណា"

"យើងទៅខាងណាទៅ"



Scanned by CamScanner

ពីរនាក់បងប្អូន ចាប់ដៃគ្នាជាប់ សាន់នី នាំប្អូនស្រី ដើរទៅផ្លូវខាងឆ្វេង ព្រោះផ្លូវនោះ មានទ្វារ សំដៅទៅជណ្តើរគេចអាសន្នរបស់អាគារ។

"កុំខ្លាច ធីណា"

"ចា ខ្ញុំនឹងព្យាយាមមិនខ្លាច"

ធីណា ដើរតាមការដឹកដៃរបស់បងស្រី។ ពេលមាន សាន់នី នៅជាមួយ នាងមានទំនុកចិត្តខ្លួនឯងនៅតែរស់។

**សាន់នី ងាកទៅឱបប្អូនស្រី បន្ទាប់ពីដឹកដៃគ្នាចៀសគេចៀសឯង ចេញ** ពីរោងរបាំស្រាតបានសម្រេច ប៉ុន្តែនៅមានមនុស្សជាច្រើនទៀត ដែលចេញមកមិនទាន់បាន ព្រោះនៅខាងក្នុង ព្រោះនៅចំកន្លែងដែលភ្លើងឆេះខ្លាំង ឡានទឹកកំពុងតែជួយពន្លត់ មិនឲ្យវាឆេះរាល ទៅក្រៅ រោងរបាំស្រាត ណាខាដៀ។

មានភាពចលាចលកើតឡើង រយៈពេលជាច្រើនម៉ោង ពីរនាក់បងប្អូន នៅតែនៅទីនោះ ដើម្បីមើលថា មានការខូចខាតកើតឡើងកម្រិតណា។

ទោះពួកនាងអាចមិនស្គាល់អ្នកដែលបាត់បង់ជីវិតនៅក្នុងនោះ តែវាក៏មានអារម្មណ៍សោកសង្រេង ដែលត្រូវជួបនឹងរឿងបែបនេះ។ វាឲ្យអារម្មណ៍រន្ធត់ ភ័យខ្លាចនិងស្រយុតស្រយង់ ប៉ុន្តែខណៈនោះ សាន់នី ក៏មានក្តីសង្ឃឹមថានាង





Scanned by CamScanner

និងប្អូនស្រី រួមទាំងមនុស្សជាច្រើនទៀត នៅ ណាខាដៀ អាចចេញមកបាន ដោយមានសេរីភាព និងមានឱកាស បានបញ្ជាការជីវិតខ្លួនឯងដោយផ្ទាល់។

"បង សាន់នី យើងរត់រួចហើយមែនទេ?"

ដូចយល់សប្តដែលនាងនិងបងស្រី ឆ្លងផុតវិនាទីនៃសេចក្តីស្លាប់ ចេញពី ណាខាដៀ បាន ចំហាយក្តៅនៅតែភាយ ទោះឈរនៅឆ្ងាយក៏ដោយ ប៉ុន្តែកម្តៅនៅក្នុងធាតុអាកាស ឆ្ងាយក៏ដោយ ហើយនៅជិតគ្នានោះ មានក្រុមមនុស្សដែលរត់ចេញមករួច ឈរយំដោយការសប្បាយចិត្ត ដែលមានឱកាសរស់រានមានជីវិត ខ្លះយំ ព្រោះអ្នកស្គាល់គ្នាមិនអាចចេញមកបាន ខ្លះក៏ដាក់បង្គុយចុះដោយគ្មានកម្លាំងកំហែង ពិបាកនឹងបរិយាយថា កំពុងគិតអី អ្នកខ្លះអាចមានខួរក្បាលទទេស្អាត ព្រោះស្ថិតនៅក្នុងស្ថានភាព ដែលទើបតែឆ្លងផុតពីសេចក្តីស្លាប់ ចាប់ពីពេលនេះទៅ ក្រៅពីនេះ ឡានរបស់ក្រុមសង្គ្រោះបន្ទាន់ និងឡានរបស់រដ្ឋាភិបាល មកពីអង្គភាពផ្សេងៗ រួមទាំងក្រុមការងារ កំពុងតែមមាញឹកនឹងការគ្រប់គ្រងស្ថានការណ៍។

"មែនហើយ"

"ខ្ញុំស្មានថាយើងយល់សប្ត"

ធីណា សម្លឹងមើល ណាខាដៀ ទីកន្លែងនោះ គ្មានការចងចាំដ៏ស្រស់



Scanned by CamScanner

ស្អាតទាំងអស់សម្រាប់នាង ប៉ុន្តែនាងមិនបានគិតថាវាមិនល្អ នាងនៅទីណាក៏បាន សុំត្រឹមមានបងស្រីនៅជាមួយ។

"ឯងមិនបានយល់សប្តទេ"

សាន់នី ច្របាច់ថ្ពាល់ប្អូនស្រី ធីណា ក៏ញញឹមពព្រាយ ដែលពួកនាងនៅតែសម្លឹងមើល ណាខាដៀ ប្អូនស្រីមើលដោយមិនបានគិតអី តែបងស្រីកំពុងគិត។

"ធីណា យើងទៅរកកន្លែងស្នាក់នៅសិនទៅ"

"ចាបងស្រី"

"តោះទៅ"

នាងប្រសព្វភ្នែកនឹងប្អូនស្រី មិនថាមានរឿងអ្វីកើតឡើងចាប់ពីពេលនេះនាងសម្រេចចិត្តរួចហើយថា ឆ្លៀតឱកាសនេះចេញពី ណាខាដៀ។

ក្រមុំទាំងពី ដឹកដៃគ្នាដើរចេញទៅ ដោយមិនងាកក្រោយ ទៅមើល ណាខាដៀ ទៀត ប៉ុន្តែគំនិតរបស់ សាន់នី នៅតែនឹកដល់មនុស្សម្នាក់ ដោយអត់មិនបាន បុរសដែលជាម្ចាស់រាងកាយរបស់នាង។ ប្លែកដែលនាងមានអារម្មណ៍ដង្ហោយរកគេ និងមានអារម្មណ៍ដូចចង់ដាច់ខ្យល់ ពេលគិតថានាងនិងគេ លែងបានជួបគ្នាទៀត។





Scanned by CamScanner

...

សាន់នី ចាយវាយប្រាក់សុទ្ធ ដែលមានជាប់ខ្លួនបន្តិចបន្តួច បើកបន្ទប់ស្នាក់នៅក្នុងសណ្ឋាគារតូចតាច ដើម្បីស្នាក់នៅបណ្ដោះអាសន្ន ហើយស្អែកនឹងទៅធនាគារដើម្បីដកប្រាក់ សម្រាប់ចាយវាយថ្ងៃបន្តបន្ទាប់។ ការពិតទៅនាងក៏លួចមានកូនចិត្តភ័យខ្លាចដែរ ព្រោះមិនធ្លាប់រស់នៅក្រៅរោងរបាំស្រោតណាខាដៀ ប៉ុន្តែគ្រប់យ៉ាងត្រូវតែមានលើកដំបូងជានិច្ច បើត្រូវត្រឡប់ទៅដើម្បីលក់ខ្លួននៅទៅនោះទៀត នាងសុខចិត្តទៅស្លាប់តាមយថាកម្ម។ ព្រោះវាគឺជាសេរីភាព ដ៏ក្រអូបផ្អែមដែលនាងទន្ទឹងរង់ចាំ។

នាងងូតទឹក ពាក់អាវឃ្លុំ និងបោកសម្លៀកបំពាក់ ដែលមានជាប់ខ្លួនមួយកំប្លេ ហាលនៅក្នុងបន្ទប់ទឹក។

"លំបាកបន្តិចហើយ ធីណា"

"មិនលំបាកទេខ្ញុំនៅបាន"

នាងបារម្ភពីប្អូនស្រី លុយសុទ្ធដែលមាន ធ្វើឲ្យនាង ជ្រើសរើសស្នាក់នៅក្នុងសណ្ឋាគារតូចតាច ដែលមានថ្លៃឈ្នួល មិនថ្លៃប៉ុន្មាន ឬដកប្រាក់ពីធនាគារក៏ពួកនាងត្រូវសន្សំសំចៃ ព្រោះពេលគិតដល់ការធ្វើការក្រៅ ណាខាដៀ ហើយនាងមិនដឹងទេថា ពីរនាក់បងប្អូន គួរធ្វើការងារអ្វី។



Scanned by CamScanner

សាន់នី មានរឿងឲ្យគិតច្រើនណាស់ដែលសំខាន់ជាងនោះ គឺនាងនិងប្អូនស្រី គ្មានការសិក្សា យ៉ៃរ៉ល និង អាដាំ ឲ្យរៀនសូត្រ ដោយឲ្យគ្រូទៅបង្រៀននៅ ណាខាដៀ ត្រឹមអានបាន សរសេរបាន តែមិនអាចយកទៅប្រើប្រាស់ក្នុងការដាក់ពាក្យធ្វើការងារបាន។

"ធីណា យើងត្រូវអត់ធ្មត់ ព្រោះបងមិននាំឯងទៅនៅ ណាខាដៀ ទៀតទេ"

"ចាបង សាន់នី ខ្ញុំនឹងអត់ធ្មត់"

ធីណា មិនគិតអីច្រើន នៅតែមានអារម្មណ៍ដដែល ត្រឹមបាននៅជាមួយបងស្រី នាងក៏ពេញចិត្តណាស់ទៅហើយ នាងមិនចង់នៅឆ្ងាយពី សាន់នី ការមានបងស្រីធ្វើឲ្យនាងមានសុវត្ថិភាព ប៉ុន្តែបងស្រី ក៏មានបទពិសោធន៍ រស់នៅក្រៅ ណាខាដៀ ស្មើសូន្យ។

ទោះខ្លាច ឬមិនច្បាស់ទេថាអាចយោងអាត្មារួចឬអត់ ក៏ សាន់នី ត្រូវតែរឹងមាំ និងម៉ត់ចត់ចំពោះការរស់នៅ ដើម្បីខ្លួនឯង និងប្អូនស្រី។ នាងញញឹមដាក់ធីណា ប្អូនស្រីក៏វារឡើងមកដេកលើគ្រែ ហើយបែរមុខទៅរកគ្រែរបស់បងស្រី។

"បង សាន់នី ទាក់ទងលោកបងថ្លៃទេ ?"

"លោកបងថ្លៃ ?"





Scanned by CamScanner

"ភ្លេចទៅ លោកបងថ្លៃហាមហៅថាលោកបងថ្លៃ"

"ឯងមានន័យពីអ្នកណា ?"

សាន់នី អាចដឹង ប៉ុន្តែត្រូវសួរឲ្យច្បាស់សិន ព្រោះមិនអ៊ីចឹង អាចមើលទៅដូចនាងគិតទៅដោយខ្លួនឯង ដោយនាងមិនចង់អាម៉ាស់មុខ មិនថានៅចំពោះមុខឬនៅក្រោយខ្នងលោក ម៉ារីសេ ម្នាក់នោះក៏ដោយ។

"លោក ម៉ារីសេ"

"ហេតុអីហៅគេបែបហ្នឹង ?"

"គឺគេជាស្វាមីរបស់បងហ្នឹងណ៎ា"

ហើយជាស្វាមីរបស់ ធីណា ដូចគ្នា...សាន់នី មានអារម្មណ៍ឈឺផៀបក្នុងទ្រូងនឹងគំនិតនេះ ប៉ុន្តែនាងមិនអាចជ្រើសរើសជីវិតឲ្យខ្លួនឯងបាន។

"គេមិនមែនជាស្វាមីបងទេ"

"តែបងមានស្ទីៗនឹងគេ"

"ឯងក៏ដឹង ស្រីរបាំនៅ ណាខាដៀ មានសម្រាប់ ធ្វើជារបស់កម្សាយអារម្មណ៍របស់មនុស្សប្រុស ប៉ុន្តែគ្មានតម្លៃដើម្បីធ្វើជាភរិយារបស់អ្នកណា"

"ត្រូវតែមានតម្លៃ បើបងគ្មានតម្លៃ គេក៏មិនជួយខ្ញុំដែរ"

"ជួយឬ ? ការធ្វើបែបនោះមិនហៅថាជួយទេ"



Scanned by CamScanner

គេអាត្មានិយមណាស់ធ្វើឲ្យ ធីណា ក្លាយជារបស់គេ ដើម្បីដួសដងយក សេចក្ដីសុខពីរាងកាយរបស់ប្អូនស្រីនាង ដូចដែលគេធ្វើដាក់នាង។

"គេជួយ"

"គេធ្វើឲ្យឯង មានមន្ទិល"

"មន្ទិលឬ?"

ធីណា ធ្វើមុខសង្ស័យ ដែលអាកប្បកិរិយារបស់ប្អូនស្រី ធ្វើឲ្យ សាន់នី នឹកភ្នក ឬថាអាចមានរឿងខ្លះនឹកស្មានមិនដល់។

"ធីណា បងសុំសួរបន្តិចបានទេ?"

"សួរបាន ខ្ញុំរីករាយឆ្លើយគ្រប់រឿង"

"លោក ម៉ារីស ធ្លាប់ទៅរកឯងនៅបន្ទប់មែនទេ ហើយគេធ្វើអីឯងខ្លះ?"

ធីណា កំពុងរៀបរៀងគំនិត ព្រោះគិតថាបងស្រីអាចត្រូវការ សួរនាំថា បងថ្លៃរបស់នាងម្នាក់នោះមើលថែនាងបានល្អឬអត់។

"តាមធម្មតាបើគេចូលទៅរកខ្ញុំ គេនឹងបណ្ដេញខ្ញុំចូលទៅក្នុងបន្ទប់ដេក ចំណែកគេចូលទៅក្នុងបន្ទប់អង្គុយលេង"

"គេធ្វើបែបនោះឬ?"



កើតមានអារម្មណ៍ម្យ៉ាង ដែលធ្វើឲ្យបេះដូងរបស់ សាន់នី ហោះហើរ។



Scanned by CamScanner

នាងបន្ទោសគេ ជេរគេនៅក្នុងចិត្តរាប់មិនអស់ ប៉ុន្តែគេបែជាមិនបានធ្វើរឿងអាក្រក់ដាក់ប្អូនស្រីរបស់នាង។

"ចា គេប្រាប់ថាហាមប្រាប់អ្នកណា ព្រោះអាចនឹងមានគ្រោះថ្នាក់ដល់ខ្ញុំ ខ្ញុំមិនយល់ ប៉ុន្តែខ្ញុំស្តាប់បង្គាប់គេ ព្រោះគេជាបងថ្លៃរបស់ខ្ញុំ ហើយគេក៏មិនធ្លាប់ធ្វើបាបខ្ញុំ"

"គេមិនធ្លាប់ប៉ះពាល់ឯងទេឬ?"

"ប៉ះពាល់បែបណា?"

"ដូចដែលឯងធ្លាប់ឃើញគេធ្វើដាក់បង"

ថ្ពាល់របស់ សាន់នី ឡើងក្រហម ប៉ុន្តែនាងត្រូវតែនិយាយឲ្យច្បាស់ ព្រោះប្អូនស្រី មិនទាន់យល់នោះទេថានាងមានន័យដល់អ្វី។

"មិនធ្លាប់ទេ!"

ជីណា ងើបអង្គុយ បើកភ្នែកធំៗមើលបងស្រី ខ្លាច សាន់នី យល់ច្រឡំនឹងខឹងនាង។

"មិនធ្លាប់ពិតមែនបងស្រី"

"បងជឿឯង"

"គេជួយខ្ញុំពិតមែន ចូលចិត្តធ្វើដូចធុញទ្រាន់ខ្ញុំទៀតផង អាងអីក៏



Scanned by CamScanner

បណ្ដោញខ្ញុំឲ្យទៅលេងឲ្យឆ្ងាយ ធ្វើដូចជាខ្ញុំជាកូនក្មេងយ៉ាងអ៊ីចឹង"

ធីណា មានអារម្មណ៍ចំពោះ សេត ដូចគេជាបងប្រុស គ្មានអារម្មណ៍ផ្អែមល្ហែមនៅក្នុងនោះ ព្រោះគេជាគូរស្នេហ៍របស់បងស្រី ... ធីណា គិតបែបហ្នឹងពិតមែន។

"បងយល់ច្រឡំឬ ?"

"កុំគិតច្រើនអី គ្មានអីទេ"

"យើងមិនបានខឹងគ្នាមែនទេ ?"

សាន់នី ដើរទៅដាក់បង្គុយលើគ្រែរបស់ប្អូនស្រី ធីណា ក៏ខិតមកឱបផ្អែកក្បាលនឹងស្មា។

"មិនបានខឹងទេ"

"ខ្ញុំខ្លាចបងខឹងខ្ញុំ"

"កុំគិតច្រើនអីក្មេងល្ងង់"

"បង សាន់នី"

"ហ៊ឺ ?"

"លោក ម៉ារីស នឹងតាមមកមែនទេ ?"

បើលោក ម៉ារីស មកតាមពួកនាងនឹងមានទីពឹងពាក់ ប៉ុន្តែបើគេមិនមក





Scanned by CamScanner

តាម ពួកនាងនឹងរស់នៅយ៉ាងណា។ សម្រាប់ ធីណា មនុស្សប្រុសគឺជាភេទរឹងមាំជាង ហើយបើមានបងថ្លៃនៅជាមួយ មានន័យថាបងស្រីរបស់នាងមានទីពឹងពាក់។

"មិនតាមមកទេ"

រវាងគេនិងនាង វាប្រហែលជាចប់ទៅហើយ។ សាន់នី មានអារម្មណ៍ក្តុកក្តួលម្តងទៀត ប៉ុន្តែត្រូវប្រឹងញញឹមដាក់ប្អូនស្រី។

"ហេតុអី ?"

"ធីណា ចាប់ពីពេលនេះទៅយើងមានគ្នាតែពីរនាក់បងប្អូនប៉ុណ្ណោះ តើបានទេ ?"

"បើខ្ញុំនិយាយពីគេ បងមិនសប្បាយចិត្តឬ ?"

"ចា"

"បើអីចឹងខ្ញុំមិននិយាយពីគេក៏បាន"

"អគុណ"

**សេត អធិប្បាយពីអារម្មណ៍ខ្លួនឯងមិនបានទេ បន្ទាប់ពីទទួលបាន**

ការរាយការណ៍រឿងរោងរបាំស្រាត ណាខាដៀ កន្លែងនោះត្រូវភ្លើងឆេះសល់តែ



Scanned by CamScanner

កម្ទេចផេះ មានទាំងមនុស្សដែលរត់រួច និងអ្នកដែលត្រូវភ្លើងឆេះ បាត់បង់ជីវិតនៅក្នុងនោះ។

"ចង្រៃយ៍!"

គេខាំធ្មេញក្រឹតៗ ដើរសំដៅទៅបន្ទប់ធ្វើការរបស់ខ្លួន។ សេត ត្រូវការនៅម្នាក់ឯង ដោយគ្មានអ្នកដទៃ ព្រោះត្រូវការនៅម្នាក់ឯង ដោយប្រាស់ចាកខ្សែភ្នែកអ្នកដទៃ។

គេដើរចូលទៅក្នុងបន្ទប់ រាំងតុធ្វើការ ទៅទាញកៅអី ដាក់បង្អុយចុះ ដោយមានអារម្មណ៍ឈឺឆៀប ត្រូវលើកដៃ សង្កត់ដើមទ្រូង ត្រង់បេះដូង។

"ម៉េចក៏ដៃញ័រ"

នេះជាលើកដំបូងដែលគិតថាមានអារម្មណ៍គ្រប់គ្រងខ្លួនឯងមិនបាន។

ប្រាប់មិនត្រូវទេថាគួរធ្វើអ្វី ខឹងសម្បា សើច ឬបង្ហាញអាការៈភ្ញាក់ផ្អើល។

"ឆ្កួតមែន!"

គេចេញបញ្ជាឲ្យមនុស្សរបស់ខ្លួនត្រួតពិនិត្យមើលឈ្មោះ អ្នកដែលបាត់បង់ជីវិតហើយយកមករាយការណ៍ប្រាប់ដោយមិនចង់ព្រមទទួលស្គាល់ទេ ថាខ្លួនឯង បន់ស្រន់ឲ្យ សាន់នី នៅរស់រានមានជីវិត។

"នាងគេចពីខ្ញុំងាយៗបែបនេះឬ?"



វាងាយពេកឬអត់ ?

គេនឹកដល់រូបភាពរបស់នាង ដែលរឹងទទឹងនិងឆ្នាសឆ្នើម ប៉ុន្តែនាងក៏មានភាពគួរឲ្យស្រឡាញ់ គួរឲ្យខ្នាញ់តាមបែបបទរបស់នាង នាងធ្វើឲ្យគេញញឹម ធ្វើឲ្យគេមានអារម្មណ៍ធូរស្រាលពីភាពតានតឹងដោយសារការងារ។

ចិញ្ចើមរបស់ សេត ជ្រួញចូលគ្នា គេមានអារម្មណ៍ដូចទទួលយកមិនបាន ដែលត្រូវនាងបោះបង់ ងាយៗបែបនេះ។

"ខ្ញុំទៅយឺតពេល"

សេត ធ្វើដំណើរទៅកោះចោរ ព្រោះត្រូវហៅ ហើយគេក៏មានការងារត្រូវធ្វើ មើលខុសត្រូវគ្រប់យ៉ាងនៅលើកោះ ជំនួសឪពុក គិតថា ពេលឪពុកត្រឡប់មកវិញ គេនឹងទៅចាត់ការរឿងរបស់ សាន់នី និង ធីណា ឲ្យរួចរាល់ ប៉ុន្តែគេដំណើរការយឺតមួយជំហាន។

"សាន់នី"

គេប្រាប់ខ្លួនឯងមិនបានទេថា គួរចាត់ការរឿងនេះយ៉ាងណា កែវភ្នែកមុតស្រួច គិតតែសម្លឹងមើលទៅក្រៅបង្អួច គេកើតគំនិតចង់បន់ស្រន់ អង្វរករ ឲ្យអ្វីក៏បាន នៅលើលោកនេះ សុំឲ្យជួយឃុំគ្រងនាងឲ្យមានជីវិតរស់រានបន្ត។

"ខ្ញុំមិនជឿទេថានាងស្លាប់"



Scanned by CamScanner

សាន់នី អាចរត់រួចក៏ថាបានព្រោះចំនួនអ្នកដែលរត់រួចច្រើនជាងអ្នកដែលបាត់បង់ជីវិត ហើយពេលនេះកំពុងតែមានការស៊ើបរកមូលហេតុនៃភ្លើងឆេះ ថាកើតឡើងពីអ្វី។

សេត អន្ទះអន្ទែង មិនចង់នៅទីនេះ ប៉ុន្តែគេត្រូវនៅ ទាល់តែឪពុកធ្វើដំណើរត្រឡប់មកវិញ នៅពីរថ្ងៃក្រោយ។

"ឆ្កួតមែន!"

ពាក្យជេរប្រទេចរបូតចេញពីមាត់របស់គេម្តងទៀត។ ពេលនេះខួរក្បាលរបស់គេស្រែស ព្រមទទួលស្គាល់ថាគិតអីមិនចេញ ក្រៅពីពាក្យជេរ ដើម្បីកម្សាយភាពក្តៅគគុកនៅក្នុងទ្រូង។

**សាន់នី ចូលធនាគារដើម្បីដកប្រាក់មួយចំនួន ដែលគណនាត្រួសៗ គឺ** គ្រប់គ្រាន់នឹងចាយវាយសម្រាប់មនុស្សពីរនាក់ ក្នុងរយៈពេល១ទៅ២ខែ ព្រោះការដាក់ប្រាក់ច្រើនតាមខ្លួនអាចធ្វើឲ្យនាងមានគ្រោះថ្នាក់។ ឲ្យប្អូនស្រីរង់ចាំនៅសណ្ឋាគារ ចំណែកខ្លួនឯងមកដកលុយនៅធនាគារហើយ ក៏ទៅច្រកស្នេហា ដើម្បីទៅមើលស្ថានការណ៍នៅទីនោះ ប៉ុន្តែទៅមិនទាន់ដល់ ណាខាដៀ ផង ក៏ត្រូវមនុស្សស្រីម្នាក់រត់ត្រហេបត្រហប មកពាំងមុខ និងចាប់ដៃជាប់ នាំចូលទៅ





Scanned by CamScanner

ពួន នៅកន្ទៀតជញ្ជាំង។

"យើងស្គាល់គ្នាឬ?"

"ខ្ញុំចាំបានថានាងជាស្រីរបាំនៅ ណាខាដៀ ដូចខ្ញុំដែរ"

ម្នាក់នោះស្គាល់នាង ប៉ុន្តែនាងមិនស្គាល់គេ។

"មានអីឬអត់?" នាងសួរ ពេលស្រីម្នាក់នោះមើលមកមិនដាក់ភ្នែក។

"នាងចង់ចូលទៅ ណាខាដៀ ឬ?"

"ចា ខ្ញុំចង់ចូលទៅមើលស្ថានការណ៍"

"ហាមទៅដាច់ខាត"

គេហាមប្រាមភ្លាម ការចូលទៅ ណាខាដៀ នៅពេលនេះជារឿងល្ងង់ខ្លៅខ្លាំងណាស់ ព្រោះមកទល់ពេលនេះមនុស្សជួជាតិ ដូច ឃៃរ៉ល និង អាដាំ នៅតែមិនចេះភ្ញាក់រឭក។

"មានអីកើតឡើង?"

"ឃៃរ៉ល និង អាដាំ នៅមានជីវិតរស់ ហើយពេលនេះបញ្ជាឲ្យមនុស្សតាមចាប់ស្រីរបាំដែលរត់រួច និងបុគ្គលិកនៅ ណាខាដៀ ឲ្យត្រឡប់ទៅទីនោះសិន ព្រោះទុកប្រើការ ខ្ញុំក៏ចូលទៅមើលដែរ ទើបប្រញាប់រត់ចេញមកវិញ"

សាន់នី រំភើប ដែលមាននមនុស្សជួយ ទាំងដែលមិនចាំបាច់ជួយក៏បាន។



Scanned by CamScanner

"ត្រូវតែរត់ឲ្យរួច ខ្ញុំក៏រត់ដែរ"

"អ្នកនាងចង់ទៅណា ?"

"ខ្ញុំមិនដឹងទេ"

ស្រីម្នាក់នោះឆ្លើយហើយ ក៏ធ្វើភ្នែកស្លឹៗ ដែលអាការៈបែបនោះធ្វើឲ្យសាន់នី ចង់ជួយដើម្បីជាការតបស្នង។

"អើក.."

នាងចេះដឹងរឿងអ្នកដទៃតើល្អឬអត់ ប៉ុន្តែបើមិនសួរ ប្រហែលមិនដឹងទេថា ម្នាក់នោះត្រូវការជំនួយឬអត់។

"មានការអី ?"

"អ្នកនាងមានបញ្ហាអីឬអត់ ?"

"គឺស្រដៀងនឹងនាងហ្នឹង មិនធ្លាប់រស់នៅក្រៅ ណាខាដៀ ប៉ុន្តែខ្ញុំត្រូវការសេរីភាព ទោះមានស្រីរបាំពេញចិត្តធ្វើការបែបនោះ ប៉ុន្តែខ្ញុំមិនពេញចិត្ត ខ្ញុំឃើញនាងម្តង ក៏ចាំបាន ព្រោះនាងស្អាតខ្លាំងណាស់ ហើយខ្សែភ្នែករបស់នាងបង្ហាញពីភាពសោកសៅដូចខ្ញុំដែរ ឬខ្ញុំគិតខុស"

"អ្នកនាងគិតត្រូវ"

"ហ្នឹងហើយ ពួកយើងមិនធ្លាប់រស់នៅក្រៅ ណាខាដៀ ខ្ញុំត្រូវតែប្រថុយ



តែខ្ញុំគ្មានប្រាក់ជាប់ខ្លួនទេ ប្រហែលត្រូវពនេចរសិន"

"ពនេចរឬ?"

"គឺទៅជារឿយ ទាល់តែមានផ្លូវចេញ តែខ្ញុំមិនព្រមឲ្យពួកនោះចាប់ទៅធ្វើការនៅក្នុងនរកទៀតទេ យ៉ៃវ៉ល និង អាដាំ ខូចខាតច្រើនណាស់ ហើយប្រហែលដំណើរការមុខជំនួញដដែល ដើម្បីប្រមូលយកប្រាក់មកវិញ តែខ្ញុំមិនព្រមឲ្យជីវិតរបស់ខ្ញុំ ត្រូវគ្រប់គ្រងដោយមនុស្សជួជាតិទៀតទេ ខ្ញុំសុខចិត្តអត់ឃ្លាន សុខចិត្តលំបាក និងទៅស្លាប់តាមយថាកម្មល្អជាង"

សំឡេងនោះ អាចមានភ័យខ្លាចខ្លះ តែពោរពេញទៅដោយភាពមួសមុតចង់នាំជីវិត ទៅឲ្យផុតពីនរកលោកិយ៍ ដែលមិនប្រាថ្នា។

"យើងត្រូវបែកគ្នា ជូនពរនាងមានសំណាងល្អ កុំត្រឡប់មកម្តុំនេះទៀត និងត្រូវចេញឲ្យឆ្ងាយពីទីនេះ ទៅឲ្យឆ្ងាយ ព្រោះមិនដឹងទេថា យ៉ៃវ៉ល និង អាដាំ មានសមត្ថភាពនៅក្នុងការតាមរកមនុស្សកម្រិតណា ជូនពរឲ្យនាងរត់រួច"

"ឈប់សិន"

សាន់នី មិនបានគិតច្រើន ពេលដែលលូកហោប៉ៅ យកប្រាក់មួយចំនួនមកហុចឲ្យ។

"យកទៅ"



Scanned by CamScanner

"មិនបានទេ នាងក៏ត្រូវរត់ដែរ"

"ខ្ញុំមានខ្លះ ខ្ញុំនឹងរត់ឲ្យរួច ហើយខ្ញុំក៏ចង់ឲ្យអ្នកនាងរត់រួចដែរ"

ស្រីម្នាក់នោះ មើលមកនាង គិតច្រើន ប្រហែលមិនចង់រំខាន ប៉ុន្តែនាងសម្រេចចិត្តញាត់លុយក្នុងហោប៉ៅអាវឲ្យ។

"យកទៅ យើងត្រូវតែរត់ឲ្យរួចដូចគ្នា ហើយថ្ងៃមួយបើយើងមានឱកាសបានជួបគ្នាទៀត បើអ្នកនាងមិនទទួល ការរត់គេចនឹងលំបាក ក្នុងពេលដែលគេចរួចហើយយើងតែងតែសង្ឃឹមថានឹងមានលទ្ធផលល្អបំផុត"

"បើខ្ញុំរត់រួច ខ្ញុំមិនភ្លេចគុណនាងទេ"

"ខ្ញុំក៏អីចឹងដែរ បើខ្ញុំរត់រួចខ្ញុំក៏មិនភ្លេចគុណរបស់អ្នកនាង"

"ជូនពរឲ្យនាងមានសំណាងល្អ"

"ចា ដូចគ្នា"

សាន់នី និងស្រីម្នាក់នោះ បំបែកផ្លូវគ្នា ដោយនាងប្រញាប់ត្រឡប់ទៅសណ្ឋាគារវិញ ដើម្បីដាក់ផែនការ នាំខ្លួនឯងនិងប្អូនស្រីចេញពីតំបន់គ្រោះថ្នាក់ឲ្យបានឆាប់បំផុត។







Scanned by CamScanner

បញ្ជីឈ្មោះអ្នកដែលបាត់បង់ជីវិតនៅ ណាខាដៀ តាមការត្រួតពិនិត្យ គ្មានឈ្មោះរបស់ សាន់នី និង ធីណា នៅក្នុងនោះ។

"នាងរត់រួចមែនទេ ?"

រឿងមួយដែលស្ទះនៅក្នុងចិត្តរបស់អ្នកកំលោះ បើមិនទាន់ជួបនាង គេប្រហែលមិនហ៊ានជានាទេថានាងនៅមានជីវិតរស់ ហើយនិងបញ្ជាមនុស្សរបស់ខ្លួន ឲ្យតាមរកនាង រកស្រីឆ្នាសដែលវីសតែគាំងបេះដូង ពេលដឹងថាភ្លើងឆេះ ណាខាដៀ។

"រាយការណ៍លម្អិតហើយ ?"

"បាទម្ចាស់តូច"

មនុស្សជំនិតឆ្លើយបញ្ជាក់ របាយការណ៍នៅក្នុងដៃរបស់ សេត ជាឯកសារមួយសំណុំធំ ដែលបញ្ជាក់ពីអត្តសញ្ញាណរបស់អ្នកដែលបាត់បង់ជីវិតនៅ ណាខាដៀ។

"ចេញទៅចុះ"

"បាទម្ចាស់តូច"

អ្នកកំលោះ ត្រូវការពេលវេលា អានឯកសារឲ្យលម្អិតម្តងទៀត អាចមានការក្លែងបន្លំរឿងបុគ្គលក៏ថាបាន គេមានការសង្ស័យជាច្រើន ហើយវានៅ



Scanned by CamScanner

តែជាមន្ទិលនៅក្នុងចិត្ត ទាល់តែបានជួប សាន់នី នោះឯង។

"ស្រីឆ្នាសនាងត្រូវតែមិនអី"

គេមិនដឹងទេថាកំពុងលួងលោមចិត្តខ្លួនឯងឬអត់ ប៉ុន្តែគេជ្រើសរើសជឿលើរបាយការណ៍ ហើយគំនិតដែលថានាងបានលាចាកលោកនេះទៅហើយ គេមិនត្រូវការគិតគូរដល់វាទៀត។

"ហើយនាងបាត់ទៅណា?"

វាគឺជាសំណួរ ដែលគេត្រូវរកចម្លើយ។ គេមិនបានត្រួតពិនិត្យទេថា ខ្លួនឯងផ្តោតសំខាន់ទៅលើមនុស្សស្រី ដែលមានឋានៈត្រឹមតែជាស្រីនៅលើគ្រែបណ្តោះអាសន្នរបស់ខ្លួនខ្លាំងជាពិសេស។

"មនុស្សស្រីដូចនាង បើទៅបាត់ ជីវិតរបស់ខ្ញុំ នឹងបាត់រស្មី"

គេនឹងតាមរកនាងឲ្យឃើញ ដើម្បីចាប់នាងឲ្យអង្គុយលើភ្លៅ ហើយសម្លឹងមើលមុខស្រស់ស្អាត ពោរពេញទៅដោយអារម្មណ៍របស់នាងឲ្យឆ្អែត។

"យើងត្រូវតែបានជួបគ្នាទៀត"

គេប្រាប់ខ្លួនឯង ដោយទឹកមុខមាំ ប៉ុន្តែដូចជាការបង្កើតទំនុកចិត្តឲ្យខ្លួនឯងដែរ ភ្នែកសម្លឹងមើលទៅក្រៅបង្អួច។ បើរកនាងមិនឃើញ គេមិនលុបចោលបញ្ហាឲ្យស្វែងរកដាច់ខាត។





Scanned by CamScanner

"ហេតុអីយើងត្រូវធ្វើខ្លួនគួរឲ្យធុញទ្រាន់បែបនេះ"

សេត រអ៊ូរទាំដាក់ខ្លួនឯង ពេលនឹកឃើញថា គេចេះតែគិតដល់រឿងរបស់សាន់នី ដល់ថ្នាក់អាចនិយាយបានថា ដេកមិនលក់បក់មិនល្ហើយ បើសាច់ញាតិជិតស្និតដឹងរឿងរបស់គេ នឹងត្រូវយកមកនិយាយនៅក្នុងរង់សន្ទនាពេលណាត់ជួបគ្នា ដល់ថ្នាក់គេអង្គុយមិនជាប់នឹងកៅអីជាមិនខាន ប៉ុន្តែណ្ហើយចុះ ទោះគេធ្វើខ្លួនគួរឲ្យធុញទ្រាន់យ៉ាងណា ក៏គេគឺជាមនុស្សតែម្នាក់ដែលដឹងរឿងនេះ ហើយគេមិនចែកចាយឲ្យអ្នកណាដឹង។

# ៨

## ផែនការរត់គេច

**ពេលនេះ សាន់នី រកផ្លូវចេញបានហើយ ដោយការសួរនាំរកការងារធ្វើ** នៅក្រុងផ្សេង ដែលមិនមែនក្រុងហ៊ីតវែល ពីបុគ្គលិកសណ្ឋាគារ ហើយក៏ត្រូវណែនាំឱ្យទៅធ្វើការនៅកោះ ស៊ី រ៉ូវើ ដែលឈ្មោះកោះ ធ្វើឱ្យនាងកាន់តែនឹកម្នាក់នោះ អ្នកដែលនាងមិនចង់ព្រមទទួលស្គាល់ថានឹកគេ។

នាងត្រូវការលុបគេចេញពីបេះដូង ទោះធ្វើមិនទាន់បាន ប៉ុន្តែនាងបានសម្រេចចិត្តរួចហើយថាធ្វើដំណើរទៅកោះ ស៊ី រ៉ូវើ ដោយហេតុផលដែលគិតថាសក្តិសម។ ការនៅលើកោះ នឹងធ្វើឱ្យពួកនាងគេចផុតពីខ្សែភ្នែករបស់ ឃៃរ៉ល និង អាដាំ ព្រោះការឡើងទៅលើកោះនោះ មិនមែនជារឿងងាយទេ បើម្ចាស់គេមិនអនុញ្ញាត។

ការរត់គេចពី ឃៃរ៉ល និង អាដាំ នៅលើដីគោក ជានាសុវត្ថិភាពរបស់ពួកនាងបានតិចជាងនៅលើកោះ ស៊ី រ៉ូវើ ហើយហេតុផលមួយទៀតរបស់នាង





Scanned by CamScanner

គឺអាចបានជួបមនុស្សដែលនាងកម្ចាត់គេចេញពីការនឹករឭកមិនបាន។

*ខ្ញុំឬចង់ជួបមនុស្សត្រេកកាមបែបនោះ?*

នាងគួរសប្បាយចិត្តទើបត្រូវ ដែលអាចគេចផុតពីគេបាន។ គេអាចគិតថានាងស្លាប់បាត់ទៅហើយ ដែលវាជារឿងល្អ ព្រោះនាងមិនចាំបាច់បម្រើគេបែបនោះទៀត។

សាន់នី លើកដៃស្ទាបទ្រូង ពេលមានអារម្មណ៍ឈឺឆៀបនៅក្នុងនោះទៀតហើយ។

"បង សាន់នី"

សំឡេងរបស់ប្អូនស្រី ធ្វើឱ្យនាងភ្ញាក់ស្មារតី ហើយដើម្បីការពារខ្លួនឯង នាងនិងប្អូនស្រីបានតែងខ្លួនជាមនុស្សប្រុស ដោយសម្លៀកបំពាក់ស៊ុលគយុលអាវសឺមី ខោខូវប៊យ សក់ត្រូវលាក់ទុកក្រោមសក់ក្លែងក្លាយម៉ូតបុរស។

នាងគួរកាត់សក់ ដើម្បីឱ្យសមដូចការពិត តែសម្ដីរបស់ ម៉ារីស ដែលសរសើរសក់របស់នាង ម្រាមដៃវែងដែលចូលចិត្តម្ចូរសក់ទន់ល្មើយ ទើបចិត្តមិនដាច់កាត់វាចោល។

បុគ្គលិកសណ្ឋាគារណែនាំឱ្យចំណាយប្រាក់ ដល់អ្នកជ្រើសរើសកម្មករ នាងក៏ធ្វើតាម ព្រោះពួកនោះមិនចាប់អារម្មណ៍រឿងប្រវត្តិរូប មិនខ្វល់ពីការបន្លំ



Scanned by CamScanner

ខ្លួនរបស់នាង និងយល់ថានាងជាមនុស្សប្រុសមុខស្រស់ ម្យ៉ាងទៀតពួកគេមានការងារធ្វើច្រើនណាស់ ពេលបានប្រាក់ហើយក៏ចប់ និងដើម្បីសុវត្ថិភាព នាងសុខចិត្តចំណាយថ្លៃបន្ទប់ស្នាក់នៅបន្ថែម ខណៈពេលធ្វើដំណើរ ដើម្បីបានបន្ទប់សម្រាកផ្ទាល់ខ្លួន។

បេះដូងរបស់នាងលោតញាប់ តែប្រាក់ធ្វើឱ្យរឿងគ្រប់យ៉ាងមានភាពងាយស្រួល។ ពួកនាងនាំគ្នាទៅបន្ទប់សម្រាក ហើយសម្រេចចិត្តថានឹងនៅក្នុងនោះ បើមិនចាំបាច់គឺមិនចេញទៅណាដាច់ខាត ព្រោះពួកនាងត្រូវប្រយ័ត្នខ្លួនឱ្យបានខ្លាំងបំផុត ក្រៅពីនេះ នាងក៏បានតបស្នងបុគ្គលិកសណ្ឋាគារម្នាក់នោះដោយប្រាក់មួយចំនួន។

"យើងរត់រួចមែនទេ បង សាន់នី?"

"ត្រូវតែរួច"

សាន់នី លើកទឹកចិត្តប្អូនស្រី។ មកដល់ដំណាក់កាលនេះទៅហើយ គឺត្រូវតែដើរទៅមុខឱ្យបានសម្រេច នៅលើកោះចោរនោះ នាងត្រៀមចិត្តធ្វើការគ្រប់យ៉ាងឱ្យដូចបុរស ទោះរាងកាយមិនអំណោយទានក៏ដោយ ប៉ុន្តែដើម្បីយោងអាត្មាឱ្យរស់ នាងត្រូវតែអត់ធ្មត់ និងធ្វើឱ្យបាន។

ត្រឹមជាមនុស្សស្រីក៏ទាក់ទាញភ្នែកណាស់ទៅហើយ ហើយនាងក៏មិន





Scanned by CamScanner

ល្ងង់ ដល់ថ្នាក់មិនដឹងថានាង និងប្អូនស្រីមានមុខមាត់ស្អាតយ៉ាងណា។ នាងមិនត្រូវការឱ្យបុរសមករញ៉េរញ៉ៃ ទើបការបន្លំខ្លួនជាមនុស្សប្រុស អាចឱ្យពីរនាក់បងប្អូនពួកនាងអាចគេចខ្លួនបានស្រួល ហើយនាងនឹងទៅសម្ងំនៅកោះចោរពីរបីខែ តាមកិច្ចសន្យាជួលបណ្ដោះអាសន្ន។

កោះចោរត្រូវការមនុស្សធ្វើការ បីខែដែលនាងត្រូវលាក់ខ្លួននៅទីនោះ ហើយចាំរកដំណោះស្រាយថ្មី ឬមិនអ៊ីចឹង នាងអាចរកវិធីចុះឈ្មោះធ្វើការនៅលើនោះនោះរយៈពេលយូរជាងនោះ វាមិនទាន់មានអ្វីទៀងទាត់ ហើយនាងត្រូវគិតដល់រឿងបច្ចុប្បន្នជាងរឿងអនាគត។

"យើងត្រូវតែធ្វើបាន ជីណា"

"ចាំ ខ្ញុំស្ដាប់បង្គាប់បង"

"ពេលនេះត្រូវបង្វឹកធ្វើសំឡេងដូចមនុស្សប្រុសឱ្យបានល្អបំផុត"

ក្រមុំពីរនាក់បងប្អូនបង្វឹកធ្វើសំឡេង ឱ្យដូចមនុស្សប្រុសជារៀងរាល់ថ្ងៃឱ្យវាគ្រលរជាងសំឡេងពិត។

"ខ្ញុំគិតហើយក៏អស់សំណើច សំឡេងរបស់យើងមិនធម្មជាតិទេ"

"តែយើងត្រូវធ្វើ មែនទេ ?"

"មែន"

នេះជារឿងអស់សំណើចតិចតួចនៅក្នុងជីវិតដែលកំពុងតានតឹង តែបើពួកនាងជាប់ការជ្រើសរើស មិនត្រូវបញ្ជូនចេញពីកោះចោរ នាងនឹងធូរទ្រូង។

"ខ្ញុំបង្ខឹកពេលណា អស់សំណើចពេលនោះ"

"អត់ធ្មត់បន្តិចទៅ"

"បងមិនបាច់បារម្ភទេ ខ្ញុំធ្វើបាន"

ធីណា និយាយឲ្យបងស្រីសប្បាយចិត្ត។ បងស្រីបារម្ភពីនាងណាស់ នាងដឹងច្បាស់ ហើយនាងមិនចង់ធ្វើខ្លួនជាបន្ទុកឲ្យបងស្រីពេកដែរ។

"បងត្រូវតែបារម្ភពីឯងហើយ"

"ខ្ញុំស្តាប់សម្តីបង មិនធ្វើជាបន្ទុកឲ្យបងទេ ខ្ញុំសន្យា"

"បងមិនធ្លាប់គិតទេថា ឯងជាបន្ទុក"

ធីណា ចាប់ដៃរបស់បងស្រីមកផ្អឹបនឹងថ្ពាល់ ម្មិកម៉ូក់ ហើយញញឹមពព្រាយដាក់ ដែលការញញឹមបែបនេះធ្វើឲ្យនាងមើលទៅដូចកំលោះតូច។

"ខ្ញុំស្រឡាញ់បងណា"

"បងដឹង"

"ចុះទៅ! ចុះទៅ" បញ្ជារបស់អ្នកគ្រប់គ្រងនៅលើទូកបន្លឺឡើង។





Scanned by CamScanner

សាន់នី និង ធីណា មានកាបូបធំជាប់ខ្លួនម្នាក់មួយប៉ុណ្ណោះ ដើម្បីភាពងាយស្រួលក្នុងការធ្វើដំណើរ ដែលនៅក្នុងនោះដាក់តែរបស់ប្រើប្រាស់ចាំបាច់ក្នុងការរស់នៅ សម្លៀកបំពាក់ពីរបីកំប្លេ មានសក់ក្លែងក្លាយ ទុកសាគួរម្នាក់បី។

"លឿន! លឿន! ដើរលឿនឡើងៗ"

សំឡេងស្រែកនោះបន្លឺឡើងដើម្បីគ្រប់គ្នាបានឮច្បាស់និងដើរតាមផ្លូវដែលមានបុរសមាឌដំបងឈរប្រចាំការ។

"លឿនឡើង! លឿនឡើង!"

"តឿនឡើងចង់ព័ន្ធជើងទៅហើយ"

ធីណា អត់រអ៊ូរទាំមិនបាន ព្រោះនាងត្រូវប្រឹងដើរផង ស្ពាយកាបូបធ្ងន់ផងនៅក្នុងគំនិតរបស់នាង តែមនុស្សប្រុសមាឌធំអស់នោះគិតតែពីស្រែកទៅកើត។

"និយាយស្អីអាក្ដិប"

ធីណា ត្រូវឃាត់មិនឲ្យចុះពីទូក សាន់នី ងាកទៅមើល និងចង់ទៅរកប្អូនស្រីក៏មិនបាន ព្រោះមានអ្នកតឿនឲ្យចុះទៅមុន តែនាងរារែក ខ្វល់ខ្វាយពីសុវត្ថិភាពរបស់ប្អូនស្រី។

"អត់មានទេ"

ធីណា ប្រញាប់ឆ្លើយប្រាប់និងរកមើលបងស្រី ហើយដើរបន្ត ប៉ុន្តែត្រូវម្នាក់នោះចាប់លើកដៃបាំង ថែមទាំងស្តីឲ្យទៀត។

"ច្បាស់ហើយ ?"

មនុស្សប្រុសមាឌដំបងមិនព្រមដោះលែង ដែលធ្វើឲ្យនាងខ្លាចឡើងញ័រខ្លួន ដៀងមើលគេ តែកែវភ្នែកមូលក្លុំស្រទន់របស់នាងធ្វើឲ្យបុរសមុខកាចចងចិញ្ចើម។

"ច្បាស់...ច្បាស់ហើយ"

"ហើយម៉េចចាំសំឡេងញ័រ"

"ខ្ញុំខ្លាច"

នាងឆ្លើយប្រាប់តាមត្រង់ មនុស្សកាចមិននិយាយអីទៀត ក្រៅពីងក់ក្បាលឲ្យនាងចុះពីទូក ទើបនាងប្រញាប់ដើរឈ្ងោកមុខទៅរកបងស្រី។

"ធីណា"

"គួរឲ្យខ្លាចដល់ហើយបង សាន់នី"

ធីណា ស្រវាចាប់ដៃបងស្រី ហើយដឹកដៃគ្នាដើរតាមគេតាមឯង ដោយមិនរអ៊ូរទាំទៀត ទោះថ្ងង់នឹងសំឡេងស្រែកប្រណាំងគ្នា។

"លឿនឡើង! លឿនឡើង! ដើរឲ្យលឿនវើយ!"





Scanned by CamScanner

...

"លោក សេត"

អ្នកនៅក្រោមការបង្គាប់បញ្ជានៅលើកោះចោរ ខិនគំនាប់ធ្វើការគោរព ម្ចាស់តូចនៃកម្រងកោះ ស៊ី រ៉ូវើ។ បើជាមនុស្សជំនិត នឹងត្រូវអនុញ្ញាតឲ្យហៅ សេត ថា ម្ចាស់តូច តែបើជាអ្នកដទៃ នឹងហៅគេថា លោក សេត។

សេត មកទីនេះដើម្បីជ្រើសរើសកម្មករឡើងកោះចោរដោយផ្ទាល់។ នៅលើកោះ គ្រប់គ្នាត្រូវធ្វើការ មានទាំងអ្នកធ្វើការឲ្យអ្នកគ្រប់គ្រងកោះ និងអ្នកភូមិដែលធ្វើការងារនេសាទ កសិកម្ម ដែលជាអាជីពសំខាន់របស់អ្នកនៅលើកោះ។ តាមពិតទៅនៅលើកោះ ស៊ី រ៉ូវើ គ្មានអ្នកណាប្រកបរបរជាចោរទេ ប៉ុន្តែតាមរយៈរឿងដំណាលដ៏យូរយាររបស់កោះ កាលសម័យដែលចោរសមុទ្រជាអ្នកគ្រប់គ្រងកោះនោះ ទើបមនុស្សភាគច្រើនហៅកម្រងកោះ ស៊ី រ៉ូវើ ថា កោះចោរ។

នៅលើទូកនេះគឺអ្នកដែលមកចុះឈ្មោះធ្វើការលើកោះចោរ ដែលតាមធម្មតា កោះចោររើសកម្មករជារយៈ ទាំងបែបបណ្ដោះអាសន្ន ជាការងាររយៈពេលខ្លី ឬការធ្វើកិច្ចសន្យាធ្វើការងាររយៈពេលវែង បើត្រូវការស្នាក់អាស្រ័យនៅលើកោះចោរ គឺត្រូវដាក់លិខិតស្នើសុំធ្វើជាប្រជាជនដែលមានដំណាក់កាលស្មុគស្មាញ។



Scanned by CamScanner

"ចុះពីទូកអស់ហើយឬនៅ?"

"អស់ហើយលោក សេត"

ម្ចាស់តូចនៃកោះចោរ ស្លៀកតែខោខូវប៊ិយមួយប៉ុណ្ណោះ បង្ហាញរាងកាយល្វែងលើ ដើរទៅទីធ្លាធំទូលាយដែលកម្មករកំពុងតម្រង់ជួរ។ លើកនេះគេត្រូវការកម្មករដើម្បីជួសជុលប្រព័ន្ធទឹកនៅលើកោះចោររយៈពេលបីខែ ចំនួនមួយរយនាក់ និងធ្វើការមិនពេញម៉ោងចំនួនមួយរយនាក់ទៀត។

មានមនុស្សឡើងទូកចំនួនពីររយម្ភៃនាក់ ចំនួនម្ភៃនាក់ដែលលើសនោះបើមានគុណសម្បត្តិត្រូវតាមតម្រូវការ សេត នឹងទទួលយក ព្រោះមានការងារច្រើនទៀតដែលអាចបញ្ចូលកម្មករមួយចំនួនបាន។

អ្នកកំលោះដើរកាត់កម្មករដែលឈរតម្រង់ជួរមួយជួរចំនួនដប់នាក់ ទៅឈរនៅចំពោះមុខពួកគេហើយបុរសមាឌដំបងនៅលើកោះ ដែលមានតួនាទីមើលការខុសត្រូវនានាឱនគំនាប់ម្ចាស់តូច។

"គ្រីស!"

សំឡេងនោះធ្វើឲ្យ សាន់នី និង ជីណា ភ្ញាក់ព្រើត ព្រោះវាប្រហែលៗណាស់ ទើបលួចមើលម្ចាស់សំឡេង ហើយ សាន់នី ក៏បានដឹងពីកម្លាំងប្របាច់ដៃរបស់ប្អូនស្រី។





Scanned by CamScanner

"លោកបងថ្លៃ បង សាន់នី"

"នៅឲ្យស្ងៀម ធីណា"

"យើងមិនប្រាប់គេទេឬថា យើងនៅទីនេះ"

"មិនបានទេ ធីណា យើងត្រូវតែមិនស្គាល់គេ ព្រោះយើងជាមនុស្សប្រុស យល់ទេ"

"យល់ហើយ បង សាន់នី"

ពីរនាក់បងប្អូនខ្សឹបខ្សៀវគ្នា ប្រយ័ត្នសំឡេងឲ្យតិចបំផុត។

"ដើម្បីសុវត្ថិភាព ហាមឆ្លោយដាច់ខាត ធីណា"

"ចាំ បង សាន់នី"

ធីណា ឆ្លើយប្រាប់បងស្រី ហើយលបមើលទៅ សេត និងបុរសដែលត្រូវហៅឈ្មោះ ក៏ដើរទៅរកគេ តាមពិតបុរសមាឌធំដែលស្ដីឲ្យនាងមុនចុះពីទូកឈ្មោះ គ្រីស នេះឯង។

"ម្ចាស់តូច"

ការគោរពរបស់ គ្រីស និងអ្នកឯទៀត ដែលមានចំពោះ សេត អាចដឹងថាគេត្រូវតែមានអំណាចគួរសមនៅលើកោះនេះនិងប្រហែលបានប្រាក់ខែច្រើនមិនអីចឹង គេម៉េចនឹងមានប្រាក់ច្រើនទិញខ្លួននាង និង ប្អូនស្រី។



Scanned by CamScanner

"រើសខ្លះហើយនៅ?"

"នៅទេ ម្ចាស់តូច"

បន្ទាប់ពីចូលជួររួចរាល់ហើយ ទើបធ្វើការជ្រើសរើស ដើម្បីមើលអ្នកដែលសក្តិសមនឹងតំណែង ហើយដំណាក់កាលបន្ទាប់ពីនោះគឺពិនិត្យរាងកាយ។

"មានបញ្ហាខ្លះ"

"ស្អី?"

គ្រីស លោមុខទៅខ្សឹបប្រាប់ ម្ចាស់តូចនៃកោះចោរក៏ងាកទៅមើលមនុស្សដែលកំពុងតម្រង់ជួរ។

"បង សាន់នី គេមើលយើងឬអត់?"

"ប្រហែលមិនមែនទេ"

គេមើលមកពួកនាងម្តេចបានទៅ បើគេមិនទាំងដឹងថាពួកនាងឡើងកោះចោរ។

"ឈ្មោកមុខ ធីណា"

"ចាំ"

នាងមិនត្រូវការឲ្យខ្លួនឯងក្លាយជាចំណុចគួរឲ្យចាប់អារម្មណ៍ ប៉ុន្តែការធ្វើបែបនេះបែរជាកាន់តែទាក់ទាញខ្សែភ្នែករបស់ សេត ឲ្យមើលមកដោយការ



សង្ស័យ។

"ខ្ញុំនឹងត្រួតពិនិត្យម្តងទៀត"

"បាទ ម្ចាស់តូច"

"ឯងរើសយកមួយចំនួនទៅជួសជុលប្រព័ន្ធទឹកមុនទៅ"

"បាទ ម្ចាស់តូច"

គ្រីស ឱនគំនាប់ទទួលបញ្ជា ហើយជ្រើសរើសយកមនុស្សប្រុសដែលមានរូបរាងធំមាឌមាំក្នុងចំណោមកម្មករថ្មីទៅធ្វើការ។

"ឈ្មោះអី ?"

សំឡេង និងការមើលមកដោយភាពសោះកក្រោះរបស់ សេត ធ្វើឲ្យសាន់នី មានអារម្មណ៍ព្រឺរងា តែក៏គិតថាគេប្រហែលជាចាំមិនបាន ព្រោះក្រៅពីពាក់សក់ខ្លីក្លែងក្លាយហើយពួកនាងក៏ពាក់ពុកមាត់ដែរ ហើយរឿងតែមួយគត់ដែលនាងគិតនៅពេលនេះគឺខ្លាចគេមកយកពួកនាងធ្វើការ។

អ្នកឯទៀតត្រូវតម្រង់ជួរពិនិត្យរាងកាយ មានតែនាងនិងប្អូនស្រីដែលត្រូវចាប់បំបែក។

នាងចង្អុលស្លាកឈ្មោះជាប់នឹងអាវរបស់ខ្លួនឯងដែលអ្នកគ្រប់គ្រងទុក



Scanned by CamScanner

សរសេរឲ្យ ហើយចែកចាយឲ្យខ្ទាស់នឹងអាវ។

"ខ្ញុំចង់ឲ្យឆ្លើយ"

សេត អង្គុយលើកៅអីដែលកូនចៅលើកមកឲ្យ មើលអ្នកដែលចង្អុលស្លាកឈ្មោះខ្លួនឯង តែគេត្រូវការឮសំឡេងរបស់អ្នកដែលគេសួរ។

"ដាស៊ី និង ខាស៊ី"

សាន់នី ជាអ្នកឆ្លើយដោយធ្វើសំឡេងឲ្យគ្រលរ ខណៈដែល សេត ទម្លាក់ភ្នែកចុះ លាក់ភាពកំណាចនៅក្នុងនោះ។ មុននេះ គ្រីស សង្ស័យថាពីរនាក់បងប្អូននោះមិនមែនជាមនុស្សប្រុស ប៉ុន្តែគេដឹងច្រើនជាងនោះ ព្រោះគេចាំបានទាំង សាន់នី និង ធីណា។

ភាពរីករាយដែលមាន ធ្វើឲ្យគេរម្សាយកំហឹងដែលនាងបោកប្រាស់គេ។ អតីតស្រីកំណាន់មុខស្រស់ដូចផ្កាទើបរីក ម៉េចក៏ហ៊ានលេងសើចដាក់ម្ចាស់តូចនៃកោះចោរ ដោយការបន្លំខ្លួនឡើងមកលើកោះអីចឹងឬ ធ្លាប់មានអ្នកណាប្រាប់នាងឬអត់មុខស្រស់ស្រទន់យ៉ាងនេះ បន្លំខ្លួនជាមនុស្សប្រុស តើអ្នកណាគេជឿទៅ។

ម្ចាស់តូចនៃកោះចោរដែលទាំងសង្ហា មាន និងឆ្លាច ដូចគេ មានឬមិនដឹងថាអ្នកណាស្រី អ្នកណាប្រុស តែនាងដើរចូលមកឲ្យគេចាប់ខ្លួនក៏ល្អហើយ





Scanned by CamScanner

គេនឹងសើរើឋានៈរបស់នាង ចាត់ចែងឲ្យនៅក្បែរ ហើយឆ្លៀតឱកាសចាប់សង្កត់លើគ្រែឲ្យឆ្អែត ដើម្បីប៉ះប៉ូវការដង្ហោយរកនិងការគិតច្រើនរឿងរបស់នាង។

"ដាស៊ី និង ខាស៊ី គ្រីស នឹងរកការងារឲ្យឯងធ្វើ"

"ទៅជាមួយម្នាក់នោះ"

"ហេតុអី ?"

ធីណា រិះតែលាក់អាការៈមិនជិត ហើយព្រោះមានអារម្មណ៍ចំពោះគេដូចបងប្រុស ទើបមើលទៅគេដោយខ្សែភ្នែកដូចដែលធ្លាប់មើល។

"គេគួរឲ្យខ្លាច មាឌធំ ហើយកាចទៀត"

សេត រិះតែផ្ទុះសំណើច។ ក្មេងនេះល្ងីល្ងើយ៉ាងណាក៏នៅតែល្ងីល្ងើយ៉ាងនោះ ស្មើដើមស្មើចុង សំណាងប៉ុនណាហើយដែលពីរនាក់បងប្អូនជួបគេ មិនមែនអ្នកដទៃ មុខមាត់ស្រស់ស្អាតយ៉ាងនេះ បើមានអ្នកណាដឹងថាពួកនាងជាមនុស្សស្រីបន្លំខ្លួន អាចនឹងត្រូវធ្វើបាបក៏ថាបាន។

"គ្រីស ឯងកុំកាចពេក"

"បាទ ម្ចាស់តូច"

"បានឮហើយ ខាស៊ី"

សេត និយាយដោយប្រឹងទប់សំណើចពេញពោះ។ គេចង់ញីសក់ក្បាល



Scanned by CamScanner

របស់ ធីណា ថែមដោយការខោកក្បាល ក្មេងល្ងីល្ងើមួយក្រញរពីរ។ ព្រោះចរិត

បែបនេះឯង ទើបបងស្រីបារម្ភពីនាងម្ល៉េះ។

"បានឮហើយ តែមិនសូវទុកចិត្ត"

"ទៅ ឬ មិនទៅ?"

គ្រីស ត្បកសួរ ធ្វើឲ្យ ធីណា ភ្ញាក់ព្រើត ត្រសុលទៅឈរបៀនបងស្រីនិង

ស្រវាចាប់ដៃជាប់ ភ្នែកក៏លួចមើលដោយការភ័យខ្លាច។

"យើងទៅជាមួយគ្នាមិនបានឬ?"

"មិនបាន"

ម្ដងនេះ សាន់នី ជាអ្នកសួរ សេត ក៏បដិសេធភ្លាម ទើបធ្វើឲ្យនាងគ្មាន

ជម្រើសច្រើន ឬប្រាប់ថានាងគ្មានជម្រើសក៏ថាបាន។

"ឡើងមកធ្វើការនៅលើកោះគឺត្រូវធ្វើតាមតួនាទី រើសការងារមិនបានទេ

ឬអ្នកទទួលចុះឈ្មោះ មិនបានប្រាប់"

"ប្រាប់"

"បើដឹងហើយ សួរធ្វើអី"

"ប្អូនរបស់ខ្ញុំមិនធ្លាប់នៅឆ្ងាយពីខ្ញុំទេ"

"ម៉ោធ្វើការ ឬមកលម្ហែ?"





Scanned by CamScanner

"ម៉ោធ្វើការ"

"បើអីចឹង គួរដឹងថាត្រូវអនុវត្តតាមបញ្ជារបស់ខ្ញុំ បើធ្វើមិនបាន ត្រូវចេញពីកោះ"

"ធ្វើបាន"

ធីណា ឆ្លើយប្រាប់ភ្លាម ព្រោះបើពួកនាងត្រូវបញ្ជូនចេញពីកោះ គឺនឹងត្រូវរត់គេចពី ឃែរ៉លេ និង អាដាំ ទៀត នាងមិនចង់ធ្វើជាបន្ទុកឲ្យបងស្រីទេ។

"ខ្ញុំទៅឥឡូវនេះ"

"ទៅៗ"

ធីណា ចង់ប្រាប់ សេត ណាស់ថា ពួកនាងជាអ្នកណា។ គេចាំពួកនាងមិនបានមែនឬ អីចឹងបញ្ជាក់ថាការបន្លំខ្លួនរបស់ពួកនាង ធ្វើបានល្អណាស់។

"បងមិនបាច់បារម្ភទេ"

ពេលឃើញ សាន់នី លើកដៃអង្អែលថ្ពាល់របស់ប្អូនស្រី សេត ចង់បង្រៀននាងមែនទែន បើចង់បន្លំខ្លួន គឺធ្វើឲ្យសមជាងនេះបន្តិចទៀត បើមិនរាប់រូបរាងតូចស្តើង និងមុខមាត់ស្រស់ស្អាត ព្រោះមនុស្សប្រុសពិតប្រាកដ គេមិនប្រើកាយវិការបែបនោះទេ។

"មើលថៃខ្លួនផង"



Scanned by CamScanner

"បាទបង ដាស៊ី បងក៏ត្រូវមើលថែខ្លួនដែរ"

"មិនបាច់លាដូចត្រូវបែកគ្នាមួយជីវិតទេ ទោះធ្វើការខុសគ្នា ពេលសម្រាកអាចទៅរកគ្នាបាន"

"មែនឬ?"

ធីណា សួរបញ្ជាក់ សេត ភ្លាម អ្នកកំលោះក៏ងក់ក្បាល និងមើលឃើញពន្លឺផ្លេកៗក្នុងភ្នែករបស់នាង ភាពរីករាយនៅក្នុងនោះបង្ហាញឲ្យឃើញច្បាស់។

"មែន"

"ហើយបានជួបគ្នាពេលណា?"

"ពេលចេញពីធ្វើការ និងថ្ងៃសម្រាក"

"អរគុណ ម្ចាស់តូច"

"កម្មករនៅលើកោះត្រូវហៅថា លោក សេត"

"មិនមែនមានឈ្មោះលោក ម៉ារីស ទេឬ អ៊ុំប!"

ធីណា ប្រញាប់លើកដៃបិទមាត់ ខណៈដែល សេត ប្រឹងលាក់សំណើចនៅក្នុងកែវភ្នែករបស់គេ ខណៈដែល សាន់នី អង្អែលដៃប្អូនស្រីតិចៗ ជាការលួងលោម។

"ឈ្មោះអ្នកណាគេ?"





Scanned by CamScanner

"សុំទោស ខ្ញុំចាំមនុស្សខុស លោក សេត"

"ទៅចុះ គ្រីស នាំឲ្យទៅបន្ទប់សម្រាក ហើយអធិប្បាយឲ្យដឹងថាត្រូវធ្វើការអីខ្លះ"

"បាទ លោក សេត"

ធីណា ឆ្លើយតប និងគិតថាខ្លួនឯងត្រូវចេញពីត្រង់នេះជាបន្ទាន់ ព្រោះខ្លាចឆ្លោយនិយាយរឿងដែលមិនគួរនិយាយ ដែលធ្វើឲ្យពួកនាងមានបញ្ហា។

"ទៅសិនហើយ បង ដាស៊ី"

ធីណា ងាកទៅឱបបងស្រី ហើយដើរទៅរក គ្រីស និងគេចភ្នែកពីគេដោយការឈ្ងោកមុខឈ្ងោកមាត់។ គ្រីស មិនសង្ហាដូច សេត តែគេក៏មិនអន់មុខមាត់របស់គេគឺសមជាបុរសពិតមានមន្តស្នេហ៍ទាក់ទាញឲ្យមើលបែបប្លែកៗតែខណ:នេះក៏គួរឲ្យខ្លាច។

"អាចទៅបានហើយ"

"តាមម៉ោ"

ដើរបានពីរជំហាន ធីណា ក៏ជំពប់ជើង សាន់នី ប្រុងស្ទុះទៅរក តែត្រូវសេត លូកជើងមកឃាត់។

"សុំទោស"



Scanned by CamScanner

"ដើរឲ្យប្រយ័ត្នបន្តិច"

គ្រីស ស្ដីឲ្យទៀតហើយ ទើប ធីណា ឱនមុខជ្រប់។ នាងក៏មិនចង់ជំពប់ជើងដែរ តែចេះតែស្លាក់ស្លើតជារឿយៗ ចាប់ពីពេលនេះទៅត្រូវបញ្ឈប់ខ្លួនឯងញឹកញាប់ហើយ។

*ត្រូវហាមស្លាក់ស្លើត! ហាមស្លាក់ស្លើត!*

**"ពេលនេះ យើងនិយាយគ្នាម្ដង"**

"បាទ លោក សេត"

សាន់នី ចងចាំឈ្មោះរបស់គេ និងគិតថាត្រូវរកទិន្នន័យរបស់គេម្ដងទៀត ហើយសម្លក់សម្លឹងគេដោយភ្លេចខ្លួន។

*ឈ្មោះ ម៉ារីស ជាឈ្មោះក្លែងក្លាយតើ! មនុស្សបោកប្រាស់!*

សាន់នី ខឹងគេ តែខឹងមិនបានពេញមួយរយភាគរយ ព្រោះពេលនេះនាងក៏ត្រូវបោកប្រាស់គេដូចគ្នា ទាស់ត្រង់ថានាងធ្វើដើម្បីជីវិតរបស់ខ្លួន។

"ដាស៊ី"

គេហៅឈ្មោះក្លែងក្លាយរបស់នាង ហើយចងចិញ្ចើមបន្តិច ដូចកំពុងអស់សំណើច ដែលវាធ្វើឱ្យនាងឆ្ងល់ចុងប្រមុះ ព្រោះគេមើលមកដូចនាងជា



តួកំប្លែង។

"បាទ លោក សេត នោះជាឈ្មោះរបស់ខ្ញុំ"

"ពីរោះតើ តែមិនសូវទម្លាប់មាត់"

អ្នកកំលោះងើបឈរ លើកដៃម្ខាងអង្អែលចង្កាខ្លួនឯង ពេលដើរក្រវែលនាងយឺតៗ។ រាងកាយរបស់គេកើតការប្រាថ្នាយ៉ាងខ្លាំងក្លាចំពោះនាង ព្រោះដឹងច្បាស់ថានៅក្រោមសម្លៀកបំពាក់ស៊ុលគឃុលនោះ លាក់សម្រស់ដែលរកអ្នកប្រៀបពុំបាន។

"ឈ្មោះពិតរបស់ឯងឬអត់ ?"

"ឈ្មោះពិតរបស់ខ្ញុំ"

ព្រោះនាងកំពុងដើរតួជា ដាស៊ី តើឆ្លើយប្រាប់គេម្តេចបានទៅថានាងមិនមែនជា ដាស៊ី ហើយពេលគេដើរមកជិតបន្តិចទៀត នាងក៏ថយក្រោយ គេចសឹងតែមិនទាន់។

"លោក...សេត"

"ឯងជាក្មេងប្រុសដែលមានមុខមាត់គួរឱ្យស្រឡាញ់"

"ខ្ញុំមិនមែនជាកូនក្មេងទេ"

"អាយុប៉ុន្មាន ដប់ប្រាំ ឬដប់ប្រាំមួយ ?"



Scanned by CamScanner

"ខ្ញុំអាយុម្ភៃពីរឆ្នាំ ខ្ញុំពេញកំលោះហើយ"

"មែនឬ?"

ហេតុអ្វីបានជាគេមិនចេះតែជឿអ្នកដទៃផ្តាសបែបនេះ ដែលធ្វើឱ្យនាងកាន់តែមិនចង់និយាយជាមួយគេ ព្រោះខ្លាចឆ្លាយអាច់កំបាំង។

"មែន"

"ពេលនេះខ្ញុំជឿឯងក៏បាន"

"ខ្ញុំអាយុម្ភៃពីរឆ្នាំពិតមែន"

គេអាចសួរបញ្ជាក់ ព្រោះគិតថានាងបោកប្រាស់រឿងអាយុក៏បាន តែនាងមិនបានកុហក គេអាចជួលនាងឱ្យធ្វើការបាន ព្រោះនាងមានអាយុគ្រប់តាមច្បាប់កំណត់ហើយ។

"ខ្ញុំជឿឯង"

"ខ្ញុំបានការងារធ្វើទេ លោក សេត?"

"បានតើ ខ្ញុំខ្វះអ្នកមើលថៃខ្លួន"

"បាទ?"

"ម៉េចចាំបាច់ភ្ញាក់ផ្អើល"

សេត កាន់តែសប្បាយ ពេលឃើញទឹកមុខផ្អើលៗរបស់នាង។ ក្នុងពេល





Scanned by CamScanner

ដែលនាងចង់ធ្វើជាមនុស្សប្រុស គេជូនតាមសំណូមពរ តែត្រូវឃុំនាងនៅក្បែរខ្លួនគេនេះឯង។

"ខ្ញុំ...ខ្ញុំចង់ធ្វើការផ្សេង"

"មាឌតូចដូចជំមិនទាន់ពេញរូបរាង អាចធ្វើការអីបាន"

"ខ្ញុំធ្វើបាន"

"ខ្ញុំមិនអនុញ្ញាត"

ពេលត្រូវនាងមើលមកដោយខ្សែភ្នែកគុំកួន សេត ចង់ទាញនាងមកឱបលួងលោមដោយការថើប ហើយសួរនាំពីហេតុផលដែលនាងបន្លំខ្លួនឡើងមកលើកោះ តែស្រីក្បាលរឹងដូចនាង មុខជាមិនព្រមប្រាប់ងាយៗទេ ដូច្នេះហើយគេត្រូវតែចាប់នាងចងឱ្យជាប់ ហើយប្រដៅនាងឱ្យដឹងថា ការរស់នៅវាពិបាកបែបនេះឯង ការបន្លំដែលនាងធ្វើ វាមិនសមអីបន្តិច។

"ខ្ញុំធ្វើបាន"

"លើកដៃឡើង"

"បាទ?"

"ខ្ញុំបញ្ជាឱ្យលើកដៃឡើង"

ព្រោះធ្លាប់រឹងក្បាលដាក់គេ ទើបភ្លេចខ្លួនមួយខណៈ ថាពេលនេះនាង



Scanned by CamScanner

មិនមែន សាន់នី តែជាកម្មករនៅលើកោះរបស់គេ ដូច្នេះហើយនាងត្រូវតែធ្វើការតាមបញ្ជារបស់គេ។

"បាទ លោក សេត លើកហើយ"

"ផ្ងារដៃ"

នាងលើកដៃ ហើយផ្ងារ ទាំងងឿងឆ្ងល់ថា សេត ត្រូវការធ្វើអ្វី ទាល់តែគេទ្រាបបាតដៃលើបាតដៃរបស់នាងនោះឯង វាធ្វើឱ្យនាងភ្ញាក់ព្រើត ប្រញាប់ដកដៃចេញ។

"ឱ្យដៃម៉ោណេះ"

ពេល សេត ដំឡើងសំឡេង នាងក៏ហុចដៃទៅឱ្យវិញ ហើយវាក៏ធ្វើឱ្យបេះដូងរបស់នាងលោតញាប់ ពេលគេទ្រាបបាតដៃម្តងទៀត បន្ទាប់មកក៏ឈ្លីបាតដៃតិចៗ។

"ដៃទន់ដូចមិនធ្លាប់ធ្វើការធ្ងន់"

"ខ្ញុំធ្វើបានមែន"

សាន់នី នៅតែបញ្ជាក់ពីគោលជំហររបស់ខ្លួន។ នាងព្រមធ្វើការលីសែង ហត់នឿយញើសជោកខ្លួនយ៉ាងណាក៏ដោយ តែមិនត្រូវការធ្វើការនៅជិត សេត ព្រោះវាប្រថុយពេកហើយ។





Scanned by CamScanner

"ខ្ញុំជឿជាក់ការសម្រេចចិត្តរបស់ខ្លួនជាង"

"តែខ្ញុំ..."

"ឬចង់ឱ្យខ្ញុំបញ្ជូនឯងចេញពីកោះ អេ៎!"

ពេលគេងាកទៅហៅមនុស្សរបស់គេ សាន់នី ក៏ស្ទុះទៅរក ដាក់ដៃលើពាក់កងរបស់គេ និងងើយមើលមុខគេដោយការអង្វរករ។

"កុំធ្វើបែបហ្នឹងអី"

"ហើយសាំញ៉ាំធ្វើអី អ្នកនៅទីនេះត្រូវរៀបចំឱ្យធ្វើការតាមការសក្តិសមតួនាទីរបស់ឯងគឺមើលថៃខ្ញុំ ធ្វើឱ្យខ្ញុំមានសេចក្ដីសុខ និងពេញចិត្ត"

"ខ្ញុំដឹងហើយ"

"ហើយធ្វើទេ ?"

បើមិនធ្វើ គេបណ្ដេញនាងចេញពីកោះមិនខាន ហើយនាងបដិសេធម្ដេចបាន គឺមានតែត្រូវព្រមឈ្ងោកមុខឈ្ងោកមាត់ធ្វើតាមបញ្ជារបស់គេ។

"ធ្វើ"

"តែប៉ុណ្ណឹង ខ្លាចស្អីក៏ខ្លាច"

"ខ្ញុំព្រមទទួលស្គាល់ថាខ្លាច"

ខ្លាចបែកការណ៍ ខ្លាចគេចាប់បាន ខ្លាចត្រូវបញ្ជូនទៅឱ្យ យ៉ៃវ៉ល និង



Scanned by CamScanner

អាដាំ ឬមិនអ៊ីចឹងអាចត្រូវគេដាក់ទោស ដែលនាងហ៊ានកុហកគេ ទើបធ្វើឱ្យនាងមានតែការភ័យខ្លាចពេញក្នុងទ្រូង។

"ខ្ញុំមិនអាក្រក់ដាក់កូនចៅទេ បើដឹងតួនាទីរបស់ខ្លួន"

"បាទ លោក សេត"

"កាបូបរបស់ឯង មានតែប៉ុណ្ណឹង មែនទេ?"

"បាទ លោក សេត"

"លើកម៉ោ ន្ទាលទៅកន្លែងសម្រាក"

"បាទ លោក សេត"

ព្រោះត្រូវគេស្ដីឱ្យ ទើបនាងក្លាយជាមនុស្សត្រូវស្ដាប់បង្គាប់គេមួយរយៈ ដើរទៅរកកាបូបស្ពាយរបស់ខ្លួន ដែលដំបូងខំប្រឹងលើកទាល់តែជ្រមិលរកកល់ចង់ដួល តែយ៉ាងណាក៏ខាំមាត់សង្កត់ចិត្ត លើកវាទាល់តែបានសម្រេច។

"ធ្ងន់ក៏អី?"

"បាទ លោក សេត"

"សាកបន្តិចមើល អ៊ីចឹង"

សាន់នី ដើរទៅរកអ្នកកំលោះ ពេលនេះគេបញ្ជាអី នាងត្រូវតែធ្វើតាម ព្រោះវាប្រថុយនឹងការដែលត្រូវគេបញ្ជូនចេញពីកោះ។





Scanned by CamScanner

"កាបូប លោក សេត"

ដៃរបស់ សាន់នី ក្រហមងាំង ព្រោះកកិតនឹងខ្សែកាបូប ពេលលើកវាឱ្យគេ ទើបគេលូកដៃម្ខាងមករក។

"វាធ្ងន់"

នាងតឿន គេចង់ប្រើដៃម្ខាងលើកកាបូបឬ ព្រោះនាងស្ពាយក៏ធ្ងន់ លើកក៏លំបាក ត្រូវប្រើកម្លាំងច្រើនណាស់។

"ស្មៀម ដាស៊ី"

នាងធ្លាប់គិតថាគេចូលចិត្តបញ្ជាតែនាងម្នាក់ កាលជាស្រីនៅលើគ្រែក៏ត្រូវគេបញ្ជាជាប្រចាំ តែមិនស្មានថាចំពោះកូនចៅ គេក៏ចូលចិត្តបញ្ជាដែរ។

"មិនធ្ងន់ទេឬ?"

សេត លើកកាបូបស្ពាយនឹងស្មា ហាក់ដូចវាមិនធ្ងន់អីបន្តិច ហើយមើលដៃក្រហមងាំងរបស់ស្រីមាឌល្អិត។

"មិនធ្ងន់ទេ"

"លោក សេត កាបូបខ្ញុំ"

សេត ដើរចេញទៅ នាងក៏ដើរតាម តែគេបែរជាមិនព្រមហុចកាបូបឱ្យនាងវិញ ទើបដើរតាមជាប់ប្រកិត ហើយដាក់ដៃលើខ្នងធំទូលាយ ពេលគេឈប់



Scanned by CamScanner

ដើរ។

"កាបូបរបស់ខ្ញុំ"

"ហ្លួងហែងស្អីណាស់ណា"

"មិនបានហ្លួងហែង តែត្រូវកាន់ដោយខ្លួនឯង"

"ខ្ញុំសុំខ្ចីកាន់សិន មួយរយៈនេះចូលចិត្តហាត់ប្រាណ"

"វាធ្ងន់"

"ដើរតាមស្ងាត់ៗ បានទេ"

"បាទ លោក សេត"

ពេលគេធ្វើសំឡេងកាចដាក់ នាងក៏យល់ព្រម ព្រោះស្ថានការណ៍របស់នាងមិនទាន់មានសុវត្ថិភាព ប្រថុយប្រថាននឹងត្រូវបញ្ជូនចេញពីកោះចោរ។

"យើងទៅណា ?"

"ផ្ទះរបស់ខ្ញុំ"

សាន់នី ភ័យខ្លាំងណាស់ ព្រោះផ្ទះរបស់គេ ធ្វើការជិតគេ ហើយនាងអាចរួចពីកណ្តាប់ដៃរបស់គេ បានយូរប៉ុនណា។

"បាទ លោក សេត"

នាងចងចិញ្ចើម គិតច្រើន និងបន់ស្រន់ឱ្យខ្លួនឯងអាចនៅទីនេះបាន



គ្រប់បីខែតាមការកំណត់ការងារ។



Scanned by CamScanner

# ៩

## ចាំបាច់ត្រូវនៅជិត

ទោះនាងគ្មានផែនការច្បាស់លាស់ ប៉ុន្តែមិនបានត្រៀមខ្លួនមកដើម្បីទទួលយករឿងបែបនេះ ទោះចិត្តលួចសង្ឃឹមថា អាចមានឱកាសបានជួបនឹងសេត ដែលស្គាល់ក្នុងនាម ម៉ារីស ប៉ុន្តែមិនធ្លាប់គិតទេថានឹងបានជួបគេតាំងពីថ្ងៃដំបូង និងត្រូវមកធ្វើការជិតគេបែបនេះ។

ភូមិគ្រឹះដ៏ស្កឹមស្កៃដែលគេស្នាក់អាស្រ័យ គ្មានផ្លូវ ដែលវាជាកន្លែងសម្រាករបស់កម្មករនៅលើកោះ ទោះតំណែងធំប៉ុនណាក៏ដោយ។ ភូមិគ្រឹះមួយនេះ នៅដាច់ដោយឡែកពីភូមិគ្រឹះមួយទៀតដែលគេចង្អុលប្រាប់នាងដោយប្រយោលថា ភូមិគ្រឹះមួយនោះជាកន្លែងស្នាក់អាស្រ័យរបស់ប្រមុខកម្រងកោះស៊ី រ៉ូវើ។

នាងចង់សួរគេច្រើនរឿង មួយនៅក្នុងនោះ គឺសំណួរដែលឆ្ងល់ជាខ្លាំងដោយទំហំផ្ទះធំស្កឹមស្កៃរបស់គេដែលគេហៅថាផ្ទះចំណែកនាងហៅថាភូមិគ្រឹះ





Scanned by CamScanner

តើគេត្រូវជាស្អីនឹងប្រមុខកម្រងកោះ ស៊ីរ៉ូវើ ប៉ុន្តែសំណួរនោះ ត្រូវលាក់ទុកនៅក្នុងចិត្ត។

"យើងស្នាក់នៅទីនេះ"

នាងក្រមុំ មើលទៅជុំវិញបន្ទប់ធំទូលាយ ដែលក្រៅពីធំហើយ វាក៏ប្រណិត ត្រូវតុបតែងយ៉ាងវិចិត្រ ដែលមិនខុសពីចំណង់ចំណូលចិត្តរបស់ សេត ប៉ុន្តែស្ថានភាពរបស់គេនៅពេលនេះ ដែលស្លៀកខោខូវប៊ិយតែមួយប៉ុណ្ណោះ និងបន្ទប់ដ៏ប្រណិតនេះ បែរជាចូលគ្នាបានល្អ ប្រហែលមកពីបុគ្គលិកលក្ខណៈដ៏មានអំណាចរបស់គេនោះឯង។ នាងមិនចង់សន្និដ្ឋានទេថាគេជាអ្នកណា ការបានជួបគេ ក្រៅពីសប្បាយចិត្តហើយ នៅឱ្យអារម្មណ៍ហេងហាងក្នុងទ្រូងទៀត ដោយសារភាពតូចទាប ដោយសារគិតថា នាងមិនសមនឹងគេ ដែលនាងគិតវាធ្វើអ្វី ក៏នាងឆ្ងល់នឹងខ្លួនឯងដែរ។

"លោក សេត ឱ្យខ្ញុំស្នាក់នៅក្នុងបន្ទប់នេះឬ ?"

បន្ទប់ធំល្វឹងល្វើយយ៉ាងនេះ ធំជាងបន្ទប់ដែលនាងស្នាក់នៅណាខាដៀបីបួនឯណោះ ទើបបានទំហំប្រហាក់ប្រហែលនឹងបន្ទប់ដែលកំពុងឈរ។

"មែន តាមខ្ញុំម៉ោ"

សេត ដើរនាំមុខនាងចូលបន្ទប់តែងខ្លួន ចេញទ្វារកោង ពេលដើរផុតទៅ



Scanned by CamScanner

គឺជាបន្ទប់មួយទៀត ដែលធំខ្លាំងណាស់ ទ្វាររបស់បន្ទប់ខោអាវ វែង តាមប្រវែងរបស់ជញ្ជាំង និងមានរបស់លម្អច្រើន ស្អាត។

"ទុកខោអាវរបស់នាងក្នុងបន្ទប់នេះ រើសយកទូមួយទៅ"

"ខ្ញុំបានសម្រាកនៅបន្ទប់នេះមែនឬ ?"

នាងនៅតែសង្ស័យ ព្រោះកម្មកររមានសិទ្ធិស្នាក់នៅបន្ទប់ទំនើបបែបនេះផងឬ ត្រឹមបន្ទប់តែងខ្លួនធំជាងបន្ទប់ដែលនាងធ្លាប់ស្នាក់នៅទៅទៀត។

"មែន"

"វាមិនទំនើបពេកទេឬ ?"

"ចុះគិតថាបន្ទប់នេះទំនើបពេកទេ ?"

"ទំនើបណាស់"

"វាជាបន្ទប់ដេកដែលធំជាងគេនៅក្នុងផ្ទះនេះ"

សេត និយាយមួយៗ ឲ្យពេលនាងគិតតាម តែនាងគិតមិនឃើញដដែលថា បន្ទប់ដែលធំបំផុត ហេតុអីបានជាគេរៀបចំឲ្យកម្មករស្នាក់នៅ តើគេចិត្តល្អដល់ម្លឹងផង។

*មុខមាត់មិនគួរណាចិត្តល្អ បើនិយាយពីចរិតចិត្តថ្លើមកាន់តែមិនឲ្យ!*



នាងធ្លាប់នៅជាមួយគេ គេមិនមែនជាមនុស្សអាក្រក់អាក្រីអី តែក៏មិន



Scanned by CamScanner

បានចិត្តល្អ មានចិត្តទូលាយដូចដែលធ្វើឲ្យឃើញនៅពេលនេះ។

"ព្រោះវាជាបន្ទប់របស់ខ្ញុំ"

"បាទ ?"

*ត្រូវធ្វើការជិតគេ ស្នាក់នៅក្នុងផ្ទះជាមួយគេ នាងដកដង្ហើមមិនចង់ពេញពោះទៅហើយ នេះត្រូវមកដេកក្នុងបន្ទប់តែមួយទៀតឬ ?*

"ឯងឮមិនខុសទេ"

"មិនពិត"

"ពិត"

ម្នាក់ភិតភ័យ ម្នាក់ទៀតបែរជារីករាយខ្លាំងណាស់។ សេត ចង់ប្រាប់ឱ្យនាងដឹងមុខមាត់ពេលភិតភ័យកាន់តែធ្វើឱ្យនាងស្រស់ស្អាតទោះនាងពាក់សក់ក្លែងក្លាយ មិនទំនងក៏ដោយ។ ដំបូង គេមិនពេញចិត្តជាខ្លាំង ពេលឃើញសក់ខ្លីដូចមនុស្សប្រុស ព្រោះគេចូលចិត្តមនុស្សស្រីសក់វែង ហើយសក់របស់ សាន់នីក៏ត្រូវចិត្តគេណាស់ដែរ តែដោយសារគេចូលចិត្តលេងសក់នាងខ្លាំងនោះឯងពេលខ្លះ មូរនឹងម្រាមដៃ ពេលខ្លះថើប ទើបចងចាំសក់របស់នាងបានច្បាស់ដែលវានៅឆ្ងាយពីសក់ពាក់ក្លែងក្លាយដែលជាសរសៃសក់ធំៗ និងមិនរលើបរលោងដូចសក់ពិតរបស់នាង។

"មិន...មិនបានទេ លោក សេត លោកប្ដូរចិត្តទៅ"

"មិនប្ដូរ"

គេត្បកមកវិញដោយទឹកមុខជម្មតា នាងកាន់តែចង់រើបម្រះ គេចចេញពីគេ គេកាន់តែឃាត់ ឱ្យនៅក្បែរខ្លួន មានឱកាសពេលណា នឹងរករឿងចាប់ស៊ីឱ្យពេញពោះ។

*ស្រីមុខស្រស់ នាងមិនរួចពីកណ្ដាប់ដៃខ្ញុំទេ!*

សាន់នី កើតមកដើម្បីឱ្យគេស៊ី ហើយគេក៏ស៊ីនាងមិនទាន់ឆ្អែតដែរ។ ពេលបានព្ទព័ត៌មានភ្លើងឆេះ ណាខាដៀ គេក៏ធ្លាក់ថ្លើមក្ដុក ប៉ុន្ដែពេលនេះនាងមកឈរនៅចំពោះមុខ ត្រឹមឈោងដៃដល់ មានឬដែលគេព្រមទុកដៃជើងនៅស្ងៀមពីរាងកាយរបស់នាង គេនឹងប៉ះពាល់បន្ដិចម្ដងៗ ប៉ះពាល់ជារឿយៗ ទ្រាំមិនបានថ្ងៃណា នឹងចាប់នាងស៊ីថ្ងៃនោះឯង។

គេជាមនុស្សប្រុសស្រេកឃ្លាន ប៉ុន្ដែត្រូវទប់ការស្រេកឃ្លាននោះ។ សាន់នី គួរដឹងខ្លួនឯង នាងជាមនុស្សស្រីគួរឱ្យស៊ី ហើយនាងក៏ត្រូវចិត្តគេណាស់ដែរ រាងកាយរបស់គេលេបត្របាក់នាង មិនធ្លាប់ទ្រលាន់ មានតែចង់ស៊ីហើយស៊ីទៀត នាងជាស្រីដំបូង ដែលធ្វើឱ្យគេប្រាថ្នា ដល់ថ្នាក់មិនអាចហាមចិត្តបាន។



"លោក សេត"



Scanned by CamScanner

"មានការអីទៀតហើយ"

"ទីនេះ គ្មានផ្ទះសម្រាប់កម្មករទេឬ ?"

"ច្បាស់ជាមាន"

តែគេមិនអនុញ្ញាតឱ្យនាងទៅសម្រាកនៅទីនោះ គេគ្មានហេតុផលអី ដែលល្អជាងត្រូវការឱ្យនាងនៅក្នុងខ្សែភ្នែក ដែលកាន់តែជិតកាន់តែល្អ។

"ខ្ញុំសុំទៅសម្រាកនៅទីនោះបានទេ ?"

"មិនបាន"

"អ៎ !" នាងឆ្ងួលចុងច្រមុះ ស្អីក៏មិនបានៗ ហេតុអីបានជាគេ ជាចៅហ្វាយ ទំនើងបែបនេះ មនុស្សឆ្កួតស្អី ទំនើងមិនដែលប្រែប្រួល នាងសាងកម្មសាងពារ អីនឹងគេណាស់ណា ពេលជាមនុស្សស្រីក៏ត្រូវកេងចំណេញតាមអំពើចិត្ត បន្លំខ្លួនជាមនុស្សប្រុសហើយ ក៏ត្រូវចាញ់ប្រៀបគេដដែល។

មនុស្សស្អី កំណាចដាក់នាង ហួសហេតុ ចង់តែខ្ទៅមុខឱ្យចេញឈាមទេ !

នាងក្រមុំបានត្រឹមតែខឹងសម្បានៅក្នុងចិត្ត ព្រោះបើកម្ចាយទោសៈចេញមក គេអាចនឹងសង្ស័យថានាងជាអ្នកណា។

"ឯងនិយាយស្អី"



Scanned by CamScanner

អ្នកកំលោះលូកដៃចូលហោប៉ៅខោ ដើរទៅរក សាន់នី ក៏ថយក្រោយក្រេស ។ មនុស្សប្រុសមាឌធំដូចយក្ស ស្លៀកខោតែមួយប៉ុណ្ណោះ អាវក៏មិនព្រមពាក់ កំពុងតែដើរមករក ធ្វើឱ្យនាងភ័យ លើកដៃទាំងពីរខ្វែងដាក់ពីមុខ និងថយក្រោយទាល់តែទៅបុកខ្នងនឹងបន្ទប់តែងខ្លួន។

ដៃប៉ះដើមទ្រូងធំទូលាយ តាមពិតនាងមិនចង់ប៉ះ ប៉ុន្តែគេនាំដើមទ្រូងរឹងកំព្រឹសនោះ មកបុកនឹងដៃរបស់នាង ហើយមានចេតនាត្រសុលមករកទៀត ដូចដឹងថាខ្លួនឯងមានរាងរៅល្អ សាច់ដុំហាប់ណែន សិចស៊ីហើយនៅមានស្នាមញញឹមកំណាចលើបបូរមាត់សិចស៊ីនោះទៀត។

ងាប់ហើយ នាងបន្លំខ្លួនជាមនុស្សប្រុសហើយ ហេតុអីគេមើលមកនាងដោយខ្សែភ្នែកត្រេកកាមបែបហ្នឹង!

"លោក...លោកសេត!"

នាងដកដង្ហើមដង្ហក់ មនុស្សឆ្កួតទ្រានដៃពីលើ មើលនាងដោយខ្សែភ្នែកដាក់សម្ពាធ ហើយដើមទ្រូងរបស់គេ ដែលមានដៃរបស់នាងនៃបនិត្យ ក៏ក្តៅភាយៗ ធ្វើឱ្យនាងអត់មិនបាននឹងគិតដល់ពេលដែលរាងកាយននលគកបបោសអង្អែលជាមួយគេនៅលើគ្រែ។

"ឯងដកដង្ហើមខ្លាំងពេក"





Scanned by CamScanner

"ខ្ញុំភ្ញាក់"

"មិនធ្លាប់ឃើញដើមទ្រូងមនុស្សប្រុសឬយ៉ាងម៉េច"

"ត្រូវតែធ្លាប់ហើយ"

"ហ្នឹងហើយ ព្រោះឯងជាមនុស្សប្រុសហ្នឹងណ៎ា មែនទេ"

"មែន...មែន"

គេត្រសុលទៅរកនាងបន្តិចទៀត សាន់នី ចង់តែស្រែក ឬមិនអីចឹង ទះគេមួយកំផ្លៀងពីរ ប៉ុន្តែក៏មិនអាចធ្វើបានដូចការគិត ព្រោះអាការៈឆ្មាសឆ្មើមបែបនោះ មានតែមនុស្សស្រីប៉ុណ្ណោះដែលធ្វើ។

"អីចឹងតើបានអម្បាញ់មិញឯងស្រែកភ្លាត់មាត់ដូចមនុស្សស្រី"

"ខ្ញុំភ្ញាក់ហ្នឹងណ៎ា"

នាងក្រមុំដោះសាឱ្យតែរួចពីមាត់ ហើយមើលទៅ សេត ដូចមិនបានសង្ស័យអីណាស់ណា គេឈប់បបួលនិយាយ តែប្រើខ្សែភ្នែក ពិនិត្យនាងតាំងពីក្បាលដល់ចុងជើង។

មើលស្អីក៏មើល!

"ឯងនេះមើលទៅមើលម៉ោដូចមនុស្សស្រី"

"ខ្ញុំជាមនុស្សប្រុស!"

នាងភ្លេចខ្លួន ស្រែកឆ្លើយខ្លាំងៗទៀតហើយ។ នាងមិនចង់ឱ្យគេដឹងការពិត ខ្លាចត្រូវគេចាប់បោះចេញពីកោះចោរ នាងមិនចង់ទៅរត់គេចពី យ៉ែរល និង អាដាំ លើដីគោក ព្រោះខ្លាចគេចមិនរួចនោះឯង។

ទោះរឹងមាំយ៉ាងណា បទពិសោធជីវិតនៅក្រៅ ណាខាដៀ ដែលមានតម្លៃស្មើសូន្យ វាធ្វើឲ្យនាងចាញ់ប្រៀប ហើយនាងក៏ដឹងច្បាស់ពីចំណុចនេះ តែនរណាទៅគិតថាគេចពីខ្លាមកជួបក្រពើ ទាស់ត្រង់ថា សេត មិនដូចក្រពើ គេដូចរាជសីហ៍ដ៏រឹងមាំ និងមានអំណាចជាង។

"ខ្លួនឯងតូចណាស់ ដៃក៏ទន់ៗ"

សំឡេងរបស់ សេត មានឥទ្ធិពលចំពោះនាង ធ្វើឲ្យនាងព្រឺសម្បុរដូចគេកំពុងស្ទាបអង្អែលរាងកាយដ៏ស្រស់ស្អាតរបស់នាង ទាំងដែលគេមិនបានធ្វើបែបនោះផង។

"ខ្ញុំ...ខ្ញុំមិនសូវបានធ្វើការប៉ុន្មាន"

"ចឹ ?"

"ខ្ញុំជាមនុស្សខ្ជិល"

ពេលគេសួរ នាងត្រូវតែឆ្លើយ ព្រោះបើមិនឆ្លើយ គេនឹងសង្ស័យ។ មនុស្សកុហក គឺបែបនេះឯង ហត់នឿយណាស់។



"ខ្ទិលហើយម៉ោធ្វើការធ្វើអី ?"

"ខ្ញុំចាំបាច់"

ហើយគេសួរធ្វើអីណាស់ណា សួរដល់ថ្នាក់នាងឆ្លើយមិនត្រូវ សួរដល់ថ្នាក់នាងទ័លច្រកទៅហើយ មនុស្សឆ្កួត។

"ចាំបាច់អី ?"

"អឺ..."

គេចង់សួរយករង្វាន់ ឬយ៉ាងម៉េច សួរដល់ថ្នាក់នាងមិនដឹងឆ្លើយយ៉ាងណាទៅហើយ សួរដល់ថ្នាក់ទ័លបញ្ញានឹងរកចម្លើយឲ្យគេ បើឆ្លើយតាមការពិតក៏មិនតឹងទ្រូងបែបនេះដែរ តែនាងប្រាប់ការពិតមិនបាន។

"ឬនៅសុខៗក៏ឧស្សាហ៍ ?"

"បាទ បែបហ្នឹងហើយ"

សេត នឹកអាណិត កាយវិការឆ្លេឆ្លារិះរកចម្លើយមិនបានរបស់នាង ទើបផ្តល់ចម្លើយឱ្យ ដែលនាងក៏ប្រញាប់សង្គ្រុបយក។

"ខ្ញុំកំពុងសង្ស័យ"

"សង្ស័យអីទៀតហើយ !"

នាងស្រែកគំហ៊ក ព្រោះភ្លេចខ្លួន គេសួរស្អីក៏សួរណាស់ណា នាងគ្រាន់តែ

ជាកម្មករម្នាក់ប៉ុណ្ណោះ ប៉ុន្តែគេសួរមិនឈប់មិនឈរ ខណៈដែល សេត នឹកអស់សំណើច នឹងការឆ្លើយសំណួរដល់ថ្នាក់ដង្ហក់ខ្យល់របស់ស្រីកំណាន់។

ព្រះអើយ ពៅព្រលឹង កុហកឡើងហត់ទៅហើយ ដើមទ្រូងក្រពុំនោះស្ទើរតែប្រាល់ចេញពីអាវហើយទេដឹង!

គេសម្លឹងមើលត្រង់នោះបន្តិច នាងប្រហែលប្រើក្រណាត់រឹតដើមទ្រូង ប៉ុន្តែព្រោះដើមទ្រូងរបស់នាងធំយ៉ាងហ្នឹង ទោះរឹតស្ទើរស្លាប់ ក៏វានៅតែមានរូបរាងឱ្យឃើញ។

"ឯងមាឌតូចណាស់ តែមើលទៅដូចមានសាច់ដុំទ្រូង"

"ហេតុអីឬ?"

"ដើមទ្រូងឯងឡើងប៉ោង"

សេត ចាប់ដៃរបស់នាងសង្កត់នឹងដើមទ្រូងរបស់គេ ហើយទាញវា ឱ្យធ្វើសកម្មភាពពេញដើមទ្រូងតែម្តង ដោយកំពុងគិតដល់វេលាដែលត្រូវនាងប្រណិបត្តន៍ ឱ្យរាងកាយរបស់គេកើតប្រាថ្នាចំពោះនាងទៀតហើយ។

"លោក...លោកសេត"

"ដើមទ្រូងខ្ញុំរឹងណាស់ ចុះដើមទ្រូងឯងរឹងទេ?"

"មិន...មិនដឹងទេ"





Scanned by CamScanner

"ខ្ញុំសុំចាប់មើលបន្តិច"

"មិនបាន!"

បើឱ្យគេចាប់ គេច្បាស់ជាដឹងថានាង ប្រើក្រណាត់រុំរាងកាយល្វែងលើ។ នាងដកដង្ហើមដង្ហក់ មនុស្សឆ្កួតនេះ ត្រេកកាមណាស់ ចំពោះមនុស្សប្រុសក៏មិនលើកលែង។

"ខ្ញុំនៅឱ្យឯងចាប់ដើមទ្រូងខ្ញុំបាន"

"ខ្ញុំមិនបានចង់ចាប់ផង"

"ដូរគ្នាចាប់"

"មិនដូរទេ ខ្ញុំមិនដូរ"

"ឯងធ្វើឱ្យខ្ញុំសង្ស័យ មាឌតូច តែសាច់ដុំទ្រូងធំណាស់ ឯងចូលចិត្តលេងសាច់ដុំឬយ៉ាងម៉េច"

"បាទ ខ្ញុំចូលចិត្ត"

"សុំចាប់បន្តិចមិនបានឬ"

គេចង់ចាប់ដើមទ្រូងរបស់នាងឱ្យបានមែនទេ ដើមទ្រូងរបស់នាងឡើងប៉ោងនេះ មិនមែនដោយសារមានសាច់ដុំដូចដើមទ្រូងរបស់គេនោះទេ តែព្រោះនាងជាស្រីវើយ។



Scanned by CamScanner

"មិនបាន!"

"តិចតួចទេ"

សេតនៅតែញ៉ោះមិនឈប់ហើយពេលគេលើកដៃនាងក៏ប្រញាប់បង្វិលខ្លួន បែរមុខទៅពិតនឹងជញ្ជាំងបន្ទប់ ប្រឹងត្រសុល ទៅរកថែមទៀត ការពារខ្លួនឯងអស់ពីសមត្ថភាព។

"ហួងហែងខ្លួនម្ល៉េះ"

សេត តាមទៅជាប់ប្រកិត ឱនទៅថើប សក់របស់នាង ប៉ុន្តែក្លិនសក់ក្លែងក្លាយដែលនាងពាក់ ធ្វើឱ្យគេឃ្នើសចិត្ត គេចង់តែដោះវាគ្រវាត់ចោល ហើយប្រើដៃជ្រងសក់របស់នាង ដើម្បីស្រង់យកក្លិនក្រអូបដែលគេចូលចិត្ត ប៉ុន្តែពេលនេះ ត្រូវអត់ធ្មត់សិន។

"គឺលោក សេត សុំស្អីក៏មិនដឹងហ្នឹងណ៎ា"

"គ្រាន់តែចាប់ដើមទ្រូង មនុស្សប្រុសដូចគ្នាវាមិនអីទេ"

"ម៉េចក៏ថាមិនអី លោក សេត ធ្វើឱ្យខ្ញុំមានអារម្មណ៍ដូចលោក សេត ចូល ចិត្តមនុស្សប្រុស"

"តាមពិត ខ្ញុំក៏មិនរើសអើង"

សេត ឱនមកថើបសក់របស់នាង ហើយធុំក្លិនដែលមិនចូលចិត្ត ទើប





Scanned by CamScanner

អូសច្រមុះទៅរកកញ្ចឹងកសខ្ចី ក្លិនខ្លួនក្រមុំនៅតែក្រអូបប្រហើរ អ៊ា! ត្រូវតែជាក្លិនបែបនេះហើយដែលគេដង្ហោយរក។

"លោក...លោក សេត"

សាន់នី ខ្ទាំម្រាមដៃនឹងជញ្ជាំង ដើម្បីរម្ងាប់អារម្មណ៍ស្រៀវស្រើបលាយឡំការភ័យខ្លាចដែលកើតឡើង ហេតុអី សេត ធ្វើដូចគេកំពុងតែត្រេកកាមដាក់នាង។

"ថី?"

"ខ្ញុំ...ខ្ញុំជាមនុស្សប្រុស"

នាងដាស់តឿនព្រោះច្រមុះរបស់គេបបោសអង្អែល កញ្ចឹងករបស់នាងតិចៗ ធ្វើឱ្យព្រឺសម្បុរ។

"មិនអីទេខ្ញុំមិនប្រកាន់"

"ស្អីគេ!"

"ខ្ញុំបានទាំងអស់ ស្រីក៏បាន ប្រុសក៏ល្អ យុត្តិធម៌ មិនរើងច្រើន"

ប៉ុន្តែនាងចង់ឱ្យគេរើងច្រើន ហើយពេលនេះក៏ចង់ខ្យល់គ ព្រោះចម្លើយនោះ។ នាងមានទំនាក់ទំនងផ្លូវកាយនឹងគេយូរហើយ មានន័យថា បើគេនៅឆ្ងាយពីភ្នែករបស់នាង គឺអាចឡើងគ្រែជាមួយអ្នកដទៃ ដែលបានទាំងមនុស្ស

ស្រីនិងមនុស្សប្រុសអីចឹងឬ។

"មនុស្សឆ្កួត!"

"ឯងថាម៉េច?"

"អត់...អត់មានទេ"

"តែខ្ញុំបានឮពាក្យថាមនុស្សឆ្កួត"

"លោក សេត ប្រហែលស្តាប់ច្រឡំ"

"ហ្នឹងហើយ សម្តីបែបហ្នឹងមានតែមនុស្សស្រីប៉ុណ្ណោះដែលគេនិយាយ"

ចម្លើយនេះ ធ្វើឱ្យនាង ធ្លាក់ថ្លើមម្តងទៀត។ ថ្ងៃ ដំបូងហាត់ដល់ថ្នាក់នេះទៅហើយ តើនាងអាចយោងអាត្មារស់បានប៉ុន្មានថ្ងៃទៅ ។

"ខ្ញុំជាមនុស្សប្រុស"

"ខ្ញុំដឹង បញ្ជាក់នោះបញ្ជាក់"

"លោក...លោក សេត បានទាំងមនុស្សស្រីនិងមនុស្សប្រុសមែនឬ?"

នាងនៅតែសង្ស័យ ទាំងដែលមិនគួរសួរគេ ប៉ុន្តែមិនអាចហាមប្រាមខ្លួនឯងបាន នាងចង់ដឹង ព្រោះវាធ្វើឱ្យបេះដូងរបស់នាងមួហ្មង។

"ឯងគិតថាម៉េច"

"ខ្ញុំមិនហ៊ានគិតទេ"





Scanned by CamScanner

"ក្មេងល្ងង់ ខ្ញុំគ្រាន់តែញ៉ោះឯងលេងទេ ខ្ញុំចូលចិត្តញ៉ោះក្មេង"

សេត ខោកក្បាលនាងមួយក្រញូរញ៉ោះហើយក៏អាណិត ទោះគេសប្បាយនឹងការញ៉ោះនាងក៏ដោយ ហើយព្រមថយចេញឱ្យឆ្ងាយ ទុកពេលឱ្យនាងបានសម្រាកដកដង្ហើមខ្លះ ហើយនាងក៏បែរខ្លួនមកវិញ សម្លឹងមុខគេ។

"ស្អី?"

"លោក សេត និយាយមែនឬ?"

"ខ្ញុំចូលចិត្តមនុស្សស្រី ចូលចិត្តខ្លាំងណាស់"

គេប្រសព្វភ្នែកនឹងនាង សង្កត់ពាក្យថាចូលចិត្តរបស់គេ ធ្វើឱ្យ សាន់នីក្រហមថ្ពាល់ ក្តៅភាយៗ។ ហេតុអីទើបនាងមានអារម្មណ៍ថាគេកំពុងតែប្រាប់នាង ប៉ុន្តែម៉េចនឹងអាចទៅ បើពេលនេះនាងជាមនុស្សប្រុសនៅក្នុងខ្សែភ្នែករបស់គេ។

"បាទ លោក សេត"

"ជឿខ្ញុំហើយឬនៅ?"

"ជឿហើយ"

"ជឿគេងាយម្ល៉េះ រៀបចំខោអាវដាក់ទូ ខ្ញុំចេញទៅចាំនៅខាងក្រៅ"

"ខ្ញុំត្រូវដេកនៅទីនេះមែនឬ?"

"មែន ព្រោះឯងត្រូវធ្វើតួនាទីមើលថែខ្ញុំ ជារឿងធម្មតាដែលអ្នកបម្រើនៅជិតខ្ញុំត្រូវតែបម្រើតាមខ្ញុំគ្រប់ជំហាននិងត្រូវដេកយាមខ្ញុំដែរក្រែងលោខ្ញុំមានរឿងឱ្យប្រើនៅពេលយប់"

ហេតុផលរបស់គេគឺបែបនេះឯង ទោះនាងលំបាកចិត្តយ៉ាងណា ក៏ត្រូវធ្វើតួនាទីនោះ។

"បាទ លោក សេត"

"និយាយចេះស្ដាប់គ្នាបែបនេះក៏ល្អ ឱ្យឆាប់ធំ"

សាន់នី រៀបចំរបស់របរផ្ទាល់ខ្លួនដាក់ក្នុងទូ ដោយជ្រើសរើសទូដែលអាចកំបាំងខ្លាំងបំផុតតាមដែលរើសបាន ព្រោះមានរបស់ជាច្រើនដែលត្រូវលាក់ ហើយក៏ឆ្លាត ជ្រើសរើសទូដែលខាងក្នុង មានថតសម្រាប់ចាក់សោទៀតផង ហើយពេលទុកដាក់រួចរាល់ នាងក៏ចាក់សោ យកកូនសោដាក់ជាប់ខ្លួន បន្ទាប់មកក៏ដកដង្ហើមចូលឱ្យពេញសួត ហើយដើរចេញពីបន្ទប់តែងខ្លួន។ ការដែលត្រូវចេញទៅជួប សេត គឺជារឿងផ្ទាញ់ផ្ទាល ធ្វើឱ្យនាងផ្អើលគ្រប់ពេលវេលា។



"រួចហើយឬនៅ?"



Scanned by CamScanner

"រួចហើយលោក សេត"

"ធ្វើស្អីស្អីកដូចមនុស្សស្រី"

"ខ្ញុំជាមនុស្សប្រុស"

នាងប្រកែកភ្លាម ដែលធ្វើឱ្យ សេត មើលមកដោយនឹកអស់សំណើចផង អាណិតផង។ ប្រកែកឡើងតឹងសរសៃក ដូចខ្លាចគេមិនជឿថានាងជាមនុស្សប្រុសដែលគេមិនជឿមែនហ្នឹង។បើមិនស្គាល់នាងគេប្រហែលចាប់នាងសម្រាតពិសោធន៍ការពិតទៅហើយថានាងជាមនុស្សស្រី ឬជាមនុស្សប្រុសឱ្យប្រាកដទៅ តែនេះ គេដឹង ទើបបណ្ដោយឱ្យនាងបានចិត្តសិន។

"ជាមនុស្សប្រុសត្រូវធ្វើខ្លួនឱ្យរហ័សរហួនដូចមនុស្សប្រុស រវាសរវៃ"

"ធ្វើបែបណា ?"

នាងគិតថាខ្លួនឯងរហ័សរហួនរវាសរវៃហើយ ប៉ុន្តែត្រូវឱ្យរហ័សរហួនជាងនេះទៀតឬនាងគិតមិនចេញទេហើយនាងម៉េចនឹងដឹងទៅបើនាងមិនមែនជាមនុស្សប្រុសផង។

"ឯងមិនដឹងទេឬ"

"ខ្ញុំម៉េចនឹងដឹងទៅ"

"ឯងជាមនុស្សប្រុសម៉េចក៏មិនដឹង"



Scanned by CamScanner

សេត សួរដូចមិនប្រាកដប្រជា គឺគ្រាន់តែត្រូវការបេះបួយនាងប៉ុណ្ណោះ ដើម្បីមើលកាយវិការផ្អើលៗគួរឱ្យស្រឡាញ់របស់នាង។

ពៅព្រលឹង កុហកមិនទំនងទេ!

អ្នកកំលោះ ឃើញនាងលួចសម្លក់សម្លឹងគេ តែគេធ្វើជាមិនឃើញ។ បើនាងជា សាន់នី គឺត្រូវតែងរង៉ក់ដាក់គេ អាការៈបែបហ្នឹងរបស់នាងគេមិនធុញទ្រាន់ ព្រោះគេអាចយកឈ្នះនាងបាន។

មនុស្សឆ្កួត ធ្វើឱ្យធ្លាក់ថ្លើមជារឿយៗ!

នាងក្រមុំបានតែតវ៉ាគេនៅក្នុងចិត្ត ហេតុអីក៏គេឆ្លាតយ៉ាងនេះ ថែមទាំងកែវភ្នែកមុតស្រួចនោះ ក៏រំខាននាងទៀត។

"យ៉ាងម៉េច ដាស៊ី?"

"ខ្ញុំមិនប្រសព្វអធិប្បាយ"

នាងរកចម្លើយល្អ ដើម្បីយករួចខ្លួន បានទាំងប្រជិតប្រជើយ សេត ក៏ព្រមឱ្យនាងបានចិត្តសិនទៅចុះ ហើយបក់ដៃឱ្យដើរមករក ហើយពេលនាងគ្រវីក្បាល ទើបគេគំរាម។

"ម៉ោណេះ!"

"មិនទៅបានទេ?"





Scanned by CamScanner

"មិនបាន"

"តែ...ខ្ញុំមិនសូវអូខេ"

"មិនអូខេអី ខ្ញុំជាចៅហ្វាយ ខ្ញុំហៅឯង ឯងត្រូវតែម៉ោ អានេះ! ម៉េចក៏រឿងច្រើនម្ល៉េះ"

"ទៅរកក៏បាន"

នាងបង្ខំចិត្តដើរទៅរក ព្រោះខ្លាចគេខឹង។ ស្ថានភាពរបស់នាងមិនទាន់មានសុវត្ថិភាព ព្រោះជាថ្ងៃដំបូងដែលឡើងមកលើកោះ មិនទាន់ដឹងគំនិតរបស់សេត គេគ្មានថ្ងៃឱ្យនាងចេញពីកោះនោះទេ ក្រៅពីគេធុញទ្រាន់នាងនោះឯង ប៉ុន្តែទោះគេធុញទ្រាន់ បើនាងត្រូវការការពារគេនឹងប្រគល់ឱ្យនាង ឃៃរ៉េល និង អាដាំ មិនហ៊ានខ្លាំងដាក់គេនោះទេ បើដឹងថាគេជាអ្នកណា។ ឃៃរ៉េល និង អាដាំ ដឹងត្រឹមថាគេគួរតែមានតំណែងធំនៅលើកោះចោរតែប៉ុណ្ណោះទើបយកចិត្តយកថ្លើមគេហាក់ដូចទេវតា។

បើពីរនាក់នោះដឹងថាគេជាម្ចាស់តូចនៃកោះចោរ មានឬហ៊ានខ្លាំងដាក់គេ គ្រាន់តែគេងឿងឆ្ងល់នឹង សាន់នី គេត្រូវហៅថាលោក សេត ប៉ុន្តែនាងនៅតែមិនដឹងថាគេជាអ្នកណា ពេញមួយជីវិតរបស់នាងប្រហែលមិនធ្លាប់ចេញពីណាខាដៀ មែនហ្នឹង។

"លោក សេត មានអីឱ្យខ្ញុំបម្រើឬ ?"

"ខ្ញុំនាំទៅមើលបន្ទប់ទឹក"

"បាទ លោក សេត"

នាងភ្លេចខ្លួនសម្លក់សម្លឹងទៀតហើយ មិនព្រមប្រាប់ពីដំបូង បែរជាធ្វើខ្លួនអាថ៌កំបាំង ដែលធ្វើឱ្យនាងមិនហ៊ានចូលទៅជិត គេមានចេតនាញ៉ោះនាង ឬគេជាមនុស្សបែបនេះស្រាប់ទៅហើយ។

"បន្ទប់ទឹក បែងចែកជាបន្ទប់ធំនិងបន្ទប់តូច"

គេនាំនាងដើរសំដៅទ្វារចូលបន្ទប់ទឹក នៅខាងក្នុង ធ្វើឱ្យនាងនឹកដល់ហារ៉េមដ៏ប្រណិត អាងទឹកធំ តុបតែងលម្អយ៉ាងវិចិត្រ ធ្វើឱ្យនាងអធិប្បាយមិនត្រូវ។

"តាមធម្មតាខ្ញុំងូតទឹកនៅបន្ទប់តូច ប្រើបន្ទប់ធំតែថ្ងៃពិសេសប៉ុណ្ណោះ"

"ថ្ងៃអី ?"

"ថ្ងៃដែលមានមនុស្សស្រីមកប្រណិបត្តន៍"

កែវភ្នែកឆ្មាសឆ្មើម ងាកខ្ទាប់បាញ់ដាក់ សេត ភ្លាម ធ្វើឱ្យអ្នកកំលោះលើកចិញ្ចើមបន្តិច តែធ្វើជាមើលមិនឃើញ។



"ត្រាំទឹកក្នុងអាងជាមួយគ្នា ហើយពួកនាងក៏ម៉ាស្សាខ្លួនឱ្យខ្ញុំ ម៉ាស្សា



Scanned by CamScanner

ប្រេង ឬម៉ាស្សាបន្ធូរអារម្មណ៍បែបផ្សេង"

"ពួកនាង ?"

ម្តងនេះក្រៅពីខ្សែភ្នែកឆ្ងាសឆ្ងើមហើយ នាងនៅដំឡើងសំឡេងទៀតផង ថែមទាំងចង់ទាញស្លឹកត្រចៀកគេឱ្យដាច់ ប្រុសព្រានមិនចេះស្កប់ស្កល់។

"អាងងូតទឹកធំយ៉ាងនេះ ឯងប្រហែលមិនគិតថាខ្ញុំដេកត្រាំជាមួយមនុស្សស្រីតែម្នាក់ទេមែនទេ បើខ្ញុំប្រើអាងធំ យ៉ាងហោចណាស់ក៏មានមនុស្សស្រីចាប់ពីប្រាំនាក់ឡើងទៅដែរ"

"ប្រាំនាក់"

"មែន ខ្ញុំគួរឱ្យប្រណែនមែនទេ"

"បាទ គួរឱ្យប្រណែនណាស់!"

នាងខាំធ្មេញឆ្លើយ សេត វិះតែបានឮសំឡេងខាំធ្មេញក្រតៗរបស់នាងទៅហើយ គេសរុបបានឬអត់ ថានាងកំពុងប្រចណ្ឌគេ។

"ឯងមិនធ្លាប់ទេអី"

"ខ្ញុំមិនធ្លាប់ពាសវាលបែបហ្នឹងទេ"

"ឯងនិយាយថាម៉េច"

"អឺ...ខ្ញុំចង់មានន័យថា ខ្ញុំមិនធ្លាប់ធ្វើបែបហ្នឹងទេ"



Scanned by CamScanner

"ឯងនៅព្រហ្មចារីឬយ៉ាងម៉េច?"

សេត សួរ សាន់នី ឆ្លើយមិនបាន នាងមិនមែនជាស្រីព្រហ្មចារីទៀតទេ គឺគេនោះឯង ដែលជារីបអូសយកវាពីនាង។

"អត់...អត់ទេ ខ្ញុំមិននៅព្រហ្មចារីទេ"

សេត ក្ដាញ់ថ្ពាល់ក្រហមងាំងរបស់នាងមែនទែន ចង់ថើប ចង់ជញ្ជក់ឱ្យខ្លាំងៗ ហើយលើកនាងព។

អត់ធ្មត់ សេត តិចក្ដាន់ផ្អើល!

"មុខមាត់មិនដឹងខ្យល់អី តែក៏ខ្លាំងដៃណាស់ដែរឯង"

"តែខ្ញុំមិនសាំសនទេ ខ្ញុំមានស្អីៗជាមួយមនុស្សតែម្នាក់ប៉ុណ្ណោះ"

"ល្អហើយ អ្នកដែលឯងមានស្អីៗជាមួយ ប្រហែលមានមោទនភាព"

"មិនដឹងទេ ព្រោះមើលទៅគេដូចសាំសន"

"គេ? ឯងឡើងគ្រែជាមួយមនុស្សប្រុសឬយ៉ាងម៉េច"

"មិន...មិនមែនទេ!"

"ម៉េចក៏ប្រញាប់បដិសេធម្ល៉េះ ខ្ញុំគ្រាន់តែលេងសើចទេ ឯងនេះ ប៉ិនផ្អើលមែនទែន តាមខ្ញុំចេញទៅខាងក្រៅ នាំទៅមើលផ្ទះត្រួសៗ កុំឱ្យវង្វេង"





Scanned by CamScanner

# ១០

## មនុស្សកាច

"ចូលទៅ"

គ្រីស បើកទ្វារផ្ទះរបស់ខ្លួនឲ្យ ធីណា ដើរចូល ព្រោះគេត្រូវចៅហ្វាយបញ្ជាឲ្យការពារនាង ការពារមនុស្សស្រីដែលហ៊ានបន្លំខ្លួនធ្វើជាមនុស្សប្រុស ។

*រញ៉េរញ៉ៃណាស់ ស្រីល្ងីល្ងើ!*

គ្រីស មិនចូលចិត្តស្រីល្ងង់ ល្ងីល្ងើ ទន់ជ្រាយ ប៉ុនយំ និងផ្សេងទៀតដែលបូករួមជាមនុស្សស្រីទន់ភ្លន់។ គេនឹងមានអារម្មណ៍ល្អជាងនេះ បើបានជួបមនុស្សស្រីដែលមើលថែខ្លួនឯងបាន ព្រោះគេប្រហែលគ្មានពេលមើលថែនាង។

"បាទលោកស្រី"

ការធ្វើខ្លួនស្តាប់បង្គាប់គឺជារឿងដែល ធីណា ស្ទាត់ ។ នាងជាក្មេងល្អស្តាប់បង្គាប់បងស្រី និងបន្ថែមឈ្មោះរបស់ សេត ចូលទៅក្នុងបញ្ជីដែរ ព្រោះគេជាបងថ្លៃរបស់នាង ទោះគេមិនចូលចិត្តឲ្យនាងហៅថាលោកបងថ្លៃក៏ដោយ



Scanned by CamScanner

ហើយពេលនេះក៏ត្រូវបន្ថែមឈ្មោះ ប្រុសមាឌយក្ស មហាកាចម្នាក់នេះ ចូលមួយទៀត ព្រោះគេគួរឲ្យខ្លាចខ្លាំងណាស់ ។

"នេះជាផ្ទះរបស់ខ្ញុំ"

"អា! ខ្ញុំមកខុសផ្ទះឬ?"

"មិនខុសទេ"

សួរប៉ុណ្ណឹង ចាំបាច់ដំឡើងសំឡេងដាក់ដែរ គឺខ្លួនឯងនិយាយថាជាផ្ទះរបស់ខ្លួន មិនមែនផ្ទះរបស់នាង មនុស្សប្រុសស្អី ពិបាកយល់មែន។

"បាទលោក គ្រីស"

ចេះតែអ៊ឺអើតាមសិនទៅ ទោះមិនសូវយល់ពីគេប៉ុន្មានក៏ដោយ ឬនិយាយឲ្យត្រូវ នាងមិនយល់ពីគេអីបន្តិច ។

"យល់ហើយ គឺត្រូវធ្វើខ្លួនឲ្យបានល្អ"

"បាទ ខ្ញុំត្រូវនៅជាមួយលោក គ្រីស មែនទេ?"

"មែន"

"ខ្ញុំជាភ្ញៀវរបស់លោក គ្រីស ឬ?"

ធីណា នឹករូបភាពមិនចេញ នាងជាស្អីបានទៅ ក្រៅពីភ្ញៀវរបស់គេ ព្រោះនាងជាអ្នកមកផ្ទះរបស់គេ តែចម្លើយដែលនាងបានទទួល គឺកែវភ្នែក





Scanned by CamScanner

កាច។

*អូយ! គួរឲ្យខ្លាចខ្លាំងណាស់!*

នាងខ្លាចគេ ទើបធ្វើខ្លួនទ្រោនៗ ថយក្រោយយឺតៗ ទាល់តែទៅឈរជិតកៀនជញ្ជាំងបាន។

"ឯងជាកូនចៅ មិនមែនភ្ញៀវ"

"បាទ កូនចៅក៏កូនចៅ"

ធីណា ម៉េចនឹងហ៊ានតវ៉ាទៅ បើកែវភ្នែកកាចនោះ គ្រាន់តែក្រឡេកមួយខ្ទាច់ ក៏ធ្វើឲ្យនាងទន់ជង្គង់ទប់ខ្លួនមិនចង់នឹងទៅហើយ ។

"អីចឹងហើយឯងត្រូវស្តាប់បង្គាប់ខ្ញុំ"

"បាទ ខ្ញុំនឹងស្តាប់បង្គាប់លោក គ្រីស"

"ហាមរឹងក្បាលដាក់ខ្ញុំ"

"ខ្ញុំមិនរឹងទេ ខ្ញុំជាក្មេងល្អ"

នាងឆ្លើយតប ដោយសំឡេងច្បាស់លាស់ ដូចទុកចិត្តចំពោះការធ្វើជាក្មេងល្អរបស់ខ្លួនខ្លាំងណាស់ គ្រីស ក៏លួចដកដង្ហើមធំ នាងគ្រាន់តែជាមនុស្សស្រីវ័យម្ភៃឆ្នាំ ដែលគួរតែមានខួរក្បាលប្រហែលក្មេងប្រាំឆ្នាំ។

"ហាមបង្ករឿង"



Scanned by CamScanner

"ខ្ញុំមិនចូលចិត្តមានរឿង ខ្ញុំខ្លាច"

"ហាមបង្កបញ្ហា"

នាងទៅបង្កបញ្ហាអីបានទៅ នាងមិនចូលចិត្តបង្កបញ្ហាផង ប៉ុន្តែនាងត្រូវទទួលសិនទៅ ដើម្បីមិនឲ្យគេខឹង។

"បាទលោក គ្រីស"

"ហាមបង្កភាពក្ដៅក្រហាយ"

"បែបណាទៅ ខ្ញុំមិនយល់"

"គ្រប់រឿង"

ក្រៅពីគេកាចហើយ នៅពិបាករស់នៅជាមួយទៀតផង ហេតុអីនាងត្រូវមកនៅជាមួយគេដែរ ប៉ុន្តែនាងត្រូវអត់ធ្មត់ ដើម្បីមិនឲ្យបងស្រីបារម្ភ។

"បាទលោក គ្រីស គ្រប់រឿងក៏គ្រប់រឿង"

"សរុបទៅឯងយល់ច្បាប់របស់យើងហើយ"

"បាទ ខ្ញុំយល់ក៏បាន"

"យល់ក៏បាន ?"

"យល់ ខ្ញុំយល់ហើយ" ធីណា ប្រញាប់ប្ដូរចម្លើយ គ្រីស ក៏ចង្អុលទៅបន្ទប់ដេក។ ផ្ទះរបស់គេគឺជាផ្ទះដែលមានបន្ទប់ដេកមួយ បន្ទប់អង្គុយលេងមួយ





Scanned by CamScanner

បន្ទប់ទឹកនៅក្នុងបន្ទប់ដេក និងមានផ្ទះបាយតូច សម្រាប់ធ្វើម្ហូបអាហារ ដែលតាមពិតទៅ វាក៏ងាយស្រួល ធំជាងបន្ទប់ដែលនាងធ្លាប់ស្នាក់អាស្រ័យនៅណាខាងៗ ទៅទៀត។

"គ្រែមានតែមួយ ត្រូវចែកគ្នាដេក ប្រហែលគ្មានបញ្ហាអីទេ"

"បាទគ្មានបញ្ហាទេ"

គ្រែធំទូលាយ នាងមានមាឌតូចតែមួយ ស៊ីផ្ទៃក្រឡាមិនច្រើនទេ នាងនឹងធ្វើខ្លួនជាក្មេងល្អ កុំឲ្យគេស្តីឲ្យ ព្រោះនាងត្រូវនៅទីនេះយូរទៀត យ៉ាងហោចណាស់ក៏បីខែដែរ នាងនឹងដើរតាមគេត្រុកៗ គេទៅណានាងទៅនោះ ។

**"ឯងជាមនុស្សប្រុសដែលងូតទឹកយូរខ្លាំងណាស់"**

សេត អង្គុយអានសៀវភៅនៅលើសាឡុង ពាក់អាវយឺតតែមួយប៉ុណ្ណោះដើម្បីត្រៀមខ្លួនចូលដេក ។ ថ្ងៃដំបូងនៃការធ្វើការ គេនាំ សាន់នី ដើរមើលទាល់តែសព្វផ្ទះធំរបស់គេ ប៉ុន្តែទោះយ៉ាងណាក៏នាងនៅតែមិនហ៊ានសួរដដែល ថាគេជាអ្នកណានៅលើកោះនេះ ។

**លោក សេត! លោក សេត!**

កម្មករហៅគេបែបហ្នឹង ចំណែកអ្នកខ្លះហៅគេថា **ម្ចាស់តូច** ប៉ុន្តែរឿងមួយ



Scanned by CamScanner

ដែលនាងដឹង គឺគេមិនមែនឈ្មោះ ម៉ារីស។ នាងចង់ខឹងគេ ឬមិនអីចឹង ប្រហែល ខឹងបាត់ទៅហើយ ទាស់ត្រង់ថាមិនបង្ហាញឲ្យឃើញ។

"អឺ...ខ្ញុំសុំទោស"

"ខ្ញុំមិនបានថាអីទេ គ្រាន់តែសង្ស័យថាឯងសម្អាតអីណាស់ណា ខ្លួនតូចតែមួយ"

សាន់នី មានទម្លាប់បែបនេះ ព្រោះត្រូវបង្រៀនឲ្យមើលថែខ្លួនប្រាណរបស់ខ្លួនឯង ដើម្បីសម្រស់ ទើបការងូតទឹកយូរ ក្លាយជាទម្លាប់ទៅហើយ។

"ខ្ញុំនឹងងូតឲ្យលឿនជាងនេះ"

"មិនអីទេ ខ្ញុំប្រាប់ហើយតើថាខ្ញុំមិនបានថាអីឲ្យឯងទេ"

"បាទលោក សេត"

នាងរកមើលកន្លែងដេករបស់ខ្លួនឯង ។ នាងត្រូវដេកជាមួយ សេត នៅក្នុងបន្ទប់នេះ ប៉ុន្តែតើដេកត្រង់ណាទៅ តាមពិតគេមានសាឡុងច្រើននៅក្នុងបន្ទប់ ប៉ុន្តែកម្មករអាចដេកនៅលើសាឡុងបានឬអត់ នាងអាចត្រូវដេកលើកម្រាល ដែលត្រូវរង់ចាំបញ្ជាពីគេ។

"ចូលដេកទៅ"

"លោក សេត"





Scanned by CamScanner

"ស្អីទៀតហើយ"

"លោកឲ្យខ្ញុំដេកនៅកន្លែងណា ?"

"លើគ្រែ"

សេត ឆ្លើយច្បាស់លាស់ ដោយទឹកមុខស្មើ ឆ្លើយដូចវាជារឿងធម្មតា ខណៈនោះក៏បិទសៀវភៅ ហើយនាំនាងដើរទៅរកគ្រែ និងឈរងក់ក្បាលឲ្យនាងដើរមករក។

"បាទ ? លើគ្រែឬ"

"ឯងបានឮហើយតើ ម៉េចចាំបាច់សួរ"

"តែខ្ញុំគ្រាន់តែជាកម្មករ"

"នោះ ក៏ច្បាសលាស់ហើយថាខ្ញុំជាចៅហ្វាយចិត្តទូលាយ"

"តែ លោក សេត ខ្ញុំគិតថា..."

សេត លើកដៃហាមប្រាម គំនិតរបស់នាងក៏ត្រូវផ្អាកត្រឹមហ្នឹង ។ គេមិនយល់ស្របដែលនាងបញ្ចេញយោបល់ នាងមានតួនាទីស្តាប់បង្គាប់គេតែប៉ុណ្ណោះ។

"ឯងមិនបាច់គិតអីច្រើនទាំងអស់"

"បាទលោក សេត"



Scanned by CamScanner

"តួនាទីរបស់ឯងគឺស្តាប់បង្គាប់ខ្ញុំ"

ជាបញ្ហាដែលខុសពីចរិតរបស់ សាន់នី នាងចង់បដិសេធ ចង់បង្ហាញពីគោលជំហររបស់ខ្លួន ប៉ុន្តែការឃោងអាត្មាឲ្យរស់រាំមានឥទ្ធិពលជាង។

"បាទលោក សេត"

"មកដោះអាវឃ្លុំឲ្យខ្ញុំ"

កែវភ្នែករបស់នាងលាយឡំដោយភ្លើងទោសៈ ដូចវាជះរស្មីឲ្យឃើញហើយ សេត ក៏ចូលចិត្តមើលវាបែបនោះខ្លាំងណាស់។ សាន់នី ដើរទៅរកគេនាងមិនចង់ព្រម តែក៏ត្រូវព្រម លូកដៃទៅស្រាយខ្សែអាវឃ្លុំ ហើយក៏គិតដល់រូបភាពដែលគេនិងនាងធ្លាប់ណែបនិត្យជិតគ្នារាប់ដងមិនអស់ ។

នាងក្រមុំងើយមើលមុខគេ សេត ក៏ឱនមករក ហើយពួកគេក៏ប្រសព្វភ្នែកគ្នា ដូចនាងនិងគេនៅក្នុងឋានៈជា ម៉ារីស និង សាន់នី ប៉ុន្តែនាងត្រូវគ្រវីក្បាលបណ្តេញគំនិតនោះចេញ និងប្រញាប់ប្រញាល់ដោះអាវឃ្លុំឲ្យគេ ។

នាងឃើញរាងកាយនននលគករបស់គេឡើងសុំទៅហើយទើបមិនផ្អើលនឹងវា មានការដង្ហោយរក រត់មកចុកក្នុងអារម្មណ៍របស់នាង ។ នាងយកអាវឃ្លុំទៅពាក់នឹងកៅអី ហើយពេលនាងបែរខ្នង សេត ក៏ឡើងទៅលើគ្រែ ទះពូកក្បែរខ្លួនដែលត្រឹមប៉ុណ្ណឹង នាងក៏ដឹងពីជោគវាសនារបស់ខ្លួនទៅហើយ ។





Scanned by CamScanner

ការតវ៉ានឹងការមិនកើតជាប្រយោជន៍អីទេ ក្រៅពីធ្វើឲ្យនាងហត់នឿយ ឬដែលធ្ងន់ធ្ងរជាងនោះ គឺធ្វើឲ្យគេខឹង ។ នាងដើរទៅរកគេ ឡើងទៅលើគ្រែជាមួយនិងសម្ងំដេកឲ្យឆ្ងាយបំផុត ហើយពេលគេបិទភ្លើង នាងក៏ប្រែខ្លួនបែរខ្នងដាក់។

ការដេកនៅជិត សេត គឺជារឿងវេទនា ព្រោះនាងធ្លាប់សម្ងំដេកនៅក្នុងរង្វង់ដៃរបស់គេ។ នាងលើកដៃឱបខ្លួនឯង តែបន្ទាប់មកក៏ត្រូវទាញទៅជិតរាងកាយមាំមួន ធ្វើឲ្យនាងភ្ញាក់កន្ត្រាក់ ពេលដែលត្រូវគេស្រវាឱប។

"រាត្រីសួស្តី"

"មនុស្សប្រុសដេកជាមួយគ្នាបែបនេះឬ?"

"ខ្ញុំចូលចិត្តដេកបែបនេះ"

គេឆ្លើយតបបែបទំនើង ហើយហេតុផលរបស់គេក៏ធ្វើឲ្យនាងមិនអាចប្រកែកប្រណាំងបាន។ សេត ដាក់ចង្កាលើក្បាលរបស់នាង ដៃឱបក្រសោបនាង ខណៈដែល សាន់នី ក៏ភ្លេចខ្លួន អែនខ្នងទៅពិតនឹងដើមទ្រូងកក់ក្តៅ។

"រាត្រីសួស្តី"

នាងធ្វើមាត់មួបៗនិយាយ តែមិនចេញសំឡេង ហើយមិនយូរប៉ុន្មានដោយសារល្ហើយ តានតឹងនឹងបញ្ហាដែលត្រូវពន់រែក ក៏ធ្វើឲ្យនាងលង់លក់។



Scanned by CamScanner

ធីណា មិនហ៊ានដេកមុន ត្រីស គិតតែអង្គុយសំកុកលើសាឡុង ដោយអារម្មណ៍ច្របូកច្របល់ រង់ចាំគេ ទាំងដែលងងុយស្ទើរស្លាប់ ប៉ុន្តែគេបែរជាអង្គុយបែរខ្នងដាក់នាង មមាញឹកនឹងការងារនៅលើតុ។

"ងងុយចង់ងាប់ទៅហើយ"

គេភ្លេចឬអត់ ថាមាននាងនៅក្នុងពិភពលោកនេះដែរ អង្គុយដកដង្ហើមដោយការក្រេងក្រែងចិត្តនៅក្នុងបន្ទប់ជាមួយគេ បើគេនៅតែមិនដេក គួរតែបញ្ជាឲ្យនាងដេកសិន។

"ងងុយមែនទែន"

ចង់ហាមាត់សួរគេ តែខ្លាចខ្លាំង មនុស្សស្អីអាងអីស្តីឲ្យ អាងអីកាច មើលធម្មតាៗក៏ចង់ញ្ញើញចង្កូមដាក់នាងរហូត។

"គ្រែអើយគ្រែ"

នាងសម្លឹងមើលគ្រែដេក ចង់ផ្តួលខ្លួនទៅលើនោះ សម្ងំនៅក្នុងភួយ តែម្ចាស់បន្ទប់មិនដឹងជាស្អី មិនខ្វល់ពីភ្ញៀវសោះ។

"ភ្លេចទៅ គេមិនចាត់ទុកយើងជាភ្ញៀវ"

ធីណា លើកដៃអេះក្បាល នាងត្រូវពាក់សក់ក្លែងក្លាយចូលដេក ដែលវាលំបាកខ្លាំងណាស់ ទើបមានគំនិតថា ស្អែកនេះនឹងកាត់សក់ ឲ្យវាចប់រឿង ។





Scanned by CamScanner

"ដេកចាំត្រង់នេះក៏បាន"

នាងផ្ទួលខ្លួនដេកលើសាឡុង បើដល់ពេលដេក គេគង់តែហៅ ពេលនេះសុំដេកត្រង់នេះសិនទៅចុះ។

"រាត្រីសួស្ដីលោក កាច"

នាងក្រមុំដេកមើលខ្នងធំទូលាយរបស់គេ គ្រីស ជាមនុស្សប្រុសមាឌធំ និងមានមាឌធំជាងនាងឆ្ងាយណាស់ ប៉ុន្តែព្រោះគេជាមនុស្សប្រុស មនុស្សប្រុសគួរតែមានមាឌធំជាងមនុស្សស្រី ដើម្បីការពារនិងឃុំគ្រង។

"ឃុំគ្រងស្អីគេ តែមានស្ដីឲ្យ"

លោកបងថ្លៃរបស់នាងថាកាចហើយ ប៉ុន្តែនៅមិនចូលចិត្តកាចគ្រប់ពេលវេលា គួរឲ្យខ្លាចដូច គ្រីស ម្នាក់នេះគ្រាន់តែដកដង្ហើមខ្លាំងបន្តិច ក៏ធ្វើឲ្យនាងភ័យឡើងញ័រខ្លួន។

"នឹងដេកថ្នមៗ"

នាងប្រាប់ខ្នងធំទូលាយរបស់គេ ត្របកភ្នែកក៏បិទ និងដោយសារល្វើយ ហើយជាមនុស្សស្រីដែលចូលចិត្តដេកច្រើន ទើបនាងលង់លក់ស្ទើរតែភ្លាមៗ។

"មនុស្សអីចូលចិត្តស្ដីឲ្យ"

ថ្នាក់ដេកលក់ទៅហើយនៅតែមមើតិចៗ គ្រីស មិនបានឮ ព្រោះកំពុង



Scanned by CamScanner

តែមមាញឹកនឹងការងារ ត្រូវប្រឹងប្រែងធ្វើឲ្យរួចរាល់ ដោយភ្លេចទៅថានៅក្នុងបន្ទប់មានមនុស្សស្រីល្ងីល្ងើ មេបញ្ហាមកនៅជាមួយ ហើយនាងក៏រង់ចាំគេមិនបាន ក៏ដេកលក់មុនទៅ។

ប្រហែលមកពីស៊ាំនឹងចំហាយកក់ក្តៅ ពីរាងកាយបុរស ទើប សាន់នី ដេកលក់ស្រួល។ រង្វង់ដៃរបស់ សេត ធ្វើឲ្យនាងមានអារម្មណ៍ធូរស្រាល ភាពតានតឹងក៏រសាយ មុខមាត់កាន់តែស្រស់ស្អាត ផ្អែមល្ហែមគួរឲ្យថ្នាក់ថ្នម។

នាងដេកលក់ ប៉ុន្តែ សេត មិនទាន់ដេក គេបើកភ្នែក ឈោងដៃទៅបើកអំពូលភ្លើង ប៉ុន្តែបើកវាព្រឹមៗប៉ុណ្ណោះ ព្រោះមិនត្រូវការឲ្យពន្លឺភ្លើងរំខានការដេកពួករបស់នាង ប៉ុន្តែបើឲ្យដេកមើលនាងនៅក្នុងភាពងងឹត វាមិនសក្តិសមនឹងចិត្តគេ។

អ្នកកំលោះដោះសក់ក្លែងក្លាយចេញពីក្បាលរបស់នាងដោយធ្វើវាថ្នមៗបំផុត ព្រោះមួម៉ៅនឹងសក់ក្លែងក្លាយចង្រៃយក៍នេះ ហើយទាញកៅស៊ូចេញពីសក់រលោង ប្រើដៃក្រសោបវាលើកមកស្រង់យកក្លិន ក្លិននេះហើយដែលគេត្រូវការ ចំណែកសក់ពាក់ដាក់វាក្បែរខ្នើយខាងនាង។

"នឹកឃើញយ៉ាងម៉េចបានជាបន្លំខ្លួនជាមនុស្សប្រុស"





Scanned by CamScanner

មុខមាត់ស្រស់ស្រទន់ដូចផ្កា រាងកាយតូចស្តើង គេចាប់ដៃរបស់នាងបើប ហើយក្តោបដោយការថ្នាក់ថ្នម ដៃទន់ល្មើយបែបនេះ អាចធ្វើការអីបានទៅ។

"នាងសក្តិសមធ្វើការងារនៅលើគ្រែឲ្យខ្ញុំប៉ុណ្ណោះ"

សេត មិនសួរយោបល់ សាន់នី ថានាងត្រូវការធ្វើតួនាទីនេះឬអត់ គេចង់ឲ្យធ្វើនាងត្រូវតែធ្វើ ព្រោះនាងជារបស់គេ ។

"ស្រីឆ្នាស"

គេឱនថើបថ្ពាសរបស់នាង ដែល សាន់នី មិនភ្ញាក់ ដេកលក់ស្រួលដល់ហើយក្នុងរង្វង់ដៃរបស់គេ ហាក់ដូចជឿទុកចិត្ត។

"ហើយនេះស្អី របស់ក្មេងលេងច្បាស់ណាស់"

ក្រៅពីសក់ក្លែងក្លាយគួរឲ្យធុញទ្រាន់នោះហើយ នៅមានពុកមាត់ដែលនាងពាក់លើបបូរមាត់ ក៏ទើសទែងភ្នែកគេណាស់ដែរ ប៉ុន្តែគេត្រូវអត់ធ្មត់នឹងវាសិន។

"នាងស្អាតយ៉ាងនេះ បន្លំខ្លួនយ៉ាងណាក៏មិនដូចមនុស្សប្រុសដែរពៅព្រលឹង"

គេអង្អែលថ្ពាល់របស់នាងថ្នមៗ មូរសក់រលោងនឹងម្រាមដៃរបស់នាង



Scanned by CamScanner

លេង ហើយក៏ជ្រេងវា ដោយអារម្មណ៍ភ្លើតភ្លើន ធ្វើឲ្យ សាន់នី មានអារម្មណ៍ដូចត្រូវបំពេឲ្យដេក។

"ក្រអូបផស់គេ"

គេប្រមៀលប្រមុះនឹងថ្ពាល់រលោង លូកដៃចូលទៅក្នុងអាវយឺត ដែលនាងរុំក្រណាត់នឹងដើមទ្រូងពិតមែន។

គេនឹកដើមទ្រូងទ្រលុកទ្រលន់របស់នាង ហើយក៏អាណិតវា ដែលត្រូវរុំឡើងសំប៉ែតបែបនេះ។

"ដល់ពេល ខ្ញុំនឹងដោះលែងឯង"

គេសន្យានឹងវា ដោយគែមមាត់មានស្នាមញញឹមកំណាច មិនដឹងថាគេអត់ធ្មត់នៅជិតនាងដោយមិនធ្វើអីនាងបែបនេះដល់ពេលណា ទ្រាំមិនបានថ្ងៃណា គេនឹងចាត់ការនាងថ្ងៃនោះ។

"ស្រីល្ងីល្ងើ"

គ្រីស ឈរមើលអ្នកដែលដេកលក់លើសាឡុង ហើយលូកដៃទៅអង្រួនដើម្បីឲ្យនាងភ្ញាក់ ប៉ុន្តែ ធីណា មិនព្រមភ្ញាក់ ទើបអង្រួនកាន់តែខ្លាំង ប៉ុន្តែនាងនៅតែបញ្ជោក់ពីគោលជំហររបស់ខ្លួន គឺដេកលក់នោះឯង។





Scanned by CamScanner

"ភ្ញាក់ភ្លាម"

គ្រែមានឲ្យដេកបែរជាមិនដេក មកដេកលើសាឡុងទៅវិញ អំពល់ទុក្ខឲ្យគេត្រូវមកខាតពេលដាស់នាងទៀត ថែមទាំងពិបាកដាស់មែនទែន ដាស់យូរហើយនៅតែមិនព្រមភ្ញាក់។

"ភ្ញាក់ឡើងស្រីល្ងីល្ងើ ភ្ញាក់!"

គ្រីស ឡូឡា ដែលសំឡេងខ្លាំងៗរបស់គេ មានតម្លៃត្រឹមឲ្យ ធីណា ប្រែខ្លួនបន្តិចប៉ុណ្ណោះ ទើបគេដកដង្ហើមធំ។ នេះគេក្លាយជាអ្នកមើលថែក្មេងទៅហើយឬនេះ។

"ខាស៊ី"

ឈ្មោះនេះ គ្មានឥទ្ធិពលចំពោះ ធីណា ព្រោះមិនមែនជាឈ្មោះពិតរបស់នាង វាជាឈ្មោះក្លែងក្លាយ បានឮហើយដូច គ្រីស ហៅអ្នកដទៃ។

"ធីណា"

គ្រីស ដាក់បង្អួយនៅមុខសាឡុង លូកដៃទៅកេះនាង និងហៅឈ្មោះពិត ទើបអ្នកដេកលក់ប្រែខ្លួន។

"បង សាន់នី"

នាងលើកដៃស្រវេស្រវាមកប៉ះខ្លួនគេ គ្រីស ក៏សម្លឹងមុខនោះមិនដាក់

ភ្នែក ហើយក៏សម្រេចចិត្ត លូកដៃទៅក្ដិចថ្ពាល់របស់នាង ដែលធ្វើឲ្យនាងបើកភ្នែកភ្លាម។

"អូយ! ឈឺ"

នាងស្ទុះងើបពេលឃើញមុខរបស់ គ្រីស ហើយថយក្រោយ ទៅពិតនឹងជញ្ជាំងខាងក្រោយ មើលគេដោយការភ័យខ្លាច។

"លោក...លោក គ្រីស"

"គ្រែមានម៉េចក៏មិនដេក"

គ្រីស ងើបឈរយឺតៗ នាងក៏មើលគេហើយធ្វើមុខសោកសៅ ព្រោះត្រូវស្ដីឲ្យទៀតហើយ គ្រីស មើលនាងហើយ ក៏លូកដៃមកចាប់ដើមដៃរបស់នាងទាញឲ្យងើបឈរ។

"សួរម៉េចក៏មិនឆ្លើយ"

"មិនហ៊ានដេក លោកមិនទាន់អនុញ្ញាត ខ្លាចត្រូវស្ដីឲ្យ"

"លើកក្រោយ បើងងុយដេកមុនទៅ បានឮទេ"

"បាទ បានឮហើយ"

គ្រីស នាំក្មេងស្រីមេញ្ញោដើរទៅរកគ្រែ ដោយឡើងគ្រែម្ខាងម្នាក់ និងដេកបែរខ្នងដាក់គ្នា។



...

**សាន់នី រំកិលខ្លួនទៅឱប សេត នាងដេកលក់ យល់សប្តថាបានដេកនៅ**
ក្នុងរង្វង់ដៃរបស់គេ ក្នុងបន្ទប់នៅ ណាខាដៀ។

"លោក ម៉ារីស"

សេត ឱនទៅថើបថ្ងាសរបស់នាង។ មិនដឹងថានាងនិងប្អូនស្រីល្ងីល្ងើរបស់នាងទៅជួបនឹងរឿងអ្វីខ្លះ ប៉ុន្តែពេលនាងមកនៅក្នុងរង្វង់ដៃរបស់គេទៅហើយ ក្រៅពីខ្លួនឯងហើយ គឺមិនព្រមឲ្យអ្នកណាធ្វើបាបនាងជាដាច់ខាត។

"ខ្លាច..."

"ខ្លាចអីពៅព្រលឹង"

គេឱបក្រសោបនាងជាប់ដើមទ្រូង នាងក៏ត្រសុលទៅរក ឲ្យគេទាំងឱបទាំងថើបដើម្បីលួងលោម។

"យល់សប្តអាក្រក់ឬ"

គេអង្អែលខ្នងនាងជាការលួងលោម។ គេមិនបដិសេធនោះទេ ពេលនាងត្រសុលមកបៀត មានតែផ្តល់ភាពងាយស្រួលឲ្យ ឲ្យបបូរមាតទន់ល្មើយថើបមុខរបស់គេ។

"យល់សប្តឃើញពេលយើងនេះនោះគ្នាឬយ៉ាងម៉េច"



Scanned by CamScanner

គេនិយាយទាំងអស់សំណើច ប៉ុន្តែអ្នកឆ្លើយនៅតែលង់លក់ ដូចនាងកំពុងមមើ។ គេចង់ចាប់ចង្ការបស់នាង ហើយខិនថើបបបូរមាត់ខ្លាំងៗ ប៉ុន្តែខ្លាចនាងភ្ញាក់ ទើបត្រូវអត់ធ្មត់។

"កុំញ៉ោះពេក បើមិនចង់ត្រូវគេលួចធ្វើអីពេលដេកលក់"

ប៉ុន្តែបើការអត់ធ្មត់របស់គេដល់ទីបំផុត គេត្រូវលុបចោលការតាំងចិត្តនោះ បន្ទាប់ពីគិតថាឲ្យនាងដេកស្រួលបួល ប្រហែលមិនបានដេកទៅជាញ៉ូវខ្លួន ព្រោះត្រូវគេចាប់សង្កត់។

"ដេកឲ្យស្រួលបួល ពៅព្រលឹង"

គេខិនថើបលួងលោម ព្យាយាមធ្វើឲ្យនាងស្ងប់ ព្រោះខ្លាចខ្លួនឯងគ្រប់គ្រងខ្លួនឯងមិនបាន។

"ពេញចិត្តហើយឬនៅ"

នាងស្អាតដូចទេពធីតាពេលដេកនៅក្នុងរង្វង់ដៃរបស់គេសក់វែងរំសាយរាយប៉ាយលើខ្លួនរបស់គេនិងខ្លួននាង។ សេត ទាញវាដោយចិត្តត្រជាក់ មិនព្រមឲ្យសក់របស់នាងដាច់សូម្បីតែមួយសរសៃ ទាល់តែរៀបចំវារួចរាល់។

"ដេកទៅ ចាំខ្ញុំការពារ"

គេខ្សឹបប្រាប់ ផ្ដល់ការជឿជាក់ឲ្យអ្នកដែលកំពុងដេកលក់ ទោះគេជាមេ





Scanned by CamScanner

គ្រោះថ្នាក់សម្រាប់នាងក៏ដោយ ប៉ុន្តែគ្រោះថ្នាក់តែនៅលើគ្រែប៉ុណ្ណោះ ចំណែករឿងផ្សេងគេពឹងពាក់បាន។

"ដេកលក់យល់សប្តល្អ ស្រីរបស់ខ្ញុំ"

គេជូនពរនាង លួងលោមដោយការឱបក្រសោប ឲ្យអ្នកនៅក្នុងរង្វង់ដៃស្ងប់និងលង់លក់ស្រួលម្តងទៀត ហើយគេក៏ឱបនាង ដេកលក់តាមដែរ។

"!"

គ្រីស ដកដង្ហើមធំ ពេលភ្ញាក់ឡើង ដោយមានវត្ថុទន់ល្មើយ សង្កត់លើខ្លួន។ គេស្មានថាមានមនុស្សមកលេងសើចនឹងគេ តែមានឯណា គឺក្មេងស្រីសំពីកនេះឯង។ គេលូកដៃកើយក្បាល សម្លឹងមើលអ្នកដែលដេកផ្កាប់មុខនៅលើខ្លួន។ នាងដេកលក់ស្រួលណាស់ និងមើលទៅដូចមានសេចក្តីសុខខ្លាំងទៀតផង។

នាងដាក់មេដៃនៅក្នុងមាត់ខ្លួនឯង ដេកបឺតឮជប់ៗ ដូចម្រាមដៃរបស់នាងឆ្ងាញ់ខ្លាំងណាស់។ នាងបោកអ្នកដទៃថាខ្លួនឯងជាមនុស្សប្រុសបានដោយរបៀបណាទៅ ក្នុងពេលដែលខ្វះការប្រុងប្រយ័ត្នខ្លួនឯងដល់ថ្នាក់នេះ។

គ្រីស មិនបានកម្រើកខ្លួន ព្រោះវេទនាអ្នកដែលមិនដឹងរឿងអី ប៉ុន្តែការ



Scanned by CamScanner

អត់ធ្មត់របស់គេក៏មានដែនកំណត់ដែរ ឲ្យពេលនាងតែដប់ប្រាំនាទីប៉ុណ្ណោះ បន្ទាប់ពីកន្លងផុតទៅដប់ប្រាំនាទី បើនាងមិនភ្ញាក់ គេនឹងដាស់។ គេព្រមធ្វើជាកម្រាលពូកឲ្យនាងទាំងដែលមានពូកមានខ្នើយទៅហើយ។

"ហ៊ឺ...ព្រឹកហើយឬ"

ធីណា ប្រែខ្លួននៅមិនសុខ ហើយក៏ភ្ញាក់មុនម៉ោងដែល គ្រីស អនុញ្ញាតនាងនៅក្នុងចិត្តទៅទៀត។

"ព្រឹកហើយ"

នាងបើកភ្នែកមិនទាន់ស្រឡះ ដាក់ដៃម្ខាងលើដើមទ្រូងធំទូលាយ ដៃម្ខាងទៀតញីភ្នែកបន្ទាប់មកក៏ព្រិចភ្នែកច្រើនដងដើម្បីឲ្យវាស៊ាំនឹងពន្លឺដែលចាំងចូលមកក្នុងបន្ទប់។

"នៅងងុយដេក"

"មនុស្សខ្ជិល"

"ងងុយហ្នឹងណា"

ធីណា តបតគេដោយភ្លេចខ្លួន បន្ទាប់មកក៏បើកភ្នែកធំៗ ពេលនឹកឃើញថាខ្លួនឯងនិយាយអី និងស្ទុះងើបអង្គុយលើគ្រែ និងមើលគេដោយកែវភ្នែកមូលក្លំ។



"អឺ...លោក គ្រីស"

នាងសម្របសំឡេងឲ្យគ្រលរ ពេល គ្រីស មិនបង្ហាញអាការៈអ្វី ប្រហែលមានន័យថាគេមិនបានឮសំឡេងរបស់នាងអម្បាញ់មិញតើមែនទេ។

"មានការអី ?"

"លោក គ្រីស មិនឆ្ងល់ទេឬ ?"

"ឆ្ងល់ ?" គ្រីស យល់សំណួររបស់នាង ប៉ុន្តែធ្វើជាមិនយល់ ទើបនាងញញឹមដាក់។

"គ្មានអីទេ"

"ច្បាស់ហើយ ?"

"ច្បាស់បំផុត"

នាងបញ្ជាក់ ដោយបបូរមាត់នៅតែលម្អដោយស្នាមញញឹម។ បើ គ្រីស នឹកសង្ស័យគេប្រហែលជាស្តីឲ្យនាងទៅហើយ ទើបនាងប្រញាប់បោសវាសរឿងនេះចោល និងប្រាប់ខ្លួនឯងឲ្យប្រុងប្រយ័ត្នខ្លួនជាងនេះ នាងមិនគួរភ្លេចខ្លួន ត្រូវធ្វើខ្លួនជាមនុស្សប្រុសឲ្យស៊ាំ ត្រូវមើលថៃខ្លួនឯងឲ្យបាន កុំឲ្យបងស្រីព្រួយបារម្ភ។

"អ៊ីចឹងងើបទៅងូតទឹក"



Scanned by CamScanner

"បាទលោក គ្រីស"

ធីណា សម្រូតខ្លួនចុះពីគ្រែ ងាកទៅមើលគេ គេជាម្ចាស់បន្ទប់ គួរតែឲ្យគេងូតមុខឬអត់។

"លោក គ្រីស មិនងូតមុនទេឬ?"

"មានស្អីទៀត?"

"ខ្ញុំក្រែងចិត្តលោក គ្រីស"

"ខ្ញុំងូតមុនក៏បាន"

គិតទៅគិតមក បើនាងងូតមុនប្រហែលជាចំណាយពេលយូរទៀត ទើបគេសម្រេចចិត្តចូលងូតមុន ហើយពេលគេចូលបន្ទប់ទឹក ធីណា ក៏ត្រៀមឧបករណ៍ប្រចាំថ្ងៃរបស់ខ្លួនឯង ថ្ងៃនេះនាងនឹងកាត់សក់នៅក្នុងបន្ទប់ទឹក កុំឲ្យពិបាកពាក់សក់ក្លែងក្លាយ។

"ម្នាក់នេះជាអ្នកណា?"

នាងដើរទៅទូនៅកៀនជញ្ជាំងដោយគ្មានចេតនា ជ្រៀតជ្រែករបស់របរផ្ទាល់ខ្លួន គ្រាន់តែគិតនេះគិតនោះ ហើយក៏ឃើញវាល្មម។ បន្ទប់ទំហំប៉ុណ្ណឹងទោះយ៉ាងណាក៏នាងត្រូវតែឃើញនៅថ្ងៃណាមួយ។ នាងឈរនៅមុខទូ មើលរូបថតនៅក្នុងស៊ុមរបស់ស្រីម្នាក់ ម្នាក់នោះប្រហែលជាមនុស្សសំខាន់របស់





Scanned by CamScanner

គ្រីស ទេដឹង ទើបរូបត្រូវដាក់ស៊ុមបានល្អ និងតាំងនៅក្នុងបន្ទប់ដេករបស់គេ ដែលពេលនោះម្ចាស់បន្ទប់ដើរចេញមកឃើញល្មម។

"ធ្វើអី ?"

"ស្រីម្នាក់នេះស្អាតដល់ហើយ គូស្នេហ៍របស់លោកឬ ?"

"មិនមែនរឿងរបស់ឯងទេ"

"ខ្ញុំសុំទោស"

"ទៅងូតទឹកទៅ នឹងអាលខ្ញុំនាំទៅធ្វើការ"

"បាទលោក គ្រីស"

ធីណា មិនបានចម្លើយ ថែមទាំងត្រូវគេស្ដីឲ្យទៀត ទើបដើររួញខ្លួន បៀត គូទទៅយករបស់របរប្រើប្រាស់ផ្ទាល់ខ្លួន ដើម្បីចូលបន្ទប់ទឹក។

"ម៉េចក៏ចូលចិត្តតែងខ្លួនក្នុងបន្ទប់ទឹក"

"វាចាំបាច់"

បើនាងមិនបន្លំខ្លួនជាមនុស្សប្រុស គឺមិនចាំបាច់ធ្វើអីស្មុគស្មាញបែប នេះទេ។ នាងដើរចូលបន្ទប់ទឹក ទោះវាជាសំណួរដែលនាងគ្មានចេតនា ប៉ុន្តែ រឿងមនុស្សស្រីនៅក្នុងរូបថតរបស់ គ្រីស នៅតែជិតដាមជាប់ក្នុងចិត្តរបស់នាង បែបប្លែកៗ។



Scanned by CamScanner

# ១១

## កុហកជារឿងមិនល្អ

សាន់នី ស្វាគមន៍អរុណរះដោយការភិតភ័យ រកមើលសក់ក្លែងក្លាយ ឃើញវានៅក្បែរខ្នើយ ចំណែកសក់ពិត រាយពេញពូក ហើយពេលមើលទៅអ្នកដែលដេកនៅក្បែរខ្លួន ឃើញ សេត ដេកលក់ស្រួល ក៏ស្ទុះចុះពីគ្រែ ឆក់យកសក់ក្លែងក្លាយរត់ចូលបន្ទប់ទឹក។

"ក្មេងមោឃ"

នាងល្អ ស្អាត ក្រអឺតក្រទម ឆ្មើងឆ្មៃ ប៉ុន្តែពេលធ្វើខ្លួនឡប់ៗ ក៏គួរឱ្យស្រឡាញ់មួយបែបទៀតដែរ។ សេត ធ្វើពុតជាដេកលក់ព្រោះអាណិត ហើយពេលនាងចូលបន្ទប់ទឹកបាត់ ក៏ប្រែខ្លួនដេកផ្អៀង ដោយមិនប្រញាប់ប្រញាល់ចុះពីគ្រែ។ គេធ្វើខ្លួនជាបុរសចិត្តទូលាយ ឱ្យពេលនាងចាត់ការខ្លួនឯងនៅក្នុងបន្ទប់ទឹកតាមសម្រួល។



"ស្លាក់ស្លឹតមែន"



Scanned by CamScanner

ពីរនាក់បងនិងប្អូនស្លាក់ស្លឹតមិនខុសគ្នាប៉ុន្មាន ប្រហែលមកពីបទពិសោធន៍ជីវិតមានតិចតួចនោះឯង។ សេត ប្រែខ្លួនដេកផ្ងារ ហើយបិទភ្នែក ព្រោះដឹងថា សាន់នី ចេញមកវិញដើរមកមើល នាងត្រូវការឱ្យច្បាស់ថា គេកំពុងដេកលក់នៅលើគ្រែ។

"ហ៊ឺយ! រាងធូរបន្តិច រួចខ្លួនហើយ សាន់នី"

នាងលើកដៃអង្អែលទ្រូង ដើរចូលទៅក្នុងបន្ទប់ទឹកម្តងទៀត ដើម្បីងូតទឹកផ្លាស់សម្លៀកបំពាក់ និងបន្លំខ្លួនជាមនុស្សប្រុស។

"ម៉េចក៏របូត"

នាងនៅតែមានការសង្ស័យចំពោះសក់ក្លែងក្លាយ ដែលរបូតពីក្បាល ហើយគិតថា នឹងប្តូរអាថ្មី ប៉ុន្តែពេលពាក់អាចាស់ដដែល ឃើញវានៅណែនល្អ។

"ផ្លោះផ្លោយត្រង់ណា"

នាងត្រូវការរកហេតុផល ប៉ុន្តែគ្មានពេលច្រើន ព្រោះអ្នកនៅលើគ្រែអាចភ្ញាក់ពីដេកហើយក៏ថាបាន ទើបប្រញាប់ប្រញាល់ងូតទឹកងូតភក់ តែងខ្លួនឱ្យរួចរាល់។

"ហ៊ឺយ! យើងអាចប្រាប់ការពិតដល់គេបានឬអត់"

នាងហាត់នឿយខ្លាំងណាស់នឹងការត្រូវបន្លំខ្លួនធ្វើជាមនុស្សប្រុស វាមិន



Scanned by CamScanner

ងាយ ហើយនៅតែធ្វើឱ្យលំបាក ថប់ដង្ហើម ពេលគិតដល់ទំនាក់ទំនងរវាងនាង និង សេត គេប្រហែលមិនចិត្តអាក្រក់ដាក់នាងទេដឹង។

"ណេក្លីយ ទុកសិនទៅចុះ"

នាងប្រសព្វភ្នែកនឹងខ្លួនឯងនៅក្នុងកញ្ចក់ ត្រឹមថ្ងៃដំបូង នៅជួបបញ្ហាច្រើនដល់ថ្នាក់នេះ ក្រៅពីហត់កាយហើយ នៅហត់ចិត្តទៀត។ នាងមិនចង់ខឹងសេត ប៉ុន្តែការកុហកវាគឺជាចំណុចចាប់ផ្តើមរបស់រឿងដែលមិនល្អ នាងអាចទទួលបានលទ្ធផលពីការកុហករបស់ខ្លួនឯង ដោយសម្រេចចិត្តមិនទាន់បាន នាងប្រហែលត្រូវឱ្យពេលវេលាខ្លួនឯងបន្តិចទៀត។

"តួនាទីរបស់ខ្ញុំត្រូវធ្វើអីខ្លះ ?"

"តាមមើលថែខ្ញុំ"

ចម្លើយងាយៗ តែនោះមានន័យថា នាងត្រូវតាមគេគ្រប់ពេលវេលា។ សាន់នី កំពុងតែជួបនឹងស្ថានការណ៍លំបាកហើយ។

"មានន័យថាម៉េច ?"

"ម៉េចក៏ឯងពិបាកយល់អីយ៉ាងនេះ"

"គឺខ្ញុំមិនយល់ហ្នឹងណា៎"





Scanned by CamScanner

"តាមមើលថៃខ្ញុំ គឺតាមមើលថៃ"

នាងក្រមុំ ត្រូវការការបញ្ជាក់ គេក៏បេះបួយនាងណាស់ដែរ ទើបភ្លេចខ្លួនសម្លក់សម្លឹងគេទៀតហើយ ប៉ុន្តែ សេត មិនបានខឹងនាង។

"ខ្ញុំមិនយល់"

"ដើរតាមខ្ញុំ"

"ខ្ញុំចង់ធ្វើការ"

"នេះអីការងាររបស់ឯង"

នាងក្រមុំដកដង្ហើមចូលឱ្យជ្រៅៗ ដើម្បីទប់អារម្មណ៍ ពេលខ្លះនាងក៏មានអារម្មណ៍ដូច សេត សប្បាយនឹងការបេះបួយនាង ប៉ុន្តែគេបេះបួយធ្វើអី បើគេមិនដឹងផងថានាងជាអ្នកណា។

"ខ្ញុំវង្វេងអស់ហើយនេ៎ះ"

"តាមមើលថៃខ្ញុំ គឺត្រូវតាមខ្ញុំគ្រប់កន្លែង ធ្វើតាមបញ្ជារបស់ខ្ញុំ"

"បែបហ្នឹង ខ្ញុំគ្មានពេលវេលាផ្ទាល់ខ្លួនទេ"

"ឯងយកពេលវេលាផ្ទាល់ខ្លួនទៅធ្វើស្អី"

"ខ្ញុំក៏ត្រូវការពេលវេលាសម្រាប់ខ្លួនឯងដែរ"

"ធ្វើខ្លួនឱ្យល្អទៅ ខ្ញុំអាចឱ្យឯងក៏ថាបាន"



Scanned by CamScanner

សាន់នី ត្រូវធ្វើខ្លួនឱ្យល្អកម្រិតណា ទើបត្រូវចិត្តលោកចៅហ្វាយ។ គេជាមនុស្សពិបាកយកចិត្ត នាងមិនដឹងទេថាត្រូវធ្វើបែបណា ទើបត្រូវចិត្តគេ។

"លោក សេត"

"ខ្ញុំគ្មានពេលនិយាយជាមួយឯងទេ"

"ខ្ញុំសុំទោស"

"ដើរតាមខ្ញុំម៉ោ យើងត្រូវទៅធ្វើការ"

សេត ធ្វើមុខមាំ ដើរចេញពីបន្ទប់ដេក ទើបនាងប្រញាប់ប្រញាល់ដើរតាមគេចេញទៅដែរ។

ស្អីគេ សុខៗក៏ធ្វើដូចខឹង មនុស្សស្អីខ្មោចចេញខ្មោចចូល!

ក្នុងពេលដែលនាងចង់ធ្វើការខ្លាំង គេក៏ជូនតាមសំណូមពរ ដោយចាប់ផ្ដើមការងារថ្ងៃនេះ ដោយការនាំនាងដើរពិនិត្យការងារនៅលើកោះ។ សាន់នី ត្រូវដើរតាមគេ មុខឡើងក្រហមងាំង បែកញើសជោកខ្លួន លើកដៃជូតញើសម្ដងហើយម្ដងទៀត ប៉ុន្តែដោយសារភាពមានះរឹងទទឹង ទើបនាងមិនមាត់មិនក មិនរអ៊ូរទាំ ក្រៅពីនេះ នាងកំពុងតែបន្លំខ្លួនជាមនុស្សប្រុស មិនអាចបង្ហាញភាពទន់ជ្រាយឱ្យគេឃើញបាន។





Scanned by CamScanner

នាងដកដង្ហើមធំ ខណៈដែល សេត នៅតែដើរទៅខាងមុខ ឱ្យរំភើយ ដោយស្លៀកតែខោខូវប៊យមួយប៉ុណ្ណោះ ពន្លៃងល្វែងលើ មានក្រដាសមួរនៅក្នុងដៃ។

"ដើរឱ្យលឿនបន្តិច"

សេត ងាកទៅប្រាប់អ្នកដែលដើរតាម អាការៈរបស់នាងបញ្ជាក់ថាជើងស្អាតដែលគេចូលចិត្តស្ទាបអង្អែលនោះ ល្វើយពេញបន្ទុកហើយ។

"បាទ លោក សេត"

នាងប្រឹងដើរឱ្យលឿន ប៉ុន្តែកាន់តែឈាន គេកាន់តែទៅឆ្ងាយពីនាងជារឿយៗទើបសេតនាំនាងដើរទៅតាមផ្លូវកាត់ដែលតាមពិតទៅវាជាកន្លែងផ្ទាល់ខ្លួនមិនអនុញ្ញាតឱ្យកម្មករចូលម៉ោរញ៉េរញ៉ៃ។

គេដើរសំដៅទៅកន្លែងដែលមានកម្មករធ្វើការកាលពីដំបូង ហើយនាំនាងដើរចេញទៅឆ្ងាយទៅៗ ដើម្បីមិនឱ្យនាងសង្ស័យថាគេមានចេតនានាំនាងដើរតែពីរនាក់ ដើម្បីធ្វើឱ្យហត់នឿយ នាងត្រូវតែឈប់ដើរ ជើងល្វើយស្ទើរតែឈានមិនរួច ប៉ុន្តែនាងឈប់បានតែបន្តិចប៉ុណ្ណោះ ក៏ត្រូវខាំមាត់សង្កត់ចិត្តដើរបន្ត។

"នៅត្រង់នេះ ខ្ញុំនឹងពង្រីកការងារ"



Scanned by CamScanner

គេនិយាយជាមួយនាងឬអត់ ប៉ុន្តែនាងស្តាប់មិនច្បាស់ ព្រោះហត់នឿយវិលមុខ និងបន់ស្រន់កុំឱ្យខ្លួនឯងខ្យល់គ។

"បាទ លោក សេត"

សេត ដៀងមើលនាង ហើយនិយាយស្អីទៀត វែងឆ្ងាយណាស់ ប៉ុន្តែនាងស្តាប់មិនយល់ ទាំងដែលព្យាយាម ស្តាប់គេទៅហើយ។

"បាទ លោក សេត"

"ឯងគិតថាម៉េច ?"

"ខ្ញុំ...មិនដឹង"

សាន់នី ងងឹតមុខមែនទែន លើកដៃស្រវេស្រវាទៅខាងមុខ ព្រោះមានអារម្មណ៍ថាបរិវេណនៅជុំវិញខ្លួនក្លេងក្លោងនៅមិននឹង។

"លោក...លោក សេត"

នាងហៅគេ ហើយក៏សន្លប់ ប៉ុន្តែរាងកាយមិនទាន់បានដួលទៅលើដីផង សេត ក៏ស្ទុះមកឱបក្រសោប ហើយលើកនាងបី។

"នៅឱ្យស្ងៀម" សេត ដាស់តឿន។

ពេលនេះគេអង្គុយនៅក្រោមដើមឈើដែលមានមែកបែកសាខាចោលម្លប់





Scanned by CamScanner

ត្រឈឹងត្រឈៃ មាន សាន់នី អង្គុយផ្អែកនឹងដើមទ្រូង យកកន្សែងដែលដាក់ក្នុង ហោប៉ៅខោ មកជ្រលក់ទឹក ហើយជូតមុខមាត់ស្រស់ស្អាតដើម្បីឱ្យនាងមាន អារម្មណ៍ស្រស់ស្រាយ។

"រាងកាយខ្សោយមែន"

គេធ្វើជារអ៊ូរទាំ នាងក៏ងើបអង្គុយ តែគ្មានកម្លាំងកំហែង មានអារម្មណ៍ដូច ព្រះអាទិត្យក្តៅខ្លាំង កំពុងតែដុតបំផ្លាញកម្លាំងកំហែងរបស់នាងយ៉ាងអឺចឹង។

"ចង់ធ្វើការមិនអឺចឹង ហើយនេះស្អី"

"ខ្ញុំសុំទោស"

នាងខាំមាត់ប្រាប់គេ។ នាងក៏មិនគិតដែរថា លទ្ធផលវាចេញមកបែបនេះ នាងតូចចិត្តគេដែលមិនចេះព្រួយបារម្ភពីនាងខ្លះសោះ ទោះគេចាំនាងមិនបាន ក៏ដោយ ប៉ុន្តែអារម្មណ៍តូចចិត្តរបស់មនុស្សស្រីវាតែងតែគ្មានហេតុផល។

"ចាំខ្ញុំជូតខ្លួនឯង"

អ្នកកំលោះញាត់កន្សែងក្នុងដៃរបស់នាង ប៉ុន្តែដៃរបស់គេនៅតែឱប ចង្កេះ តូចស្តើង ទើប សាន់នី យកកន្សែងមកជូតមុខខ្លួនឯងថ្នមៗ ហើយក្តាប់វា ជាប់។

"ធូរហើយឬនៅ?"



Scanned by CamScanner

"ធូរហើយ"

"ដើរបន្តរួចទេ?"

ពេលគិតដល់ការប្រើជើងទាំងពីរដែលនៅខ្សោយខ្លាំង នាងក៏មានអារម្មណ៍បាក់ទឹកចិត្ត ប៉ុន្តែត្រូវតែអត់ធ្មត់ ព្រោះនាងមានឋានៈជាកម្មករ។

"គិតថារួច"

"គិតថារួច?"

"បាទ រួច"

នាងមិនអាចឆ្លើយឱ្យតែរួចពីមាត់បានទេ ពេលជាមនុស្សប្រុស គឺត្រូវតែរឹងមាំ ទើបប្តូរចម្លើយថ្មី។

"បន្តិចទៀតចាំដើរទៅចុះ"

"បាទ លោក សេត"

តែ សេត ដឹងថានាងទៅមិនរួច ទើបពន្យារពេលឱ្យនាងសម្រាកបន្ត នាងក៏មានអារម្មណ៍ភ្លើតភ្លើន។ តើមានចៅហ្វាយប្រុសប៉ុន្មាននាក់ ដែលព្រមឱ្យកូនចៅប្រុសអង្គុយពិតដើមទ្រូង។

"ខ្ញុំចង់អង្គុយលេងបន្តិចទៀត ទីនេះអាកាសធាតុល្អ ទេសភាពស្អាត"



"បាទ លោក សេត"



Scanned by CamScanner

"ឬឯងចង់ដើរបន្ត?"

"មិនចង់ទេ លោក សេត"

កាន់តែដើរ គឺកាន់តែគ្មានប្រយោជន៍បានសម្រាកមួយសន្ទុះទៀតហើយ ចាំដើរក៏ល្អដែរ។ នាងមើលកន្សែងជូតមុខនៅក្នុងដៃ ហើយក្តាប់វាជាប់ ព្រោះវាជាកន្សែងជូតមុខរបស់ សេត។

*ហើយហេតុអីយើងត្រូវផ្តោតសំខាន់ទៅលើវា!*

សាន់នី មិនយល់ពីខ្លួនឯង ប៉ុន្តែនាងកំពុងគិតថាកន្សែងជូតមុខមួយនេះ មានសារៈសំខាន់ វាគ្រាន់តែជាកន្សែងជូតមុខប៉ុណ្ណោះ ថែមទាំងជាកន្សែងរបស់មនុស្សប្រុសដែលចូលចិត្តកេងចំណេញលើនាងទៀតផង។

*គេក៏មានចំណុចល្អខ្លះដែរ!*

សំឡេងមួយទៀតប្រកែកនៅក្នុងចិត្ត នាងយល់ច្រឡំថាគេចាត់ការប្អូនស្រីនាងទៅហើយ ប៉ុន្តែគេបែរជាមិនធ្វើ។

*គេជួយយើងតាមសំណូមពរ!*

ចំណុចល្អជាច្រើនដែល សេត ធ្វើឱ្យនាង ដោយមិនអួតអាង វាលុបរឿងដែលគេប្រើឈ្មោះក្លែងក្លាយ ដើម្បីចូលទៅកម្សាន្តនៅរោងរបាំស្រាតណាខាដៀ។



Scanned by CamScanner

*ដែលបែបនេះ អ្នកដទៃក៏ប្រើឈ្មោះក្លែងក្លាយច្រើនដែរណាំ!*

សំឡេងនៅក្នុងខួរក្បាលរបស់នាង គាំទ្រហេតុផលដែលធ្វើឱ្យនាងសរសើរ សេត នៅក្នុងចិត្ត និងអភ័យឱ្យគេ។ វាគ្រាន់តែជារឿងតូចតាចដែលមិនសំខាន់ បើប្រៀបធៀបនឹងរឿងដែលគេធ្វើឱ្យនាង។

"កើតអីអង្គុយស្ងៀម"

សេត កេះនាង ខណៈនោះ ក៏ដាក់ដៃលើក្បាល។ សក់នៅលើក្បាលរបស់នាង មិនថាពេលណាក៏ដោយ ក៏គេគ្មានអារម្មណ៍ថាចូលចិត្តវាដែរ។

"អត់មានទេ"

"តោះទៅបន្ត"

"បាទ លោក សេត កន្សែងជូតមុខមួយនេះចាំខ្ញុំបោកឱ្យ"

"មិនបាច់ទេ"

សេត យកកន្សែងពីដៃរបស់នាង បោះចោលនៅចំពោះមុខចំពោះមាត់ ធ្វើឱ្យនាងក្រមុំតាមមើលវាដោយការភ្ញាក់ផ្អើល។

"ចោលទៅ"

គេបោះចោលងាយៗអ៊ីចឹងឬ។ គេបោះចោលកន្សែងជូតមុខ ហើយក៏ទាញនាងឱ្យងើបឈរ បន្ទាប់មក ក៏បែរខ្នង ដើរចេញទៅ។





Scanned by CamScanner

"តាមម៉ោ ដាស៊ី"

គេដើរចេញទៅហើយ ប៉ុន្តែ សាន់នី បែរជាស្ទុះទៅរើសយកកន្សែងជូតមុខ គេចោលហើយ តែនាងចោលមិនបាន ទើបបត់វាដាក់ក្នុងហោប៉ៅ ហើយប្រញាប់ប្រញាល់ដើរតាមដើម្បីកុំឱ្យគេសង្ស័យប៉ុន្តែសេតមើលឃើញទៅហើយគ្រាន់តែមិនបានបង្ហាញអាការៈអី។

ចោរស្រីមុខស្រស់អើយ!

សេត ដាក់រហស្សនាម សាន់នី ក្នុងចិត្តថា ស្រីចោរ គ្រាន់តែនាងលួចរើសកន្សែងជូតមុខដែលគេគ្រវាត់ចោល យកទៅទុក ដោយគ្មានការអនុញ្ញាត។ នាងរស់នៅលើកោះ បានទទួលរហស្សនាមថាស្រីចោរ គឺសក្តិសមហើយព្រោះនាងជាស្រីរបស់គេ។

សេត ធ្វើជាដើរទៅខាងមុខ តែតាមពិត គេបន្ថយល្បឿនដើម្បីរង់ចាំនាង។ រាងកាយដែលត្រូវប្រើការពេក ខុសពីទម្លាប់ ធ្វើឱ្យនាងហត់នឿយខ្លាំងថ្ពាល់ទាំងពីរឡើងក្រហមងាំង ហើយគេក៏សរសើរការអត់ធ្មត់ដែលនាងព្យាយាមធ្វើខ្លួនឱ្យរឹងមាំឱ្យសក្តិសមនឹងការបន្លំខ្លួនជាមនុស្សប្រុស។

*ចាត់ទុកថា ចិត្តខ្លាំងតែរាងកាយមិនខ្លាំង!*

នាងផុយស្រួយ ត្រូវបង្ខំកឱ្យធ្វើជាស្រីរបាំ ធ្វើតួនាទីបម្រើសេចក្តីសុខឱ្យ



Scanned by CamScanner

មនុស្សប្រុស រាងកាយល្វត់ល្វន់នោះ មិនបានត្រូវបង្ខឹកមកដើម្បីធ្វើការងារលំបាកលំបិន។

"ដាស៊ី"

"បាទ លោក សេត"

"ខ្ញុំគិតថាដើរត្រួតពិនិត្យកោះទៅដល់ត្រង់នោះ"

សេត ធ្វើជាលើកដៃចង្អុល ឃើញហើយនាងក៏ចង់ខ្យល់គ ព្រោះទិសដៅនោះ ឃើញហើយ វានៅដាច់កន្ទុយភ្នែក មើលមិនឃើញទីតាំងច្បាស់លាស់។

"បាទ លោក សេត"

នាងធ្វើបានត្រឹមតែខាំមាត់ឆ្លើយ ហើយប្រមូលកម្លាំងកំហែងទុកសម្រាប់ធ្វើការ ចំណែកការប្រើអារម្មណ៍ទៅលើ សេត វាមានតែធ្វើឱ្យហត់នឿយឥតប្រយោជន៍។

"តែគិតម្តងទៀត ខ្ញុំថាទៅថ្ងៃស្អែកវិញ"

ឃើញមុខស្លេកស្លាំងមួយរំពេចរបស់នាងហើយ គេក៏ធ្វើជាចងចិញ្ចើមគិត ហើយប្តូរចិត្តមួយរំពេច ទើប សាន់នី លួចសម្លក់សម្លឹងគេម្តងទៀត។ មនុស្សដូចគេរកទុកចិត្តមិនបានសោះ ត្រឹមមួយនាទីសោះ ក៏ក្រឡាប់ផ្កាប់ផ្ងារដូចមានចេតនាធ្វើបាបនាង។





Scanned by CamScanner

"បាទ លោក សេត"

"ឯងគិតថាម៉េច ?"

"ខ្ញុំគ្មានយោបល់ទេ"

"ឬឯងចង់ដើរបន្ត ?"

នាងក្រមុំ ចង់ខាំធ្មេញក្រតៗដាក់គេ គេសួរបញ្ជាក់ដើម្បីឱ្យបានស្អី ប៉ុន្តែត្រូវទប់អារម្មណ៍ ដើម្បីតបតគេយ៉ាងសុភាព។

"ខ្ញុំគ្មានយោបល់ទេ"

នាងដកដង្ហើមធំម្តងទៀត ថ្ពាល់ក្រហមគួរឱ្យក្រញិច គេនឹកសង្ស័យថានាងកំពុងខឹងគេ ឬហាត់នឿយឱ្យប្រាកដទៅ។

សាន់នី ប្រសព្វភ្នែកនឹងអ្នកកំលោះ ហើយគេចចេញភ្លាម នាងប្រហែលគិតដោយខ្លួនឯងទៀតហើយ ដូចគេដឹងថា នាងជាអ្នកណា។

**ធីណា គិតថាខ្លួនឯងធ្វើការបានល្អបំផុតហើយ ប៉ុន្តែអ្នកពិនិត្យការងារ** ឈ្មោះថា គ្រីស ប្រហែលមិនគិតដូចនាង។ គេចេញបញ្ជាឱ្យនាងដាំដើមឈើ ប៉ុន្តែមើលទៅគេ មិនពេញចិត្តនឹងការដាំរបស់នាង។

"ធ្វើអី ?"



Scanned by CamScanner

"ដាំដើមឈើ"

នាងហឹងត្រចៀកឬអត់ ដូចបានឮសំឡេងខាំធ្មេញរបស់គេ ប៉ុន្តែគេប្រហែលមិនធ្វើបែបនោះទេ ព្រោះនាងមិនបានធ្វើរឿងអីដែលគេសក្តិសមនឹងឱ្យគេដាក់ទោសផង។

"នេះហៅថាដាំដើមឈើ ?"

គេមើលរោងដើមឈើ ខំរកការងារឱ្យនាងធ្វើបាំងមុខហើយ ប៉ុន្តែនាងដាំកូនឈើមិនកើតជាការសោះ។

"បាទ លោក គ្រីស"

"វាស្អាតទេ ?"

"មើលទៅល្អ"

"បែបនេះហៅថាមើលទៅល្អ ?"

ដើមឈើមិនត្រង់ជួរ ហើយក៏រង្គោះរង្គើរកកល់ចង់ដួលដែរ បែបនេះឬហៅថាស្អាត។ គ្រីស មិនមែនជាមនុស្សរឿងច្រើន ឬយកចិត្តទុកដាក់នឹងរឿងសម្រស់ស្រស់ស្អាត ប៉ុន្តែគេរកមើលពាក្យថាស្អាតមិនឃើញ។

"ឯងម្ជូបឬអត់ ?"

"ភ្នែកខ្ញុំធម្មតា"





Scanned by CamScanner

គ្រីស សួរបញ្ឈឺ តែ ធីណា មិនដឹងខ្លួន ថែមទាំងញញឹមដាក់ទៀតផង។ នាងយកផ្កាអស់នេះ មកដាក់ក្នុងដីយ៉ាងលំបាក ហត់នឿយ ញើសជោកខ្លួន ប៉ុន្តែក៏មានមោទនភាពពេលធ្វើការបានសម្រេច។

"ខ្ញុំគិតថាវាខុសប្រក្រតីច្រើនជាង"

"វាមិនស្អាតឬ?"

ធីណា ដឹងហើយនៅពេលនេះ រឿងសម្រស់របស់នាងនិង គ្រីស ប្រហែលខុសគ្នា ទើបធ្វើភ្នែកម៉ក់ៗរង់ចាំចម្លើយពីគេ។

"មិនស្អាត"

គ្រីស ក៏ឆ្លើយ ត្រង់ៗ មិនបង្វែរបង្វៀង ព្រោះមើលមិនឃើញសម្រស់របស់ផ្កា ដែលនាងយកមកដាំ។

"មិនស្អាតទេឬ?"

"ក្រៅពីមិនស្អាតហើយ វានៅយ៉ាប់មើលទៀតផង"

"អីចឹងឬ"

"ចូលដល់ថ្នាក់រញ៉េរញ៉ៃ"

គ្រីស វិភាគជាបន្តបន្ទាប់ ធីណាក៏ស្តាប់គេដោយមិនមាត់មិនក ខណៈនោះក៏ងាកទៅមើលរោងផ្កាម្តងទៀត។ វាយ៉ាប់យ៉ឺនដល់ថ្នាក់នោះផងឬ ការ



Scanned by CamScanner

ព្យាយាមរបស់នាង គ្រីស បែរជាមើលឃើញថារញ៉េរញ៉ៃ។

"លោកមិនចូលចិត្តវាមែនទេ ?"

"មិនចូលចិត្ត"

"អ៊ីចឹងខ្ញុំដាំសាថ្មី"

នាងប្រាប់ដោយសំឡេងខ្សាវៗ ភាពស្រស់ស្រាយ ត្រូវហែកហួរដោយពាក្យសម្ដីគ្មានទឹកចិត្តរបស់ គ្រីស ប៉ុន្តែគេមិនដឹងខ្លួនអីបន្តិច ថាគេបានវាយប្រហារអារម្មណ៍របស់នាងទៅហើយ។

"មិនបាច់"

"ខ្ញុំធ្វើបាន"

"ផ្កាជាំអស់ហើយ"

"ខ្ញុំធ្វើសាថ្មីបាន"

"មិនបាច់"

ការងារដាំផ្កា ជាការងារពិសេសសម្រាប់ ធីណា នាយតូចនៃកោះចោរ គ្មានការងារអីឱ្យនាងធ្វើ ចំណែកគេ មានតួនាទីធ្វើជាអ្នកមើលថែក្មេង។

"ហេតុអី ?"

"បានហើយ ព្រោះឯងធ្វើវាមិនបានល្អ"





Scanned by CamScanner

"លោក គ្រីស ខឹងឬ"

"ឯងគិតថាខ្ញុំគួរពេញចិត្ត ?"

នាងក្រមុំគ្រវីក្បាល ដោយមិនបានគិតអីទេ ក្រៅពីប្រឹងប្រែងធ្វើឱ្យអស់ពីសមត្ថភាព គ្រាន់តែនាងធ្វើវាមិនបានល្អតែប៉ុណ្ណោះ។

"ខ្ញុំសុំទោស"

នាងឈ្ងោកមុខ ស្រស់ទឹកភ្នែកតក់ៗ ប៉ុន្តែ គ្រីស នៅតែមិនដឹងខ្លួនថាក្លាយជាដើមហេតុ ធ្វើឱ្យនាងស្រក់ទឹកភ្នែក ព្រោះនាងអង្គុយឈ្ងោកមុខ។

"ខ្ញុំសុំទោស ខ្ញុំសុំទោស"

នាងនិយាយពាក្យដដែលៗដោយសំឡេងញ័រ លាយឡំអណ្ដឹតអណ្ដក ទើប គ្រីស ចងចិញ្ចើមដើរមករក និងដាក់បង្គុយទល់មុខ។

"យំធ្វើអី ?"

"ខ្ញុំសោកស្ដាយ"

"កូនប្រុសគេមិនយំងាយៗទេ"

គ្រីស ប្រាប់ដោយការធុញទ្រាន់ ហើយបញ្ចប់បញ្ហាដោយការចាប់ដៃទាញនាងឱ្យងើបឈរ ហើយនាំដើរចូលទៅក្នុងផ្ទះ ចំណែក ធីណា នៅតែឈ្ងោកមុខឈ្ងោកមាត់ លើកដៃជូតទឹកភ្នែក ដើរតាមគេទាំងភ្នែកស្រវាំង។



Scanned by CamScanner

...

សេត សម្រេចចិត្តត្រឡប់ទៅផ្ទះរបស់គេ ប៉ុន្តែទោះជាដូច្នោះក៏ដោយ ពេលគិតថានាងត្រូវដើរត្រឡប់ទៅវិញ ដោយចម្ងាយផ្លូវស្មើនឹងពេលដើរមក សាន់នី ក៏ខ្សោះ ដល់ថ្នាក់ចង់ចេះយុទ្ធសិល្ប៍បំបាំងខ្លួន។

"ម៉េចក៏ធ្វើមុខអីចឹង ?"

គេដឹងគំនិតរបស់នាង ប៉ុន្តែនៅតែធ្វើជាសួរ ទើបនាងងាកទៅរក ថែមទាំងធ្វើភ្នែកឆ្មាសដាក់ទៀតផង។

"ធ្វើភ្នែកឆ្មាសដាក់ខ្ញុំធ្វើអី ?"

"អត់មានទេ"

"ឯងនេះចរិតដូចមនុស្សស្រី"

"អេ៎! ខ្ញុំជាមនុស្សប្រុស"

"មនុស្សប្រុសដែលខ្ញុំស្គាល់ គ្មានអ្នកណាដូចឯងទេ"

"ខ្ញុំមិនចាំបាច់ដូចអ្នកដទៃហ្នឹងណា៎"

នាងក្រមុំនៅតែអះអាងដោយទឹកមុខមាំ នាងសម្រេចចិត្តប្រាប់ការពិតដល់គេមិនទាន់បានទេនៅពេលនេះ ព្រោះត្រូវការការពារឋានៈរបស់ខ្លួនឯងសិន។





Scanned by CamScanner

"ប៉ុន្តែវានៅតែប្លែកដដែល"

"ហេតុអីលោក សេត ប៊ិនសង្ស័យម្ល៉េះ"

"វាគួរតែចរិតរបស់អ្នកដឹកនាំមិនអីចឹង"

"អ្នកដឹកនាំ ?"

"នាងមិនដឹងទេឬថាខ្ញុំជាអ្នកណា ?"

នាងក្រមុំគ្រវីក្បាល ចង់សួរស្ទើរតែដាច់ខ្យល់ ប៉ុន្តែមិនហ៊ានហាមាត់សួរ បើឆ្លៀតឱកាសនេះសួរ តើគេព្រមប្រាប់ដែរទេ។

"ឯងកំពុងហៅខ្ញុំថាលោក សេត"

"បាទ"

ហៅ ព្រោះជាបញ្ជា ប៉ុន្តែនាងមិនដឹងហេតុផលថាហេតុអីត្រូវហៅគេថា លោក សេត ហើយគេជាអ្នកណា មានតំណែងធំដុំប៉ុនណានៅលើកោះនេះ។

"អូខេ"

"ហើយលោក សេត មិនប្រាប់ខ្ញុំទេឬ ?"

"ប្រាប់អី"

"ប្រាប់ថាលោក សេត ជាអ្នកណា ?"

"ខ្ញុំគឺលោក សេត ហ្នឹងអី"



Scanned by CamScanner

"លោក សេត!"

ចម្លើយបេះបួយរបស់គេ ធ្វើឱ្យនាងភ្លេចខ្លួន ស្រែកគំហ៊កដាក់គេទៀត ហើយ សេត ក៏ញញឹមចុងមាត់ រង់ចាំមើលថានាងនឹងធ្វើយ៉ាងណាបន្ត។

"ស្រែកហៅខ្ញុំធ្វើអី"

"លោក សេត ញ៉ោះខ្ញុំ"

"ខ្ញុំត្រូវញ៉ោះឯងដែរ ?"

"ខ្ញុំក៏មិនដឹងហេតុផលដូចគ្នា"

"ឯងនិយាយម៉ោ ឯងត្រូវតែមានហេតុផល"

អ្នកកំលោះដើរទៅរក នាងក៏ឈានជើងថយក្រោយ ថយទាល់តែទៅបុកខ្នងនឹងដើមឈើ ទើបគេទ្រានដៃនឹងដើមឈើនោះពីលើរាងកាយរបស់នាង។

"លោក សេត ខឹងខ្ញុំឬ ?"

"តាមធម្មតាខ្ញុំជាមនុស្សចិត្តទូលាយ"

"អីចឹងបញ្ជាក់ថាមិនខឹង"

"តែពេលខ្លះដែលមិនធម្មតា ខ្ញុំក៏ជាមនុស្សចិត្តចង្អៀត"

ហើយសរុបទៅពេលនេះ គេខឹងឬមិនខឹង នាងបែកអំពិលអំពែកហើយនេះ ហើយក៏ឆ្ងល់ចុងច្រមុះនឹងចម្លើយរបស់គេ ដែលធ្វើឱ្យនាងដៅមិនត្រូវ។





Scanned by CamScanner

"លោក សេត ចង់យ៉ាងម៉េច?"

"សួរដូចរករឿង"

"អត់មានទេ តែខ្ញុំមិនយល់ពីលោក សេត"

សេតម្ដងល្អម្ដងអាក្រក់ដូចសប្បាយនឹងការបេះបួយនាងនិយាយហើយ ក៏មិនសូវបានសេចក្ដីអី ព្រោះដូចនាងត្រូវញ៉ោះដោយប្រយោល។

"ឯងចង់យល់ពីខ្ញុំឬយ៉ាងម៉េច"

"អត់...អត់ទេ"

កែវភ្នែកមួយគូនោះ មានពន្លឺគឃ្លើន ដូចគេប្រើមើលនាង ពេលត្រូវការរាយមន្តស្នេហ៍ ប៉ុន្តែហេតុអីគេប្រើខ្សែភ្នែកបែបនេះមើលមនុស្សប្រុស។

"តាមពិតឯងមិនបាច់យល់ពីខ្ញុំទេ បើឯងចង់នៅទីនេះដោយមានសុវត្ថិភាពឯងត្រូវស្ដាប់បញ្ជាខ្ញុំ និងត្រូវយកចិត្តយកថ្លើមខ្ញុំ"

"យកចិត្តយកថ្លើម ឆឹស!"

"ឯងនិយាយថាម៉េច?"

"អត់មានទេ"

"អីចឹងល្អ តោះទៅវិញ ខ្ញុំឱ្យគេយកឡានម៉ោ នោះម៉ោហើយ"

សេត ចង្អុលទៅឡានហ្វរីលដែលកំពុងតែរត់មករក ហើយនាំខ្លួនឯង



Scanned by CamScanner

ចេញឱ្យឆ្ងាយពីនាង ធ្វើឱ្យ សាន់នី ធូរទ្រូង ដែលមិនចាំបាច់វេទនាដើង ពេល ត្រឡប់ទៅវិញ ប៉ុន្តែនាងនៅតែគិតដដែល ថានាងដូចត្រូវគេធ្វើបាប។





Scanned by CamScanner

# ១២

## ស្រីរំអួយ

ធីណា លើកដៃជូតទឹកភ្នែកគួរឱ្យអាណិត អង្គុយរួញខ្លួនលើសាឡុងក្នុងបន្ទប់អង្គុយលេង ឱនមុខជ្រប់ ប្រាសចាកស្នាមញញឹមស្រស់ស្រាយដូចរាល់ដង។

"ខាស៊ី"

នាងនៅតែអង្គុយស្ងៀមមើលដៃខ្លួនឯង មិនហ៊ានងើយមុខមើល គ្រីស ព្រោះនាងធ្វើអ្វីក៏មិនត្រូវចិត្តគេដែរ។

"ខាស៊ី ខ្ញុំហៅមិនឮទេអី"

"បាទ ឮតើ"

"ហើយម៉េចក៏មិនឆ្លើយ"

"មិនដឹងទេ"

នាងគ្រាន់តែចង់អង្គុយស្ងាត់ៗ នាងធ្វើខ្លួនមិនត្រូវ ព្រោះធ្វើអ្វីក៏មិនត្រូវ



Scanned by CamScanner

ចិត្ត គ្រីស គិតតែពីស្រាក់ដៃ រឹតខ្លាំងឡើងឈឺអស់ទៅហើយ ព្រោះប្រើដៃដាំដើមផ្កា ទាល់តែមានរបួស តែមិនបានយកចិត្តទុកដាក់នឹងរបួសនោះតាំងពីដំបូង ព្រោះរំភើបនឹងការដាំដើមផ្កាទាល់តែរួចរាល់។

ចិត្តរំភើបរបស់នាង ត្រូវ គ្រីស បំផ្លាញខ្ទេចខ្ទីអស់ ពេលនេះអាចប្រាប់បានមួយម៉ាត់ថា នាងអន់ចិត្ត និងចង់ទ្រហោយំឱ្យឮខ្លាំងៗ ប៉ុន្តែបើធ្វើបែបនោះខ្លាចគេខឹង។

នាងអន់ចិត្តខ្លាំងណាស់ ហើយនៅក្នុងអារម្មណ៍នោះ ក៏មានការតូចចិត្តលាយឡំដែរ។ គ្រីស មិនសរសើរនាងក៏បាន ប៉ុន្តែនាងនៅតែមានអារម្មណ៍មិនល្អនឹងការស្តីបន្ទោស។ នាងប្រទះឃើញថា ខ្លួនឯងមានអារម្មណ៍ច្របូកច្របល់ដល់ថ្នាក់មិនយល់ពីខ្លួនឯង។

ធីណា ពិនិត្យមើលដៃ មានរបួស ទឹកភ្នែកដែលប្រឹងទប់ ក៏ស្រក់តក់ហើយពេលបានស្រក់ វាក៏ស្រក់ជាបន្តបន្ទាប់។

"បញ្ឈឺមែនទេ"

គ្រីស បានទទួលចម្លើយជាភាពស្ងប់ស្ងាត់ សំឡេងដែលធ្លាប់តែស្រស់ស្រាយរបស់នាង ទៅជាមួហ្មង ទោះនៅជាមួយនាងបានមួយថ្ងៃមួយយប់ ប៉ុន្តែនាងជាមនុស្សដែលមើលដឹងស្រួលខ្លាំងណាស់ នាងស្រស់ស្រាយ រីករាយ





Scanned by CamScanner

មានគំនិតវិជ្ជមាន ជាមនុស្សស្រីដែលមិនសក្តិសមនឹងការបណ្តោយឱ្យទៅប៉ប៉ុកនៅជាមួយអ្នកផ្សេង ព្រោះងាយនឹងរងការកេងចំណេញ។ នាងជាមនុស្សស្រីដែលមានចរិតល្អគួរសម ប៉ុន្តែមិនសក្តិសមនឹងការធ្វើការអីទាំងអស់ សមហើយដែលនាងត្រូវត្រៀមខ្លួនធ្វើជាស្រីរបាំនៅរោងរបាំស្រោត ណាខាដៀ ព្រោះនាងសក្តិសម នឹងការធ្វើជាស្រីដែលត្រូវមនុស្សប្រុសចិញ្ចឹមមើលថែនិងការពារ។

"ខ្ញុំឬ?"

គ្រីស ដើរទៅរក ឈរជ្រងោនៅចំពោះមុខ ប្រើម្រាមដៃភ្លើយចង្កាឱ្យនាងងើយមករក។ រោមភ្នែកក្រាស់ ដូចផ្លិតរបស់នាង សើមជោក ដូចកញ្ចុប។ ទោះគេមើលដោយកែវភ្នែកសោះកក្រោះ ប៉ុន្តែក៏មិនចូលចិត្តដែលនាងយំព្រោះតែគេ។

ហេតុផលតែមួយគឺរំខានចិត្ត គ្រីស មិនចូលចិត្តធ្វើបាបអ្នកណាដែលទន់ជ្រាយជាង ជាពិសេសមនុស្សស្រី គេមិនយកចិត្តទុកដាក់នឹងពួកនាង តែមិនបដិសេធនឹងមានទំនាក់ទំនងជាមួយនៅពេលខ្លះ ដែលរាងកាយត្រូវការការកម្សាយ។ គេមិនប្រាកដប្រជានឹងអ្នកណា តែក៏មិនបានត្រូវការធ្វើបាប ឬធ្វើឱ្យពួកនាងមានទឹកភ្នែក។



Scanned by CamScanner

"ឈប់យំ"

"ឈប់មិនបានទេ"

"ហេតុអី ?"

"ទឹកភ្នែកវាហូរឯកឯង"

គ្រីស ជួយជូតទឹកភ្នែកឱ្យ ដោយវាសនឹងម្រាមដៃ ធ្វើឱ្យនាងភ័យ ដល់ថ្នាក់ទឹកភ្នែកឈប់ហូរ។

"លោក គ្រីស..."

កែវភ្នែកមូលហ្មងរបស់នាង ស្រស់ស្រាយម្តងទៀត ព្រោះគេជូតទឹកភ្នែកឱ្យ អីចឹងបញ្ជាក់ថាគេមិនបានខឹងនាង នាងក៏មិនចង់ឱ្យគេខឹងដែរ ដោយសារនាងត្រូវនៅជាមួយគេ។

"ស្អី ?"

នាងញញឹមពព្រាយដាក់ មុខមាត់ស្រស់ស្អាត មានពន្លឺចែងចាំងបែបមនុស្សស្រីមិនដឹងខ្យល់អី ស្អាតផូរផង់ និងមានភាពគួរឱ្យស្រឡាញ់ លាយទាំំនៅក្នុងនោះ។

"លោក គ្រីស លែងខឹងខ្ញុំហើយមែនទេ"

"ហេតុអីខ្ញុំត្រូវខឹងឯង"





Scanned by CamScanner

"លោកស្តីឱ្យខ្ញុំ"

"ខ្ញុំស្តីឱ្យ ព្រោះឯងធ្វើការមិនបានល្អ បើឯងធ្វើមិនបាន ឯងត្រូវប្រាប់ខ្ញុំឬរង់ចាំខ្ញុំ មិនមែនធ្វើឱ្យខូចខាតបែបហ្នឹងទេ"

"ខ្ញុំសុំទោស"

ជីណា ស្រវាចាប់ដៃអ្នកកំលោះ កន្ទ្រាក់តិចៗ ទើប គ្រីស លើកចិញ្ចើមជាការសួរថា នាងត្រូវការអី។

"ខ្ញុំគិតថាខ្ញុំធ្វើល្អហើយ"

"វាស្អាតឬយ៉ាងម៉េច"

"ស្អាត"

គ្រីស ដកដង្ហើមធំ ងាកខ្លួនទៅចំហៀងបន្តិច ហើយដាក់បង្គុយក្បែរនាងក៏បែរមករក។

"ភ្នែកមិនសូវល្អឬយ៉ាងម៉េច"

"ខ្ញុំសុំទោសលោក គ្រីស"

ក្រៅពីសុំទោសហើយ នាងនៅអែនមកស្រវាឱប ផ្អឹបថ្ពាល់នឹងដើមទ្រូងរបស់គេ ដែលទង្វើរបស់នាង ធ្វើឱ្យ គ្រីស ភាំង។

"ធ្វើអី ?"



Scanned by CamScanner

គេក្អកគ្រហែមតិចៗ ហើយសួរ ដៃនៅតែដាក់កន្លែងដើម មិនបានប៉ះពាល់រាងកាយរបស់នាង។

"ខ្ញុំសុំទោសលោក គ្រីស"

"អ្នកណាបង្រៀនឱ្យសុំទោសបែបនេះ"

"ខ្ញុំធ្វើដាក់បងស្រីខ្ញុំជាប្រចាំ"

"បងស្រី ?" គេសួរបញ្ជាក់ម្តងទៀត ធីណា ក៏ស្ទុះងើប លើកដៃបិទមាត់ បើកភ្នែកធំៗ សម្លឹងមើលគេដោយការភិតភ័យ។

"អឺ...អឺ..."

"នាងនិយាយថាបងស្រី"

"បាទ...បាទ មែន...មែន"

គ្រីស នៅតែធ្វើពុតជាមិនយល់ ទាំងដែលការពិតទៅគេយល់ទៅហើយ គ្រាន់តែចង់បើកផ្លូវឱ្យនាងសារភាពថានាងជាមនុស្សស្រី ដើម្បីចាត់ការជីវិតរបស់នាងបានកាន់តែងាយ។

"ខ្ញុំ ខ្ញុំ...ខ្ញុំ...ខ្ញុំ"

នាងក្លាយជាមនុស្សត្រដិតទៅហើយ ពេលធ្លោយមាត់និយាយស្អីក៏មិនដឹង ហើយក្រៅពីខ្លួនឯងមានគ្រោះថ្នាក់ ក៏ធ្វើឱ្យបងស្រីគ្រោះថ្នាក់ដែរ។





Scanned by CamScanner

"ខ្ញុំស្អី?"

"ខ្ញុំគ្មានចេតនា"

"ឬឯងមានរឿងកុហក"

គ្រីស ចាប់ចង្ការបស់នាងឱ្យនៅស្ងៀម ធីណា ក៏និយាយមិនចេញ នាងមិនប្រសព្វកុហក ពេលត្រូវគេសម្លឹងមុខ ក៏ធ្លាក់ថ្លើមក្តុក ស្មារតីរត់ខ្វាត់ខ្វាយ។

"ខ្ញុំគ្មានចេតនាទេ"

"បញ្ជាក់ថាឯងមានរឿងកុហក?"

"បាទ អើយ! ខ្ញុំ...ខ្ញុំឆ្លើយយ៉ាងម៉េចទៅ"

"ឆ្លើយការពិត"

"ខ្ញុំឆ្លើយការពិតមិនបានទេ"

"ហេតុអី?"

"ព្រោះខ្ញុំនឹងធ្វើឱ្យបងស្រីមានគ្រោះថ្នាក់"

នាងឆ្លើយតាមចរិតមោឃៗ ប៉ុន្តែកាន់តែឆ្លើយ កាន់តែចងខ្លួនឯង។ នាងជាមនុស្សមោឃដល់ថ្នាក់នេះ ការរស់នៅក្រៅ ណាខាដៀ គឺជារឿងគ្រោះថ្នាក់ណាស់ ធ្វើឱ្យ គ្រីស ដកដង្ហើមធំ។ តើគេត្រូវហាត់នឿយដោយសារនាងដល់ពេលណា។



Scanned by CamScanner

"អង្គុយខាងក្រោយ"

"ហេតុអី ?"

"ព្រោះខ្ញុំបញ្ជា ចប់ទេ ?"

អ្នកកំលោះឆ្លើយបែបបិទច្រក ដែលបញ្ជារបស់គេមិនចាំបាច់មានហេតុផល ពេលបញ្ជាហើយ នាងត្រូវតែធ្វើតាម។

"បាទ លោក សេត"

នាងខាំធ្មេញក្រតៗទៀតហើយ។ បើនៅជាមួយគេយូរជាងនេះ សុខភាពធ្មេញរបស់នាងប្រហែលមានបញ្ហា។ នាងថយមកក្រោយ បើកទ្វារ ហើយប្រឹងឡើង។

"ទន់ជ្រាយមែន"

"មានអីឬ លោក សេត ?"

នាងក្រមុំផ្អាកប្រវេប្រវា ដើម្បីងាកទៅមើលគេដោយខ្សែភ្នែកឆ្ងាសឆ្មើមព្រោះគេរំខានការព្យាយាមរបស់នាង។

"ខ្ញុំនិយាយអីឬ ?"

"ខ្ញុំបានឮ"

"បានឮហើយសួរធ្វើអី"



Scanned by CamScanner

"ខ្ញុំបានឮមិនច្បាស់"

គេមានចេតនារករឿងនាងច្បាស់ណាស់ ហៅនាងមកធ្វើការជាមួយព្រោះមិនចូលចិត្តមុខ ហើយមានចេតនាបណ្ដេញនាងចេញពីការងារដោយប្រយោលឬអត់ មនុស្សឆ្កួតនេះ។

"អ៊ីចឹងមិនបាច់សួរទេ"

"អេ៎! លោក សេត"

"ឯងមានការស្អីទៀត"

"លោក សេត ធ្វើបាបខ្ញុំឬ?"

"ហេតុអីខ្ញុំត្រូវធ្វើបាបឯង?"

សេត ធ្វើបាបនាងមែនហ្នឹង ប៉ុន្តែគេមិនព្រមទទួល ហើយអស់សំណើចពេលត្រូវនាងសម្លក់សម្លឹង មុខឡើងក្រម្ហវតែម្ដង។

មនុស្សឆ្កួត!

ស្រីស្អី ខឹងក៏ស្អាត ងរក៏គួរឱ្យស្រឡាញ់!

អ្នកកំលោះគិតដោយការពេញចិត្ត ហើយលើកចិញ្ចើមមើលនាង បន្ទាប់មកក៏ដើរទៅរកមួយជំហានទៀត ដែលធ្វើឱ្យនាងភ្ញាក់ព្រើត។

"លោក...លោក សេត ចូលម៉ោធ្វើអី"





Scanned by CamScanner

"ខ្ញុំបានឮមិនច្បាស់"

គេមានចេតនារករឿងនាងច្បាស់ណាស់ ហៅនាងមកធ្វើការជាមួយព្រោះមិនចូលចិត្តមុខ ហើយមានចេតនាបណ្តេញនាងចេញពីការងារដោយប្រយោលឬអត់ មនុស្សឆ្កួតនេះ។

"អីចឹងមិនបាច់សួរទេ"

"អេ៎! លោក សេត"

"ឯងមានការស្អីទៀត"

"លោក សេត ធ្វើបាបខ្ញុំឬ ?"

"ហេតុអីខ្ញុំត្រូវធ្វើបាបឯង ?"

សេត ធ្វើបាបនាងមែនហ្នឹង ប៉ុន្តែគេមិនព្រមទទួល ហើយអស់សំណើចពេលត្រូវនាងសម្លក់សម្លឹង មុខឡើងក្រមូវតែម្តង។

មនុស្សឆ្កួត!

ស្រីស្អី ខឹងក៏ស្អាត ងរក៏គួរឱ្យស្រឡាញ់!

អ្នកកំលោះគិតដោយការពេញចិត្ត ហើយលើកចិញ្ចើមមើលនាង បន្ទាប់មកក៏ដើរទៅរកមួយជំហានទៀត ដែលធ្វើឱ្យនាងភ្ញាក់ព្រើត។

"លោក...លោក សេត ចូលម៉ោធ្វើអី"





Scanned by CamScanner

"ខ្ញុំក៏ត្រូវឡើងឡាន ឱ្យឆាប់ឡើង"

"ឡើងម្ខាងទៀតក៏បានដែរ"

"ខ្ញុំចង់ឡើងខាងណោះ"

"លោក សេត ធ្វើបាបខ្ញុំឬអត់ ?"

"ឯងនេះចរិតដូចមនុស្សស្រី និយាយច្រើន"

នាងក្រមុំភាំងមួយរំពេច  នាងព្រមឱ្យគេសង្ស័យភាពជាបុរសរបស់នាងមិនបានដាច់ខាត ទើបបែរខ្នងដាក់គេ ដើម្បីនាំខ្លួនឯងឡើងឡានឱ្យបាន។

"ឡានស្អីខ្ពស់នោះខ្ពស់"

"ឡានជិះ"

គេឆ្លើយប្រាប់ ព្រោះបានឮនាងរអ៊ូ សាន់នី ក៏ងាកទៅមើល និងសម្លក់សម្លឹងគេទៀតហើយ បន្ទាប់មក ក៏ងាកមកវិញ សេត ក៏ដើរមកឈរក្រោយខ្នងចាប់ចង្កេះរបស់នាងដោយដៃទាំងពីរ លើកឱ្យហើបជើងផុតពីដី។

"អ៊ំា !"

នាងស្រែកភ្លាត់មាត់ហើយប្រញាប់លើកដៃបិទមាត់ហើយរឹងខ្លួនស្តូកតែម្តង ពេលត្រូវ សេត ចាប់ជាប់បែបនេះ។

"អម្បាញ់មិញឯងស្រែក ?"



Scanned by CamScanner

នាងក្រមុំងក់ក្បាលហើយប្រញាប់គ្រវីក្បាល។នាងព្រមទទួលស្គាល់មិនបានជាដាច់ខាត ពេលនេះយ៉ាងណា ត្រូវតែអះអាងឱ្យគេក្លាយជាមនុស្សហឹងត្រចៀកសិនទៅចុះ ប៉ុន្តែ សេត ជឿនាងអីចឹងឬ សរុបទៅនាងបន់ស្រន់ឱ្យគេជឿនាងទៅចុះ។

ហ៊ឺយ! ហត់នឿយណាស់ ហត់នឿយបំផុត!

"មានតែមនុស្សស្រីប៉ុណ្ណោះដែលស្រែកគ្រឹត"

សេត នៅតែនិយាយរឿងគួរឱ្យខ្លាចសម្រាប់នាង ដែល សាន់នី ក៏ភ័យខ្លាច តែត្រូវគ្រប់គ្រងខ្លួនឯងឱ្យនឹងធឹង។

"ខ្ញុំកំពុងសង្ស័យ"

គេចាប់នាងញាត់ចូលទៅក្នុងឡាន ហើយឡើងមកតាម នាងក៏ថយទៅពិតនឹងជញ្ជាំងម្ខាងទៀត ទើប សេត ទាញទ្វារខាងខ្លួនឯងបិទ។

"ចេញឡាន"

គេចេញបញ្ជា ហើយលោទៅរក ទើបនាងប្រញាប់លើកដៃរុញដើមទ្រូងរបស់គេ។

"តិចធ្លាក់ ចាក់សោទ្វារសិន"

គេជួយចាក់សោទ្វារខាងនាងឱ្យ សាន់នី ដែលរឹងខ្លួនស្ពូក ក៏មាន



អារម្មណ៍ធូរស្រាលពេលគេថយទៅវិញ។

"អរគុណខ្ញុំហើយឬនៅ?"

"អរគុណលោក សេត"

"ឯងត្រូវធ្វើខ្លួនជាមនុស្សមានមារយាទ ដឹងទេ"

គេជេរថានាងគ្មានមារយាទអីចឹងឬ មនុស្សមាត់ដាច! គេមានមារយាទងាប់ហើយ ពូកែតែចេញបញ្ហា បញ្ហា និងបញ្ហាអ្នកដទៃ ថែមទាំងចូលចិត្តធ្វើបាបអ្នកដទៃទៀតផង។

"ប៉ុន្តែយើងនិយាយគ្នារឿងសំឡេងស្រែកគ្រីតរបស់ឯងមិនទាន់ចប់"

នាងក្រមុំលួចមើលអ្នកបើកបរ ដែលបំពេញតួនាទីរបស់ខ្លួនដូចមនុស្សយន្ត មិនខ្វល់ពីអីបន្តិចថា នាងនិង សេត កំពុងតែនិយាយគ្នាពីអ្វី។

"ចប់...ចប់ទៅ ខ្ញុំគ្រាន់តែភ្លេចខ្លួន"

"ឯងព្រមទទួលស្គាល់ថាឯងស្រែកគ្រីត"

ពេលនាង ភ្លាត់ស្នៀត ស្រែកគ្រីត ក៏ញាត់ញៀតឱ្យគេជាមនុស្សហឹងត្រចៀក ប៉ុន្តែគេមិនព្រមទទួលយក ទើបត្រូវសម្រេចចិត្ត ព្រមទទួលខ្លួនឯងឱ្យវាចប់រឿង។

"បាទ"



Scanned by CamScanner

"ឯងមានអាថ៌កំបាំងអីបិទបាំងខ្ញុំ ?"

"អត់...អត់មានទេ"

"ត្រូវតែមាន"

"អត់មានទេ"

"ឯងមានពិរុទ្ធ ដល់ផ្ទះចាំនិយាយគ្នា"

សេតធ្វើឱ្យសរសៃប្រសាទរបស់នាងភ័យខ្លាចប៉ុន្តែក្រៅពីមិននិយាយឱ្យអស់ បែរជាធ្វើឱ្យនាងខ្វល់ខ្វាយ ថាគេនឹងនិយាយអ្វីទៀត ពេលត្រឡប់ទៅដល់ផ្ទះ។

"តាមម៉ោ"

ពេល គ្រីស បញ្ជាឱ្យតាម នាងក៏ងើបដើរតាមគេចូលទៅក្នុងបន្ទប់ដេកត្រុកៗ ហើយពេលចូលទៅដល់ ក៏ឈររួញខ្លួន ស្រាក់ដៃដាក់ពីមុខ រង់ចាំការសួរចម្លើយ។

"ខ្ញុំគ្មានអីឆ្លើយទេ"

"ខ្ញុំមិនទាន់សួរផង"

ធីណា លួចមើលគេទាំងបុកពោះ ទើបគេចង្អុលឱ្យនាងទៅអង្គុយលើគ្រែ





Scanned by CamScanner

ចំណែកខ្លួនឯងដើរទៅដាក់បង្គុយលើកៅអីតុធ្វើការបែរមុខមករកនិងសម្លឹងមុខនាងចំ។

"បងស្រីរបស់ឯងជាអ្នកណា?"

"ខ្ញុំឆ្លើយមិនបានទេ"

"ខ្ញុំត្រូវសុំអនុញ្ញាតពីបង សាន់នី សិន"

"សាន់នី?"

ធីណា ចង់ខោកក្បាលខ្លួនឯងឱ្យខ្លាំងៗ ហេតុអីកាន់តែឆ្លើយ កាន់តែធ្លាយទិន្នន័យ ទាំងដែលគេមិនបានសួរអីមួយម៉ាត់។

ការកុហកនេះ វាហត់នឿយមែនទែន!

"ឈ្មោះរបស់បងស្រីខ្ញុំ" នាងព្រមឆ្លើយប្រាប់ដោយសំឡេងខ្សាវៗ។ នាងធ្វើយ៉ាងណាល្អទៅ ចំពោះហេតុការណ៍ដែលកើតឡើង ទើបតែបោកគេមិនបានពីរថ្ងៃផង ក៏ត្រូវគេចាប់បានទៅហើយឬនេះ។

"បងស្រីដែលឯងនិយាយតាំងពីដំបូងឬអត់?"

"បាទ"

ធីណា សម្លឹងមើលគេដោយការអង្វរករ ចង់ឱ្យគេឈប់សួរ។

"ម្នាក់ណា?"



Scanned by CamScanner

ហេតុអីគេចង់ដឹងម្ល៉េះ ម្នាក់ណាក៏ម្នាក់ទៅ នាងមិនចង់ឆ្លើយ ព្រោះឆ្លើយមិនបាន បើឆ្លើយ បងស្រីនឹងមានគ្រោះថ្នាក់ព្រោះតែនាង។

"ខ្ញុំឆ្លើយមិនបាន"

"សុំហេតុផល"

"បងស្រីនឹងគ្រោះថ្នាក់ព្រោះតែខ្ញុំ"

"សុំហេតុផល"

"ហេតុអីលោក គ្រីស ប៉ិនសុំម្ល៉េះ"

គេសុំអីក៏សុំម្ល៉េះ សុំឡើងនាងធ្វើខ្លួនមិនត្រូវទៅហើយ។

ប៉ុន្តែពេល គ្រីស មើលមកនាងដោយខ្សែភ្នែកកាចលើសដើម ទើបនាងសើចញឹមៗយកចិត្តគេ។

"ខ្ញុំសុំទោស"

"ខ្ញុំសួរត្រូវតែឆ្លើយ"

"វាពិបាកឆ្លើយ"

"ឯងធ្វើឱ្យខ្ញុំខាតពេល"

"សុំទោស"

នាងក្រមុំសុំទោសសុំពៃរ៍ ដោយមិនព្រមនិយាយរឿងបងស្រី ប៉ុន្តែ គ្រីស





Scanned by CamScanner

គិតថាគ្មានបញ្ហាអីទេ គេអាចគាស់មាត់នាងយកចម្លើយបាន។

"ឯងគិតតែសុំទោសដើម្បីអី"

"ខ្ញុំមិនដឹង"

"ខាស៊ី!"

"លោក គ្រីស កុំខឹងខ្ញុំអី"

គ្រីស ដំឡើងសំឡេង មានចេតនាគំរាម ដែលវាបានផលល្អណាស់ ធ្វើឱ្យ ធីណា ភ្ញាក់ក្រញាង និងភ័យខ្លាច ទើបពេបមាត់ស្បែប រកកល់ចង់យំ។

"ហាមយំ"

"ខ្ញុំសុំទោស"

"បើយំនឹងដាក់ទោស ឱ្យចេញទៅដេកនៅក្រៅផ្ទះ"

"ខ្ញុំសុំទោស"

នាងប្រឹងទប់ទឹកភ្នែក នាងមិនចង់ចេញទៅដេកនៅក្រៅផ្ទះហ្នឹងណា៎ វាប្រហែលដេកមិនលក់ស្រួលទេ ហើយនាងក៏ខ្លាចដែរ។

"ខ្លាចឬ?"

"ខ្លាច"

"ខ្លាចធ្វើអី?"



Scanned by CamScanner

"លោក គ្រីស កាច"

"ដឹងថាខ្ញុំកាច គឺត្រូវតែឆ្លើយសំណួររបស់ខ្ញុំឱ្យស្រួលបួល"

"ខ្ញុំនឹងព្យាយាម"

"ឯងត្រូវសន្យាឱ្យម៉ឺងម៉ាត់ជាងនេះ"

"ខ្ញុំធ្វើមិនបាន"

"ខាស៊ី!"

អ្នកកំលោះហៅឈ្មោះរបស់នាងជាការដាស់តឿន ដែលសំឡេងកាចរបស់គេ កាន់តែធ្វើឱ្យ ធីណា លំបាកចិត្ត នាងខ្លាចគេឡើងត្រជាក់ដៃត្រជាក់ជើងអស់ទៅហើយ។

"ខ្ញុំមិនចង់កុហកលោក គ្រីស ទៀតហ្នឹងណា៎"

"បញ្ជាក់ថាឯងមានរឿងកុហកខ្ញុំ"

ភាពស្មោះត្រង់របស់នាង ថាគួរឱ្យអាណិតក៏មិនចំ គួរឱ្យអស់សំណើចក៏មិនមែន ហើយក៏គួរឱ្យធុញទ្រាន់ ព្រោះតែអាការៈត្រដិតនិយាយស្ដីមិនដឹងរឿងនេះឯង។

"ឯងនិយាយដោយខ្លួនឯងថា មិនចង់កុហកខ្ញុំទៀតទេ"



ពេលនាង ហាមាត់ចង់ឆ្លើយ គេក៏និយាយកាត់ ទើបនាងធ្វើមុខលំបាក



Scanned by CamScanner

ចិត្ត ដូចមនុស្សជួបនឹងផ្លូវទ័ល ហើយត្រូវយកមុខ ជ្រប់នឹងកំផែង ថប់ដង្ហើម តែក៏ព្យាយាមដកដង្ហើម។

"បាទ លោក គ្រីស"

"កុហកលើកដំបូងខ្ញុំអភ័យឱ្យបានតែបើកកុហកទៀតនឹងគ្មានការលើកលែង"

គ្រីស រកដំណោះស្រាយឱ្យ ទើបនាងព្រមងើយមុខ មកមើលគេ មើលដោយខ្សែភ្នែកមានសង្ឃឹម។

"មែនឬ?"

"មែន...ហើយម្យ៉ាងទៀត បើរឿងកុហកដំបូងរបស់ឯងមិនធ្វើឱ្យខ្ញុំមានបញ្ហា ខ្ញុំនឹងចិត្តទូលាយអភ័យឱ្យឯង"

"មិនពាក់ព័ន្ធនឹងលោក គ្រីស ទេ"

"ហើយពាក់ព័ន្ធនឹងអ្នកណា?"

"សុវត្ថិភាពរបស់ខ្ញុំនិងបងស្រី"

"បងស្រីដែលនៅជាមួយម្ចាស់តូច?"

"បាទ អ៊ុំ!"

ធីណា ឆ្លើយ ព្រោះភ្លេចខ្លួន ហើយបើកភ្នែកធំៗ ស្ទះងើបឈរ ប៉ុន្តែត្រូវ



Scanned by CamScanner

គ្រីស ចង្អុលគ្រែ ទើបនាងដាក់បង្គោយចុះវិញ។

"លោក...លោកគ្រីស"

"បើនោះជាបងស្រីឯង ហើយឯងជាប្អូនស្រីឬប្អូនប្រុស ?"

"ខ្ញុំ...ខ្ញុំ"

គ្រីសប្រុងកៀងក្ដាន់ឱ្យចូលស៊ូងប៉ុន្ដែគេមិនរហេករហន់ត្រូវឱ្យពេលនាងបន្ដិច។

"ខ្ញុំជា...ប្អូន...ប្អូន..."

"ខ្ញុំត្រូវការចម្លើយថ្ងៃនេះ"

"ខ្ញុំដឹងហើយ"

"ដឹងហើយត្រូវតែឆ្លើយ"

"លោក គ្រីស បើខ្ញុំឆ្លើយលោកនឹងខឹងខ្ញុំទេ ?"

"បើឯងមានហេតុផលល្អ ខ្ញុំនឹងស្ដាប់"

"សុំអនុញ្ញាតដើរទៅរកបានទេ"

"បាន ខ្ញុំអនុញ្ញាត"

នាងដើរទៅរកគេ ប៉ុន្ដែមុននឹងទៅដល់ ក៏ជំពប់ជើងខ្លួនឯង ជ្រមិលទៅសង្កត់លើគេបានចំល្អមែនទែន។





Scanned by CamScanner

"សុំអនុញ្ញាតដើម្បីម៉ោសង្កត់ខ្ញុំ?"

"ខ្ញុំជំពប់ជើង"

អ្នកកំលោះ ក្រសោប លើកនាងឱ្យអង្គុយលើភ្លៅ ជាការបញ្ចប់បញ្ហាដែលធ្វើឱ្យបេះដូងរបស់ ធីណា លោតញាប់នឹងភាពស្និទ្ធស្នាលដែលកើតឡើងនេះ តែនាងមិនហ៊ានកម្រើកខ្លួន ព្រោះខ្លាចគេ។

"ព្រមសារភាពហើយឬនៅ នាងច្រមក់"

ធីណា បើកភ្នែកធំៗដាក់គេម្តងទៀត បេះដូងលោតកាន់តែញាប់។ គេដឹងហើយអីចឹងឬ ថានាងជាមនុស្សស្រី ហេតុអីភ្នែករបស់គេមុតបែបនេះ។

"ចាំ លោក គ្រីស"

"និយាយម៉ោ ខ្ញុំនឹងស្តាប់ដោយការយកចិត្តទុកដាក់"

នាងក្រមុំដកដង្ហើមចូលឱ្យជ្រៅៗ ដូចកំពុងត្រៀមខ្លួនធ្វើរឿងសំខាន់ខ្លាំង ប៉ុន្តែនេះគឺជារឿងសំខាន់សម្រាប់នាងមែនហ្នឹង។

"ខ្ញុំនិងបងស្រី យើងទាំងពីរជាស្រីទាំងពីរនាក់"

"ហើយបន្លំខ្លួនជាមនុស្សប្រុសធ្វើអី?"

"ដើម្បីសុវត្ថិភាព"

នាងរៀបរាប់រឿងរ៉ាវនៅរោងរបាំងស្រាតណាខាដៀឱ្យគេស្តាប់ ហើយ



Scanned by CamScanner

និយាយពីហេតុការណ៍ដែលត្រូវរត់គេចព្រោះខ្លាចត្រូវចាប់ខ្លួនបាន ឱ្យទៅធ្វើការនៅទីនោះវិញ។ នាងមិនឆ្លាត ប៉ុន្តែដឹងថាត្រូវនិយាយតែរឿងរបស់ខ្លួនឯងប៉ុណ្ណោះ ព្រោះរឿងរបស់បងស្រី មិនគួរលាតត្រដាងឱ្យអ្នកដទៃដឹង ក្រៅពីបងស្រីជាមនុស្សស្រីដែលនាងព្រមសារភាពប្រាប់ គ្រីស ទៅហើយ។

"ខ្ញុំគ្មានចេតនាទេ ការធ្វើជាមនុស្សប្រុស នឹងធ្វើឱ្យខ្ញុំនិងបងស្រីមិនត្រូវអ្នកណាចាប់អារម្មណ៍"

"គិតផ្តេសផ្តាស មនុស្សប្រុសចេកៗ កាន់តែក្លាយជាចំណុចចាប់អារម្មណ៍"

"លោក គ្រីស ខឹងទេ"

នាងមើលគេដោយការភ័យខ្លាច ប៉ុន្តែពេល គ្រីស គ្រវីក្បាល នាងក៏ញញឹមពព្រាយ។ បើដឹងថា គេចិត្តល្អបែបនេះ នាងប្រហែលសារភាពតាំងពីជួបមុខគ្នាម្ល៉េះ កុំឱ្យមានការភ័យខ្លាច ពិបាកធ្វើខ្លួន។

"លោក គ្រីស ចិត្តល្អដល់ហើយ សុំឱបបន្តិច"

នាងស្រវាឱបគេ ឱបណែន ដល់ថ្នាក់ គ្រីស ត្រូវក្អកគ្រហែមជាការដាស់តឿន។ គេមិនបានឱបនាងវិញ តែក៏មិនបានរុញច្រានចេញ។





Scanned by CamScanner

# ១៣

## ញ៉ោះព្រោះស្រឡាញ់

សាន់នី មិនចង់និយាយរកគេ ហើយក៏ត្រៀមខ្លួនគេចវេះគ្រប់ពេលវេលា ដូច្នេះហើយដើម្បីបង្ការនាងគេចវេះ ទើបគេបីនាងចុះពីឡាន ហើយចាប់ដៃជាប់នាំដើរទៅជាមួយ។

"លោក សេត"

"មានការអី ?"

"លោកសម្រាកសិនល្អទេ ?"

"ខ្ញុំមិនហត់ទេ"

សេត នៅតែអូសដៃនាងទៅដល់បន្ទប់ដេក ក៏មិនព្រមពន្លែង ដែលទោះបន្ទប់ដេករបស់គេធំល្វឹងល្វើយ ប៉ុន្តែការនៅក្នុងបន្ទប់ជាមួយគ្នាតែពីរនាក់ នៅតែធ្វើឱ្យនាងបុកពោះដដែល។

"យើងទៅអង្គុយនិយាយគ្នា"



Scanned by CamScanner

កន្លែងនិយាយគ្នារបស់គេ ក្រៅពីបន្ទប់ដេក ដែលគំរាមព្រលឹងហើយ នៅនាំមកអង្គុយនៅចុងគ្រែ ហើយឱ្យនាងអង្គុយលើភ្លៅទៀត។

"លោក សេត"

"ខ្ញុំនឹងចាប់កុហកឯង"

សាន់នី ប្រកែកមិនចេញ ចង់អះអាងថានាងមិនបានកុហកក៏ធ្វើមិនបាន ទើបត្រូវព្រមអង្គុយលើភ្លៅរបស់គេ និងប្រឹងឡើងរឹងខ្លួនស្ងួក ដើម្បីមិនឱ្យពិតនឹងដើមទ្រូងធំទូលាយ។

"លោក សេត ចង់សួរអី ?"

"ឯងស្រែកគ្រីតដូចមនុស្សស្រី ខ្ញុំកាន់តែសង្ស័យ"

"ខ្ញុំគ្មានចេតនាមិនល្អចំពោះលោក សេត ទេ"

ការប្រាប់គេបែបនេះ គឺដូចព្រមទទួលដោយប្រយោលថា នាងមានរឿងខ្លះបិទបាំងគេ ហើយពេល សេត ដាក់ចង្ការលើស្មាតូចស្តើង នាងកាន់តែរឹងខ្លួន។

"ខ្លួនឯងតូចតែមួយ មានក្លិនក្រអូបដូចមនុស្សស្រី"

"អឺ...អឺ..."

"សំឡេងក៏ពីរោះ មុខក៏ស្រស់ កាយវិការល្វត់ល្វន់ដូចមនុស្សស្រី"





Scanned by CamScanner

"លោក...លោក សេត និយាយធម្មតាៗបានទេ"

នាងក្តិចខ្នងដៃរបស់គេ។ ត្រឹមនិយាយ បេះដូងរបស់នាងក៏លោតញាប់ព្រោះខ្លាច ត្រូវចាប់បានទៅហើយ គេនៅអង្អែលភ្លៅរបស់នាងទៀត។

"ឬឯងជា..."

សេត មិនខ្វល់ពីការស្តីឱ្យរបស់នាង ប៉ុន្តែពេលនិយាយបានកន្លះប្រយោគហើយ គេក៏នៅស្ងៀម ដែលការធ្វើបែបនេះ ធ្វើឱ្យបេះដូងរបស់នាងលោតកាន់តែញាប់។

"លោកគិតថាខ្ញុំជា ស្អី?"

"ជា..."

"ជា?"

គេមានចេតនាផ្អាកនិយាយឱ្យនាងគិតច្រើនធ្វើអីនាងចាំអ៊ុតឡើងរឹងខ្លួនស្តូកទៅហើយ។

"ជាមនុស្សប្រុសដែលចង់ធ្វើស្រី"

"បាទ?"

នាងដំឡើងសំឡេងខ្លាំងៗ គេគិតបានតែប៉ុណ្ណឹងទេឬ?

នាងងាកទៅមើលមុខគេ តែគេធ្វើមុខតានតឹងដាក់វិញ។



Scanned by CamScanner

"តើមែនឬអត់ ដាស៊ី"

"ឈប់សិន លោក សេត"

"ឯងភ្ញាក់ផ្អើលដែលខ្ញុំដឹងការពិតមែនទេ"

"ខ្ញុំគិតថា...."

"ឯងព្រមទទួលស្គាល់ការពិតម៉ោ"

គេឱ្យនាងព្រមទទួលស្គាល់ថា មានរាងកាយជាមនុស្សប្រុស តែបេះដូងជាមនុស្សស្រីអីចឹងឬ តែណ្ហើយចុះ មនុស្សប្រុសពាក់កណ្ដាលខ្លួន អាចងាយស្រួលសម្រាប់នាងជាងក៏ថាបាន។

"បាទ លោក សេត"

"ប៉ុណ្ណឹង ម៉េចចាំបាច់គិតច្រើនធ្វើអី"

"ខ្ញុំគិតថាលោក សេត ទទួលយកខ្ញុំមិនបាន"

"ខ្ញុំធ្លាប់ប្រាប់ឯងហើយតើថាខ្ញុំជាមនុស្សចិត្តទូលាយ"

មានន័យដល់ចំណង់ចំណូលចិត្តរបស់គេ ព្រមទទួលគ្រប់ភេទរបស់គេឬ?

សាន់នីឆ្ងលចុងច្រមុះមួយរំពេច មនុស្សដូចគេនេះ នេះនាងប្រចណ្ឌត្រឹមមនុស្សស្រីមិនគ្រប់ នៅមកប្រចណ្ឌមនុស្សប្រុសទៀតឬនេះ!





Scanned by CamScanner

យើងប្រចណ្ឌគេឬ?

នាងក្រមុំភ្ញាក់ផ្អើលនឹងគំនិតរបស់ខ្លួនឯងច្រើនជាង ហើយព្រោះនាងគិតរឿងមិនទំនងបែបនេះឯង ទើបមិនបានយកចិត្តទុកដាក់ថា ដៃរបស់ សេត កំពុងតែស្ទាបអង្អែលរាងកាយរបស់នាង។

"តែខ្លួនរបស់ឯងទន់ល្អណាស់ ដាស៊ី"

"អឺ...បាទ ខ្ញុំមើលថែខ្លួនឯង"

"ឯងបើកចំហចំពោះខ្ញុំ ខ្ញុំមិនប្រកាន់ទេ"

"អរគុណលោក សេត"

"ហើយនៅមានរឿងដែលខ្ញុំសង្ស័យមុននេះទៀត"

នាងនឹកមិនចេញ សេត មានរឿងសង្ស័យច្រើនណាស់ ហើយនាងដឹងដោយរបៀបណា ថាគេសង្ស័យរឿងមួយណា។

"រឿងអី?"

សេត ទ្រាបដៃនឹងពោះរាបស្មើ ញញឹមលាក់កំណួច ប៉ុន្តែនាងមើលមិនឃើញ ព្រោះអង្គុយលើភ្លៅរបស់គេនោះឯង ហើយ សេត ក៏សម្លឹងកញ្ចឹងករបស់នាង បន្ទាប់មក ក៏ថើបពីរបីខ្សឺត។

*ថ្ងៃនេះត្រូវតែបានថើប!*

ទ្រាំយូរហើយ គេនឹងបានថើបនាងនៅថ្ងៃនេះ ប៉ុន្តែត្រូវតែត្រួសត្រាយផ្លូវដើម្បីកុំឱ្យនាងខ្វល់ខ្វាយ ហើយធ្វើឱ្យគេអាចប៉ះពាល់នាងបានតាមតម្រូវការ។

"ដើមទ្រូងរបស់ឯងដែលវាប៉ោង វាមិនមែនជាសាច់ដុំទ្រូងដូចដែលខ្ញុំធ្លាប់សួរទេមែនទេ មាឌឯងតូចល្អិត ម៉េចក៏ដើមទ្រូងធំបែបនេះ"

"អឺ...លោក...លោក សេត ចង់មានន័យថាម៉េច ?"

"ឯងធ្វើដើមទ្រូងមែនទេ ?"

"បាទ"

នាងក្រមុំ ព្រមទទួលក៏បានដែរ ក្រែងលោវាធ្វើឱ្យជីវិតរបស់នាងកាត់បន្ថយភាពតានតឹងបានបន្តិចទៀត ខណៈដែល សេត ញញឹមលាក់កំណួចនៅចុងមាត់ទៀតហើយ។

"ខ្ញុំសុំចាប់មើលបន្តិច"

"បាទ ?"

"កុំរើមើល៍ ឯងភ្ញាក់ផ្អើលធ្វើអី យើងជាប្រុសដូចគ្នាតើ"

"លោក...លោក សេត ចង់ចាប់ធ្វើអី ?"

"ខ្ញុំចង់ដឹង សុំចាប់បន្តិច"

គេខ្សឹបដាក់ត្រចៀក ធ្វើឱ្យនាងដឹងពីជោគវាសនារបស់ខ្លួនឯង ថាបើ





Scanned by CamScanner

បដិសេធ សេត ត្រូវតែរករឿង កេងចំណេញលើសនេះ។

"បាទ លោក សេត"

សេត លូកដៃចូលទៅក្នុងអាវធំសុលគយុលដែលនាងពាក់ ខណៈដែលម្ចាស់អាវ ប្រឹងអត់ដង្ហើម ពេលដៃរបស់គេ អូសកាត់ពោះយឺតៗ ទៅរកដើមទ្រូង។

"ឯងរុំក្រណាត់ឬ?"

"បា...បាទ"

"ខ្ញុំដោះចេញ"

ថ្ពាល់របស់នាងឡើងក្រហមងាំង សំណាងដែលអង្គុយបែរខ្នងដាក់គេ និងឆ្លើយតបដោយសំឡេងខ្សាវៗ ខណៈដែល សេត លើកអាវផ្នែកខាងក្រោយរបស់នាងឡើងលើ ដើម្បីស្រាយចំណងរបស់ក្រណាត់រុំដើមទ្រូង ពេលរួចរាល់ក៏ទាញវាចេញពីខ្លួនរបស់នាង ទើប សាន់នី លូកដៃចូលទៅក្នុងអាវ ក្រសោបដើមទ្រូងរបស់ខ្លួនឯង។

"លោក...លោក សេត ចង់ចាប់មែនឬ?"

"មែន"

មកដល់ដំណាក់កាលនេះទៅហើយ មានឬ ដែលគេដកថយ ទោះត្រូវនាងហៅថា អាត្រេកកាម ក៏គេព្រមទទួលយក ព្រោះគេចង់ប៉ះពាល់ខ្លួនប្រាណ



Scanned by CamScanner

របស់នាងដែលនឹកខ្លាំង ឡើងញ័រដៃ ទប់អាការៈមិនចង់ជាប់។

"សុំចាប់បន្តិច"

សំឡេងរបស់គេស្អកខុសពីធម្មតា សាន់នី មិនបានជាសង្កេត ព្រោះរវល់តែអៀន បន្ទាប់មក គេក៏លូកដៃចូលទៅក្នុងអាវរបស់នាងម្តងទៀត បេះដៃនាងចេញ ហើយប្រើដៃទាំងពីររបស់ខ្លួនឯងក្រសោបវា។

"ពេញដៃល្អណាស់"

នាងកញ្ជ្របស្មា ពេលត្រូវគេច្របាច់ដោយបាតដៃទាំងពីរ ហើយផ្តេកខ្នងនឹងដើមទ្រូងធំទូលាយ ទន់ខ្លួនល្មក ព្រោះអារម្មណ៍ស្រៀវស្រើប ដែលត្រូវគេដុត។

"ដូចរបស់ពិត"

"បាទ...បាទ ពេទ្យពូកែ"

នាងពូកែរកហេតុផលមកឆ្លើយបានជារឿយៗ ខណៈដែល សេត សង្កត់បបូរមាត់លើថ្ពាល់រលោង ថើបវាដោយការនឹករឭក។

"ធ្វើដូចណាស់ ធ្វើឱ្យគិតថាជាដើមទ្រូងរបស់មនុស្សស្រីមែនទែន"

"បាទ លោក សេត អ៊ំា!"

"ឯងមានអារម្មណ៍ដែរឬ ?"





Scanned by CamScanner

"មាន...មាន"

"ចុះបើខ្ញុំធ្វើបែបនេះ"

គេសង្កត់មេដៃនឹងចុងទ្រូងរបស់នាង ប៉ះពាល់តាមទម្លាប់ ព្រោះវាគឺជាផ្នែកដែលគេចូលចិត្ត។

"អ៎ា! អ្ហឺ!"

"មានអារម្មណ៍មែនក៏អី?"

គេខ្សឹបសួរ នាងក៏ដកដង្ហើមដង្ហក់។ រាងកាយរបស់នាងស៊ាំនឹងការប៉ះពាល់របស់ សេត ហើយគេក៏ប៉ះពាល់ដូចដឹងថា ប៉ះបែបណាទើបចំចំណុចខ្សោយរបស់នាង។

"ដើមទ្រូងរបស់ឯងប្រហែលដៃរបស់ខ្ញុំប្លែកៗ"

ពេលនាងធ្វើខ្លួនរឹងកំព្រឹស ដូចចង់រារាំង គេក៏ខ្សឹបប្រាប់ដូចគំរាម ទើបនាងព្រមចុះញ៉ម ឱ្យគេចាប់តាមអំពើចិត្ត។

"វាប្រហែលមែន"

នាងមិននិយាយរកទៀត ព្រមឱ្យគេប៉ះពាល់ និងប្រឹងខ្ទឹបបបូរមាត់ដើម្បីទប់សំឡេងរំជួលចិត្ត។

"សុំប្រាប់ឱ្យយូរបន្តិច"



Scanned by CamScanner

អ្នកកំលោះដាក់ចង្កាលើក្បាលរបស់នាង ខណៈនោះដៃក៏ប្រចាប់ដើមទ្រូងធំទ្រលុកទ្រលន់ ដោយអារម្មណ៍ឈ្លក់វង្វេង។ គេពេញចិត្តដែលនាងព្រមឱ្យគេប៉ះពាល់ ហើយរាងកាយរបស់នាង ក៏មានប្រតិកម្មចំពោះការប៉ះពាល់របស់គេដែរ។ តើមកពីនាង នឹកដល់ពេលវេលាដែលធ្លាប់មានជាមួយគេឬអត់។

សេត មានកម្លាំងព្រឺស នឹងគំនិតរបស់ខ្លួនឯង ថានាងត្រូវតែនឹកគេ ព្រោះគេជាបុរសដំបូងរបស់នាង ហើយគេក៏ត្រូវតែជាបុរសតែម្នាក់គត់ មិនអនុញ្ញាតឱ្យអ្នកណាជាន់ដានរបស់គេជាដាច់ខាត។

"ខ្ញុំសង្ការទេ"

ពេលគេដឹងការពិតថានាងជាមនុស្សស្រី ធីណា ក៏បណ្តោយខ្លួនបណ្តោយប្រាណតាមធម្មជាតិ ដល់ថ្នាក់សុំឱ្យ គ្រីស ជួយកាត់សក់ឱ្យ។ អ្នកកំលោះជួយកាត់សក់ខ្លីឱ្យនាង ប៉ុន្តែពេលវាក្តោបមុខស្រស់ស្រទន់ ក៏នាងនៅតែស្អាតនិងគួរឱ្យស្រឡាញ់ដដែល។

"អឺម" គ្រីស តបនៅដើមក ហើយយកកន្ត្រៃទៅទុកដាក់ នាងក៏ដើរទៅតាម ព្រោះពេលនេះ គេលែងជាមនុស្សគួរឱ្យខ្លាចសម្រាប់នាងហើយ គេក្លាយជាទីពឹងពាក់របស់នាង ព្រោះគេដឹងអាថ៌កំបាំងរបស់នាង។



"លោក គ្រីស"

នាងស្រវាឱបគេពីក្រោយ ព្រោះ គ្រីស ឈរនៅមុខទូដាក់អីវ៉ាន់ គេត្រូវអប់រំនាងប្រមក់នេះសាជាថ្មីហើយ ពីរឿងស្និទ្ធស្នាលនឹងមនុស្សប្រុស។

"មានការអី ?"

"អរគុណដែលកាត់សក់ឱ្យខ្ញុំ"

"អរគុណធម្មតាៗក៏បាន មិនបាច់ឱប"

នាងរសាយរង្វង់ដៃ ហើយពេលគេបែរមករក ក៏ត្រសុលទៅបៀត និងស្រវាឱបរឹតតែម្ដង។

"ចង់ឱប ខ្លួនលោក គ្រីស កក់ក្ដៅ"

"ខ្ញុំជាមនុស្សប្រុសនាងជាមនុស្សស្រី នាងត្រូវប្រយ័ត្នខ្លួន"

"ប្រយ័ត្នធ្វើអី ?"

"នាងមិនខ្លាចខ្ញុំធ្វើស្អីនាងទេឬយ៉ាងម៉េច"

"គិតថាមិនធ្វើ"

នាងងើយមុខ ទៅឆ្លើយ ហើយញញឹមលឹបភ្នែកដាក់ ហើយពេលត្រូវ គ្រីស ចាប់ក្បាលរុញចេញឱ្យឆ្ងាយពីខ្លួន ក៏ជ្រួញប្រមុះដាក់គេ។

"ប្រយ័ត្នខ្លួន ប្រយ័ត្នខ្ញុំវ៉ៃ"



Scanned by CamScanner

"លោក គ្រីស ចិត្តអាក្រក់"

"ទៅញ៉ាំអាហារពេលល្ងាច"

"ថ្ងៃនេះមានអីញ៉ាំ"

ធីណា ដូចកូនក្មេង ពេលនៅជាមួយអ្នកណា ឱ្យអារម្មណ៍សប្បាយចិត្ត ហើយនាងក៏លាតត្រដាងភាពជាខ្លួនឯងឱ្យឃើញទាំងអស់។នាងដើរមកឱបដៃរបស់គេ យកដើមទ្រូងដែលមិនបានរុំដោយកន្សែង មកបៀតនឹងដៃរបស់គេ។

"ចេញទៅមើល គង់តែឃើញ"

"ចាំ លោក គ្រីស"

នាងឆ្លើយតបដោយសំឡេងពីរោះ ហើយញញឹមដាក់ពេលគេឱនមករក និងប្រសព្វភ្នែកគ្នា។ ធីណា ញញឹមស្រស់ ពូកែម្ទិកម៉្ងក់ បើបណ្ដោញ ខ្លាចនាងយំ។

ហ៊ឹយ នៅជាមួយមនុស្សស្រី វាស្មុគស្មាញខ្លាំងណាស់!

**សេត ជាមនុស្សមិនចេះស្កប់ស្កល់ បានមួយចង្អាមចង់ថែមមួយហាត់ ហើយនាងដែលស្ថិតក្នុងឋានៈចាញ់ប្រៀប ក៏ត្រូវព្រមធ្វើតាមចិត្តរបស់គេ ទោះមិនចង់ព្រមក៏ដោយ។**





Scanned by CamScanner

"អា៎!"

នាងខ្ទឹបបបបូរមាត់ អង្គុយកន្ទែកជើង ផ្អែកនឹងក្បាលគ្រែ ទ្បេវអាវសើមិខាង មុខ ត្រូវប្រឡេះអស់រលីង ដោយមានមុខសង្ហារបស់គេ ឈ្មុលដើមទ្រូង។

សាន់នី លួចមើលគេ នឹកដល់ពេលវេលាដែលបបោសអង្អែលគ្នា ជាមួយគេហើយ កែវភ្នែករបស់នាងក៏ស្រទន់ លើកដៃដាក់លើស្មាធំទូលាយ ខ្ញាំ នឹងក្រចក ពេលអារម្មណ៍ស្រៀវស្រើបនៅក្នុងខ្លួន ត្រូវដុត។ នាងនៅឆ្ងាយពីការ ប៉ះពាល់របស់គេយូរគួរសម ពេលដែលត្រូវប៉ះពាល់បែបនេះ រាងកាយក៏បង្ហាញ ឱ្យឃើញពីការដង្ហោយរក។

គេចង់ប៉ះពាល់ដើមទ្រូង ដែលគិតថាឆ្លងកាត់កាំបិតពេទ្យដោយមាត់ ធ្វើ តែស្ពភាពទន់ល្មើយរបស់វានេះគេត្រេកកាមខ្លាំងមិនថាជាមនុស្សស្រីឬមនុស្ស ប្រុសក៏មិនលើកលែង។

"ក្រអូប ទន់ល្មើយ"

គេបបោសអង្អែលដោយការនឹករឭក ប៉ះពាល់នាងដោយវិធីដែលតែងតែ ដុតនាងបានសម្រេច ប៉ុន្តែ សាន់នី ប្រហែលមិនដឹង។

"ឯងមើលថែខ្លួនឯងបានល្អណាស់"

"បាទ...បាទ លោក សេត"



Scanned by CamScanner

គេពេញចិត្តហើយឬនៅណា៎ ព្រោះអារម្មណ៍របស់នាងកំពុងតែជ្រួលច្របល់ខ្លាំង។ នាងបានដឹងថា គេទាញមុខចេញពីដើមទ្រូង ហើយពេលបើកភ្នែក ក៏ឃើញគេលុតជង្គង់ បន្ទាប់មក ក៏ឱនមកបបោសអង្អែលរាងកាយរបស់នាងបន្ត។

*លោកចាំខ្ញុំមិនបានមែនឬ?*

ខ្សែភ្នែករបស់នាងមើលមកគេដោយការដង្ហោយរក ដោយមិនដឹងខ្លួនសេត ដែលគិតតែថើបដើមទ្រូង ពេលឃើញពន្លឺនៅក្នុងកែវភ្នែកនោះហើយ ក៏ទប់ចិត្តមិនជាប់។

"សុំថើបសាកមើល"

គេភ្ញើយចង្ការបស់នាង សួរ តែមិនរង់ចាំចម្លើយ ដោយការឱនទៅថើបបបូរមាត់ទន់ល្មើយ ហើយគ្រហឹមនៅដើមក បន្ទាប់ពីបានត្រឹមតែលួចថើបពេលនាងដេកលក់ តែពេលនេះ គេបានថើបស្រួលបួលហើយ។

"អ៊ា! អ៊ា..."

គេថើបជញ្ជក់បបូរមាត់របស់នាង ឱបរឹតរាងតូចស្តើងណែនដៃ បន្ទាប់មកក៏អូសបាតដៃមកក្រសោបដើមទ្រូង ប្របាច់ភ្លោចអារម្មណ៍របស់នាង ឱ្យក្តៅគគុក។





Scanned by CamScanner

...

"លោក សេត លោក សេត"

សំឡេងរបស់អ្នកបម្រើដែលបន្លឺឡើងនៅបន្ទប់ផ្នែកខាងក្រៅ ធ្វើឱ្យសាន់នី ភ្ញាក់ស្មារតី ហើយក៏ដកដង្ហើមដង្ហក់មើលគេដែលដកបបូរមាត់ចេញពីបបូរមាត់របស់នាង។

"មានការស្អី!"

"ព្រះនាងយាងមក"

អ្នកបម្រើស្រែកប្រាប់ជាការរាយការណ៍ ព្រោះបើចៅហ្វាយគ្មានបញ្ជាអ្នកបម្រើក៏មិនអាចចូលទៅក្នុងបន្ទប់ដេកផ្នែកខាងក្នុងបានដែរ។

"ទូលទ្រង់ទៅ ថាបន្តិចទៀតខ្ញុំចេញទៅជួប"

"ចា៎ លោក សេត"

សាន់នី ចងចិញ្ចើម ពេលបានឮការរាយការណ៍ទាំងអស់ ពេលនោះ សេត ក៏ឱនមកថើបបបូរមាត់ទន់ល្មើយ ថើបជញ្ជក់ខ្លាំងៗ។

"អ្អឺ! ថើបខ្លាំងពេកហើយ"

នាងរអ៊ូរទាំដោយភ្លេចខ្លួនថែមទាំងសម្លក់សម្លឹងគេដែលគេឱនមកមើលដើមទ្រូងទ្រលុកទ្រលន់ដោយខ្សែភ្នែកសោកស្ដាយ។



Scanned by CamScanner

"នៅចង់បើបអានេះទៀត"

"បានហើយ"

"ត្រូវតែបានហ្នឹង ខ្ញុំត្រូវចេញទៅជួបម៉ាក់ ឯងរង់ចាំនៅក្នុងនេះ"

"បាទ លោក សេត"

"ហើយពេលនៅជាមួយខ្ញុំមិនបាច់ប្រើក្រណាត់រុំដើមទ្រូងទេវាថប់ដង្ហើមអាណិតវា"

គេក្រសោបដើមទ្រូងទ្រលុកទ្រលន់ដោយដៃទាំងពីរ ថែមទាំងច្របាច់ដូចវាជារបស់លេង ដែលធ្វើឱ្យនាងក្តៅថ្ពាល់។

"បាទ លោក សេត"

"និយាយចេះស្តាប់គ្នាបែបនេះគួរឱ្យស្រឡាញ់"

សាន់នី សម្លក់សម្លឹងគេម្តងទៀត នាងគួរឱ្យស្រឡាញ់ព្រោះមិនធ្វើឱ្យគេឃ្នើសចិត្ត គេជាមនុស្សប្រុសប្លែក ហើយទោះរាងកាយរបស់នាងទោរទន់ទៅតាមការប៉ះពាល់របស់គេ ប៉ុន្តែនាងនៅតែតឹងចិត្តនឹងចំណង់ចំណូលចិត្តផ្ទាល់ខ្លួនរបស់ សេត។

"សុំពេលមួយភ្លែត"

គេប្រាប់នាងដោយមានមារយាទ សម្រួតចុះពីគ្រែ តែមិនភ្លេចឱនមក





Scanned by CamScanner

ថើបដើមទ្រូងទន់ល្មើយពុជុប និងមានចេតនា បឺតជញ្ជក់ ជាលើកចុងក្រោយ។

"លោក សេត!"

"ខ្ញុំទៅមែនទែនហើយ"

"សួស្តីម៉ាក់"

ព្រះនាង ឃែតទ្រីណា ងើបចេញពីសាឡុង លើកដៃឱបកូនប្រុសដែលដើរមករកឱ្យគេថើបថ្ពាល់ និងនាំទៅអង្គុយលើសាឡុងវិញ។

"ម៉ាក់មានការបន្ទាន់ឬ?"

"គិតថាបន្ទាន់"

សេត នៅតែញញឹមដាក់ម្តាយ ស្នាមញញឹមនិងកែវភ្នែកពោរពេញដោយល្បិចបែបនេះ ព្រះនាង ឃែតទ្រីណា ស្គាល់ច្បាស់ ព្រោះព្រះនាងចិញ្ចឹមមើលថែបុត្រដោយផ្ទាល់ដៃតាំងពីតូច។

"រឿងអី?"

"ម៉ាក់នៅជាមួយលោកប៉ាលើកំផែង គយគន់ទេសភាព ពេលកូនឡើងឡានត្រឡប់មកផ្ទះវិញ"

កំពែងគយគន់ទេសភាព មានកែវយឺតទំហំធំ ទុកសម្រាប់មើល

ទស្សនីយភាព នៅជុំវិញកោះ ប៉ុន្តែតាមរយៈការមើលទស្សនីយភាពនោះ អ្នកម្តាយ ប្រហែលចៃដន្យឃើញគេនៅជាមួយ សាន់នី ល្មម។

"លោកប៉ាឃើញកូន លើកក្មេងប្រុសឡើងឡាន"

"បាទ ម៉ាក់"

"នៅញញឹមទៀត"

"ញញឹមមិនបានឬ"

"ញញឹមលាក់កំណួចបែបនេះ មិនមែនជាសុភាពបុរសទេ"

ម្តាយរបស់គេ ជាស្ត្រីស្រស់ស្អាត និងឆ្លៀវឆ្លាត ទាស់ត្រង់ថាព្រះនាងយៃតទ្រីណា បង្ហាញភាពឆ្លៀវឆ្លាតឱ្យឃើញបែបទន់ភ្លន់ មិនគំរាមកំហែងស្វាមីមិនអួតអាង។

"ម៉ាក់ចោទប្រកាន់ខ្ញុំ"

"ប៉ាមើលឃើញជាក្មេងប្រុសមាឌល្អិតតែសម្រាប់ម៉ាក់រូបរាងបែបហ្នឹងគួរតែជាមនុស្សស្រី"

សេត ញញឹមញញែម មើលពីចម្ងាយបែបនេះ អ្នកម្តាយនៅមើលដឹង ប៉ុន្តែគេក៏មិនបានញញើត ព្រោះមិនគិតថាវាជារឿងខុសឆ្គង។

"គ្រាន់តែជាមនុស្សស្រីដែលបន្លំខ្លួនជាមនុស្សប្រុសប៉ុណ្ណោះម៉ាក់"





Scanned by CamScanner

"ថាម៉េច ?"

"ម៉ាក់បានឮមិនខុសទេ"

"ហើយនាងធ្វើបែបនោះដើម្បីអី ?"

"នាងចង់ឡើងមកលួចរបស់នៅលើកោះ"

ព្រះនាង ឃៃតទ្រីណា កាន់តែភ្ញាក់ផ្អើល ពេលបានឮ ដល់ថ្នាក់លើកដៃស្ទាបទ្រូង។ ឡើងមកលួចរបស់ គឺមានន័យថាជាចោរ តែកូនប្រុសបែរជាមិនចាត់ការ។

"នាងជាចោរឬ ?"

"បាទ ម៉ាក់"

សេត នៅតែឆ្លើយតបដោយទឹកមុខញញឹម ថែមទាំងអស់សំណើចទៀតផង ប៉ុន្តែព្រះនាងមិនសើចជាមួយ។

"សេត កូននិយាយលេងឬមែន"

"នាងជាចោរកំណាចណាំម៉ាក់ ដូច្នេះហើយខ្ញុំត្រូវព្រមាន"

សាន់នី ត្រូវញាត់ញៀតជាចោរ សម្រាប់គេ នាងជាស្រីចោរមុខស្រស់លួចឡើងមកលើកោះ ដើម្បីលួចចំណាប់អារម្មណ៍របស់គេ។

"សេត ម៉ាក់ត្រូវការការអធិប្បាយ"

"គ្រាន់តែជាចោរកំប៉ិកកំប៉ុកទេម៉ាក់"

"តែចោរគឺចោរ"

"ម៉ាក់កុំខ្វល់ខ្វាយអី"

សេត ប្រាប់ថាស្រីម្នាក់នោះជាចោរ ប៉ុន្តែបញ្ជាក់មិនឱ្យម្តាយខ្វល់ខ្វាយ ហើយវាហាមបានដែរឬ មានចោរមកនៅជិតកូនប្រុស ព្រះនាងតែងតែគិតច្រើន។

"ត្រូវតែខ្វល់ខ្វាយ បើកូនមានគ្រោះថ្នាក់ តើគិតយ៉ាងម៉េច"

"ខ្ញុំគ្រប់គ្រងស្ថានការណ៍បាន"

"សេត ម៉ាក់មិនសប្បាយចិត្តទេ"

"នាងគ្រាន់តែជាចោរមិនដឹងខ្យល់អីទេម៉ាក់"

"ម្តងកំប៉ិកកំប៉ុក ម្តងមិនដឹងខ្យល់អី សម្រេចថាជាចោរឬជាស្អី?"

ព្រះនាង បារម្ភពីកូនប្រុស ប៉ុន្តែចម្លើយរបស់ សេត ធ្វើឱ្យទ្រង់ចាប់ផ្តើមមានស្មារតី នឹកដល់ហេតុការណ៍ប្លែកៗដែលកើតឡើង។

"ស្រីចោរមុខស្រស់ដែលឡើងមកលើកោះដើម្បីលួចចំណាប់អារម្មណ៍ពីខ្ញុំ"

"សេត ម៉ាក់លស់ព្រលឹងអស់"





Scanned by CamScanner

ព្រះនាង វៃខ្នងដៃកូនប្រុសតិចៗ ទើប សេត ចាប់ដៃរបស់ម្តាយបើប ខ្សឹតៗជាការយកចិត្ត។

"សុំទោសម៉ាក់"

"ធ្វើឱ្យម៉ាក់លស់ព្រលឹងអស់"

"សរុបទៅចោរឬមិនមែនចោរ ?"

"នាងជាស្រីចោរ ប៉ុន្តែខ្ញុំអាចគ្រប់គ្រងបាន"

ព្រះនាងឈឺក្បាលនឹងចម្លើយរបស់កូនប្រុស ប៉ុន្តែក៏គិតឃើញថា សេត និងមនុស្សស្រីដែលគេហៅថា ស្រីចោរ អាចមានទំនាក់ទំនងអ្វីនឹងគ្នាហើយ។

"ម៉ាក់ចាប់ផ្តើមសង្ស័យកូនហើយ"

"ខ្ញុំជាមនុស្សមោឃៗ ម៉ាក់"

"មែនឬ ហេតុអីម៉ាក់ទើបតែដឹង"

"ព្រះអើយម៉ាក់!"

ព្រះនាងអង្អែលថ្ពាល់កូនប្រុស។ និយាយដល់ស្រីចោរហើយ ក៏ធ្វើមុខញញឹមញញែម លាក់កំណួច ទើបទ្រង់មិនច្បាស់ទេថា គួរបារម្ភពីកូនប្រុស ឬបារម្ភពីស្រីចោរម្នាក់នោះ។

"មិនបានធ្វើរឿងខុសច្បាប់អីទេមែនទេ ?"



Scanned by CamScanner

"គ្មានទេម៉ាក់ ខ្ញុំស្បថ"

"ឃុំឃាំង រំលោភបំពាន ?"

"នោះក៏មិនមែនដែរ"

សេត ឆ្លើយប្រាប់ឱ្យម្ដាយសប្បាយចិត្ត តែគេមិនបាននិយាយរឿងទាំងអស់ឱ្យទ្រង់ស្ដាប់។ ជីវិតផ្ទាល់ខ្លួននៅពេលខ្លះរបស់គេ ព្រះនាងប្រហែលមិនយល់ស្រប។

"ច្បាស់ហើយថាមិនបានធ្វើខុសច្បាប់ ?"

"ច្បាស់ហើយម៉ាក់ ខ្ញុំធានា"

"ម៉ាក់ក៏ចង់ជឿកូន តែស្នាមញញឹមរបស់កូន ធ្វើឱ្យម៉ាក់ខ្វល់ខ្វាយ"

"ខ្ញុំញញឹម មិនល្អឬ ?"

"កូនញញឹមលាក់កំណួច"

"ព្រះអើយម៉ាក់ ខ្ញុំបញ្ជាក់ ខ្ញុំមិនបានធ្វើអីខុសច្បាប់ទេ ចោរស្រីមុខស្រស់របស់ខ្ញុំ ឡើងមកលើកោះ ដើម្បីឱ្យខ្ញុំចាប់អារកប៉ុណ្ណោះ"

"ចាប់អារក ?"

"ខ្ញុំចង់មានន័យថា មើលថែ និងប្រដៅ"

កូនប្រុសរបស់ព្រះនាង កំពុងសប្បាយ នេះចោរស្រី ឬថាជាចំណីរីករាយ





Scanned by CamScanner

របស់ សេត ឱ្យប្រាកដទៅ ប៉ុន្តែការដែលគេមិនប្រាប់សេចក្តីលម្អិត វាគឺជាការបញ្ជាក់ច្បាស់លាស់ហើយ ថា សេត មិនត្រូវការឱ្យព្រះនាងរវីរវល់នឹងរឿងនេះ ហើយទ្រង់ក៏គោរពការសម្រេចចិត្តរបស់កូនប្រុស។

"ម៉ាក់ជឿថាកូនជាសុភាពបុរស"

"បាទ ម៉ាក់ ជឿខ្ញុំបាន"

"ម៉ាក់នឹងប្រាប់ប៉ាថាគ្រប់យ៉ាងអូខេ ប៉ុន្តែបើមិនអូខេ កូនត្រូវដោះស្រាយបញ្ហានាពេលអនាគតដោយខ្លួនឯងហើយកូនសម្លាញ់"

"បាទ ម៉ាក់ ខ្ញុំស្រឡាញ់ម៉ាក់"

សេត ស្រវាឱបម្តាយ ត្រឹមប៉ុណ្ណឹង ព្រះនាងក៏ទន់ចិត្តទៅហើយ ហើយបើបថ្ពាល់កូនប្រុសដ៏គួរឱ្យស្រឡាញ់ បន្ទាប់មក ក៏ឡើងឡានត្រឡប់ទៅផ្ទះវិញ។



Scanned by CamScanner

# ១៤

## ទុកចិត្ត

ពេលត្រូវ សេត បញ្ញាឱ្យរង់ចាំនៅក្នុងបន្ទប់ដេក នាងក៏មានពេលនៅជាមួយខ្លួនឯង បានពិចារណាដល់ការរាយការណ៍របស់អ្នកបម្រើ។ ម្ដាយរបស់គេត្រូវហៅថា **ព្រះនាង** ដែលធ្វើឱ្យនាងមានការសង្ស័យ និងត្រូវការចម្លើយ។

"កំពុងគិតអី?"

គេដើរមករកអ្នកដែលឈរនៅមាត់បង្អួច ស្រវាឱបពីក្រោយ ថែមទាំងថើបថ្ពាល់ទន់ល្មឿយ ដែលធ្វើឱ្យនាងភ្ញាក់ក្រញាង។

"លោក សេត!"

"ស្រែកធ្វើអី"

"ខ្ញុំជាមនុស្សប្រុស"

"ខ្ញុំធ្លាប់ប្រាប់ហើយតើ ថាខ្ញុំមិនប្រកាន់"

"តែខ្ញុំប្រកាន់"





Scanned by CamScanner

"ឯងគួរតែចូលចិត្ត ឯងធ្វើដើមទ្រូង ធ្វើឫកល្វត់ល្វន់បែបនេះ ឯងត្រូវតែចូលចិត្តមនុស្សប្រុស ឬឯងចូលចិត្តមនុស្សស្រី ?"

សេត តែងតែមានសំណួរ ដែលធ្វើឱ្យនាងលំបាកចិត្តក្នុងការឆ្លើយ មកអុកឡុកនាងជារឿយៗ តែទោះប្រកែកនឹងគេមិនបានក៏បានធ្វើមុខខ្វះដាក់ដែរ។

"អឺម! ទៀតហើយ"

នាងផ្អៀងមុខគេច ប៉ុន្តែច្រមុះ និងមាត់របស់គេ នៅតែតាមថើបខ្សឹតៗ ថើបខ្លាំងៗ ធ្វើឱ្យនាងទាំងខឹង ទាំងញាប់ញ័រ ខឹងដែលគេថើបដូចជាប់ចិត្តទាំងដែលនាងជាមនុស្សប្រុស។ គេប្រហែលភ្លេចស្រីកំណាន់របស់គេ ដែលមានឈ្មោះថា សាន់នី ទៅហើយ នាងប្រហែលមិនសំខាន់ចំពោះគេទេ ចំណែកអារម្មណ៍ញាប់ញ័រផ្លូវកាយ ជារឿងដែលនាងគ្រប់គ្រងមិនបាន ព្រោះរាងកាយរបស់នាងទោរទន់ទៅរកគេ។

សេត ជាបុរសដំបូងរបស់នាង ក្រៅពីនេះគេក៏ជាបុរសតែម្នាក់គត់ដែលបានគ្រប់គ្រងនាង ហើយនាងក៏មិនមែនជាមនុស្សស្រី ដែលត្រូវយករាងកាយទៅឱ្យប្រុសផ្សេងជាន់ឈ្លីដោយគ្មានអារម្មណ៍អី ទើបអារម្មណ៍ដែលមានចំពោះគេ ក្លាយជាចំណង ដោយនាងមិនដឹងខ្លួន។

នាងទើបតែដឹង ពេលត្រូវឃ្លាតឆ្ងាយពីគេ ដោយគ្មានឱកាសជួបគ្នា



Scanned by CamScanner

ទៀត។ ការចេញពីណាខាដៀ ធ្វើឱ្យនាងមានអារម្មណ៍ដូចបានកើតជាថ្មី ប៉ុន្តែខណៈនោះក៏ដង្ហោយរកការជួបគេ រហូតដល់បានជួបនៅលើកោះចោរ ធ្វើឱ្យបេះដូងនៅក្នុងទ្រូង លោតញាប់ដោយក្តីរីករាយ។

"ខ្ញុំបើបដើមទ្រូង បើបមាត់ឯង បឺតជញ្ជក់ដល់ថ្នាក់នោះទៅហើយ ឯងព្រមឱ្យខ្ញុំសិនទៅ"

"ខ្ញុំខាតបង់"

"យើងជាប្រុសដូចគ្នា ឯងគិតច្រើនធ្វើអី"

"លោក សេត គិតតែពីបាន"

"នេះក៏អីចឹងដែរ ចូលចិត្តតវ៉ាដូចមនុស្សស្រី ឬព្រោះឯងស៊ីអរម៉ូនស្រីច្រើន"

"លោក សេត ចូលចិត្តរករឿងខ្ញុំជារឿយៗ"

នាងក្រមុំតវ៉ា សេត នៅតែឱបក្រសោប ហើយដៃលគួរឱ្យខឹងគឺរង្វង់ដៃរបស់គេកក់ក្តៅមែនទែន កក់ក្តៅដល់ថ្នាក់នាងមិនចង់ឱ្យគេដកចេញ។

"មួយរយៈនេះខ្ញុំធុញ ស្រីកំណាន់ក៏ស្លាប់ទៀត"

"ស្រីកំណាន់ម្នាក់ណា ?"

"ឯងនិយាយដូចដឹងថាខ្ញុំមានស្រីកំណាន់ច្រើន"





Scanned by CamScanner

"ខ្ញុំមិនដឹងអីទេ ខ្ញុំទៅដឹងរឿងរបស់លោក សេត ដោយរបៀបណាទៅ"

នាងដោះសាភ្លាម អណ្ដាតចង់ព័ន្ធគ្នា សេត ក៏ឱនមកបើបថ្ពាល់ និងឱបរឹត ដូចមិនចង់ទៅណា។

"មិនដឹងក៏មិនដឹង ឆោទ្បោធ្វើអី"

"លោក សេត និយាយរឿងស្រីកំណាន់របស់លោកបន្តទៅ"

នាងចង់ដឹង ថាក្រៅពីនាងហើយ គេមានអ្នកដទៃឬអត់ ខណៈដែលសេត ញញឹមលាក់កំណួច មុនពេលឆ្លើយក៏ឆ្លៀតរកកម្រៃដោយការបៀតបៀនថ្ពាល់ម៉ដ្ឋរលោងរបស់អ្នកដែលធ្វើខ្លួនដូចមនុស្សឆ្លាត ប៉ុន្តែនៅតែមោយៗ គ្មានបទពិសោធជីវិត។

គេឱបចើប ស្ទាបអង្អែលដល់ថ្នាក់នេះទៅហើយ នៅមិនសង្ស័យថាគេដឹងអាថ៌កំបាំងរបស់នាង ព្រោះរវល់តែព្យាយាមបិទបាំងអត្តសញ្ញាណ។

បើនាងបន្លំខ្លួនបែបនេះហើយ បោកអ្នកដទៃបាន ចាប់ពីពេលនេះទៅនាងប្រហែលបន្លំខ្លួនធ្វើជាមនុស្សប្រុស បានយ៉ាងរីករាយ ដោយគ្មានអ្នកណាចាប់បាន តែជីវិតពិតវាមិនងាយដល់ថ្នាក់នោះទេ ព្រោះក្រៅពីនាង មុខស្រស់ដើមទ្រូងធំរបស់នាងក៏លេចធ្លោច្បាស់ដែរ ។

មនុស្សប្រុសដែលមានដើមទ្រូងដល់ថ្នាក់នេះ វាគ្មានទេ បើជាដើមទ្រូង



Scanned by CamScanner

ដោយសារការលេងសាច់ដុំ គឺរឹងកំព្រឹស មិនមែនទន់ល្មឿយ សខ្ចីបែបនេះ។

សេត ដាក់បង្អុយលើសាឡុង ទាញនាងឱ្យមកអង្គុយលើភ្លៅ ឱបរឹត និងថើបថ្ពាល់ខ្សឹតៗបន្ត។

"លោក សេត បានហើយ"

"ថ្ពាល់ឯងក្រអូប"

សេត មើលបបូរមាត់ក្រហម ដោយខ្សែភ្នែកមានពន្លឺផ្លេកៗ ធ្វើឱ្យចិត្តនាងញ័រ ព្រោះតតាំងនឹងមន្តស្នេហ៍របស់គេមិនដែលបាន។

"លោក សេត ខ្ញុំចង់ដឹងរឿងស្រីកំណាន់របស់លោក"

"ឯងចាប់អារម្មណ៍រឿងស្រីកំណាន់របស់ខ្ញុំខ្លាំងដល់ម្លឹងផង"

"បាទ ខ្ញុំចង់ដឹង"

"គ្រាន់តែជាស្រីកំណាន់"

"លោក សេត!"

អ្នកកំលោះមានចេតនានិយាយបែបនេះ ហើយអ្វីដែលទទួលបាន គឺកែវភ្នែកឆ្មាសឆ្មើមរបស់មនុស្សស្រីនៅលើភ្លៅ។

*ព្រះអើយ ពៅព្រលឹង ហេតុអីក៏គួរឱ្យស្រឡាញ់បែបនេះ!*

"ខឹងអី"





Scanned by CamScanner

"លោក សេត ម៉េចក៏និយាយពីមនុស្សស្រីបែបហ្នឹង"

"នាងគ្រាន់តែជាស្រីកំណាន់ ខ្ញុំចិញ្ចឹមទុកនៅ ណាខាដៀ ឯងស្គាល់ណាខាដៀ ឬអត់ ?"

"ខ្ញុំធ្លាប់បានឮឈ្មោះខ្លះដែរ"

បើកុហកថាមិនស្គាល់ នាងក៏ខ្មាសមាត់ ទើបព្រមឆ្លើយតាមត្រង់។

"ជារោងរបាំស្រោតនៅច្រកស្នេហាដែលមនុស្សប្រុសគេចូលចិត្តទៅ"

"បាទ ខ្ញុំអាចនឹករូបភាពចេញ"

"ខ្ញុំចៃដន្យជួបនាងនៅយប់ដំបូងដែលនាងទទួលភ្ញៀវល្មម មនុស្សស្រីស្អីក៏មិនដឹង ស្អាតនិយាយពីស្អាត ស្អាតហួសហេតុ"

ថ្ពាល់របស់ សាន់នី ឡើងក្រហម ព្រោះត្រូវគេសម្លឹងមិនដាក់ភ្នែកពេលសរសើរស្រីកំណាន់ម្នាក់នោះ ដែលនាងមិនបានគិតដោយខ្លួនឯងទេមែនទេថាត្រូវគេសរសើរ។

"លោក សេត ចូលចិត្តនាងទេ ?"

"ចូលចិត្ត បើមិនចូលចិត្ត ដែលរើសយកធ្វើស្រីកំណាន់ធ្វើអី នាងស្អាតតែឆ្លាសមិនសូវយកចិត្តយកថ្លើមខ្ញុំ ទាំងដែលខ្ញុំមើលថែគ្រប់យ៉ាង នាងសុំឱ្យខ្ញុំជួយប្អូនស្រីរបស់នាង ក៏ខ្ញុំព្រមជួយ តែនាងបែរជាយល់ច្រឡំ គិតថាខ្ញុំឡើង



Scanned by CamScanner

គ្រែជាមួយប្អូនស្រីរបស់នាង មនុស្សស្រីនេះគួរឱ្យឈឺក្បាលណាស់"

"អឺ...អឺចឹងឬ"

"ខ្ញុំចិញ្ចឹមមនុស្សប្រុសដូចឯងល្អជាង"

"មិន...បាច់ចិញ្ចឹមខ្ញុំទេ លោក សេត និយាយរឿងស្រីកំណាន់ម្នាក់នោះបន្តទៅ"

"ឯងចង់ដឹងធ្វើអី ?"

"អឺ...ខ្ញុំចូលចិត្តស្តាប់រឿងតំណាល"

"ឬតាមពិតទៅឯងក៏មានអារម្មណ៍ចូលចិត្តមនុស្សស្រីតិចៗដែរ"

"ខ្ញុំអាចដូចលោក សេត ក៏ថាបាន"

នាងចាក់បណ្តោយ ថែមទាំងយកហេតុផលរបស់គេធ្វើជាលេស ធ្វើឱ្យគេអត់ក្អាញ់មិនបាន ឱនមកថើបថ្ពាល់ខ្សឹតៗ។

"អឺ...លោក សេត ចូលចិត្តថើបខ្លាំងៗ"

"វាធ្វើឱ្យពេញចិត្តហ្នឹងណា៎ ថ្ពាល់ឯងទាំងទន់ ទាំងក្រអូប ដូចថ្ពាល់មនុស្សស្រី"

គេថើបហើយថើបទៀត ប៉ុន្តែពេលត្រូវនាងមើលមកដោយខ្សែភ្នែកតវ៉ា ទើបផ្អាកការបេះបួយបណ្តោះអាសន្ន។





Scanned by CamScanner

"ខ្ញុំនិយាយបន្ត"

"បាទ លោក សេត"

សាន់នី ងក់ក្បាលភ្លាម ហើយពេលត្រូវគេឱបរឹតបន្តិចទៀត នាងក៏ជ្រប់មុខនឹងប្រទ្បោះក ព្រមឱ្យគេឱបក្រសោបជាប់ដើមទ្រូង។

"ខ្ញុំចូលចិត្តនាងណាស់ ទោះនាងឆ្ងាស ហើយមិនសូវចូលចិត្តមើលឃើញបំណងល្អដែលខ្ញុំធ្វើឱ្យ ប៉ុន្តែនាងគួរតែបាត់បង់ជីវិតទៅហើយ ព្រោះរោងរបាំស្រោតណាខាងជៀត្រូវភ្លើងឆេះ"

"គួរឱ្យអាណិតណ៎ះ!"

"មិនដឹងទេ"

"លោក សេត គ្មានអារម្មណ៍អីទេឬ?"

សំឡេងរបស់នាងសោកសៅ ដែលគេមើលដឹង ប៉ុន្តែគេមិនព្រមឆ្លើយភ្លាមៗ ធ្វើដូចគិតរកចម្លើយ។

"មិនដឹងទេ ឆ្លើយមិនបាន"

"នាងនៅជាមួយលោក សេត ដល់ទៅពីរឆ្នាំ"

"ម៉េចក៏ឯងដឹង?"

ពេល សេត សួរ នាងក៏ភ្ញាក់ស្មារតី ព្រោះនាងចង់ដឹងថាខ្លួនឯងសំខាន់



Scanned by CamScanner

ចំពោះគេឬអត់ ប៉ុន្តែគេធ្វើដូចមិននឹកនានាងអីបន្តិច។

"ខ្ញុំសន្និដ្ឋាន"

"ពូកែ ព្រោះឯងសន្និដ្ឋានត្រូវ"

សេត ព្រមជឿសិនទៅចុះ ដើម្បីឱ្យនាងសប្បាយចិត្ត។

"ហ្នឹងហើយ រឿងរបស់ខ្ញុំនិងនាង គឺមានតែប៉ុណ្ណឹង"

"លោក សេត នឹកនាងខ្លះទេ ?"

"ប្រហែលមានខ្លះដែរ"

"លោក សេត ឆ្លើយដូចនាងមិនសំខាន់"

"ព្រោះខ្ញុំធ្លាប់គិតថា ផ្តោតសំខាន់ទៅលើនាង ប៉ុន្តែនាងឆ្នាសពេក ទើបខ្ញុំគិតថានាងប្រហែលស្អប់ខ្ញុំ មិនពេញចិត្តបម្រើខ្ញុំ"

"មិនពិតទេ"

នាងបដិសេធ ទោះចង់ស្អប់គេ ប៉ុន្តែមិនធ្លាប់ស្អប់សូម្បីតែម្តង។ នាងគ្រាន់តែងរង៉ក់ដាក់គេ ប៉ុន្តែចង់នៅជិតគេដែរ។

"មែនឬ ?"

"មែន"

"ម៉េចក៏ឯងដឹង ?"





Scanned by CamScanner

"អឺ...ខ្ញុំ..."

"ឬឯងចង់លើកទឹកចិត្តខ្ញុំ"

ឃើញនាងឆ្លើយមិនចេញ គេក៏អាណិត ទើបជួយរកចម្លើយឱ្យ។

"បាទ លោក សេត"

"ឯងចិត្តល្អ  អាចល្អចំពោះខ្ញុំជាងស្រីកំណាន់ឆ្មាសរបស់ខ្ញុំម្នាក់នោះទៅទៀត"

គេប្រហែលមិននឹកនាដល់នាងទៀតទេ។

"រឿងស្រីកំណាន់ម្នាក់នោះកុំទៅចាប់អារម្មណ៍អី"

"លោក សេត ចាំឈ្មោះរបស់នាងបានឬអត់ ?"

"ចាំបានតើ ខ្ញុំមាននាងតែម្នាក់ឡើងយូរ"

"តែម្នាក់ឬ ?"

"គឺតាំងពីមានស្អីៗជាមួយនាង ខ្ញុំក៏មានតែនាងម្នាក់ ប៉ុន្តែនាងប្រហែលមិនចូលចិត្តខ្ញុំ ខ្ញុំគិតថានាំនាងចេញពីណាខាដៀ តែមិនទាន់បានធ្វើផង ភ្លើងក៏ឆេះទីនោះបាត់ទៅហើយ ជួនកាលវាប្រហែលជាល្អចំពោះខ្ញុំ"

"ហេតុអី ?"

"នាងអាចមិនចង់ចេញម៉ោជាមួយខ្ញុំ ហើយបដិសេធ បើបែបនោះ ខ្ញុំនឹង



Scanned by CamScanner

ខូចចិត្ត"

"លោក សេត និយាយមែនឬ?"

"មែន ខ្ញុំប្រហែលជាជួយទាំងបងទាំងប្អូនហ្នឹង ព្រោះនាងស្រឡាញ់ប្អូនណាស់"

"ខ្ញុំមិនធ្លាប់ដឹងទេថាលោក សេត គិតបែបនេះ"

"ខ្ញុំទើបតែបានស្គាល់ឯង ឯងម៉េចនឹងដឹងរឿងផ្ទាល់ខ្លួនរបស់ខ្ញុំ"

"អឺ...មែនហើយ"

"ពូកែលើកទឹកចិត្តអ្នកដទៃណាស់យើងនេះ"

សេត ប្រាប់ចំផ្ទាល់របស់នាង មានចេតនាមើលដោយខ្សែភ្នែកស្រទន់។ គេប្រហែលគិតថានាងអឺអើតាម ព្រោះបារម្ភពីគេ តែតាមពិតទៅ នាងចង់ប្រាប់គេថា នាងជាស្រីកំណាន់ម្នាក់នោះទៅវិញទេ។

"លោក សេត ប្រហែលសោកសៅរឿងនាងខ្លះហើយមែនទេ?"

"ពេលនេះខ្ញុំមានឯងហើយតើ"

"ខ្ញុំដឹង តែលោក សេត ឆ្លើយប្រាប់ខ្ញុំបានទេ"

"ខ្ញុំសុំលាក់ទុកនឹងខ្លួនឯងល្អជាង ឯងមិនបាច់ចាប់អារម្មណ៍ទេ"

គេមានចេតនាលាក់ទុកជាអាថ៌កំបាំង មិនព្រមឆ្លើយប្រាប់ ដើម្បីឱ្យនាង





Scanned by CamScanner

ខ្វល់ខ្វាយចិត្តនិងចង់ដឹង ដែលកាយវិការនេះ ធ្វើឱ្យគេចង់ថើបនាងឱ្យខ្លាំងៗ ពីបទដែលធ្វើខ្លួនគួរឱ្យស្រឡាញ់ដាក់គេ។

"ខ្ញុំត្រូវតែចាប់អារម្មណ៍"

"ឯងនេះ ពេលខ្ញុំចិត្តល្អដាក់ ក៏ចង់ឡើងចាង"

"ខ្ញុំសុំទោសលោក សេត ខ្ញុំគ្មានចេតនាទេ"

"ឈប់និយាយពីរឿងនេះទៅ"

"លោក សេត"

"មានអីទៀតហើយ ថ្ងៃនេះឯងមានបញ្ហាច្រើនម្ល៉េះ"

"ខ្ញុំនិយាយមែន បើនាងដឹងថាលោក សេត ចង់ជួយនាង នាងប្រហែលសប្បាយចិត្ត"

"មិនដឹងទេ ពេលនេះនាងស្លាប់បាត់ហើយ"

គេញ្ញាក់ស្មាបន្តិច ហើយការឆ្លើយតបដោយសំឡេងគ្មានភាពសោកសៅឬសូម្បីតែកែវភ្នែកគ្មានការអាឡោះអាល័យ ធ្វើឱ្យនាងរំជួលចិត្តជាខ្លាំង។ គេអាចចិត្តល្អ និងមេត្តានាង តែនាងមិនសំខាន់ចំពោះគេ ក្រៅពីស្រីកំណាន់ម្នាក់ប៉ុណ្ណោះ។

"លោក សេត ខ្ញុំចង់រំខានសួររឿងផ្សេង"



Scanned by CamScanner

"រឿងអី ?"

"បើខ្ញុំជួបម៉ាក់របស់លោក សេត ខ្ញុំត្រូវហៅគាត់ថាម៉េច ?"

"ព្រះនាង"

សេត ឆ្លើយហើយ ឱនមកថើបថ្ពាល់របស់នាង បបោសអង្អែលមិនព្រម ទៅណាឆ្ងាយ ថើបហើយចង់ថើបទៀត ថើបឱ្យសព្វសាច់។

"ព្រះនាងឬ ?"

"ម៉ាក់ គឺព្រះនាង ឃែតទ្រីណា នៃរាជវង្ស ម៉ាលខៃសេនតេ"

"ហ៎ា !"

"ចំណែកប៉ារបស់ខ្ញុំ គឺ ជីសាស់ ស៊ី រ៉ូវើ ប្រមុខកោះចោរ ចំណែកខ្ញុំ គឺ នាយតូចនៃកោះចោរ ទើបគ្រប់គ្នាហៅខ្ញុំថានាយតូច ឬលោក សេត ហ្នឹងអី"

ឋានៈរបស់គេ ធ្វើឱ្យនាងភាំងតែម្ដង។ គេនៅខ្ពស់ជាងនាងឆ្ងាយណាស់ ការពិតរឿងកំណើតកើតជារបស់គេ ធ្វើឱ្យនាងសោកសៅមួយហ្នុង។

"ចឹ ម៉េចក៏នៅស្ងៀម ?"

"អត់មានអីទេ"

"ឬឯងខ្លាច"

"បាទ ខ្ញុំខ្លាច"





Scanned by CamScanner

ព្រោះការពិត វាឃោរឃៅមែនទែន គេជាបុរសដែលខ្ពង់ខ្ពស់ ជាងនាង មិនដឹងជាប៉ុន្មានដង ធ្វើឱ្យបេះដូងរបស់នាងក្រៀមស្រពោន។

"ខ្លាចអី ខ្ញុំឱបឱ្យណែនល្អទេ"

"បាទ លោក សេត"

អ្នកកំលោះរឹតវង្វង់ដៃ ឱបកាន់តែណែន នាងក៏សម្ងំនៅក្នុងវង្វង់ដៃរបស់គេ ឬនិយាយឱ្យត្រូវ គឺប្រមូលយកសេចក្ដីសុខនៅវេលានេះឱ្យបានច្រើនបំផុត ព្រោះពេលឡើងគោក នាងត្រូវដើរទៅតាមផ្លូវរបស់ខ្លួនឯង គិតថាយ៉ាងណាក៏ក្រុមគ្រួសារដ៏ខ្ពង់ខ្ពស់របស់គេ មិនព្រមទទួលយកនាងដែរ។

*ទទួលយកស្អីទៅ កុំរវើរវាយពេក សាន់នី គេចាត់ទុកឯងជាស្រីកំណាន់ប៉ុណ្ណោះ!*

"ខាស៊ី"

"បាទ លោក គ្រីស"

ធីណា ងើប ដើរទៅរក គ្រីស ដែលហុចកន្ត្រក មានកន្ត្រៃនៅក្នុងនោះមកឱ្យ ហើយចាប់នាងបង្វែរទៅរករងផ្កា។

"ទៅកាត់កុលាបត្រង់នោះ"



Scanned by CamScanner

ផ្កាកុលាបទាំងនេះ កោះចោរបញ្ជូនទៅលក់នៅដីគោក ដើម្បីជាចំណូលរបស់ប្រជាជននៅលើកោះ។

"បាទ លោក គ្រីស"

"យកមួកទៅពាក់ផង"

"អរគុណ"

គ្រីស លះបង់មួកលើក្បាលរបស់ខ្លួនទៅដាក់លើក្បាលរបស់ ធីណា។ គេត្រូវប្តូរការងារឱ្យនាងភ្លាមៗ ព្រោះការជួសជុលរបង ដែលជាការងារធ្ងន់ពេកហើយសម្រាប់នាង។

"កាត់ឱ្យពេញកន្ត្រក"

"បាទ លោក គ្រីស"

"ទៅបានហើយ"

ធីណា ញញឹមស្រស់ដាក់អ្នកបញ្ជា ហើយដើរសំដៅរងកុលាប ដែលកម្មករស្រីៗ កំពុងធ្វើការ។

"អាល្អិតនោះមុខស្រស់ ភ្នែកស្រទន់ ហើយញញឹមស្រស់ទៀត ជាមនុស្សប្រុស តែស្អាតជាងមនុស្សស្រីអស់នោះទៅទៀត លោកបង"

ពេល ធីណា ដើរទៅបាត់ កម្មករជួសជុលរបងក៏នាំគ្នានិយាយដើមនាង





Scanned by CamScanner

ដាក់ គ្រីស។

"តាមនោះ"

"វាស្នាក់នៅជាមួយលោកបង មែនទេ?"

"មែន ជាបញ្ជារបស់ម្ចាស់តូច"

ព្រោះជាបញ្ជារបស់ សេត ទើប គ្រីស មិនចាំបាច់អធិប្បាយបន្ថែម។ តម្រូវការរបស់ សេត កម្មករនៅលើកោះដឹងថាពួកគេមានតួនាទីត្រូវធ្វើតាម។

"វាដូចមនុស្សស្រីពិតមែន លោកបង"

"អីចឹងឬ"

"បើខ្ញុំបានវាជាប្រពន្ធ ខ្ញុំក៏យក"

"ធ្វើការទៅ ន្ទាលឆាប់រួចត្រង់នេះ នៅមានការងារច្រើនទៀតត្រូវធ្វើ"

គ្រីស បញ្ចប់ប្រធានបទនេះ ហើយសំឡេងកាចរបស់គេ ធ្វើឱ្យកម្មករប្រញាប់ឈ្ងោកមុខឈ្ងោកមាត់ធ្វើការ ដើម្បីជួសជុលរបងឱ្យទាន់ពេល។

**សេត ចេញមកដើរពិនិត្យការងាររបស់ខ្លួនតាមធម្មតា ដែល សាន់នី ក៏**បានឃើញផ្នែកមួយទៀតរបស់គេ គេជាមនុស្សប្រាកដប្រជានឹងគ្រប់យ៉ាង។ នាងតែងតែ ត្រូវហៅឱ្យទៅតាម តែភាគច្រើនក៏ឱ្យនាងនៅក្នុងផ្ទះ និងបញ្ជាឱ្យ



Scanned by CamScanner

រង់ចាំតែក្នុងបន្ទប់ដេកប៉ុណ្ណោះ។

នាងព្យាយាមស្តាប់បង្គាប់គេ ពេលគ្រប់ការកំណត់កិច្ចសន្យាជួល ត្រូវចាកចេញពីកោះ នាងប្រហែលគ្មានឱកាសជួបគេទៀតទេ ឬទោះមានឱកាសក៏នាងមិនហ៊ានជួបដែរ ព្រោះគេនិងនាងខុសគ្នាពេកហើយ រឿងតែមួយគត់ដែលធ្វើបាន គឺរក្សាទុកគេនៅក្នុងការចងចាំដែលល្អរបស់នាង។

នាងរក្សាទុកគេនៅក្នុងចិត្តបន្តិចម្តងៗ ពេលបេះដូងបើកចំហ ទាល់តែច្បាស់ថាមានអារម្មណ៍ពិសេសចំពោះគេ។ នាងចងចាំមុខមាត់របស់គេ រូបរាងរបស់គេ កាយវិការ និងសង្កេតអត្តចរិតរបស់គេបន្តិចម្តងៗ ក្រៅពីនេះបានលួចរបស់ប្រើប្រាស់របស់គេទុកក្នុងប្រអប់សម្បត្តិរបស់នាងដែរ ដោយចាប់ផ្តើមពីកន្សែងជូតមុខដែលគេបោះចោល នាងក៏រើសយកវា មកបោកអ៊ុត និងបត់ទុក បន្តដោយសៀវភៅដែលគេអាន កន្សែងពោះគោដែលគេប្រើ អាវយឺតរបស់គេជាដើម។

ទោះជាការលួច ធ្វើខ្លួនដូចចោរ ក៏នាងរអៀសចិត្ត មិនគិតថាខ្លួនឯងហ៊ានធ្វើបែបហ្នឹង តែនាងបានធ្វើវារួចទៅហើយ ព្រោះត្រូវការរបស់បញ្ចាំចិត្តដែលប្រើវាតំណាងឱ្យ សេត ពេលមិនបាននៅជាមួយគេ។

"ក្តៅណាស់"





Scanned by CamScanner

សេត រអ៊ូរទាំ ហើយចាប់នាង នាំទៅអង្គុយក្រោមដើមឈើ ហើយផ្ដួលខ្លួនដេក កើយភ្លៅរបស់នាង និងលើកដៃជូតញើសចេញពីមុខស្រស់ស្អាត។

"ជូតមុខទេ?"

"មិនអីទេ ចង់ដេកយកខ្យល់អាកាសមួយសន្ទុះ"

"ហត់ទេ?"

"ហត់ ទៅដល់ផ្ទះវិញ ឯងត្រូវយកចិត្តខ្ញុំ"

"អឺ...លោក សេត ចង់ឱ្យខ្ញុំធ្វើអី?"

អ្នកកំលោះលើកដៃចាប់ដើមទ្រូងរបស់នាង ច្របាច់វាតិចៗ ហើយដាក់ដៃចុះ។ គេបញ្ជានាងមិនបាច់រឹតដើមទ្រូងទៀតតេ ព្រោះពេលចេញពីផ្ទះក៏មានគេនៅជាមួយ គ្មានអ្វីឱ្យខ្លាច។

"ចង់លេងអានេះ"

ថ្ពាល់របស់ សាន់នី ឡើងក្រហម ព្រោះសេត លេងវារាល់ថ្ងៃ ដូចវាជារបស់លេងផ្ទាល់ខ្លួនរបស់គេ លេងដោយដៃនិងមាត់ ធ្វើឱ្យនាងទន់ខ្លួនល្មូក។ គេសរសើរញឹកញាប់ថា ពេទ្យធ្វើវាបានដូចមែនទែន ចំណែកនាងក៏អឺអើតាម មិនហ៊ានប្រាប់ថាវាជារបស់ពិត ពីធម្មជាតិ ដែលមិនបានតុងតែងអីបន្តិច។

នាងងក់ក្បាលទទួលយកតម្រូវការរបស់គេ តាំងចិត្តហើយថាព្យាយាម

យកចិត្តគេ ដើម្បីសេចក្តីសុខខ្លួនឯងដែរ។

"ជាមនុស្សប្រុសស្អី មកធ្វើការមនុស្សស្រី"

កម្មករដែលកំពុងតែកាត់ផ្កានៅរងកុលាប ដៀមដាម កាច់កុង ធីណា ដោយសំឡេងខ្លាំងៗ ឱ្យឮ ទើបនាងងាកទៅញញឹមដាក់។

"លោក គ្រីស បញ្ញា"

"មើលវាចុះ"

អ្នកដែលឈរក្បែរអ្នកសួរ ធីណា កាលពីដំបូងលូកមាត់។ ពួកនាងជាកម្មករស្រីដែលលួចឱ្យភ្នែក គ្រីស ញឹកញាប់ តែគេមិនធ្លាប់ចាប់អារម្មណ៍ ខុសពីអាក្មេងកម្មករថ្មីនេះ គ្រីស បែរជាព្រមឱ្យតាមស្អិតដូចតុកកែ។ ទោះក្មេងនេះជាមនុស្សប្រុស តែមុខមាត់ស្រស់ស្អាត មានតួចល្មិត ញ៉ិកញ៉ក់ដូចមនុស្សស្រី ក៏ធ្វើឱ្យពួកនាងជ្រេញ ព្រោះប្រចណ្ឌហួងហែង គ្រីស។

គ្រីស ជាបុរសម្នាក់ដែលស្រីៗនៅលើកោះនាំគ្នាចាប់អារម្មណ៍។ គេជាមនុស្សម្នាក់ក្នុងចំណោមកូនចៅជំនិតរបស់ម្ចាស់តូច បើបានធ្វើជាប្រពន្ធរបស់គេនឹងរស់ស្រួលមួយជាតិ ហើយពួកនាងប្រហែលជាខូចចិត្តមួយជាតិ បើគេយកមនុស្សប្រុសដូចគ្នាជាគូជីវិត។ ចាញ់មនុស្សស្រីដូចគ្នាវាឈឺចិត្តណាស់ តែ





Scanned by CamScanner

នឹងឈឺជាងនេះ បើចាញ់មនុស្សប្រុសដែលមានមុខមាត់ស្អាតដូចស្រី។

ហើយពេលនេះ ពួកនាងមកដើម្បីរករឿង ដើម្បីប្រដៅ និងដាស់តឿនមិនឱ្យអាចេកនេះទាក់ទាញ គ្រីស។

"ឯងទាក់ទាញលោក គ្រីស មែនទេ?"

"ទាក់ទាញបែបណា?"

ធីណា មិនយល់ជាខ្លាំង តើការទាក់ទាញបែបណាទៅណាដែលស្រីៗទាំងនេះនិយាយ ហើយហេតុអីចាំបាច់ធ្វើសំឡេងកាច មុខកាចបែបនេះដាក់នាងដែរ។

"នៅមកហាកទៀត"

"ខ្ញុំមិនយល់ទេ"

"ទាក់ទាញបែបដែលធ្វើឱ្យលោក គ្រីស ចូលចិត្តមនុស្សប្រុស"

"ខ្ញុំឬ?"

ធីណា លើកដៃចង្អុលខ្លួនឯង។ នាងមិនធ្លាប់មានគំនិតទាក់ទាញ គ្រីសទេ នាងគ្រាន់តែចូលចិត្តនៅជាមួយគេ ទាំងដែលកាលមុនខ្លាច តែឥឡូវនេះស្និទ្ធស្នាលគ្នា ប្រហែលមកពីគេដឹងអាថ៌កំបាំងរបស់នាង ធ្វើឱ្យនាងមិនចាំបាច់ប្រុងប្រយ័ត្នខ្លួន។



Scanned by CamScanner

កម្មករស្រីទាំងពីរភ្ញាក់ក្រញាង ពេលបានឮបញ្ហា។ ការដែលពួកនាងហ៊ានរករឿង ធីណា គឺព្រោះ ធីណា ជាមនុស្សប្រុស ទោះយ៉ាងណាក៏មិនត្រូវដាក់ទោសធ្ងន់ដែរ។

"លោក គ្រីស ខ្ញុំឈឺ"

"ម៉ោណេះ មករកខ្ញុំ"

ធីណា នាំរាងកាយទ្រុឌទ្រោម ដើរទៅរក គ្រីស ភ្លាម ហើយត្រូវគេទាញទៅជិត បន្ទាប់មក គ្រីស ក៏ងាកទៅរកកម្មករស្រីទាំងពីរ។

"ឈ្លោះគ្នាធ្វើអី?"

"វាជាមនុស្សប្រុស តែរករឿងពួកយើងមុន"

"រករឿងអី?"

"វារករឿងស្អីពួកនាង?"

"វាប្រាប់ថាយើងមិនស្អាត"

កម្មករស្រីទាំងពីរឆ្លើយដំណាលគ្នា ដើម្បីកុំឱ្យត្រូវដាក់ទោស ទើប គ្រីស ឈ្ងោកមើលមនុស្សស្រីដែលត្រូវគេឱបចង្កេះ ព្រោះនាងស្ថិតនៅក្នុងស្រោមមនុស្សប្រុស ទោះនាងរងការធ្វើបាប ប៉ុន្តែអ្នកធ្វើបាបជាមនុស្សស្រី ទើបគេមិនអាចផ្តល់យុត្តិធម៌ឱ្យនាងបានច្រើនទេ។



Scanned by CamScanner

"មែនឬអត់ ខាស៊ី"

"មែន...មែន"

"បានឮហើយមែនទេ លោក គ្រីស"

"នាងគួរមានមារយាទដាក់ខ្ញុំជាងនេះ"

គ្រីស ស្តីឱ្យមនុស្សស្រីដែលហ៊ានលូកមាត់ ធ្វើឱ្យនាងស្លេកមុខ ព្រោះគេនិយាយដោយសំឡេងកាចជាងសព្វមួយដង។

"ជូនដំណឹងទៅផ្នែកគណនេយ្យ កាត់ប្រាក់ខែបីនាក់នេះចំនួនបីថ្ងៃ ពីបទឈ្លោះទាស់ទែងគ្នា"

"បាទ លោក គ្រីស"

គ្រីស ងាកទៅបញ្ជាមេការកម្មករ ហើយងាកទៅរកកម្មករស្រីទាំងពីរ និងចេញបញ្ជាឮខ្លាំងៗ ដើម្បីបង្ការការឈ្លោះទាស់ទែងគ្នានាពេលអនាគត។

"ហាមពួកនាងមករញ៉េរញ៉ៃនឹង ខាស៊ី ទៀត មិនអីចឹង លើកក្រោយនាងនឹងមានទោសធ្ងន់"

"លោក គ្រីស!"

"ខ្ញុំមិនមែនមិត្តភក្តិនាងទេ កុំម៉ោដំឡើងសំឡេងដាក់ខ្ញុំ បញ្ជារបស់ខ្ញុំត្រូវអនុវត្តតាម បើមិនពេញចិត្ត ខ្ញុំនឹងដកនាងពីការងារ"





Scanned by CamScanner

"កុំ...កុំអី លោក គ្រីស ខ្ញុំសុំទោស ខ្ញុំសុំទោស"

"ជាកម្មករ ត្រូវយកចិត្តទុកដាក់ធ្វើការ ធ្វើខ្លួនក្មេងក្អាងដាក់កម្មករថ្មីមិនបានទេ"

"ចាំ លោក គ្រីស"

ទោះចង់ស្រែកដាក់មុខគេយ៉ាងណា ក៏ត្រូវយល់ស្របសិនដែរ ព្រោះ គ្រីស អាចបញ្ជាឱ្យដកនាងចេញពីការងារបាន ដែលគេមានសិទ្ធិធ្វើបែបនោះ ព្រោះនាងគ្រាន់តែជាកម្មករទូទៅ មិនមែនជាកម្មករតំណែងសំខាន់ ដែលត្រូវរាយការណ៍ដល់ម្ចាស់តូចមុនពេលត្រូវដកចេញ។

"ទៅធ្វើការ"

"ចាំ លោក គ្រីស"

ពួកនាងប្រញាប់បែរខ្លួនដើរទៅដាក់បង្គុយចុះ ធ្វើការរបស់ខ្លួនបន្ត ទើប គ្រីស ចាប់ដៃ ធីណា នាំនាងដើរសំដៅឡានដឹកទំនិញជំនំ ដែលគេប្រើប្រាស់វាជាយានជំនិះនៅលើកោះនេះ។

"យើងទៅណា លោក គ្រីស ?"

"ទៅផ្ទះ"

"តែមិនទាន់ដល់ម៉ោងចេញពីធ្វើការផង"



Scanned by CamScanner

"នាំទៅលាងរបួស"

"ខ្ញុំធ្វើការមិនទាន់រួចផង"

"មិនអីទេ អនុញ្ញាតឱ្យឈប់កន្លះថ្ងៃ"

មនុស្សដូច ធីណា ឬទៅរករឿងស្រីពីរនាក់នោះ មានតែត្រូវពីរនាក់នោះរករឿងច្រើនជាង គ្រីស ជឿជាក់អ៊ីចឹង ព្រោះចរិតល្ងីល្ងើរបស់ ធីណា។

"លោក គ្រីស ទៅជាមួយឬ?"

"មែន ខ្ញុំមិនទៅជាមួយ តើទៅវិញយ៉ាងម៉េច"

"អរគុណ លោក គ្រីស អ៊ូយ!"

ពេលញញឹមដាក់គេហើយ ធីណា ក៏លើកដៃក្ដោបមុខ ដែលត្រូវទះ។ សំណាងហើយដែល គ្រីស មកឃើញទាន់ មិនអ៊ីចឹងអាចត្រូវទះច្រើនជាងនេះ ស្រីម្នាក់នោះដៃធ្ងន់ណាស់ ដៃទាំងធំ ទាំងគ្រើម មិនទន់ដូចដៃបង សាន់នី ដែលតែងតែអង្អែលមុខនាងដោយក្ដីស្រឡាញ់។





Scanned by CamScanner

# ១៥

## បារម្ភ

"នាងរករឿងពីរនាក់នោះមែនឬ?"

ពេលនៅជាមួយគ្នាតែពីរនាក់នៅក្នុងផ្ទះ គ្រីស ដែលកំពុងលាងរបួសឱ្យ ធីណា ក៏សួរនាំ តែនាងគ្រវីក្បាលយឺតៗ។

"អត់ទេ"

"ហើយព្រមទទួលធ្វើអី?"

"ព្រោះពេលនោះ ខ្ញុំជាមនុស្សប្រុស មនុស្សប្រុសគឺត្រូវតែមិនគិតច្រើន រឿងបែបហ្នឹងមែនទេ"

"ត្រង់រឿងអីចឹងឆ្លាត តែរឿងគួរឆ្លាត បែរជាមិនឆ្លាត"

គ្រីស លាងរបួសឱ្យនាងទាល់តែរួច យកឧបករណ៍ទៅទុកដាក់នៅក្នុង ប្រអប់ថ្នាំ ទើប ធីណា ដើរតាមទៅ ឱបពីក្រោយ។

"មានស្អី?"

"គ្រាន់តែចង់ឱប"

នាងទើបតែរងការទះតប់ ទើបត្រូវការមនុស្សលួងលោម បើបងស្រីនៅជាមួយ នាងនឹងម្ទិកម៉ូក់ដាក់បងស្រី តែដោយសារពេលនេះបងស្រីនៅជាមួយលោក សេត ហើយបងប្អូនពួកនាងត្រូវអនុញ្ញាតឱ្យជួបគ្នាមួយសប្តាហ៍ពីរដងប៉ុណ្ណោះ។

"ភ័យឬយ៉ាងម៉េច ?"

គ្រីស ទុកដាក់ឧបករណ៍រួចរាល់ ក៏ចាប់ដៃនាង បេះចេញពីខ្លួន ហើយបែរទៅរក តែត្រូវនាងត្រសុលមករក។

"ចាំ ភ័យ"

គ្រីស លើកដៃឱបនាងវិញ។ ធីណា ប៉ុនម្ទិកម៉ូក់ ពេលយប់ក៏ដេកឱបគេទាល់តែលក់ ធ្វើឱ្យសព្វថ្ងៃនេះ មនុស្សដែលធុញទ្រាន់នឹងខ្មើយឱបសាច់ក៏ស៊ាំនឹងការបានដេកឱបនាង ហើយលង់លក់ជាមួយគ្នា។

"ហេតុអីត្រូវពួកគេរករឿង ?"

គ្រីស ចាប់ផ្តើមគិតដូចគ្នា ការដែល ធីណា បន្លំខ្លួនជាមនុស្សប្រុសក៏មានចំណុចល្អដែរ ព្រោះបើនាងធ្វើការនៅទីនេះក្នុងឋានៈជាមនុស្សស្រីនឹងត្រូវប្រណែនជាងនេះ ដែលចិត្តប្រណែនរបស់មនុស្សស្រីជារឿងគួរឱ្យធុញទ្រាន់។





Scanned by CamScanner

"មិនដឹងទេ"

"ម៉េចក៏មិនដឹង ត្រូវទះឡើងក្រហមថ្ពាល់យ៉ាងនេះ"

អ្នកកំលោះនាំនាងដើរទៅរកសាឡុង តែ ធីណា មិនអង្គុយភ្លាមៗ គិតតែធ្វើភ្នែកម៉ក់ៗ ដូចកូនឆ្មា មើលគេ។

"មានស្អី?"

"អង្គុយលើភ្លៅបានទេ?"

"អេ៎! អញ្ជើញ"

ធីណា ដាក់បង្គុយពាក់ឆៀងលើភ្លៅរឹងមាំ លើកដៃឱប.ករបស់គេ ផ្តេកក្បាលនឹងប្រឡោះក។

"ឆ្លើយបានហើយនៅ ហេតុអីត្រូវទះ?"

"អឹ...វាពិបាកឆ្លើយ"

"គ្រាន់តែប្រាប់ការពិតដល់ខ្ញុំ"

"ខ្ញុំគ្រាន់តែមិនច្បាស់ តែពីរនាក់នោះនិយាយថាខ្ញុំទាក់ទាញលោក"

គ្រីស ត្រូវភាពម្ញិកម៉្ញក់របស់នាងរម្លាយភាពរឹងកំព្រឹសក្នុងបេះដូងរបស់គេជារៀងរាល់ថ្ងៃ មកដល់ពេលនេះ វាទន់ដាក់នាងច្រើនណាស់។

"មនុស្សស្រីប៉ិនប្រណែន"



Scanned by CamScanner

"ពីរនាក់នោះចូលចិត្តលោកឬអត់ ?"

"ខ្ញុំមិនដឹងទេ"

នាងសម្ងំក្នុងលង្វែកទ្រូងមាំមួន និងត្រូវអនុញ្ញាតឱ្យសម្រាកពីការងារកន្លះថ្ងៃ ខណៈដែល គ្រីស ត្រូវទៅធ្វើការបន្ត ប៉ុន្តែត្រូវខាតពេលនៅលួងក្មេងប៊ុនម៉ិកម៉ូក់។

"លោកសម្បូរស្នេហ៍ដល់ហើយ"

"ម៉េចក៏ដឹង"

"ខ្ញុំគិតថាពីរនាក់នោះចូលចិត្តលោក"

"ខ្ញុំនៅលីវ"

ពេលគេប្រាប់បែបនេះ នាងក៏ងក់ក្បាលស្ដាប់ ហើយនាងគិតថាគេនៅលីវនោះឯង ទោះមានរូបថតមនុស្សស្រីនៅក្នុងទូ ប៉ុន្តែគិតថាស្រីម្នាក់នោះជាសង្សារចាស់។

"តែខ្ញុំធ្លាប់រៀបការម្ដងហើយ ជាមួយមនុស្សស្រីក្នុងរូបថត ដែលនាងធ្លាប់ឃើញ"

"ចុះពេលនេះស្រីម្នាក់នោះនៅឯណា ?"

"មានសហាយ រត់តាមសហាយបាត់ហើយ"





Scanned by CamScanner

បានឮហើយ ធីណា មានការភ្ញាក់ផ្អើលជាខ្លាំង។ ហេតុអីស្រីម្នាក់នោះហ៊ានធ្វើបែបនោះដាក់គេ ព្រោះតែបែបនេះឬអត់ទើប គ្រីស ចូលចិត្តកាចដាក់មនុស្សស្រី។

"ហេតុអីបានជាគេចិត្តអាក្រក់ម្ល៉េះ បើបានលោកជាស្វាមី ខ្ញុំមិនរត់តាមប្រុសផ្សេងទេ"

ធីណា លើកដៃក្រសោបមុខសង្ហា ដោយញញឹមស្រស់ដាក់ ហើយលោទៅថើបថ្ពាល់ថ្នមៗ។

"មិនអីទេ"

"ធ្វើអី ?"

"លួងចិត្តលោក"

"ខ្ញុំគ្មានអារម្មណ៍អីទេ"

"តែលោកនៅតែទុករូបថតរបស់នាង"

នាងអង្អែលថ្ពាល់គ្រើមថ្នមៗ ដោយបាតដៃទន់ល្មើយ ហើយនៅមានខ្សែភ្នែកស្រទន់នោះទៀត កំពុងតែធ្វើឱ្យបេះដូងរបស់ គ្រីស លោតខុសចង្វាក់មួយរំពេច។

"គ្រាន់តែគ្មានពេលគ្រវាត់ចោល"



Scanned by CamScanner

"មែនឬ?"

"ស្រីបែបនោះ ខ្ញុំមិនស្តាយទេ ចង់ទៅក៏ទៅទៅ ល្អជាងនៅជាមួយគ្នាហើយ លួចមានទាក់ទងអ្នកផ្សេងជារឿយៗ បែបនោះវាគួរឱ្យខ្ពើមរអើម"

"លោកមិនខូចចិត្តមែនឬ?"

"មែន"

"អ៊ីចឹងល្អហើយ" នាងញញឹមដាក់គេ។

គ្រីស មើលមុខស្រស់ស្អាតដែលមានស្នាមជាំម្រាមដៃហើយ កាន់តែខឹងកម្មករស្រីទាំងពីរនាក់នោះ។

"ថ្ពាល់ហើម"

"មិនអីទេ គង់តែជា"

"ធ្លាប់ខឹងអ្នកណាខ្លះឬអត់?"

"ខឹងតើ តែខ្ញុំខឹងហើយ ឆាប់បាត់"

"ទៅដេកល្អជាង ន្ទាលខ្ញុំទៅធ្វើការវិញ"

"បីទៅបន្តិចម៉ោ"

"នាងត្រូវទះកំផ្លៀង មិនមែនជើងទេ"

"ចង់ឱ្យបីហ្នឹងណ៎ា"





Scanned by CamScanner

"ស្រីល្វីល្វើប៊ិនមុិកម៉ូក់"

គ្រីស រអ៊ូរទាំ ប៉ុន្តែក៏ព្រមនាងបី ទើបនាងជ្រប់មុខនឹងប្រទ្បោះករឹងមាំ ឱបគេទាល់តែដល់បន្ទប់ដេក។

"ដេកមែនទេ ឬអង្គុយលេងលើសាឡុង?"

"ដេកលើសាឡុងក៏បាន"

នាងជ្រើសរើសយកការដេកលេងលើសាឡុង ទើប គ្រីស បីយកទៅដាក់លើនោះ ហើយដើរទៅយកភួយនៅលើគ្រែ។

"ភួយ យកទេ?"

"យក"

ពេលលាតភួយដណ្តប់ឱ្យនាងហើយ គ្រីស ក៏ដើរទៅទូដាក់អីវ៉ាន់ យកស៊ុមរូបថតរបស់អតីតភរិយា បើកស៊ុម យករូបបោះចូលធុងសំរាម។

"នៅម្នាក់ឯង កុំរពឹស"

"ចាំ លោក គ្រីស"

**"ម៉ោះ ដាស៊ី"**

សេត បី សាន់នី បី អង្គុយលើឡាន។ គេលើកអីវ៉ាន់ដាក់គូទឡាន ប្រាប់



Scanned by CamScanner

ថានាំនាងទៅដើរលេង តែមានអ្នកណាដើរលេងពេលយប់បែបនេះទៅ។

"លោក សេត នាំខ្ញុំទៅដើរលេងមែន ?"

"មែន"

សេត បើកឡានចេញទៅ ដែលទៅទិសដៅខាងណា នាងក៏មិនដឹងដែរ តែប្រហែលសាមសិបនាទីក្រោយមកក៏មើលឃើញពន្លឺភ្លើងចេញពីខ្ទមមួយ។

"ទីនេះឬ ?"

"ខ្ទមសម្រាករបស់ខ្ញុំ"

គេមានផ្ទះធំមហិមាទៅហើយ នៅមានខ្ទមសម្រាកទៀតអីចឹងឬ ប៉ុន្តែ ទោះហៅខ្ទមសម្រាក ក៏ខ្ទមឈើនោះមានទំហំធំដែរ។

"ចុះម៉ោ"

គេហុចដៃបីនាងចុះពីឡាន ហើយពេលដាក់ឱ្យនាងឈររួច ក៏យកអីវ៉ាន់ចុះពីគូទឡាន។

"ខ្ញុំជួយ"

"មិនបាច់ទេ ដើរទៅខ្ទមទៅ"

សេត យកអីវ៉ាន់ចេញពីគូទឡាន ដែលមានសម្លៀកបំពាក់របស់ សាន់នី របស់របរចាំបាច់បន្តិចបន្តួចទៀត និងម្ហូបចំណី ដើរតាមនាងសំដៅខ្ទម ហើយ



ចាក់សោ បើកចូលទៅ។

"ថ្ងៃនេះផ្កាយពេញមេឃ បើមើលផ្កាយនៅទីនេះ ឃើញច្បាស់ណាស់"

សាន់នី ងើយមើលមេឃ ឃើញផ្កាយរះព្រោងព្រាត បញ្ចេញពន្លឺព្រិចៗ ស្អាតមែននោះឯង ទើបនាងមិនដើរតាម សេត ចូលទៅក្នុងខ្ទម តែដើរតាមរានហាល ដើម្បីមើលផ្កាយ។

"ស្អាតមែនទេ?"

អ្នកកំលោះដើរមករកនាង ស្រវាឱបពីក្រោយ ទើប សាន់នី ផ្ដេកក្បាលនឹងរាងកាយមាំមួន។

"ស្អាតណាស់"

"បើចូលចិត្ត នឹងនាំមកញឹកញាប់"

"លោក សេត ទំនេរឬ?"

"ទំនេរតើ"

សេត ថើបថ្ពាល់រលោង ហើយដឹកដៃនាង ដើរចូលខ្ទម នាងក៏ព្រមដើរតាម និងលួចមើលគេដោយមិនមាត់មិន.ក។

"ដើរពិនិត្យតាមសប្បាយ"

សាន់នី ចូលចិត្តលួចមើលគេ មើលគ្រប់កាយវិការ ឥរិយាបថរបស់គេ



Scanned by CamScanner

លួចភាពផ្ទាល់ខ្លួនរបស់គេតាមខ្សែភ្នែក ដើម្បីរក្សាទុកជាការចងចាំ។

"បាទ លោក សេត"

គេបញ្ជាឱ្យដើរពិនិត្យខ្ទម នាងក៏ធ្វើតាម ហើយពេលគេមិនមើលនាង នាងក៏លួចមើលគេទៀត តែពេលនាងមិនមើលគេ សេត ក៏លួចមើលនាងម្ដង ដែលពេលខ្លះ នាងក៏ស្ដាប់បង្គាប់ ហើយមិនថាជាចរិតផ្នែកណារបស់នាង គេទទួលបានទាំងអស់។

"ចូលចិត្តទេ ?"

"ចូលចិត្តលោក សេត"

នាងញញឹមដាក់គេ ហើយដើរទៅរក។ ខ្ទមសម្រាករបស់ សេត មានបន្ទប់ដេកមួយ បន្ទប់ទឹកមួយ និងបន្ទប់ធំផ្នែកខាងក្រៅដែលពិតានខ្ពស់ណាស់ ការតុបតែងផ្នែកខាងក្នុងមានភាពស្រទ្បះល្អ។

"ឃ្លានហើយឬនៅ ?"

"នៅទេ"

"អ៊ីចឹងផឹកអីក្ដៅៗល្អជាង ឆុងតែបានទេ ?"

"បាទ"

សេត ដើរទៅអង្គុយនៅរានហាលខាងក្រៅ ដែលអាចបើកទ្វារចេញពី





Scanned by CamScanner

បន្ទប់អង្គុយលេងបាន ទើប សាន់នី កាន់ទឹកតែដើរទៅតាម ពេលឆុងរួច។

"ទឹកតែ លោក សេត"

"អង្គុយម៉ោ"

"បាទ លោក សេត"

"ចង់ទៅណា ?"

"ទៅអង្គុយកៅអីនោះ"

"អង្គុយកៅអីនេះ"

អង្គុយកៅអីនេះ ដែលគេចង្អុលប្រាប់ ជាកៅអីដែលគេកំពុងអង្គុយ តើនាងអង្គុយយ៉ាងម៉េចទៅ។ នេះគេចង់ញ៉ោះនាងទៀតហើយឬ មានអារម្មណ៍ថាមួយរយៈនេះ គេមានសេចក្ដីសុខនឹងការញ៉ោះនាងខ្លាំងណាស់។

"លោក សេត កំពុងអង្គុយហ្នឹងណ៎ា"

"អង្គុយបែបនេះម៉ោ"

គេចាប់ដៃនាង កន្ត្រាក់តែបន្តិច ក៏ធ្វើឱ្យជ្រមិលមកអង្គុយលើភ្លៅ ហើយលើកដៃឱបរឹត និងកេងកម្រៃដោយការថើបថ្ពាល់រលោង។

"ងាយចង់ងាប់ គិតមិនឃើញដែរប៉ុណ្ណឹង ល្ងង់មែន"

"ខ្ញុំល្ងង់ឬ ?"



Scanned by CamScanner

"ល្ងង់ណាស់"

"លោក សេត រករឿងខ្ញុំរហូត"

សេត ចាប់ក្បាលរបស់នាងជ្រប់នឹងដើមទ្រូងរបស់គេ។ វិធីប្រណិប័តន៍ចំពោះមនុស្សប្រុសរបស់គេប្លែកៗ តែអាចមកពីគេយល់ថានាងជាមនុស្សប្រុសដែលមានបេះដូងជាមនុស្សស្រីឬអត់។

*ណ្ហើយចុះ! គេចង់គិតថាយើងជាស្អីក៏គិតទៅ វាមិនសំខាន់ទេ!*

នាងមានពេលនៅជាមួយគេតិចតួចណាស់ ទើបសុខចិត្តធ្វើឱ្យខ្លួនឯងមានសេចក្ដីសុខក្នុងមួយរយៈពេលខ្លីនេះ ហើយការប្រឆាំងនឹងគេ វាមិនកើតប្រយោជន៍អីទេ ព្រោះពេលនាងចាកចេញពីទីនេះ ពួកនាងនឹងមិនបានជួបគ្នាទៀតទេ។

*គេគិតថាយើងស្លាប់ហើយ!*

ស្រីកំណាន់ដែលធ្លាប់ប្រណិប័តន៍គេស្លាប់ក្នុងភ្នក់ភ្លើងរបស់ ណាខាដៀ ឬទោះគេដឹង ថានាងនៅមានជីវិតរស់ ក៏ពួកនាងមិនអាចរួមរស់នឹងគ្នាដដែល។

*យើងនិងគឺខុសគ្នាខ្លាំងណាស់!*

ឬហៅថាវណ្ណៈខុសគ្នាក៏មិនខុស ព្រោះគេជាបុរសដែលកើតនិងធំធាត់ក្នុងវណ្ណៈជាន់ខ្ពស់ ចំណែកនាង...គ្រាន់តែជាមនុស្សស្រីតូចទាបម្នាក់។





Scanned by CamScanner

"គិតអី?"

"អត់មានទេ"

"ឯងនេះមានចរិតច្រើនប្រភេទដូចមនុស្សស្រី"

"យ៉ាងម៉េចឬ?"

"ចូលចិត្តឆ្លើយដូចមនុស្សស្រី"

*គឺព្រោះតែនាងជាមនុស្សស្រី!*

សាន់នី ធ្លាប់មានចិត្តពីរ គឺចង់ប្រាប់ការពិតដល់គេ តែពេលបានឮសម្ដីដែលគេប្រាប់នាង គេគិតថានាងស្លាប់បាត់ហើយ គឺស៊ូឱ្យបែបនេះបន្តល្អជាង ហើយពេលនាងចាកចេញពីជីវិតរបស់គេ វានឹងគ្មានអ្វីប្រែប្រួលសម្រាប់គេទេ ប៉ុន្តែសម្រាប់នាងវិញ ការផ្លាស់ប្ដូរវិថីជីវិតពីការមានគេ ទៅជាគ្មានគេ វាត្រូវចំណាយពេល ឱ្យទាល់តែសុាំ។

មុននេះនាងរស់នៅ ណាខាដៀ ទោះមិនបានជួបគ្នាច្រើនខែ តែនាងគ្មានអារម្មណ៍ហែងហាង ព្រោះដឹងថាត្រូវជួបគេនៅថ្ងៃណាមួយ ប៉ុន្តែការដែលនាងដើរចេញពីកោះពេលចប់កិច្ចសន្យាការងាររយៈពេលខ្លី វាជាការចាកចេញដែលមានភាពខុសគ្នា ព្រោះវាមានន័យដល់ការចាកចេញជារៀងរាល់រហូត។

សាន់នី ស្លាប់បាត់ហើយ ទើបពេលនេះ នាងមានឱកាសប្រមូលយក



Scanned by CamScanner

ការចងចាំតិចតួច ដែលមានជាមួយគេក្នុងនាមរបស់ ដាស៊ី។

*យើងចាញ់ដៃគេឱ្យទាល់តែបាន!*

សាន់នី ធ្លាប់គិតថាខ្លួនឯងមិនចូលចិត្តគេ មិនចង់នៅជិតគេ ខឹងដែលរាងកាយរបស់នាងតបស្នងគេ តាមពិតទៅនាងបោកខ្លួនឯងប៉ុណ្ណោះ រាងកាយរបស់នាងទៅវិញទេ ដែលមិនធ្លាប់បោកប្រាស់ថា វាត្រូវការ សេត។

"មិនចង់និយាយទេអី?"

នាងមិនមាត់ក និងត្រសុលទៅរកលង្វែកទ្រូងមាំមួន ហើយពេលគេសួរនាងក៏ងក់ក្បាលជាចម្លើយ ព្រោះមិនចង់រកហេតុផល ដើម្បីកុហក ដូច្នេះហើយការស្ងប់ស្ងាត់ក៏ល្អដែរ។

**"ថ្ងៃនេះផ្កាយស្អាតដល់ហើយ"**

ធីណា ឈរទ្រានដៃនឹងបង្អួចកញ្ចក់ថ្លាយង់ មើលទៅខាងក្រៅ ដោយការចាប់អារម្មណ៍។

"ចូលចិត្តផ្កាយឬអី?"

"គួរតែចូលចិត្ត"

"គួរតែចូលចិត្ត?"





Scanned by CamScanner

"ពេលនៅ ណាខាដៀ មិនធ្លាប់ឃើញផ្កាយបែបនេះទេ"

នាងរំភើបដូចកូនក្មេង និងដូចភ្លេចការឈឺចាប់លើមុខ ដែលកើតឡើងដោយសារត្រូវកម្មករស្រីពីរនាក់ទះ។ វាបាត់ស្នាមហើយ ព្រោះគេទៅសុំថ្នាំឈើមកឱ្យ ដែលក្លិនរបស់វាមិនគួរឱ្យប៉ះអីបន្តិច តែលទ្ធផលវាល្អណាស់។

"លោក គ្រីស"

នាងដើរទៅរកម្ចាស់ឈ្មោះ ដែលអង្គុយសណ្ដូកជើង ផ្អែកនឹងក្បាលគ្រែអានសៀវភៅ ហើយលោខ្លួនទៅឱប ត្រដុសថ្ពាល់នឹងដៃមាំមួន។

"មានស្អី ?"

"ចេញទៅមើលផ្កាយទៅ"

"អង្គុយមើលនៅមាត់បង្អួចទៅ"

"ចង់ចេញទៅខាងក្រៅហ្នឹងណាំ"

"អាកាសធាតុត្រជាក់"

នាងតោងដៃគេជាប់ ត្រដុសថ្ពាល់នឹងដៃដោយភាពម៉ិកម៉ូក់។ មុននេះញេធុញទ្រាន់ បើនាងធ្វើបែបនេះ ប៉ុន្តែពេលនេះគេស៊ាំនឹងនាងហើយទេដឹងទើបគិតថាស្រីល្ងីល្ងើនេះក៏គួរឱ្យស្រឡាញ់ដែរ។

"ដេកទៅ"



Scanned by CamScanner

"លោក គ្រីស"

ធីណា ទាញសៀវភៅចេញពីដៃគេ ហើយមុជក្រោមដៃមាំមួន ចូលទៅអង្គុយលើភ្លៅ លើកដៃឱប.ករបស់គេ។

"ចេញទៅមើលផ្កាយទៅ"

នាងញញឹមទាំងមាត់ ទាំងភ្នែក បំណងឱ្យគេទន់ចិត្ត គ្រីស ក៏លើកដៃខោកថ្ងាសរបស់មនុស្សប៉ិនម្មិកម្ម៉ក់។ តាមរយៈការសង្កេត ធីណា ប្រយ័ត្នខ្លួនដាក់អ្នកដទៃណាស់ មិនថាជាមនុស្សស្រី ឬមនុស្សប្រុស តែចំពោះគេ នាងតែងតែមកម្មិកម្ម៉ក់ដាក់ មិនខ្វល់ទេថាគេជាមនុស្សប្រុស។

"ហេតុអីត្រូវមើលផ្កាយ ?"

"ព្រោះផ្កាយស្អាត"

"ផ្កាយស្អាត ?"

គេលើកចិញ្ចើម ដូចមិនយល់ស្របនឹងគំនិតនោះ ធីណា ក៏ងក់ក្បាលញញឹមញញៀមយកចិត្តយកថ្លើមគេពេញទី ព្រោះចង់ចេញទៅមើលផ្កាយ តែចេញពីផ្ទះម្នាក់ឯងនៅពេលយប់គឺមិនបានទេ ទោះជារានហាលខាងក្រៅ ក៏ជាកន្លែងហាមឃាត់ពេលរាត្រីកាល។

"វាមិនគួរណាជាហេតុផលទេ ធីណា"





Scanned by CamScanner

"ណាំៗ ណាំៗ"

ម្ញិកម៉្ញក់ ហើយក៏ញញឹម លោខ្លួនទៅរក យកថ្ពាល់រលោងត្រដុសនឹងថ្ពាល់គ្រើមតិចៗ ធ្វើឱ្យគេភាំងបន្តិច ហើយលើកដៃឱបចង្កេះរបស់នាង។

"អ្នកណាបង្រៀនឱ្យម៉្ញិកម៉្ញក់បែបនេះ"

"ម៉្ញិកម៉្ញក់មិនបានឬ ?"

"វាស្និទ្ធស្នាលពេកហើយ"

"ស្និទ្ធស្នាលជាក់លោកមិនបានឬ យើងជាគូស្នេហ៍នឹងគ្នាហ្នឹងណាំ"

គ្រីស ទើបតែដឹង ថាគេក្លាយជាគូស្នេហ៍របស់នាងទៅហើយ ទើបចង់ចិញ្ចើម តែត្រូវនាងយកម្រាមដៃឈ្លីតិចៗ។

"ប្រយ័ត្នត្រង់នេះជ្រួញជាតាចាស់"

"នាងអាយុប៉ុន្មាន ?"

"ម្ភៃឆ្នាំ"

"អីចឹងខ្ញុំសមជាតាចាស់ហើយ ព្រោះខ្ញុំអាយុសាមសិបបីឆ្នាំហើយ"

"ចាស់ក៏មិនបោលដែរ ខ្ញុំសន្យា"

*ក្មេងស្រីម្នាក់នេះបបោលអង្អែលគេរាល់ថ្ងៃ ព្រោះគិតថាគេជាគូស្នេហ៍របស់នាងឬនេះ!*

"ធីណា"

"ចាំ លោក គ្រីស"

"យើងជាគូស្នេហ៍នឹងគ្នាតាំងពីអង្កាល់ អធិប្បាយម៉ោ"

"មិនដឹងទេ" ធីណា ជ្រប់មុខនឹងដើមទ្រូងធំទូលាយ។

*ទទួលចិញ្ចឹមក្មេងស្រីស្អាតម្នាក់ ធ្វើឱ្យគេក្លាយជាមនុស្សមានម្ចាស់ទៅហើយឬ!*

"គឺ...យើងដេកឱបគ្នារាល់យប់ ពេលថ្ងៃក៏ឱបគ្នា ពេលយប់ក៏ឱបគ្នា"

"ពេលថ្ងៃយើងឱបគ្នាដែរឬ ?"

"ឱបញឹកញាប់សឹងអី ?"

"ភរហើយ"

"អត់មានទេ"

នាងក្រមុំជ្រួញច្រមុះដាក់ គ្រីស ធ្វើមុខតាមធម្មតារបស់គេ តែក៏ប្រចាប់ច្រមុះរបស់នាងជាការដាក់ទោស ទើបនាងលើកដៃអង្អែលវាតិចៗ ពេលគេដកដៃចេញ។

"ញ៉ោះឬ ?"

"ដាក់ទោសក្មេងចូលចិត្តភរ"





Scanned by CamScanner

"មិនដឹងទេ កក់ទុកហើយ" នាងឱបរឹតតែណែនដៃ។

គ្រីស មិនធ្លាប់ជួបស្រីណាប៉ិនម្រិកម្ញ៉ក់ ថែមទាំងចូលចិត្តភរបែបនេះទេ ទើបញញឹមចុងមាត់ជាច្រើនដង ព្រោះទ្រាំលែងបានហើយ ទោះប្រឹងធ្វើមុខមាំក៏ដោយ។

"កក់អ្នកណា?"

"កក់មាសស្នេហ៍"

"នាងហៅខ្ញុំថាម៉េច?"

"មាសស្នេហ៍ សង្សារនឹងគ្នា គេហៅគ្នាបែបនេះ"

ធីណា ធ្វើភ្នែកម៉ក់ៗ ដាក់ ទើបត្រូវ គ្រីស ប្រើខ្នងដៃគោះថ្ងាស តែនាងក៏ញញឹមស៊ូ ឱប.កគេ មិនព្រមលែង។

"អ្នកណាបង្រៀននាង?"

"នៅ ណាខាដៀ អ្នកណាៗក៏គេធ្វើ"

"សរុបទៅ ខ្ញុំត្រូវក្មេងកក់?"

"ខ្ញុំមិនមែនក្មេងទេ"

"ស្មានថាទើបអាយុដប់ឆ្នាំ"

"មិនពិតទេ"

ធីណា មិនចង់ឱ្យប្រមាថថាជាកូនក្មេង ព្រោះនាងចូលចិត្ត គ្រីស ណាស់ និងមិនចង់ឱ្យគេក្លាយជារបស់អ្នកណា ក្រៅពីនាងម្នាក់គត់។

"ហ៎ា!"

គ្រីស ស្រែកភ្លាត់មាត់ ពេលត្រូវនាងចាប់ដៃទៅដាក់លើដើមទ្រូង។

"ក្មេងស្អី ដើមទ្រូងខ្ញុំធំណាស់ ជិតខាប់ប៊ី"

គ្រីស ចង់ដកដៃចេញ តែត្រូវនាងសង្កត់ជាប់ មិនព្រមលែង ទើបធ្វើមុខកាចដាក់។

"លែង ធីណា"

"ខ្ញុំមិនមែនក្មេងទេ"

"រពឹសណាស់ តិចត្រូវ"

"ត្រូវអី ?"

"ត្រូវបែបនេះហ្នឹងអី"

គេត្រូវគំរាមកំហែង ទើបដកដៃ ដែលនាងគិតខុស ព្រោះគេមិនបានដកថយ តែបែរជាលូកដៃចូលអាវឃើតធំស៊ុលគយុលរបស់នាង។

"អ៊ុំ!"

ធីណា ភ្ញាក់ផ្អើល ពេលត្រូវគេប៉ះដើមទ្រូងដោយផ្ទាល់ ជាងនោះទៅ





Scanned by CamScanner

ទៀត អារយឺតត្រូវលើកទៅដល់ណាដល់ណី ម្យ៉ាងទៀតមិនបានពាក់អាវក្នុង ពាក់តែអាវទ្រនាប់ស្តើង ព្រោះជាឈុតពាក់ដេក។

"ខ្លាចទេ ?"

"មិនខ្លាចទេ ដៃលោកកក់ក្ដៅដល់ហើយ"

"ក្មេងព្រើល"

នាងពើងទ្រូងមករក ថ្ពាល់រលោងឡើងក្រហមងាំង ឱ្យគេមានអារម្មណ៍ ថានាងគួរឱ្យស្រឡាញ់ ទើបប្រចាប់ដើមទ្រូងរបស់នាងដោយភាពភ្លើតភ្លើន។

"លោក គ្រីស"

"ម៉េច ?"

"យើងជាគូស្នេហ៍នឹងគ្នាមែនទេ ?"

"ខ្ញុំតាមចិត្តនាង"

គ្រីស ចិត្តទុកដាក់ក្មេង ធីណា ក៏ញញឹមពព្រាយ ថើបថ្ពាល់គេព្នខ្សឹតៗ ដែលគេក៏ប្រឹងទប់ស្នាមញញឹម និងជ្រឹមភ្នែកមើលនាង ហើយក៏សើចញឹមៗ ឱ្យទាល់តែបាន។

"ល្អដល់ហើយ យើងនឹងនៅជាមួយគ្នារហូត"

"ចុះបើថ្ងៃមួយនាងមិនចង់នៅជាមួយខ្ញុំ ?"



Scanned by CamScanner

"គ្មានថ្ងៃទេ ខ្ញុំនឹងនៅជាមួយលោករហូត ព្រោះខ្ញុំចង់នៅជាមួយលោកខ្លាំងណាស់"

"ក្មេងប្រសប់និយាយ"

"លោកចូលចិត្តក្មេងទេ ?"

"ប្រហែលចូលចិត្តហើយ មានសង្សារក្មេងហ្នឹងណា៎"

"លែងចាប់ហើយឬ ?"

អ្នកកំលោះដកចេញពីខ្លួនរបស់នាង នាងក៏សួរដូចសោកស្តាយ និងធ្វើភ្នែកម៉ក់ៗ មើលមក ទើបគេដកដង្ហើមចូលឱ្យពេញសួត រំកិលខ្លួនចុះពីគ្រែហើយលើកបីនាង។

"ចង់ទៅមើលផ្កាយមិនអីចឹង"

"ចា៎ ទៅមើលផ្កាយ មើលផ្កាយរួចហើយ បើលោក គ្រីស ចង់ចាប់ សឹមមកចាប់បន្ត"

"ក្មេងព្រើល"

"ស្មានថាចូលចិត្តតើ"

"ចូលចិត្ត ហ៊ីយ! នាងនេះ ធ្វើឱ្យខ្ញុំខូចមនុស្សអស់ហើយ តោះៗ ទៅមើលផ្កាយ"





Scanned by CamScanner

គ្រីស បីនាងចេញទៅរានហានខាងក្រៅ ហើយដាក់បង្គុយលើកៅអី និងឱ្យនាងអង្គុយលើភ្លៅ ដៃក៏ឱបក្រសោបជាប់ ព្រោះអាកាសធាតុនៅខាងក្រៅរាងត្រជាក់។

ក្មេងព្រើលរបស់គេធ្វើភ្នែកព្រិចៗ ប្រណាំងនឹងផ្កាយនៅលើមេឃ។ បើនាងចូលចិត្តផ្កាយដល់ថ្នាក់នេះ គេត្រូវតែរកពេលនាំនាងទៅដេកមើលផ្កាយនៅលើភ្នំនៅថ្ងៃសម្រាករបស់គេហើយ។



Scanned by CamScanner

# ១៦

## ព្រោះអូន ទើបស្រឡាញ់

អាកាសធាតុត្រជាក់ស្រេង និងការសម្ងំនៅក្នុងរង្វង់ដៃរបស់ សេត ជាសេចក្តីសុខរបស់នាង ក្រៅពីនេះ សាន់នី ក៏មានកែវកាកាវក្តៅនៅក្នុងដៃ ទើបនាងទទួលបានភាពកក់ក្តៅទាំងពីមនុស្ស និងភេសជ្ជៈ។ នៅលើកោះមានព្យុះ នាងភ័យជាខ្លាំង តែត្រូវ សេត ឱបក្រសោប លួងលោមថា ជារឿងធម្មតារបស់អ្នកដែលរស់នៅលើកោះនៅចន្លោះពេលនេះជារៀងរាល់ឆ្នាំ។

ពេលនេះពួកនាងនៅក្នុងបន្ទប់ដេក មានបង្អួចកម្ពស់ជិតដល់ពិតាន សេត ទាញវាំងននបើករួចហើយ ទើបនាងអាចមើលឃើញទឹកភ្លៀង ដែលកំពុងធ្លាក់ខ្លោកៗ ខ្យល់ខ្លាំងធ្វើឱ្យមែកឈើធំយោលយោក ផ្គរគ្រហឹមគ្រឹមៗ បើនៅក្រៅផ្ទះ ប្រហែលធ្លាក់ថ្លើមទៅហើយ។

សាន់នី បារម្ភពីប្អូនស្រី តែបានចម្លើយពី សេត ថាផ្ទះទាំងអស់នៅលើកោះ រួមទាំងអគារដែលជាបន្ទប់ស្នាក់នៅរបស់កម្មករ ក៏កសាងដោយវត្ថុដែល



មានគុណភាពរឹងមាំណាស់ សក្តិសមនឹងស្ថានភាពអាកាសធាតុនៅលើកោះ។

"ឆ្ងាញ់ទេ?"

"ឆ្ងាញ់"

សេត បដិសេធផឹកកាការក្តៅ ទើបនាងឆុងផឹកម្នាក់ឯង។ នាងចូលចិត្ត ឱ្យរាងកាយរបស់ខ្លួនឯងកក់ក្តៅ ទើបផឹកវាអស់ពីកែវ។

"សុំផឹកផង"

"អស់ហើយ ខ្ញុំទៅឆុងឱ្យ"

"មិនបាច់ទេ ខ្ញុំមានរបស់ផឹកហើយ"

សាន់នី មិងមាំង ទាល់តែត្រូវគេចាប់ផ្ញើយចង្កា និងឱនមករកនោះឯង ទើបគិតចេញ។ សេត ត្រូវការផឹកកាការពីមាត់របស់នាង ដោយការបឺតជញ្ជក់ខ្លាំងៗ ចំណែកកែវ គេក៏បេះពីដៃរបស់នាង ដាក់លើកម្រាលលើកម្រាល ព្រោះពួកនាងក្រាលក្រណាត់ទន់ល្មើយ អង្គុយឱបគ្នា។

ការថើបរបស់គេពោរពេញទៅដោយថាមពល ជាការថើបដែលអាចទាញទាក់ចំណាប់អារម្មណ៍របស់នាងឱ្យនៅជាមួយគេ និងមិនចង់ដឹងឮអ្វីផ្សេងទេ ទើបបិទភ្នែក សម្ងំនៅក្នុងលង្វែកទ្រូងមាំមួន។

សេត ថើបជញ្ជក់បបូរមាត់ទន់ល្មើយ ដែលកាន់តែថើន កាន់តែផ្អែម ឬ



Scanned by CamScanner

ភាពផ្អែមល្ហែមនោះកើតឡើងចំពោះ សាន់នី តែម្នាក់ ព្រោះនាងចាប់ផ្ដើមមានចំណងជាមួយគេ។ ចំណងដែលកើតឡើង ធ្វើឱ្យនាងមានសេចក្ដីសុខ ដែលបាននៅជិតគេ មិនថាដោយហេតុផលអ្វីក៏ដោយ ទោះចំណង់ចំណូលចិត្តរឿងផ្លូវភេទរបស់គេ ធ្វើឱ្យនាងមានអារម្មណ៍ឈឺចាប់ តែនាងក៏ព្យាយាមបំភ្លេចវា។

"ផ្អែម កាន់តែបើប កាន់តែផ្អែម"

"អ៊ា..." នាងថ្ងូចថ្ងូរតិចៗ ព្រោះសម្ដីរបស់ សេត។

ការបើបរបស់គេដូចទឹកកំពុងពុះ ជ្រែកអណ្ដាតចូលមកក្នុងប្រអប់មាត់របស់នាង គេរឹតរួតអណ្ដាតរបស់នាង ដើម្បីស្វែងរករសជាតិផ្អែមល្ហែម ដែលគេប្រាថ្នា ហើយពេលស្វែងរកឃើញ ក៏ដួសដងយកដោយមិនក្រែងចិត្ត។

"ល្អ ពៅព្រលឹង"

គេនិងនាងមិនធ្លាប់មានអារម្មណ៍រួមក្ដៅគគុកកម្រិតនេះទេ នាងចង់មានន័យដល់ពេលដែលនាងជា សាន់នី តែមានន័យដល់ពេលដែលនាងបន្លំខ្លួនជាមនុស្សប្រុស ហើយការដែលត្រូវគេហៅបែបនេះ កាន់តែផ្ទោចឱ្យនាងគិតដល់រូបភាពកាលពីអតីត។

"អ៊ា..."

ការស្រមើស្រមៃបំពេអារម្មណ៍ ផ្ទោចទៅដល់រាងកាយ ឱ្យកាន់តែក្ដៅ



ដោយភ្លើងប្រាថ្នា។ អណ្ដាតរបស់ សេត ជ្រែកចូលមកក្នុងប្រអប់មាត់ រាងកាយរបស់នាងក៏កន្ត្រាក់ចូលមកក្នុងលង្វែកទ្រូងមាំមួន។ នាងដឹងថាអាវយឺតរបស់នាងត្រូវលើកខ្ពស់ ដៃរបស់គេក៏លូកមកក្ដោបដើមទ្រូងណែនក្បំ ដែលវាលោតដូចរ៉ឺស័រដាក់បាតដៃធំក្រាស់ ហើយនាងក៏ថ្ងូចថ្ងូរតាមបបូរមាត់ ដើម្បីឱ្យគេបឺតជញ្ជប់យកសំឡេងនោះ។

គេបើបមាត់ តែរាងកាយបែរជាត្រូវផ្ទោចគ្រប់ផ្នែក ឱ្យនាងភ្លើតភ្លើនទៅតាមការផ្ទោចនោះ ប្រហែលមកពីនាងនិងគេប៉ះពាល់គ្នាជារៀងរាល់ថ្ងៃ តែគេមិនធ្លាប់ធ្វើលើសពីឱបថើបមាត់ ឬដើមទ្រូងរបស់នាង។ ការប្រាថ្នាដែលមិនទាន់ទៅដល់គោលដៅ វាសន្សំបន្តិចម្ដងៗ ទាល់តែស្ទះរាងកាយចង់ផ្ទុះ វាជាភាពវេទនា តែ សេត ក៏ធ្វើវាជារៀងរាល់យប់ ដូចគេព្រមឱ្យដៃនិងមាត់នៅឆ្ងាយពីការបៀតបៀននាងចូលដេកមិនបាន។

"ហ៊ឺ! លោក សេត"

នាងក្រមុំហៅគេដោយសំឡេងផ្អែមដោយភ្លេចខ្លួន ហើយ សេត ក៏មិនដាស់តឿនឱ្យនាងដឹងខ្លួនដែរ។ គេថើបនាង ថើបដោយភាពជ្រាលជ្រៅ ដើម្បីផ្ទោចស្មារតីរបស់នាងឱ្យរត់ខ្ចាត់ខ្ចាយ ដៃក៏ប្រចាប់ដើមទ្រូងក្រពុំ ចុងរបស់វាក៏ទៅជារឹងកំព្រឹស ហើយទឹកពណ៌ទឹកដោះគោដែលដោយតាមមេដៃរបស់គេក៏

ឱ្យរសជាតិផ្អែមល្ហែកៗ។

"អាំ...អាំ!"

សំឡេងថ្ងូចថ្ងូរដ៏ពីរោះរបស់នាងបន្លឺឡើង ដោយមិនអាចហាមចិត្តបាន ពេលស្មារតីត្រូវបណ្ដោញឱ្យរត់ខ្ចាត់ខ្ចាយ។ នាងក៏វេទនាមិនចាញ់ សេត ដែរ ត្រូវគេបឺតជញ្ជប់ដើមទ្រូងរាល់ថ្ងៃ តែរាងកាយដែលមិនធ្លាប់ទទួលបានការបំពេញដោយភាពមហិមារបស់គេ តែងតែដង្ហោយរកគេ ត្រូវការសេចក្ដីសុខហូរហៀរដែលធ្លាប់ទទួលបានពី សេត។

ការប៉ះពាល់របស់គេដូចញ៉ោះ ធ្វើឱ្យនាងមានសេចក្ដីសុខ តែមិនត្រូវបានដោះលែងឱ្យទៅដល់គោលដៅ ដែលរាងកាយប្រាថ្នា តែនាងមិនគួរព្រមឱ្យប៉ះពាល់ដល់ថ្នាក់នេះទេ ព្រោះវាប្រថុយណាស់ ហើយការប្រថុយនេះកំពុងកើតឡើងហើយនៅពេលនេះ។ បបូរមាត់របស់គេកំពុងបង្កើតសេចក្ដីសុខឱ្យនាង នាងកំពុងតបស្នងគេដូចពេលដែលនៅជាស្រីរបាំ។

"លោក...លោក សេត"

"ពៅព្រលឹង ផ្អែមអីយ៉ាងនេះ" សេត ថើបនាង ព្រោះអត់ធ្មត់លែងបានតទៅទៀត។

ព្យុះដែលកំពុងបោកបក់នៅខាងក្រៅ មិនខ្លាំងដូចព្យុះអារម្មណ៍របស់





Scanned by CamScanner

អ្នកនៅក្នុងបន្ទប់ ហើយពេលគេដោះអាវចេញ បង្ហាញរាងកាយសុទ្ធតែសាច់ដុំហាប់ណែន ឱ្យនាងត្រសុលមករក ដោយមិនខ្វល់ទេថានាងជា ដាសុី និងមិនខ្វល់ទេ ថាការមានទំនាក់ទំនងផ្លូវកាយ ធ្វើឱ្យការពិតត្រូវលាតត្រដាង។

សេត មានការពុញទ្រាន់នឹងពុកមាត់ក្លែងក្លាយរបស់នាង តែត្រូវរកវិធីកម្ចាត់វាឱ្យទំនង ដោយការថើបជញ្ជក់ ស្ទាបអង្អែល ហើយលួចទាញវាចេញពីមុខស្រស់ស្អាត ដោយមិនឱ្យនាងដឹងខ្លួន ថាមុខមាត់ស្រស់ស្អាត នៅពេលនេះស្ថិតនៅក្រោមខ្សែភ្នែករបស់គេហើយ។

"ស្រីស្អាតរបស់ខ្ញុំ"

*គេហៅយើងថាស្រីស្អាត ដូចដឹងថាយើងជាមនុស្សស្រី!*

សាន់នី ត្រូវចាប់ដោះខោអាវ ឱ្យល្វែងលើអាក្រាត រាងកាយរបស់នាងត្រូវការឱ្យគេបំពេញ វាពិបាកនឹងទ្រាំបាន ដូចនាងឃើញនំផ្អែមដែលចូលចិត្តកំពុងទាក់ទាញចិត្ត ទាក់ទាញភ្នែករាល់ថ្ងៃ តែគ្មានឱកាសបានញ៉ាំឱ្យពេញមាត់ទើបធ្វើឱ្យការស្រេកឃ្លានសន្សំបានច្រើន។

*បិសាចរាគៈនៅក្នុងខ្លួនយើងកំពុងកើតការប្រាថ្នា!*

នាងថ្ងូចថ្ងូរដោយភាពក្ដៅគគុកនៅក្នុងចិត្ត បន្ទាប់មកក៏ត្រូវគេចាប់ឱ្យដេកផ្ងារខ្លួនលើព្រំ និងដោះខោអាវទាល់តែអស់ពីខ្លួន។



Scanned by CamScanner

សេត មានការធុញទ្រាន់នឹងសក់ក្លែងក្លាយទៀតហើយ ថ្ងៃនេះគេត្រូវតែបានស៊ីនាងឱ្យឆ្អែត ដូច្នេះហើយ គេនឹងធ្វើតាមចិត្តខ្លួនឯង។

គេតាមទៅឱប ពិតដើមទ្រូងនឹងដើមទ្រូងទន់ល្មើយ ត្រដុសគ្នាតិចៗ ឱ្យរោមទ្រូងធ្វើឱ្យនាងរមាស់ បន្ទាប់មកក៏ងើបចេញ ដើម្បីចាត់ការល្វែងក្រោមរបស់ខ្លួន។

សាន់នី សម្លឹងមើលរាងកាយសម្បូរបែបរបស់គេ ដោយភ្លេចទៅថានាងកំពុងននលគកនៅចំពោះមុខគេដូចគ្នា ហើយពេល សេត ទ្រោបមកលើនាងម្តងទៀត ក៏ថើបតាំងពីបបូរមាត់ទន់ល្មើយ ដេញមករកដើមទ្រូងទ្រលុកទ្រលន់ បន្តទៅចង្កេះតូច ត្រគាកមូលក្លំ ចុះដល់ភាពផ្អែមល្ហែម ដែលគេស្រេកឃ្លានចង់បឺតជញ្ជក់ខ្លាំង។

"លោក សេត លោក សេត"

នាងថ្ងូរហៅឈ្មោះរបស់គេ ហើយប្រឹងខ្ទឹបមាត់ដោយអារម្មណ៍វេទនា ព្រោះត្រូវគេដាស់អារម្មណ៍ឱ្យចង់ដាច់ខ្យល់ទៅហើយ នាងមិនអាចហាមប្រាមខ្លួនឯងបានតទៅទៀតទេ ជាពិសេសពេលគេលុតជង្គង់ត្រង់ប្រឡោះជើង នាងក៏បើកផ្លូវ ផ្តល់ភាពងាយស្រួលឱ្យគេទៀត។

សេត នាំខ្លួនឯងចូលទៅរកភាពទន់ល្មើយដោយការនឹករឮក និងទាញ





Scanned by CamScanner

នាងមកឱបរឹត ទាញសក់ក្លែងក្លាយគ្រវាត់ចោល ដើម្បីឱ្យគេបានថើបសក់ស្អាត ខណៈនោះក៏គ្រប់គ្រងនាងដោយភាពក្ដៅគគុក។

នាងក្រមុំបើកភ្នែកធំៗ ដោយភាពស្រៀវស្រើប អារម្មណ៍ក្ដៅគគុកកំពុងលុកលុយរាងកាយតាមចង្វាក់នៃការគ្រវែងត្រគាករបស់ សេត។ នាងពើងទ្រូងទៅរក លើកដៃបិទមាត់ខ្លួនឯង ព្រោះអាម៉ាស់នឹងសំឡេងស្រែកថ្ងូរដែលឮខ្លាំងហួសពីការស្មានរបស់ខ្លួន។

សេត ឱបចង្កេះរបស់នាងដោយដៃម្ខាងពីក្រោយ ដៃម្ខាងទៀតក្ដោបដើមទ្រូងក្រពុំ ប្របាច់ម្ដងម្ខាងឆ្លាស់គ្នា ពេលខ្លះក៏ប្រើម្រាមដៃញក់ញីចុងរបស់វា ធ្វោចរាងកាយរបស់នាងឱ្យកាន់តែស្រៀវស្រើប សក់វែងរសាយក៏រាយប៉ាយពេញរាងកាយសើមដោយញើស។

"ស្អាតមែនទែន"

មិនថាគេចាប់នាងឱ្យនៅក្នុងកាយវិការណា ក៏នាងស្រស់ស្អាត។ នាងជាមនុស្សស្រីដែលពេលពាក់ខោអាវក៏ស្អាត ពេលននលគកក៏ស្អាត ពេលត្រូវគេពង្វក់ដោយភ្លើងប្រាថ្នា កាន់តែទាក់ទាញ និងគួរឱ្យប្រាថ្នា។

គេប្រើម្រាមដៃកៀបចុងទ្រូងរឹងកំព្រឹសជាការដុតអារម្មណ៍ ឱ្យនាងញ័រខ្លួន ព្រោះត្រគាករបស់គេក៏ធ្វើចលនាមិនឈប់។ សេត អាចប្រគល់អារម្មណ៍



Scanned by CamScanner

អស្ចារ្យឱ្យនាងបានជានិច្ច ជាពិសេសពេលមានទំនាក់ទំនងរាងកាយជាមួយគ្នា បន្ទាប់ពីដង្ហោយរកយ៉ាងជ្រាលជ្រៅ ទើបទាំងនាង ទាំងគេ គ្មានអ្នកណាអាច ទប់តម្រូវការបានតទៅទៀត។

"ហ៊ឹ! អ៊ា!"

នាងអង្អែលស្មៅរបស់គេ ពេលត្រូវចាប់បង្វែរឱ្យបែរមុខទៅរក ដោយត្រូវ ចាប់ឱ្យអង្គុយច្រកកៀវលើភ្លៅរបស់គេម្តងទៀត។ ភាពផ្អែមល្ហែមដែលត្រូវគេ បំពេញឱ្យហូរហៀរ កំពុងតែដង្ហោយរកការធ្វើចលនារបស់គេ។

"ដេកលើគ្រែទន់ៗ ល្អជាង"

គេនិយាយបែបនោះ តែមិនអនុញ្ញាតឱ្យនាងដេក បន្ទាប់ពីលើកពមក ដាក់លើគ្រែ ទាល់តែចប់ភារកិច្ចបញ្ចេញថាមពលពីរាងកាយអស់។

"ពៅព្រលឹង"

សេត ហៅនាងដោយសំឡេងពីរោះ និងផ្ញើយចង្កា ឱនទៅថើបជញ្ជក់ ហើយអូសបាតដៃទៅចាប់ត្រគាកមូលក្លំ។ រាងកាយផ្អែមល្ហែមរបស់នាងត្រូវគេ លេបត្របាក់លើសពីបីដង តែនាងក៏មិនស្វាងពីរសជាតិស្រៀវស្រើប។

"ចាំ សេត" នាងឆ្លើយតបដូចមនុស្សមមើ។

សេត ថើបជញ្ជប់មាត់ជាការឱ្យរង្វាន់ ហើយអង្រួនពិភពរបស់នាងដោ





Scanned by CamScanner

យបទភ្លេងប្រាថ្នាដែលកាន់តែក្ដៅទៅៗ។

"ហ៊ឺ! សេត សេត"

ម្រាមដៃស្រឡូនខ្វាំស្មាធំទូលាយ រាងកាយញាប់ញ័រទៅតាមតម្រូវការ ភ្លើងប្រាថ្នាដុតរម្លាយរាងកាយទាំងពីរឱ្យសមបំណងរៀងខ្លួន មិនប្រាថ្នាដឹងឮអ្វីនៅជុំវិញខ្លួន ក្រៅពីសេចក្ដីសុខមួយនេះ។

សាន់នី ទះកំផ្លៀង **សេត នាងតបស្នងគេដោយភាពក្ដៅគគុក ប៉ុន្តែ** ពេលមានស្មារតីឡើងវិញ ក៏អាម៉ាស់មុខជាខ្លាំង មិនមែនដោយសារនាងធ្វើរឿងលើគ្រែជាមួយគេ ប៉ុន្តែវាមានន័យថាគេដឹងមករហូតថានាងបន្លំខ្លួន។

"ពេលសមចិត្តចង់ហើយ ក៏ឆ្មាសឆ្មើមណាំ ពៅព្រលឹង"

សេត លើកដៃអង្អែលថ្ពាល់ខ្លួនឯង។ គេឈឺថ្ពាល់មួយចំហៀង ចំណែកនាងប្រហែលជាឈឺដៃខ្លាំង ព្រោះដៃនាងតូចខ្លាំងណាស់។

"មនុស្សបោកទាប"

"ខ្ញុំបោកទាបព្រោះស្អី ព្រោះខ្ញុំផ្ដល់សេចក្ដីសុខឲ្យ ឲ្យនាងស្រែកពេញមួយយប់"

"មនុស្សបោកទាប!"



Scanned by CamScanner

នាងស្ទុះទៅរក តែ សេត មិនអនុញ្ញាតឲ្យទះកំផ្លៀងជាលើកទីពីរ ទើបស្រវាចាប់ដៃរបស់នាងជាប់ និងសម្លឹងមុខដោយខ្សែភ្នែកកាច។ គេព្រមឲ្យនាងឆ្នាសបាន ប៉ុន្តែបើគ្មានហេតុផលពេក ត្រូវតែបង្ក្រាប។

"នាងកើតស្អី យើងមានសេចក្តីសុខជាមួយគ្នាតើ នាងថ្ងូរហៅឈ្មោះខ្ញុំ និងសរសើរខ្ញុំគ្រប់សព្វ"

"ឈប់និយាយ"

"វាជារឿងពិតហ្នឹងណា ពៅព្រលឹង"

"ខ្ញុំមិនមែនពៅព្រលឹងរបស់លោក"

"ហើយឲ្យខ្ញុំហៅនាងថាស្អី ស្រីកំណាន់?"

"ប្រុសឆ្កួត!"

គេចាប់កដៃរបស់នាងជាប់ ដែលខឹងស្រែកគំហកដាក់គេប្រែតៗ នេះ មិនមែនស្អីនោះទេ គឺគ្រាន់តែអាម៉ាស់មុខ ដែលដឹងថានាងបោកគេមិនបានសម្រេចនោះឯង។

"កុំឆ្នាសបានទេ មានហេតុផលបន្តិច យប់មិញយើងមានសេចក្តីសុខជាមួយគ្នា ព្រឹកឡើងខ្ញុំនៅចង់បន្តពីរដងទៀត"

"ទៅបន្តម្នាក់ឯងទៅ"





Scanned by CamScanner

"ត្រូវធ្វើជាមួយគ្នា"

"អាមនុស្សបោកប្រាស់!"

"ដេរឲ្យវាត្រូវសាច់រឿងបន្តិច ពៅព្រលឹង អ្នកណាឲ្យប្រាកដទៅដែលបោកប្រាស់"

សាន់នី ខ្ចីបបបូរមាត់ណែន មើលគេដោយអារម្មណ៍តានតឹង។ គេដឹងតែមិនប្រាប់ ថែមទាំងប៉ះពាល់នាង ធ្វើដាក់នាងគ្រប់សារពើ គេធ្វើបែបនោះព្រោះដឹងថាជានាងនេះឯង អាមនុស្សអាក្រក់។

"លោកដឹងគ្រប់រឿង"

"សាន់នី នាងឡូឡាធ្វើអី ខ្ញុំបង្គាប់ឲ្យនាងបន្លំខ្លួនឡើងមកលើកោះឬយ៉ាងម៉េច"

"មិនមែនទេ តែបើលោកដឹង លោកគួរតែប្រាប់ខ្ញុំ មិនមែនបណ្ដោយឲ្យខ្ញុំធ្វើខ្លួនល្ងង់ៗ បែបនេះ"

"នាងចង់ល្ងង់ធ្វើអី"

"អាមនុស្សមាត់ដាច"

"មានកញ្ចក់ ក៏ឆ្លុះសាកមើលទៅ មុខរបស់នាងទាំងស្អាត ទាំងស្រស់រាងរៅបែបនេះ អ្នកណាគេជឿថានាងជាមនុស្សប្រុស ខ្ញុំមិនហាមឃាត់ ព្រោះ



Scanned by CamScanner

មិនដឹងថានាងធ្វើដើម្បីអី"

"ទោះយ៉ាងណាលោកគួរតែប្រាប់ខ្ញុំ"

"កុំគ្មានហេតុផលពេក សាន់នី"

"ខ្ញុំគ្មានហេតុផល ?"

"កុំឲ្យខ្ញុំអស់ការអត់ធ្មត់ទៅលើនាង"

សេត ចុះពីគ្រែ ពេល សាន់នី និយាយមិនចេះស្តាប់គ្នា ហើយគេក៏មួម៉ៅដល់ថ្នាក់មិនចង់នៅជិតនាង នាងអាចរំខានអារម្មណ៍ ធ្វើឲ្យគេបាត់បង់ការគ្រប់គ្រងខ្លួនឯង។

"រម្ងាប់អារម្មណ៍ទៅ"

"ខ្ញុំនឹងចាកចេញពីទីនេះ"

"បើមានសមត្ថភាពហែលទឹកឡើលគោកដោយខ្លួនឯងទៅ"

នាងខឹងឡើងក្តៅគគុក ក្រៅពីនេះនៅអាម៉ាស់មុខទៀតផង អាម៉ាស់ដែលបង្ហាញឲ្យឃើញពីតម្រូវការដែលមានចំពោះគេ សេត បង្វិលខួរនាងឡើងវិលខ្វាល់តែម្តង។

"ខ្ញុំច្បាស់ជាធ្វើ"

"បើចង់ងាប់ធ្វើទៅ អញ្ជើញ!"





Scanned by CamScanner

សេត ស្រែកគំហក ធ្វើឲ្យនាងភ្ញាក់ព្រើត ស្រវាចាប់ភួយដែលទាញមកឃ្លុំខ្លួនជាប់ ហើយគេក៏ដើរទៅទាញអាវឃ្លុំមកពាក់។

"ខ្ញុំចង់ស្លាប់ ខ្ញុំមិនចង់ឃើញមុខលោក"

"អីចឹងផង ថ្នាក់មិនចង់ឃើញមុខខ្ញុំនៅអ៊ែនមករក ថ្ងូរឡើងស្តាប់មិនយល់ទៅហើយ"

"អាមនុស្សហេងស៊យ"

"កុំមកឈ្លើយដាក់ខ្ញុំ សាន់នី ខ្ញុំមិនចូលចិត្តមនុស្សស្រីគ្មានមារយាទ"

"លោកបោកប្រាស់ខ្ញុំ"

"ឈប់ត្អូញត្អែរគ្មានបានការទៅ នាងធំហើយមិនមែនកូនក្មេងទេ ហើយបើនាងចេះពិចារណារកហេតុផល ខ្ញុំមិនបានចាប់ផ្តើមរឿងនេះទេ ខ្ញុំគ្រាន់តែចាក់បណ្តោយតាមនាងត្រូវការ"

"ទោះយ៉ាងណាក៏លោកខុស ដែលបោកខ្ញុំ"

"បើនាងគិតបែបហ្នឹងហើយធ្វើឲ្យនាងសប្បាយចិត្តក៏អញ្ជើញ តែខ្ញុំនៅតែបញ្ជាក់ដដែល បើនាងចង់ចាកចេញពីទីនេះត្រូវហែលទឹកទៅដោយខ្លួនឯង ហើយនាងកុំភ្លេចថានាងមិនបាននៅលើកោះនេះម្នាក់ឯងទេ នាងមានប្អូនស្រីម្នាក់ទៀត"



Scanned by CamScanner

នាងភាំងនឹងការបញ្ជាក់របស់គេ ព្រោះគេមិនត្រឹមតែចាំនាងបាននោះទេ នៅចាំប្អូនស្រីរបស់នាងបានទៀតផង។

"ពេលនេះប្អូនស្រីរបស់នាងប្រហែលមិនចង់ហែលទឹក ទៅធ្វើជាខ្មោចជាមួយនាងទេ បើចង់ដឹងថាព្រោះស្អី ឲ្យអ្នកបម្រើនាំទៅផ្ទះរបស់ គ្រីស ទៅ ធុញណាស់ ស្រីគ្មានហេតុផល"

"ហ៊ឺ!"

សេត ទៅងូតទឹកនៅបន្ទប់ផ្សេង ដោយឲ្យអ្នកបម្រើយកសម្លៀកបំពាក់នៅក្នុងបន្ទប់ដេកមកឱ្យ ហើយផ្លាស់ឈុតថ្មី ដើរចេញមក ប៉ុន្តែបែរជាជួបនឹងបុរសដ៏ខ្ពង់ខ្ពស់ អង្គុយជិបតែនៅលើសាឡុងក្នុងបន្ទប់ទទួលភ្ញៀវ។

"ប៊ុនភ្ញាក់មែន"

"ព្រះអង្គម្ចាស់ ហ្គាវៀន"

សេត ឱនគំនាប់ព្រះអង្គម្ចាស់ ហើយងាកទៅបញ្ជាអ្នកបម្រើ ឲ្យចេញឆ្ងាយពីបន្ទប់ទទួលភ្ញៀវ ហើយគេក៏ដើរធ្វើមុខក្រមូវទៅទម្លាក់គូទលើសាឡុងលាន់ទឹះតែម្តង។

"ឯងមកធ្វើអី ?"





Scanned by CamScanner

"មកបំពេញធុរៈ"

"មករកលោកប៉ា ?"

"មែន មានការងារត្រូវនិយាយតិចតួច និយាយរួចហើយក៏មករកឯង"

"ខ្ញុំកំពុងមួម៉ៅ ប៉ុន្តែឯងមកក៏ល្អដែរ ឲ្យខ្ញុំមានអ្នកកំដរនិយាយ"

"សរុបទៅវត្តមានរបស់ខ្ញុំល្អ ឬមិនល្អ ?"

"បើមិនបូករួមសំឡេងត្រជាក់ដូចខ្មោចឆៅរបស់ឯង គ្រប់យ៉ាងវាអូខេសឹងតែឥតខ្ចោះ"

ព្រះអង្គម្ចាស់ ហ្វារៀន ស្តាប់ដោយទឹកមុខស្មើ។ សេត មិនភ្ញាក់ផ្អើលទេដែលបងប្អូនជីដូនមួយដ៏ខ្ពង់ខ្ពស់របស់គេ អង្គុយធ្វើមុខស្មើបែបនេះ ព្រោះគេស៊ាំនឹងភ្នំទឹកកកដើរបានមួយនេះហើយ។

"វាជាបញ្ហាដែលឯងត្រូវដោះស្រាយដោយខ្លួនឯង ខ្ញុំមានសេចក្តីសុខនឹងសំឡេងរបស់ខ្ញុំហើយ"

"សុំទោស ដែលចេះដឹង"

"មិនអីទេ"

"ហេ៎ ! ឯងមកបេះបួយអារម្មណ៍ខ្ញុំម្នាក់ទៀតឬយ៉ាងម៉េច"

"អ្នកមុននេះគឺសុភាពនារី ដែលឯងឈ្លោះជាមួយឬ"



Scanned by CamScanner

"បានឮ?"

"ចៃដន្យ"

សេត ដកដង្ហើមធំ។ គេមិនចង់និយាយស្ដីខ្លាំងៗដាក់នាង តែ សាន់នីគ្មានហេតុផលពេកហើយ នាងខឹងនឹងរឿងដែលមិនសមជារឿងដើម្បីអី ការពិតលាតត្រដាងក៏ល្អទៅហើយ ឲ្យនាងបានធ្វើជាមនុស្សស្រីវិញពេញលក្ខណៈ មិនចាំបាច់លំបាកបន្លំខ្លួន ដោយមិនទំនងអីបែបនោះទៀត។

"មនុស្សស្រីជាភេទដែលមាត់ក្បត់ចិត្ត ឯងជឿទេ ពេលបណ្ដេញ យើងទៅមែនទែនក៏ខឹង ប្រាប់ថាមិនបាច់មករវល់ តែក៏រង់ចាំឲ្យលួង ហើយបញ្ជូនសញ្ញាលួងខ្ញុំឥឡូវនេះ មិនលួង កាន់តែបញ្ចេញរស្មីខឹងសម្បាចេញពីខ្លួន"

"ឯងរអ៊ូឲ្យខ្ញុំស្ដាប់មែនទេ"

"អឺ! ស្ដាប់ទៅ"

"ឯងមានន័យដល់អ្នកណា?"

"ប្រពន្ធខ្ញុំហ្នឹងអី"

"មានប្រពន្ធហើយឬ?"

ពេលគេងក់ក្បាលបញ្ជាក់ ព្រះអង្គម្ចាស់ ហ្វារៀន ក៏ស្ដាប់ដោយមិនបង្ហាញអាការៈភ្ញាក់ផ្អើល ទើបគេក៏លូកដៃទៅរក។





Scanned by CamScanner

"ផឹកបន្តិចមក ចង់ឲ្យចិត្តត្រជាក់"

"ទឹកតែក្តៅ កាន់តែធ្វើឲ្យចិត្តឯងក្តៅ អីចឹងហើយមិនបាច់ទេ"

ព្រះអង្គម្ចាស់បដិសេធការចែករំលែក សេត ក៏មើលមកដោយងឿងឆ្ងល់ហេតុអីក៏គេផឹកមិនបាន ត្រង់មនុស្សឈាមត្រជាក់នៅផឹកតែក្តៅបាន។

"គំរិះមែន ខ្ញុំជាម្ចាស់ផ្ទះ"

"តែខ្ញុំជាម្ចាស់ប្រទេស"

"យីះ! គំរាមអញទៀត អី! ព្រមក៏បានដែរ"

សេត រអ៊ូរទាំដោយអារម្មណ៍ក្តៅគគុក ភាគតិចណាស់ដែលគេបង្ហាញអារម្មណ៍បែបនេះឲ្យឃើញ តែងតែបញ្ជាក់ថាស្ត្រីម្នាក់នោះមានឥទ្ធិពលចំពោះសេត មិនតិចទេ ហើយ សេត ដល់ថ្នាក់ហៅថា **ប្រពន្ធ** គឺដឹងតែប្រាកដប្រជា។

"ឯងលួងប្រពន្ធឯងយ៉ាងម៉េច?"

"ហេតុការណ៍កើតឡើងដោយសារការចាប់សង្កត់ ហើយបើឲ្យលួង គឺត្រូវចាប់សង្កត់ទៀត"

ព្រះអង្គម្ចាស់ ហ្គារៀន ទប់ដៃដែលកំពុងលើកតែផឹក ដៀងភ្នែកមើលសេត បន្តិច ហើយគ្រវីក្បាលតិចៗ ហើយជិបតែបន្ត។

"ឯងកុំមើលមកខ្ញុំ ដូចខ្ញុំជាមនុស្សល្ងង់បានទេអម្ចាស់"



Scanned by CamScanner

"មិនត្រឹមតែដូចទេ"

"ឯងមានន័យថាម៉េច ?"

"តែល្បង់មែន"

"ឯងមិនបាច់ធ្វើសំឡេងឡកឡឺយខ្ញុំទេ មនុស្សស្រីត្រូវការអីណាស់ណា នាងសំណាងល្អប៉ុនណាហើយ ដែលបានខ្ញុំជាប្ដីសង្ហា មានប្រាក់ មន្តស្នេហ៍ និងមានអំណាច ងរគ្មានប្រយោជន៍អីសោះ ខ្ញុំធុញទ្រាន់រើយ ខ្ញុំមានការងារធ្វើច្រើនណាស់ ងរឲ្យវាល្មមៗ ខ្ញុំគ្មានពេលលួងទេ"

សេត ចាត់ចែងខ្លួនឯងជាស្វាមីរបស់ សាន់នី រួចរាល់ នាងព្រមទទួលឬអត់គេមិនខ្វល់ ហើយទោះនាងបដិសេធទាល់តែស្ដឹកមាត់ ក៏នៅតែញាត់ញៀតឲ្យនាងព្រមទទួលឲ្យបានដដែល។

"សេត"

"ស្អី ?"

"ឯងគួរទុកចំណុចល្អខ្លះឲ្យអ្នកដទៃសរសើរឯងខ្លះផង"

"មិនអីទេ ខ្ញុំសរសើរខ្លួនឯងបាន ខ្ញុំដឹងថាខ្ញុំមានរបស់ល្អច្រើន"

"បើគិតថាល្អ អ៊ីចឹងធ្វើបន្តទៅ"

"ឯងមិនជួយខ្ញុំគិតបន្តិចទេឬ"





Scanned by CamScanner

"គិតស្អី?"

"ល្អងស្រី"

"ទៅធ្វើចិត្តឲ្យត្រជាក់សិនទៅ"

"ចេះនិយាយលេងទៅកើត ហើយអ្នកណាស្វាគមន៍ឯង"

ព្រះអង្គម្ចាស់ ហ្គាវៀន មិនត្រូវការឲ្យ សេត មកស្វាគមន៍ ព្រោះទ្រង់អាចមើលថែខ្លួនឯងបាន យ៉ាងហោចណាស់ ប្រសើរជាងត្រូវអង្គុយស្ដាប់ សេត ប៉ប៉ាច់ប៉ប៉ោចរឿងគ្មានបានការ។

"ខ្ញុំស្វាគមន៍ខ្លួនឯងបាន"

"ដេកទេ?"

"ដេកមួយយប់ទៅចុះ"

"អូខេ អ៊ីចឹងខ្ញុំទៅរម្ងាប់អារម្មណ៍ ហើយពេលមានអារម្មណ៍ល្អចាំខ្ញុំមកស្វាគមន៍ឯងវិញ"

"ខ្ញុំរំភើបណាស់"

ព្រះអង្គម្ចាស់ងក់ក្បាលបន្តិចដាក់ ទើបម្ចាស់ផ្ទះដើរចេញពីទីនេះ ទៅធ្វើការងារស្អីក៏ដោយ ដែលធ្វើឲ្យបែកញើស ដើម្បីជាការកម្ចាយអារម្មណ៍។



Scanned by CamScanner

"អឺ..."

សាន់នី ដើរទាំងមុខក្រហមងាំងចេញមក ហើយភ្ញាក់ព្រើត ពេលជួបបុរសដែលមិនធ្លាប់ស្គាល់នៅក្នុងបន្ទប់ទទួលភ្ញៀវ ខណៈដែលព្រះអង្គម្ចាស់ហ្គាវៀន គិតថាពីរនាក់នេះដូចគ្នាមែនទែន។

*ភ្ញាក់ព្រោះយើងធ្វើអី!*

"សួស្ដី"

ព្រះអង្គម្ចាស់ងើបឈរ ទើបនាងដើរទៅរក។

"លោកជាភ្ញៀវរបស់លោក សេត ឬ?"

"យើងព្រះអង្គម្ចាស់ ហ្គាវៀន ម៉ាលខៃសេនតេ ជាបងប្អូនជីដូនមួយរបស់ សេត អញ្ជើញនាងធ្វើខ្លួនតាមធម្មតា"

សាន់នី ស្ទើរតែទន់ជង្គង់ ពេលបានឮការណែនាំខ្លួនបែបនេះរបស់បុរសនៅចំពោះមុខ។

"ខ្ញុំម្ចាស់ សាន់នី សូមថ្វាយបង្គំព្រះអង្គម្ចាស់"

"ដោយក្ដីរីករាយ ធ្វើខ្លួនតាមធម្មតាទៅ ផឹកទឹកតែជាមួយគ្នាទេ?"

"អឺ...អរគុណព្រះពរ"

"អញ្ជើញអង្គុយ"





Scanned by CamScanner

ព្រះអង្គម្ចាស់ងាដៃឲ្យអង្គុយ និងចាក់ទឹកតែ ហុចឲ្យដោយកាយវិការសុភាពបុរស នាងក៏ប្រញាប់លូកដៃទទួលយក។

"នាងរើសអើងទេ បើយើងនិយាយគ្នា"

"ដោយក្តីរីករាយព្រះអង្គម្ចាស់"

"មានកិត្តិយសណាស់ ដែលបាននិយាយជាមួយនាង និងជារឿងល្អដែល សេត មិននៅទីនេះ នៅពេលនេះ"

"ព្រះពរ"

នាងក្រេបទឹកតែ ហើយដាក់វាលើភ្លៅ ដោយក្រសោបនឹងដៃទាំងពីរ មើលបុរសខ្ពង់ខ្ពស់នៅចំពោះមុខ ដោយអារម្មណ៍ញាប់ញ័រនឹងឋានៈរបស់គេ។

"នាងត្រូវជាស្ដីនឹង សេត ?"

"ខ្ញុំគ្រាន់តែជាស្រីល្ងង់ដែលត្រូវគេបោកប្រាស់"

"នាងមិនពេញចិត្តនៅទីនេះ ?"

"ខ្ញុំម្ចាស់ចង់ចេញពីទីនេះ ប៉ុន្តែគេប្រាប់ឲ្យខ្ញុំម្ចាស់ហែលទឹកទៅគោកដោយខ្លួនឯង"

"អឺចឹងឬ មើលទៅដូចនាងមិនពេញចិត្តមក"

ព្រះអង្គម្ចាស់ នៅតែនិយាយមួយៗ ខណៈនោះក៏មើលមនុស្សស្រីនៅ



Scanned by CamScanner

ចំពោះមុខ។ នាងស្អាតខ្លាំងណាស់ ប៉ុន្តែទ្រង់មិនរំភើបញាប់ញ័រនឹងសម្រស់នោះ ទ្រង់មានមនុស្សស្រីឲ្យជ្រើសរើសដេកជាមួយនៅក្នុងហារ៉េមរាប់រយនាក់ ទើបសម្រស់របស់នាងមិនអាចទាក់ទាញចំណាប់អារម្មណ៍របស់ទ្រង់បាន។

"ខ្ញុំម្ចាស់ចង់ចេញពីទីនេះ ចង់គេចទៅឲ្យផុត"

"សេត ប្រាប់យើងថានាងជាភរិយារបស់គេ"

"មិនមែនទេ!"

"ហ្នឹងហើយ ខ្ញុំជឿហើយថាមិនមែន"

ព្រះអង្គម្ចាស់ ហ្វាវៀន ងក់ក្បាល ហើយមានចេតនាមើលនាងតាំងពីក្បាលដល់ចុងជើង មើលឲ្យដឹងថាមើល និងពិចារណា ឲ្យនាងបុកពោះ ថ្ពាល់ឡើងក្រហមងាំង ព្រោះមានអារម្មណ៍ដូចខ្សែភ្នែកមុតស្រួចមួយគូនោះ កំពុងប្រមាថមើលងាយនាង។

"សុភាពនារីដែលមិនចេះទុកមុខឲ្យ សេត មិនសក្តិសមនឹងធ្វើជាភរិយារបស់គេទេ"

"មិនទុកមុខ?"

"សេត ជាម្ចាស់តូចរបស់កោះចោរ គេជាអនាគតប្រមុខកោះចោរ ជាប់សាច់ឈាមនឹងរាជ្យវង្ស ម៉ាលខៃសេនតេ សុភាពនារីដែលជាភរិយារបស់គេ





Scanned by CamScanner

ត្រូវតែមិនបំបាក់មុខគេនៅចំពោះមុខអ្នកដទៃ ចេះផ្តល់កិត្តិយស មិននិយាយផ្តេសផ្តាស រៀបចំខ្លួនឲ្យសក្តិសម ប៉ុន្តែនាងគ្មានគុណសម្បត្តិទាំងនោះ"

ព្រះអង្គម្ចាស់និយាយត្រង់ៗ និងសម្លឹងមើលមុខនាងចំៗ ដែលធ្វើឲ្យសាន់នី កាន់តែមើលឃើញការប្រមាថមើលងាយ នៅក្នុងកែវភ្នែករបស់ទ្រង់បានច្បាស់។

"អ្វីដែលនាងមាននៅក្នុងកម្រិតលេចធ្លោ គឺសម្រស់ ដែលកម្ររកស្រីណាមកប្រៀបធៀបបាន"

"ខ្ញុំ...ខ្ញុំម្ចាស់..."

"ដឹងទេ សម្រាប់មនុស្សប្រុសដែលនៅថ្នាក់គ្រប់គ្រង មនុស្សស្រីស្អាតតែគ្មានខួរក្បាល គ្មានប្រយោជន៍អី ក្រៅពីទុកនៅជិតខ្លួនដើម្បីរកសេចក្តីសុខប៉ុន្តែបើជាភរិយា មិនចាំបាច់ស្អាតក៏បានដែរ ត្រឹមធ្វើខ្លួនឲ្យសក្តិសម និងមានខួរក្បាល ប៉ុណ្ណឹងគឺគ្រប់គ្រាន់ហើយ"

"ទ្រង់ថាខ្ញុំម្ចាស់គ្មានខួរក្បាលឬ?"

"មនុស្សស្រីដែលមិនចេះទប់អារម្មណ៍ ចូលចិត្តបញ្ចេញកំហឹង ប្រកាសឲ្យមនុស្សទូទាំងពិភពលោកដឹងថាកំពុងឈ្លោះនឹងស្វាមី មនុស្សស្រីបែបហ្នឹងមានតែធ្វើឲ្យ សេត រងការប្រមាថ ហើយយើងសរសើរ ថានាងជាមនុស្សមាន



Scanned by CamScanner

ខួរក្បាល គឺមិនសក្តិសមទេ"

"តែ សេត បោកប្រាស់ខ្ញុំម្ចាស់"

"នោះជារឿងដែលនាងត្រូវចាត់ការ សេត ជម្រះបញ្ហាតែពីរនាក់ យើងទើបតែជួបគ្នាលើកដំបូង នាងក៏និយាយពីគេ ដោយមិនរក្សាកិត្តិយស រឿងរូបភាពសំខាន់ខ្លាំងណាស់សម្រាប់ថ្នាក់គ្រប់គ្រង"

"ខ្ញុំ...ខ្ញុំម្ចាស់..."

"នាងនឹងធ្វើឲ្យ សេត រងការប្រមាថដោយអាកប្បកិរិយាគ្មានការអប់រំរបស់នាង"

"ខ្ញុំម្ចាស់សូមថ្វាយបង្គំលា"

"ឈប់! អង្គុយចុះ" ព្រះអង្គម្ចាស់ ងើបឈរ ឃាត់ដំណើរនាង។

សាន់នី ទ្រាំស្តាប់លែងបានតទៅទៀត ទោះសម្តីរបស់ព្រះអង្គម្ចាស់លេងឈឺៗ ប៉ុន្តែនាងមិនអាចតបតបាន ព្រោះវាគឺជាការពិត ហើយពេលទ្រង់ចេញបញ្ជាពេលដែលនាងងើបឈរ ក៏ធ្វើឲ្យនាងទន់ជង្គង់ ដួលខ្ពោកតែម្តង។

"បើនាងចង់ចេញពីទីនេះ មិនបាច់ហែលទឹកទេ យើងនឹងនាំនាងចេញ"

"ទ្រង់ត្រូវការឲ្យខ្ញុំម្ចាស់ចាកចេញពី សេត តែខ្ញុំម្ចាស់គ្មានអ្វីសក្តិសមនឹងគេទេ"



"នាងធ្វើការអី មកពីណា?"

"បើធ្វើឲ្យទ្រង់មានសេចក្ដីសុខ ដែលបានប្រមាថខ្ញុំម្ចាស់ ខ្ញុំម្ចាស់ធ្លាប់ធ្វើការនៅរោងរបាំស្រោត ណាខាដៀ"

"បែបនេះ គឺកាន់តែត្រូវគិតឲ្យម៉ត់ចត់ បើថ្ងៃមួយប្រវត្តិរបស់នាងត្រូវគាស់កកាយ នាងគិតថា សេត ទប់ទល់នឹងរឿងអាស្រូវដែលកើតឡើងដោយរបៀបណា ភរិយាដែលកើត និងធំធាត់នៅរោងរបាំស្រោត"

សម្ដីសោះកក្រោះរបស់ព្រះអង្គម្ចាស់ជាងពីកាំបិតមុតស្រួច ដែលកំពុងចាក់បេះដូងរបស់នាងសន្សឹមៗ។ រឿងដែលនាងភ័យខ្លាចកំពុងតែកើតឡើងហើយ នាងនិង សេត មិនសក្តិសមនឹងគ្នាអីបន្តិច គេមិនមែនជាបុរសធម្មតាប៉ុន្តែគេជាអនាគតប្រមុខកោះចោរ ជាសាច់ញាតិរបស់រាជវង្សដ៏ខ្ពង់ខ្ពស់នៃប្រទេសសាក់ខាវៀ។ ប្រវត្តិរបស់នាងនឹងធ្វើឲ្យគេមានបញ្ហា ទាញគេទម្លាក់ពីទីខ្ពស់មកកាន់ទីទាប។

សាន់នី ដ៏រឹងមាំធ្លាប់គិតថាខ្លួនឯងជាមនុស្សបែបហ្នឹង ប៉ុន្តែពេលនាងកំពុងតែបង្ហាញឲ្យឃើញភាពទន់ជ្រាយ។

ជង្គង់ដែលបុកនឹងកម្រាលលែងឈឺហើយ ព្រោះពេលនេះបេះដូងរបស់នាងឈឺជាង ដៃទាំងពីរញ័រទទ្រើត ទ្រានកម្រាលដែលក្រាលដោយព្រំតម្លៃថ្លៃ



Scanned by CamScanner

នៅចំពោះមុខនាង ដែលមើលឃើញដោយភ្នែកស្រវាំង គឺស្បែកជើងពណ៌ខ្មៅខាត់ចាំងស្រមោលរបស់ព្រះអង្គម្ចាស់ដ៏ខ្ពង់ខ្ពស់។

"តែខ្ញុំម្ចាស់ស្រឡាញ់ សេត"

"ពាក្យថាស្រឡាញ់ អ្នកណាក៏និយាយបានដែរ ប៉ុន្តែបើវាជាស្នេហាពិតគឺត្រូវតែស្រឡាញ់ឲ្យត្រឹមត្រូវ"

"ធ្វើឲ្យត្រឹមត្រូវ ?"

"នាងមិនទាំងដឹងវិធីប្រណិប័តន៍ខ្លួនឲ្យសក្តិសមផង"

ព្រះអង្គម្ចាស់ត្បកមកវិញដោយភាពសោះកក្រោះ នាងក៏ក្តាប់ដៃណែនបណ្តោយឲ្យទឹកភ្នែកហូររហាម។

"យើងនឹងចាកចេញពីកោះនេះ នៅថ្ងៃស្អែក ម៉ោងប្រាំបួនព្រឹក បើនាងត្រូវការទៅជាមួយ ទៅរកយើងនៅទីលានឧទ្ធម្ភាគចក្រ គ្មានអ្នកណាឃាត់នាងបានទេ សូម្បីតែ សេត"

"ខ្ញុំម្ចាស់ត្រូវធ្វើដើម្បីគេមែនទេ ?"

"នាងកំពុងតែនាំខ្លួនឯងចេញឲ្យឆ្ងាយពីប្រធានបទសន្ទនាហើយ តែយើងមិនអធិប្បាយទេ នាងត្រូវចាត់ការគំនិតរបស់នាងដោយខ្លួនឯង បើនាងឆ្លាត នាងនឹងគិតឃើញ ហើយដឹងថាគួរធ្វើយ៉ាងណា"





Scanned by CamScanner

"ព្រះពរ"

"មិនសប្បាយចិត្តទេឬ ដែលបានចាកចេញពី សេត តាមការទាមទារ"

"មិនសប្បាយចិត្តទេ"

"នាងចង់ចាកចេញពីគេ និងបដិសេធទៀតថានាងមិនមែនជាភរិយារបស់គេ ទាំងដែល សេត ណែនាំនាងដោយការផ្តល់កិត្តិយស និងត្រូវការការពារនាង"

សាន់នី អណ្តឹតអណ្តក ព្រះអង្គម្ចាស់ ហ្គាវៀន ក៏ដើរទៅដាក់បង្កុយលើសាឡុងវិញ និងសម្លឹងមើលនាងដោយខ្សែភ្នែកសោះកក្រោះ។

"ពេលនេះខ្ញុំម្ចាស់ឈឺចាប់ ហើយខ្ញុំម្ចាស់ក៏មិនយល់ ហេតុអីខ្ញុំម្ចាស់ត្រូវទូលទ្រង់ថាខ្ញុំស្រឡាញ់គេ ទាំងដែលខ្ញុំម្ចាស់មិនធ្លាប់ប្រាប់គេ"

"ព្រោះនាងមានគំនិតមានះបែបមនុស្សល្ងង់នោះអី យកពេលយំយែកទៅគិតរឿងដែលគួរគិតទៅ ឬមិនអីចឹងត្រៀមខ្លួនរៀបចំខោអាវ ព្រោះយើងមិនរង់ចាំទេ បើនាងខកណាត់ នាងត្រូវរកវិធីចាកចេញពីកោះនេះដោយខ្លួនឯង"

"ព្រះពរ"

សាន់នី ទ្រានដៃងើបឈរ ហើយដើរទ្រេតទ្រោតចេញពីបន្ទប់ទទួលភ្ញៀវដោយមានព្រះអង្គម្ចាស់តាមមើលទាល់តែបាត់ពីភ្នែក។



Scanned by CamScanner

"ស្ត្រីដែលល្ងង់ខ្លៅមិនសក្តិសមនឹង សេត ទេ"

ព្រះអង្គម្ចាស់ ហ្គារៀន លើកតែជិបឲ្យប្រហើរ ធ្វើហាក់ដូចអម្បាញ់មិញ មិនបានធ្វើឲ្យមនុស្សស្រីម្នាក់យំយែក។

**សាន់នី ធ្វើដំណើរទៅផ្ទះរបស់ គ្រីស ដោយពឹងឲ្យអ្នកបម្រើជូនទៅ** ដែលអ្នកបម្រើនៅទីនេះទទួលបានការអប់រំល្អណាស់ ទោះមានការងឿងឆ្ងល់ ដែលនាងក្លាយជាមនុស្សស្រី តែមិនសួរនាំឬបង្ហាញអាការៈភ្ញាក់ផ្អើល។

អ្នកបម្រើជូននាងទៅផ្ទះរបស់ គ្រីស តែមិនទាន់ទៅដល់ផង ត្រឹមឈរ មើលពីត្រង់នេះ មើលឃើញភាពស្រស់ស្រាយរបស់ប្អូនស្រី ដែលតែងខ្លួន ដោយអាវដៃតុក្កតា មានរំជរ មានរំភាយ ស្លៀកសំពត់វែង នោះមានន័យថា ធីណា មិនបានបិទបាំងអត្តសញ្ញាណរបស់ខ្លួនចំពោះ គ្រីស។

"បង សាន់នី!"

ប្អូនស្រីងាកមកឃើញ ក៏ដាក់ការងារនៅក្នុងរងផ្កាចោល ងើបឈរជូតដៃ នឹងសំពត់ ហើយរត់មករក។

"ទៅវិញមុនក៏បាន"



សាន់នី ងាកទៅប្រាប់អ្នកបម្រើ ហើយដើរទៅរកប្អូនស្រី ដែលពេលទៅ



Scanned by CamScanner

ដល់ក៏ត្រូវ ធីណា ត្រួតពិនិត្យហើយស្រវាឱប។

"ម៉េចក៏ភ្នែកហើម បងឈ្លោះនឹងលោកបងថ្លៃឬ?"

"មិនមែនទេ បងមើលកុន វាសោកសៅ"

"ខ្ញុំមិនចូលចិត្តមើលកុនសោកសៅទេ ចូលទៅក្នុងផ្ទះទៅ"

"ធីណា តែងខ្លួនជាស្រីវិញតាំងពីពេលណា?"

"មួយរយៈហើយ"

ធីណា ចាប់ដៃបងស្រី ដើរចូលទៅក្នុងផ្ទះ ហើយដើរទៅចាក់ទឹកដាក់កែវមកឲ្យ និងដាក់បង្អួយក្បែរ។

"បង សាន់នី ខ្ញុំនិង គ្រីស ស្រឡាញ់គ្នា ហើយយើងក៏រស់នៅជាមួយគ្នាបែបស្វាមីភរិយា បងមិនខឹងខ្ញុំទេ មែនទេ?"

ពេលមានឱកាសបានជួបគ្នា ក៏ត្រូវប្រាប់ការពិត សាន់នី ក៏ញញឹមដាក់ប្អូនស្រី ឃើញ ធីណា មានសេចក្តីសុខដល់ថ្នាក់នេះ នាងថាអីបានទៅ។

"បងមានតែអបអរ"

"បង សាន់នី យើងនៅទីនេះរហូតទៅ ខ្ញុំនឹងមានកូនជាមួយ គ្រីស ហើយបង្កើតក្រុមគ្រួសារជាមួយគ្នា ចំណែកបងបានបង្កើតក្រុមគ្រួសារជាមួយលោកបងថ្លៃ"



Scanned by CamScanner

"ចេះដឹងរឿងគេមែន"

"ខ្ញុំចង់ឲ្យបង សាន់នី មានសេចក្តីសុខហ្នឹងណា បង សាន់នី ខ្ញុំដឹងថា បងស្រឡាញ់លោកបងថ្លៃ ដំបូងខ្ញុំក៏មិនដឹងដែរ ប៉ុន្តែពេលខ្ញុំស្រឡាញ់ គ្រីស ទើបខ្ញុំយល់ពីបង"

"ក្លាយជាក្មេងចេះដឹងទៅហើយ"

"ខ្ញុំបារម្ភពីបង បងសក្តិសមនឹងលោកបងថ្លៃណាស់ មិនមែនដោយសារ បងស្អាត លោកបងថ្លៃសង្ហា ប៉ុន្តែព្រោះអ្នកទាំងពីរស្រឡាញ់គ្នា"

"តែគេខុសពីបងឆ្ងាយណាស់ ធីណា"

សាន់នី ជាមនុស្សដែលពន់រែកបញ្ហា ចាំការពារប្អូនស្រី តែថ្ងៃនេះនាង ដូចមករៀបរាប់ទុក្ខសោកដាក់ប្អូនស្រីទៅវិញ។

"ស្នេហា ការយល់ និងការផ្តល់កិត្តិយសឲ្យគ្នាទៅវិញទេ ដែលសំខាន់ បើលោកបងថ្លៃជ្រើសរើសបង ហើយបងធ្វើឲ្យខ្លួនឯងនិងលោកបងថ្លៃខូចចិត្ត ដោយការសម្រេចចិត្តត្រឹមរឿងសក្តិសមឬមិនសក្តិសមនោះ បើជាខ្ញុំ ខ្ញុំគ្រាន់តែ ធ្វើខ្លួនឯងឲ្យសក្តិសមនឹងគេ មើលថែគេ ទោះជារឿងពិបាក តែខ្ញុំនឹងព្យាយាម ដូចពេលនេះ ខ្ញុំធ្វើបានច្រើនហើយ"

"ពូកែណាស់"





Scanned by CamScanner

"ព្រោះខ្ញុំតាំងចិត្ត ខ្ញុំចង់ធ្វើជាភរិយាល្អរបស់ គ្រីស មិនឲ្យគេអាម៉ាស់មុខ តែពេលខ្លះ យើងក៏មានរឿងឈ្លោះគ្នា គេចូលចិត្តស្តីឲ្យខ្ញុំ ប៉ុន្តែនៅចំពោះមុខអ្នកដទៃខ្ញុំព្រមថយឲ្យគេ ហើយចាំមកឯងរគេពេលយើងតែពីរនាក់"

ពិភពរបស់ សាន់នី ត្រូវបើកចំហ ដោយប្អូនស្រីដែលធ្លាប់តែមិនដឹងខ្យល់អី។

"បើយើងនៅតែពីរនាក់ គេនឹងលួងខ្ញុំ តែបើនៅចំពោះមុខអ្នកដទៃ គេប្រហែលមិនលួងទេ តែខ្ញុំមិនធ្លាប់សាកល្បង ខ្ញុំមិនចង់ធ្វើឲ្យគេអាម៉ាស់មុខ គេជាស្វាមីរបស់ខ្ញុំ ខ្ញុំត្រូវតែផ្តល់កិត្តិយសឲ្យគេ"

"ឯងធ្វើត្រូវហើយ"

"ខ្ញុំចង់ប្រាប់បង រឿងរបស់ខ្ញុំនិងគេ តែយើងមិនទាន់មានឱកាសបានជួបគ្នា ពេលបានប្រាប់ហើយ ខ្ញុំក៏សប្បាយចិត្ត"

"ត្រឹមឯងមានសេចក្តីសុខទៅ គ្រប់គ្រាន់ហើយ"

"ខ្ញុំក៏ចង់ឲ្យបងមានសេចក្តីសុខដែរ ពួកយើងមិនតូចទាបជាងអ្នកណាទេ គ្រាន់តែយើងគ្មានឱកាសជ្រើសរើសកើតមកជាអ្នកមានប៉ុណ្ណោះ ប៉ុន្តែយើងមិនធ្លាប់ធ្វើបាបអ្នកណា បងស្រីរបស់ខ្ញុំជាមនុស្សល្អណាស់ ការពារខ្ញុំ ធ្វើឲ្យខ្ញុំមានរបស់ដែលគួរហួងហែងជាប់ខ្លួន ទុកឲ្យអ្នកដែលខ្ញុំស្រឡាញ់"



Scanned by CamScanner

"មុខមាត់ស្រស់ស្រាយដល់ហើយ"

"ខ្ញុំចូលចិត្តនេះនោះជាមួយ គ្រីស ហត់នឿយ តែមានសេចក្តីសុខ"

"ធីណា ព្រើលណាស់"

"ខ្ញុំចូលចិត្ត ខ្ញុំក៏ប្រាប់ ហើយខ្ញុំក៏ប្រាប់បងស្រី មិនមែនអ្នកដទៃឯណា គ្រីស ក៏ខ្ញុំប្រាប់ ខ្ញុំមិនចង់ធ្វើឫកដាក់អ្នកដែលខ្ញុំស្រឡាញ់ និងស្រឡាញ់ខ្ញុំ"

សាន់នី និយាយជាមួយប្អូនស្រីយូរគួរសម ទើបត្រឡប់ទៅវិញ។

សាន់នី ត្រាំត្រែងនឹងគំនិតខ្លួនឯងពេញមួយថ្ងៃ ហើយឃើញថាខ្លួនជាអ្នកខុស។ នាងចូលចិត្តប្រើអារម្មណ៍ គ្មានហេតុផល ធ្វើរឿងតូចក្លាយជារឿងធំ ព្រោះតែអាម៉ាស់មុខ មិនធ្លាប់គិតទេថានាងសំណាងល្អប៉ុនណាដែលជួប សេត ជាងការជួបអ្នកដទៃ ដែលអាចធ្វើឲ្យនាងមានគ្រោះថ្នាក់ទាំងរាងកាយនិងចិត្ត។

សេត ទៅធ្វើការបាត់ពេញមួយថ្ងៃ ក្រៅពីឲ្យពេលដល់ខ្លួនឯងហើយ ក៏ឲ្យពេលដល់ សាន់នី រម្ងាប់អារម្មណ៍ដែរ។ គេក៏មានចំណែកខុសដែលធ្វើឲ្យនាងមានអារម្មណ៍អាម៉ាស់មុខ ដែលមិនគួរដំឡើងសំឡេងដាក់នាង គេគួរតែលួងលោមនាង ព្រោះនាងកំពុងនាំខ្លួនឯងរត់គេច។ គេគួរប្រាប់តាំងពីដំបូងថាចាំនាងបាន ហើយចេញមុខការពារនាង តែគេមានចេតនាបោកនាងនោះឯង។





Scanned by CamScanner

"សេត"

សេត ស្រេ្តសខ្លាំងណាស់ ព្រោះត្រូវត្រៀមខ្លួន ទទួលយកការប៉ះទង្គិចផ្លូវអារម្មណ៍នឹង សាន់នី បន្ត តែនាងមិនបានធ្វើខ្លួនដូចកាលពីព្រឹក នាងដើរលឿនស្លេវមករក ទើបគេត្រូវស្រវាឱបនាងភ្លាម។

"កើតអី អ្នកណាធ្វើបាបនាង ឬខ្ញុំធ្វើអីមិនល្អទៀតហើយ"

គេសួរ ដោយមិនសូវជឿជាក់ប៉ុន្មាន។ គេបាត់បង់ទំនុកចិត្តរបស់ខ្លួនព្រោះប្រពន្ធមុខស្រស់របស់គេនោះឯង នាងធ្វើឲ្យគេភ័យខ្លាចគ្រប់យ៉ាង ទាំងដែលនាងគ្រាន់តែជាស្រីមាឌល្អិតម្នាក់ប៉ុណ្ណោះ។

"សុំទោស"

"សុំទោសធ្វើអី ?"

"ខ្ញុំទំនើង ខ្ញុំធ្វើខ្លួនមិនល្អ ខ្ញុំអន់ចរិត"

សេត ឱនថើបថ្ងាសរបស់នាង ឱបរឹតនាងណែនដៃ ហើយនាំទៅអង្គុយលើសាឡុងជាមួយគ្នា។

"ឈប់ថាឲ្យខ្លួនឯងទៅ នាងជាមនុស្សស្រី មនុស្សស្រីគឺត្រូវតែមានអារម្មណ៍ងរង៉ក់ ខឹងសម្បា ខ្ញុំគួរចិត្តត្រជាក់ដាក់នាងជាងនេះ"

"លោកចិត្តត្រជាក់ហើយ ខ្ញុំទេជាអ្នកខុស ខ្ញុំឡូឡា ខ្ញុំនិយាយមិនពីរោះ



Scanned by CamScanner

ដាក់លោក ហើយយកទៅប្ដឹងព្រះអង្គម្ចាស់ ហ្វាវៀន ទៀត"

"នាងជួបគេហើយ ?"

"ចា៎"

សាន់នី មិនបានប្រាប់គេថានាងនិងព្រះអង្គម្ចាស់និយាយគ្នាពីរឿងអីខ្លះ ហើយពេលនាងមានស្មារតីត្រិះរិះពិចារណា ក៏សិក្សាស្វែងយល់ពីវា។

"នាងមិនបានលង់ស្នេហ៍គេទេ មែនទេ ?"

"ខ្ញុំធ្វើបែបនោះម៉េចបាន"

"អ្នកណាទៅដឹង ខ្ញុំឃើញមនុស្សស្រី ឲ្យតែជួបព្រះអង្គម្ចាស់ ហ្វាវៀន តែងតែចំហមាត់ឆ្លង"

"ខ្ញុំមានស្វាមីហើយ"

សេត មានអារម្មណ៍ដូចខ្លួនឯងអាចហោះហើរបាន ក្រៅពីឱនទៅមើលមុខនាងហើយ នៅថើបមាត់របស់នាងខ្លាំងៗ បន្តដោយការថើបថ្ពាល់ខ្សឹតៗ។

"ខ្ញុំមែនទេ ស្វាមីរបស់នាងទេ ?"

"ចា៎ ខ្ញុំមានតែលោកម្នាក់ប៉ុណ្ណោះ"

"ពៅព្រលឹង"

គេថើបថ្ពាល់នាងខ្សឹតៗ ទាញនាងឲ្យមកអង្គុយលើភ្លៅ ជ្រប់មុខនឹង





Scanned by CamScanner

ប្រទ្បោះកក្រអូបប្រហើរ។

"ខ្ញុំនឹងរៀបការជាមួយនាង យើងនឹងរៀបការជាមួយគ្នា"

"បើលោកគិតថាខ្ញុំសក្តិសម ខ្ញុំនឹងធ្វើជាភរិយាដ៏ល្អរបស់លោក"

ព្រះអង្គម្ចាស់ ហ្គាវៀន និយាយត្រូវ នាងមិនសក្តិសម មិនមែនព្រោះកំណើតកើតជា ប៉ុន្តែព្រោះទង្វើរបស់នាង ហើយនាងត្រូវតែកែប្រែខ្លួនឯង។

"ខ្ញុំជ្រើសរើសនាងហើយ ហើយនាងជ្រើសរើសខ្ញុំទេ ?"

គេចាប់ដៃរបស់នាងមកថើប សាន់នី ក៏ញញឹមពព្រាយដាក់ ហើយលោមកថើបថ្ពាល់ ចំណែកដៃក៏អង្អែលរាងកាយរបស់គេ។

"ខ្ញុំជ្រើសរើសលោក ទាំងរាងកាយ និងបេះដូង"

សេត ញញឹមដាក់ នាងក៏ញញឹមដាក់វិញ ជាស្នាមញញឹម ដែលធ្វើឲ្យគេមើលនាងដោយខ្សែភ្នែកគគ្លើនតែម្តង ដែលនាងយល់ពីតម្រូវការរបស់គេ។

"ស្អិតខ្លួន ចង់ឲ្យងូតទឹកឲ្យទេ"

"ដោយក្តីរីករាយ"

សេត បី សាន់នី ចូលបន្ទប់ដេក និងហាមអ្នកបម្រើរំខាន ហើយបន្ទាប់ពីងូតទឹករួច ក៏បបោសអង្អែលនាង ដល់ថ្នាក់ភ្លេចទទួលទានអាហារ រហូតដល់ព្រឹកថ្ងៃថ្មី ក៏មិនព្រមចេញពីបន្ទប់ទាំងពីរនាក់ ទុកឲ្យភ្ញៀវដ៏ខ្ពង់ខ្ពង់ស្វាគមន៍ខ្លួន



Scanned by CamScanner

ឯង និងដល់ពេលត្រូវធ្វើដំណើរត្រឡប់ទៅក្រុងសេនថាម៉ារ៉ា វិញ។

ព្រះអង្គម្ចាស់ ហ្គារៀន ប្រែដៃ មើលនាឡិកា ទ្រនិចចង្អុលម៉ោងប្រាំបួនគត់ ទើបនាំខ្លួនឯងឡលឧទ្ធម្ភាគចក្រ។ ទ្រង់មិនបង្ហាញអាការៈខឹងសម្បា ដែលសាន់នី មិនបានវេចបង្វេចមករង់ចាំ ដើម្បីឲ្យទ្រង់នាំចេញពីកោះ។

"បើធ្វើបែបហ្នឹង នាងគឺមនុស្សស្រីល្ងង់ខ្លៅ តែការជ្រើសរើសរបស់នាងគឺជាមនុស្សស្រីឆ្លាត អ៊ីចឹងហើយ ប្រហែលមិនអាចនិយាយបានថា នាងមិនសក្តិសមនឹង សេត ទេ"

ព្រះអង្គម្ចាស់ និយាយដាក់ខ្លួនឯង ហើយចេញបញ្ជាឲ្យឧទ្ធម្ភាគចក្រធ្វើដំណើរចេញពីកោះចោរ។

គំនិតមានះរបស់មនុស្សស្រី ពេលខ្លះអាចធ្វើឲ្យពួកនាងខកខានឱកាសនឹងមានជីវិតដែលមានសេចក្តីសុខ អ្នកខ្លះធ្វើឲ្យរបស់សំខាន់របូតពីដៃ ព្រោះតែអារម្មណ៍ និងគំនិតមានះនេះឯង។

"អបអរដែលនាងឆ្លាត"

ព្រះអង្គម្ចាស់សម្លឹងមើលកោះចោរ ជឿថាមិនយូរទេ ទ្រង់នឹងបានមកចូលរួមពិធីមង្គលការរបស់ សេត។





Scanned by CamScanner

# សុភមង្គលស្នេហ៍

វាជាសេចក្ដីសុខផ្ទាល់ខ្លួនរបស់ សេត គ្រីនៀសដេម៉ង់ត៍ ពេលវេលាលម្ហែជាមួយស្រីស្អាត នៅកន្លែងដែលមានភាពផ្ទាល់ខ្លួន កន្លែងកម្សាន្តប្រចាំរបស់គេពេលត្រូវការកម្សាយភាពតានតឹង គឺរោងរបាំស្រាត ណាខាងដៀ។

សេត នៅទីនេះ តែមិនមែនក្នុងឋានៈជា សេត គ្រីនៀសដេម៉ង់ត៍ ឬ សេត ស៊ី រ៉ូវើ ឈ្មោះរបស់គេត្រូវតែជាអាថ៌កំបាំង។ រឿងខិលខូចស្រីញីរបស់គេអាចនាំរឿងអំពល់ទុក្ខខ្លះ តាមពិតគេមិនសូវយកចិត្តទុកដាក់ចំពោះរឿងនេះទេ ពេលនឹកឃើញ គេក៏ធ្វើ ពេលខ្លះក៏បណ្ដោយវាតាមដំណើរ ប៉ុន្តែនៅប្រកស្នេហា គេត្រូវតែបិទបាំងឈ្មោះពិតរបស់ខ្លួនឯង។

នៅរោងរបាំស្រាត ណាខាងដៀ បើប្រាប់ថាគេជាភ្ញៀវប្រចាំក៏មិនខុស។ គេនឹងមកទីនេះមួយឆ្នាំ បី ឬបួនដង។ ស្រីរបាំនៅទីនេះសុទ្ធតែស្អាត និងចេះវិធីយកចិត្តយកថ្លើមភ្ញៀវបានល្អ ហើយក្រៅពីស្រីៗ នៅរោងរបាំស្រាតមួយនេះក៏មានការកម្សាន្តច្រើនប្រភេទទៀត។

ការបង្ហាញរបាំស្រាត មិនត្រឹមតែឡើងទៅលើវេទិកា ហើយដោះខោអាវចេញពីរាងកាយប៉ុណ្ណោះទេ ស្រីរបាំម្នាក់ៗ ធ្វើកាយវិការល្វតល្វន់ ជាការសម្ដែង



Scanned by CamScanner

ដែលគួរឱ្យជាប់ចិត្ត បើកាត់រឿងការដោះសម្លៀកបំពាក់ចេញពីខ្លួនម្តងមួយៗ វាជាការសិល្បៈផ្នែកសម្តែងមួយប្រភេទ។

'លោក ម៉ារីស'

ពេល សេត ដើរចូលអគារ ណាខាដៀ ឃៃរ៉ល ក៏ម្នីម្នាដើរមកស្វាគមន៍ ដោយទឹកមុខពព្រាយ ប៉ុន្តែគេគិតថា នាងរីករាយទុកជាមុននឹងប្រាក់ដែលអាចទាញចេញពីហោប៉ៅរបស់គេច្រើនជាង។

'សួស្តី'

'អញ្ជើញទៅបន្ទប់វីអាយភី លោក ម៉ារីស'

ឃៃរ៉ល នាំ សេត ទៅបន្ទប់វីអាយភី ដោយចាំបានថាគេតែងតែមកទីនេះជាមួយកូនចៅម្នាក់ ទើបបើកបន្ទប់វីអាយភីពីរបន្ទប់។

'ការសម្តែងជិតចាប់ផ្តើមហើយ'

សេត កុម្ម៉ង់ភេសជ្ជៈ ហើយដាក់បង្គុយលើសាឡុង បើកវាំងនន ដើម្បីមើលតាមកញ្ចក់ ដែលអាចទស្សនាការសម្តែងលើវេទិកាបាន។ គេមកទីនេះដើម្បីបន្ធូរអារម្មណ៍ ហើយការបានគយគន់សម្រស់ស្រីស្អាត គឺជារឿងដែលមិនអាចបដិសេធបាន។



'សូមអនុញ្ញាតបម្រើភេសជ្ជៈ'



Scanned by CamScanner

ភេសជ្ជៈត្រូវលើកមកដាក់រួចរួចរាល់ ហើយពេល សេត នៅម្នាក់ឯងក្នុង

បន្ទប់ ការសម្ដែងលើវេទិកាក៏ចាប់ផ្ដើមឡើង។

**សេត មានអារម្មណ៍ដូចខ្លួនឯងត្រូវសណ្ដំមួយរំពេច ពេលបានជួបនឹង**

ស្រីម្នាក់ ដែលស្អាតលេចធ្លោនៅលើវេទិការបាំស្រោត។ គេសម្លឹងមើលនាង និង

មិនអាចដកខ្សែភ្នែកចេញបាន ព្រោះតាំងពីមុខមាត់ស្រស់ស្អាត ទាក់ទាញភ្នែក

ដែលចាក់ទម្លុះកញ្ចក់បង្អួចមកដល់កែវភ្នែករបស់គេបានច្បាស់ ហើយនៅមាន

រូបរាងសិចស៊ីនោះទៀត ដែលមិនអាចបរិយាយបានថានាងស្អាតកម្រិតណា

តែដឹងត្រឹមថា គេត្រូវការគ្រប់គ្រងនាង។

សេត ពិនិត្យមើលរាងកាយរបស់នាង នៅក្នុងឈុតរបាំស្អាត តែមាន

ភាពទាក់ទាញ ហើយនាងត្រូវតែជាស្រីរបាំម្នាក់ក្នុងចំណោមនោះ ដែលនឹងដោះ

ខោអាវចេញពីខ្លួនម្ដងមួយៗ ទាល់តែអស់។

'ឃែរ៉ល ខ្ញុំត្រូវការជួបអ្នកស្រី'

សេត ចុចទូរសព្ទផ្នែកខាងក្នុងបន្ទប់វីអាយភីដល់ម្ចាស់ ណាខាដៀ។ គេ

មិនអាចបង្អែបង្អង់បានទេ ព្រោះខ្លាចត្មៀវដែលកំពុងទស្សនាការសម្ដែងនៅ

ពេលនេះឆក់យកនាងទៅបាត់ ហើយពេលសន្ទនាជាមួយ ឃែរ៉ល ពីរបីម៉ាត់ក៏



Scanned by CamScanner

មានបុគ្គលិករបស់រោងរបាំស្រាតនាំគេចេញពីបន្ទប់វីអាយភីទៅបន្ទប់សម្រាក។

អ្នកកំលោះចូលមកក្នុងបន្ទប់ ដាក់បង្កុយលើសាឡុង ដើម្បីរង់ចាំស្រីស្អាត ដែល ឃែរ៉ល ប្រាប់ថាឈ្មោះ សាន់នី។ សម្រស់របស់នាងស្រស់ស្រោយ ចាក់ភ្នែករបស់គេ ហើយពេលនាងមកដល់ គេនឹងលេបត្របាក់នាងឱ្យណាណី ពេញមួយរាត្រីនេះ។

( តម្លៃខ្ពស់បន្តិចហើយលោក ម៉ារីស ព្រោះនៅព្រហ្មចារី )

ឃែរ៉ល ប្រាប់បែបនេះ តែ សេត គ្មានបញ្ហារឿងប្រាក់កាស់។ ទោះជាតម្លៃខ្ពស់សម្រាប់ ឃែរ៉ល តែវាតិចណាស់សម្រាប់គេ។ គេទិញសេចក្តីសុខឱ្យខ្លួនឯង ហើយក៏មិនស្តាយ បើទទួលបានសេវាកម្មដែលសមាមាត្រ។

' គ្មានបញ្ហាទេ '

( លោក ម៉ារីស ចិត្តទូលាយជានិច្ច )

' នាំនាងចុះម៉ោ ហើយនាំមកជួបខ្ញុំ '

( នាងខ្ញុំនឹងចាត់ការជូនភ្លាម )

ការសន្ទនារវាង សេត និង ឃែរ៉ល គ្មានការពិចារណា គេត្រូវការទំនិញ ចំណែក ឃែរ៉ល ដែលជាម្ចាស់ទំនិញ ក៏សម្រេចចិត្តលក់ឱ្យគេ។

' ស្អាតណាស់ '





Scanned by CamScanner

សេត អ៊ែនខ្នងផ្អែកនឹងបង្អែកសាឡុង នឹកដល់មុខមាត់របស់ស្រីស្អាតម្នាក់នោះ ទោះមើលតាមកញ្ចក់ប្រភេទពិសេស ហើយក្រៅពីសម្រស់ គេនៅមើលឃើញភាពតានតឹងរបស់នាងដែរ។

'ខ្ញុំត្រូវរុករកប្រស្នា'

ពាក្យថា **ប្រាថ្នា** ដែលផុសថ្កោលក្នុងមនោរម្មណ៍ កាន់តែធ្វើឱ្យ សេតត្រូវការនាង ទើបចំណាយប្រាក់ទៅលើនាងដោយមិនស្ទាក់ស្ទើរ។ គេគ្មានចំណង់ចំណូលចិត្តលើស្រីព្រហ្មចារី ព្រោះការគ្មានបទពិសោធរបស់ពួកនាងធ្វើឱ្យគេត្រូវខាតពេលបង្រៀន ដែលមនុស្សរកសេចក្ដីសុខភ្លើងចំបើងដូចគេមិនចង់ខាតពេលធ្វើរឿងបែបនោះ ប៉ុន្ដែស្រីស្អាតម្នាក់នោះ គេរីករាយជាខ្លាំងនឹងបង្រៀននាងឱ្យក្លាយជាអ្នកជំនាញ ផ្នែកប្រណិប័តន៍មនុស្សប្រុស។

**បេះដូងរបស់នាងលោតឌុកឌាក់ ដោយមិនធ្លាប់មានអារម្មណ៍បែបនេះ** ពេលប្រសព្វភ្នែកនឹងមនុស្សប្រុស ប៉ុន្ដែវាតែងតែមានភាពខុសគ្នា ព្រោះគេជាបុរស ដែលនាងត្រូវប្រគល់ខ្លួនប្រាណឱ្យគេ។ បុរសនៅចំពោះមុខនាងសង្ហា និងមានបុគ្គលិកលក្ខណៈលេចធ្លោ គេជាបុរសដែលមនុស្សស្រីអាចលង់ស្នេហ៍បានយ៉ាងងាយ។ កែវភ្នែកមុតស្រួច មានមន្ដស្នេហ៍ បបូរមាត់ដែលញោចចេញ



Scanned by CamScanner

ជាស្នាមញញឹមតិចៗ បង្កប់ល្បិចកល រូបរាងខ្ពស់ មាឌធំអង់អាច។ ការប្រសព្វភ្នែកនឹងគេ ធ្វើឱ្យនាងមានអារម្មណ៍ដូចត្រូវរន្ទះបាញ់កណ្ដាលថ្ងៃ និងគួរឱ្យប្លែកដែលនាងគិតថា គេត្រូវតែមានអារម្មណ៍ដូចនាង។

សាន់នី ដើរទៅរកគេ ដោយព្យាយាមគិតដល់ចំណុចល្អសម្រាប់រាត្រីនេះ យ៉ាងហោចណាស់ ក៏មិនចាំបាច់ដេកជាមួយមនុស្សប្រុសវ័យស្រករឪពុក ឬ មានរូបរាង មុខមាត់គួរឱ្យស្អប់ ចរិតត្រេកកាមគួរឱ្យរត់គេច។ បុរសនៅចំពោះមុខនៅឆ្ងាយពីភិនភាគទាំងនោះ ហើយបើនាងជួបគេក្រៅ ណាខាដៀ គឺទៅរួចដែលស្រឡាំងកាំងនឹងសម្រស់ ភាពលេចធ្លោតាមបែបបទបុរសរបស់គេ។

'សួស្ដី លោក ម៉ារីស'

នាងលំទោនខ្លួនគោរពគេយ៉ាងទន់ភ្លន់។ មនុស្សស្រីម្នាក់នេះ ក្រៅពីមានមុខមាត់ស្អាត រូបរាងសិចស៊ីទាក់ទាញ ការធ្វើកាយវិការរបស់នាងក៏គួរឱ្យមើលដែរ។

សេត ងើបដើរទៅរកនាង ដែលត្រូវ ឃៃរ៉ល ឈរកាងជាប់។

'មើលថៃ លោក ម៉ារីស ឱ្យបានល្អ សាន់នី'

'ចាំ អ្នកស្រី'



សាន់នី ឆ្លើយតបដោយស្នាមញញឹម តែគ្មានសេចក្ដីសុខ ដែល សេត



Scanned by CamScanner

មានអារម្មណ៍ដល់វា ហើយមិនបានចាប់អារម្មណ៍ យ៉ៃរ៉ល ដែលដឹកដៃស្រីស្អាតមកជិតនិងនិយាយច្រើនពីស្អីក៏មិនដឹង ព្រោះគេរវល់តែចាប់អារម្មណ៍ សាន់នី ទើប យ៉ៃរ៉ល ញញឹមញញែមដោយការពេញចិត្ត ហើយដើរចេញពីបន្ទប់។

ពេលនៅតែពីរនាក់ សេត ក៏ទាញនាងទៅពិតនឹងខ្លួនភ្លាម ទើបនាងលើកដៃទ្រានដើមទ្រូងមាំមួន។ ការពិតនាងមិនបានប្រកែក មិនចង់ធ្វើការទេ គ្រាន់តែភាពស្និទ្ធស្នាលដែលកើតឡើងទាំងគំហុក ធ្វើឱ្យនាងភ្ញាក់។

'នាងមកដើម្បីប្រណិតប័តន៍ខ្ញុំមិនអ៊ីចឹង សាន់នី'

'ចាំ លោក ម៉ារីស'

ការដែលត្រូវនៅជិតរាងកាយរបស់គេ ធ្វើឱ្យនាងចង់រត់គេច ហើយនៅមានអារម្មណ៍ប្លែកៗ នៅក្នុងទ្រូង វាជាភាពស្រៀវស្រើបដែលនាងមិនស្គាល់។

'នាងស្អាតណាស់'

សេត ផ្ញើយចង្ការបស់នាង ប្រដេញម្រាមដៃតាមស្បែកថ្ពាល់រលោង។ នាងជាមនុស្សស្រីដែលស្អាតដូចទេពធីតា និងសក្តិសមឱ្យថ្នាក់ថ្នម មិនមែនមកនៅក្នុងរោងរបាំស្រាត តែគេជាអ្នកទិញនាងដោយប្រាក់។

កែវភ្នែកមុតស្រួចរបស់គេបង្ហាញឱ្យឃើញអារម្មណ៍ក្តៅគគុក ហើយនាងក៏យល់ន័យនៅក្នុងខ្សែភ្នែកមួយគូនោះ ព្រោះសញ្ជាតិញ្ញាណរបស់មនុស្សស្រី



Scanned by CamScanner

ពេលត្រូវមនុស្សប្រុសចាប់អារម្មណ៍ជួយដាស់តឿនឱ្យនាងដឹងខ្លួន។

'យ៉េរ៉ល ប្រាប់ថានាងនៅបរិសុទ្ធ'

'ចាំ លោក ម៉ារីស'

សំឡេងរបស់នាងរាងរឹងបន្តិច ដូចគេបៀតបៀនភាពផ្ទាល់ខ្លួនរបស់នាង តែអាការៈឆ្មាសឆ្មើមតិចៗ នេះ គួរឱ្យចាប់អារម្មណ៍សម្រាប់ សេត។

'ហើយធ្លាប់ថើបជាមួយមនុស្សប្រុសទេ ?'

'មិនធ្លាប់ទេ'

'នាងមិនធ្លាប់មានសង្សារ ?'

'មិនធ្លាប់ទេ'

'ជារឿងអស្ចារ្យណាស់ សម្រាប់មនុស្សស្រីដែលស្អាតខ្លាំងដូចនាង'

គឺព្រោះតែសម្រស់នេះឯង ទើបធ្វើឱ្យនាងត្រូវមកវេទនានៅចំពោះមុខគេនេះអី។ បើជ្រើសរើសបាន នាងសុំជ្រើសរើសធ្វើការនៅក្រៅ ណាខាដៀ និងមិនបាច់ធ្វើជាស្រីស្អាតល្អជាង។

'ខ្ញុំមិនធ្លាប់ចូលចិត្តស្រីព្រហ្មចារី ព្រោះត្រូវបង្រៀនច្រើន'

សាន់នី ក្តៅថ្ពាល់ គិតថាគេប្រហែលជាចូលចិត្តមនុស្សស្រី ដែលមានជំនាញ បេះវិធីប្រណិតប័តន៍គេ។ នៅណាខាដៀ មានមនុស្សស្រីចាំបង្រៀន





Scanned by CamScanner

រឿងនេះដល់ស្រីរចាំ តែទ្រឹស្តី និងអនុវត្ត វាតែងតែខុសគ្នា។

'តែសម្រាប់នាង ខ្ញុំព្យាយាមធ្វើចិត្តឱ្យត្រជាក់ទៅចុះ'

'ចាំ លោក ម៉ារីស'

'ទៅគ្រែទៅ'

'លោក ម៉ារីស មិនផឹកសិនទេឬ?'

'ខ្ញុំផឹកមកពីខាងក្រោមហើយ'

សេត បដិសេធការផឹកស្រា ព្រោះពេលនេះត្រូវការស៊ីផឹករាងកាយរបស់នាងជាង។ មាត់របស់គេស្រេកឃ្លានការប៉ះពាល់រាងកាយរបស់នាង។

'ចាំ លោក ម៉ារីស'

'មិនបាច់ខ្លាចទេ នាងនឹងចូលចិត្តវា'

'តែខ្ញុំអាចមិនចូលចិត្តវាក៏ថាបាន'

នាងឆ្លោយមាត់តវ៉ា ទើប សេត ងាកមកញញឹមលាក់កំណួចដាក់ និងចាប់ដៃរបស់នាង ទាញឱ្យដើរទៅបន្ទប់។

'ចុះបើនាងចូលចិត្តវា តើភ្នាល់គ្នាទេ?'

'ភ្នាល់ឬ?'

'បើនាងចូលចិត្តវា ខ្ញុំនឹងស៊ីនាងពេញមួយយប់ដល់ព្រឹក'



Scanned by CamScanner

*នេះជាការភ្នាល់ដែលចាញ់ប្រៀបណាស់!*

សាន់នី មិនទាន់បានឆ្លើយផង សេត ក៏សរុបដោយខ្លួនឯងថានាងព្រមភ្នាល់ជាមួយគេទៅហើយ។

'សម្រេចតាមនេះ ខ្ញុំនឹងប្រឹងប្រែងឱ្យអស់ពីសមត្ថភាព ធ្វើឱ្យនាងថ្ងូរទាល់តែខះកមិនខាន'

*គេពូកែពេកហើយ!*

សាន់នី ចុះចាញ់ឱ្យបុរសដែលកំពុងតែចង់លេបត្របាក់នាង។ នាងដឹងថាគេមានថ្វីដៃកំណាច ព្រោះរាងកាយដែលត្រូវគេដុតនោះ ដូចវាលែងជារបស់នាងទៀតហើយ ឱ្យនាងរើបម្រះពេញគ្រែ ដកដង្ហើមដង្ហក់ ដោយអារម្មណ៍រញ្ជួយដូចមានភ្លើងនៅខ្លួន។

'ជឿខ្ញុំហើយឬនៅ ពៅព្រលឹង'

សេត មិនចាំបាច់សួរថានាងមានសេចក្ដីសុខទេ រាងកាយរបស់នាងបានបញ្ជាក់ច្បាស់ ហើយឱនទៅថើបបបូរមាត់ផ្អែមល្ហែម ដែលត្រូវគេថើបឡើងជាំទៅហើយ។

'អាំ...លោក ម៉ារីស'

'សំឡេងរបស់នាងពីរោះ ខ្ញុំចូលចិត្ត'





Scanned by CamScanner

សំឡេងថ្ងូចថ្ងូររបស់នាងផ្ដោចឱ្យគេកាន់តែកើតអារម្មណ៍ប្រាថ្នា ដូចមានព្យុះបោកបក់នៅក្នុងខ្លួនរបស់ពួកគេទាំងពីរ ហើយ សេត ក៏ចេះវិធីបំផ្ទុះវាដែរ។

'ក្រអូបសព្វសាច់'

គេថើបជញ្ជក់នាងសព្វសាច់ បន្ទាប់ពីចាប់នាងសម្រាតខោអាវ ស្បែករបស់នាងសព្រលាំផ្កាឈូក ស្អាត រលោង ម៉ដ្ឋខៃ។

'មាត់របស់នាង កាន់តែថើប កាន់តែផ្អែម'

សាន់នី ចង់ស្អប់ខ្លួនឯងខ្លាំងណាស់ ក្រៅពីមិនស្អប់ខ្ពើម និងរើបម្រះហើយ នាងនៅដេកមានសេចក្ដីសុខនៅក្រោមរាងកាយរបស់គេ បន្ទាប់មកពេល សេត ដកបបូរមាត់ចេញ ក៏ឱ្យគេចាប់ជើងទាំងពីរុញចេញពីគ្នា ជាការបើកផ្លូវ ឱ្យគេគ្រប់គ្រង ដោយធ្វើឱ្យនាងឈឺចាប់តិចបំផុត ប៉ុន្តែនាងត្រូវតែឈឺដដែល។

'ឈឺតិចតួចទេ ពៅព្រលឹង'

អ្នកកំលោះល្បួងលោម ពេលត្រួតពិនិត្យរាងកាយរបស់នាងម្ដងទៀត។ សាន់នី ស្រស់ស្អាតមែនទែន រាងកាយរបស់នាងផ្ដោចរាគៈ ឱ្យគេព្រិលភ្នែកដោយភ្លើងតណ្ហា។

'ហ៊ឺ!'



Scanned by CamScanner

'បន្តិចទៀត ពៅព្រលឹង'

សេត ងើបមកស្រវាឱបរាងកាយតូចប្រឡឹង ពេលនាំខ្លួនឯងជ្រៀតជ្រែកចូលរាងកាយរបស់នាង ដែលការធ្វើឱ្យរាងកាយទាំងពីរលាយក្លាយជាសាច់មួយ វាដំណើរការរអាក់រអួលណាស់។

'ឈឺ'

'ខ្ញុំដឹង តិចទៀត វានឹងលែងអី'

គេថើបថ្ងាសរលោង ដោយមិនព្រមបញ្ឈប់ការគ្រប់គ្រងរាងកាយរបស់នាងដោយភាពក្ដៅគគុក ព្រោះវានឹងក្លាយជាជាបទពិសោធឃោរឃៅសម្រាប់នាង។ សេត ធ្វើឱ្យនាងឈឺចាប់ចង់ដាច់ខ្យល់ ហើយពេលគេគ្រប់គ្រងរាងកាយរបស់នាងបានសម្រេច ក៏ធ្វើឱ្យនាងមានសេចក្ដីសុខជោរជន់ ដូចកំពុងហោះទៅកាន់ឋានសួគ៌។

"ហ៊ឹ..."

ស្រីសម្ពឹកដែលដេកផ្កាប់មុខទាំងនលគកនៅលើខ្លួនរបស់គេ ថ្ងូរឱ្យឮស្វាគមន៍អរុណរះ ហើយប្រឹងបើកភ្នែកយ៉ាងលំបាក។

"ស្រីសម្ពឹកគួរឱ្យស្រឡាញ់"





Scanned by CamScanner

សេត ឱបក្រសោបនាងជាប់ទ្រូង និងឱនថើបត្របកភ្នែក ទើបនាងលើកដៃឱប និងប្រឹងរំកិលឡើងលើ ដើម្បីជ្រប់មុខនឹងប្រឡោះកគេបានស្រួល។

"ភ្ញាក់ហើយឬនៅ អូនសម្លាញ់"

"ភ្ញាក់ហើយ"

"បើភ្ញាក់ហើយ ម៉េចមិនបើកភ្នែក"

"ងងុយហ្នឹងណា៎"

សាន់នី ប្រឹងត្រសុលទៅរក ហើយការដែលរាងកាយនលគកកកិតគ្នាស្វាគមន៍អរុណរះ ធ្វើឱ្យការប្រាថ្នារបស់ សេត មានប្រតិកម្ម ក្តៅបន្តិចម្តងៗ។

សាន់នី ដែលជាស្រីរបាំស្រោតនៅថ្ងៃនោះ បានក្លាយជាភរិយារបស់គេនៅថ្ងៃនេះ។ ពួកគេបានរៀបការនឹងគ្នាកាលពីបីថ្ងៃមុន និងហាន់នីមូនរាល់យប់ដូចទើបតែរៀបការថ្មោងថ្មី។

"បើមិនភ្ញាក់ បបួលបង្កព្យុះហើយ"

"បង្កព្យុះទៀតហើយ" សាន់នី អង្អែលដើមទ្រូងធំទូលាយ។

ការបង្កព្យុះរបស់ សេត ជាការបង្កព្យុះប្រាថ្នា ហើយកាលពីយប់ម្សិលនាងបង្កព្យុះជាមួយគេជិតទៀបភ្លឺ ទើបលទ្ធផលនៃការបង្កព្យុះយ៉ាងសាហាវរបស់ស្វាមី គឺនាងងងុយដេកស្វាគមន៍អរុណរះបែបនេះ។



Scanned by CamScanner

"យប់មិញក៏បង្កព្យុះធំប៉ុនណាប៉ុណ្ណឹ"

"អាហ្នឹងជារឿងយប់មិញ អានេះជាពេលព្រឹក"

"មិនហត់ខ្លះទេអី"

"បងរឹងមាំណាស់ អូនក៏ដឹង"

សេត ចាប់ផ្ដើមដោយការខាំស្លឹកត្រចៀករបស់ភរិយា ឱ្យនាងសើចខឹកៗ ហើយលោមកថើបថ្ពាល់គ្រើម បន្ទាប់មកនាងក៏ស្ទុះងើបអង្គុយលើពោះរឹងមាំ។

"ត្រេកកាមពេកហើយ"

"គឺមនុស្សទើបតែរៀបការរួចហ្នឹងណា៎"

សាន់នី ចាក់ដើមទ្រូងធំទូលាយនឹងចង្អុល ព្រោះស្វាមីរបស់នាងតែងតែហេតុផលល្អសម្រាប់ភាពត្រេកកាម ដែលធ្វើឱ្យនាងស្ទើរតែសន្លប់នៅលើគ្រែបានជានិច្ច។

"លេសច្បាស់ណាស់ ប្រុសកំណាច"

"នៅសុខៗ ក៏ថាឱ្យប្ដី"

អ្នកកំលោះចាប់ដៃទន់ល្មើយរបស់ភរិយាមកថើប ក្រៅពីដៃរបស់នាងហើយ គេក៏ចូលចិត្តថើបខ្លួនប្រាណដែរ។ ការងារចម្បងរបស់គេគឺចាប់នាងស៊ីនៅលើគ្រែ ឯការងារកែអផ្សុកគឺចាប់ភរិយាសម្រាត ថើបជញ្ជក់ ស្ទាបអង្អែល គឺ





Scanned by CamScanner

នាងស្អាតសព្វសាច់ មិនចាំបាច់មានសម្លៀកបំពាក់ជាប់ខ្លួនក៏នៅតែស្អាត។

"ងើបឡើង"

សេត ងើបអង្គុយ ស្រវាឱបរាងកាយនននលគក ឱ្យនាងត្រសុលមកបៀត លើកដៃឱប.កមាំមួន។

"ថើបស្វាគមន៍អរុណរះហើយឬនៅ"

"នៅទេ ពៅព្រលឹង"

"ថើបម៉ោចឹង"

"ហេតុអីប្រពន្ធគួរឱ្យខ្លាចបែបនេះ ហ៊ឺ!"

គេសួរលេង ហើយឱនថើបបបូរមាត់ក្រពុំ។ រឿងបែបនេះ សេត មិន បដិសេធទេ ព្រោះគេចូលចិត្តវាខ្លាំងណាស់។

"ស្រឡាញ់បង"

"បាទ"

"ចុះបង ស្រឡាញ់អូនទេ ?"

"ស្រឡាញ់ បើមិនស្រឡាញ់ បងរៀបការនឹងអូនធ្វើអី ត្រូវកម្ចាត់ស្រីៗ ឡើងគរគោក អ៊ូយ!"

សាន់នី ក្តិចខ្នងដៃស្វាមី ឱ្យ សេត សើចក្អាកក្អាយ ព្រោះនាងតែងតែ

បែបនេះ ប្រចណ្ឌហួងហែងគួរឱ្យស្រឡាញ់ជានិច្ច តែគេបែរជាចូលចិត្តវា។

"បើនិយាយតែមួយម៉ាត់ទៀត ត្រូវមិនខាន"

"ថី ឬចង់សុំលែងលះ"

"មិនលែងទេ កុំសង្ឃឹមឱ្យសោះ ត្រូវនៅជាមួយគ្នាមួយជីវិត"

"ល្អណាស់ ពៅព្រលឹង"

សេត ឱនថើបភរិយា។ នាងសម្របខ្លួនឱ្យចុះសម្រុងនឹងគេ ហើយគួរឱ្យស្រឡាញ់ណាស់ មានហេតុផលជាងមុន មិនសូវឆ្នាសដូចមុន។ នៅថ្ងៃរៀបការ នាងនិយាយជាមួយព្រះអង្គម្ចាស់ ហ្គារៀន យ៉ាងយូរ មិនដឹងទៅស្និទស្នាលគ្នាតាំងពីពេលណា ឬការនិយាយជាមួយព្រះអង្គម្ចាស់ក្រអឺតក្រទម ធ្វើឱ្យនាងប្រែប្រួល យល់ពីគេកាន់តែខ្លាំង។

"សេត"

"បាទ ពីព្រលឹង"

"ក្រែងប្រាប់ថាបង្កព្យុះនោះអី ពេលណាបង្ក ?"

"ឥឡូវនេះអូនសម្លាញ់"

សេត មិនបង្អង់យូរ ពេលភរិយាអនុញ្ញាតដោយប្រយោលបែបនេះ ក៏ក្រសោបឱបរឹតនាងណែនដៃ ហើយឱនថើបបបូរមាត់ទន់ល្មើយ ដើម្បីដាស់



Scanned by CamScanner

អារម្មណ៍របស់នាងឱ្យក្ដៅដូចភ្លើង។

ថ្ងៃឈប់សម្រាករបស់ពួកគេជាថ្ងៃដែល គ្រីស ប្រកាសមិនទទួលភ្ញៀវ ដែលពេលនៅចំពោះមុខអ្នកដទៃ គេជាមនុស្សកាច តែពេលនៅជាមួយ ធីណា គេក្លាយជាស្វាមីលង់ប្រពន្ធក្មេងទៅហើយ។

"អូយ! បងសម្លាញ់"

ធីណា ម្រិកម្រ៉ូក់គួរឱ្យស្រឡាញ់ ថែមទាំងរោគត្រេកកាមឡើងពេញភ្នែកទៀត ចូលចិត្តបបួលគេននលគកនៅជាមួយគ្នាក្នុងថ្ងៃឈប់សម្រាក។ នាងដូចមនុស្សគ្មានការអៀនខ្មាស តែរឿងខ្លះ នាងក៏ធ្វើឱ្យគេភ្ញាក់ផ្អើល។

"បាទ"

"ខ្លាំងៗ"

ធីណា ញញឹមរបិលរប៉ូច ហើយចេញបញ្ជាដាក់ស្វាមី គ្រីស ក៏គ្រហឹមនៅដើម.ក។

"ខ្លាំងទៀត"

"ប្រយ័ត្ន ធីណា"

"ប្រយ័ត្នអី"



Scanned by CamScanner

"ប្រយ័ត្នត្រូវ"

"ចង់ត្រូវដល់ហើយ"

ធីណា ស្រវាឱប.ករបស់ស្វាមី។ នាងសប្បាយចិត្តណាស់ដែលនាងនិងបងស្រីបាននៅជុំគ្នាលើកោះ ទោះមានឋានៈខុសគ្នា តែមិនច្រណែនបងស្រីទេ មានតែអបអរសាទរ ចំណែកនាងបង្កើតគ្រួសារតូចជាមួយ គ្រីស។

ចំណែក គ្រីស ក៏បានយល់ដឹងពីចិត្តស្មោះរបស់ ធីណា ដែលប្រគល់ឱ្យគេ។ ចំពោះគេ នាងងាយគ្រប់រឿង សូម្បីតែការប្រគល់ខ្លួនប្រាណឱ្យគេ ប៉ុន្តែនាងមិនងាយចំពោះអ្នកដទៃទេ ហើយបើចុះពីកោះ ទៅដើរលេង នាងនឹងតោងគេជាប់ស្អិត ហួងហែងគេពីខ្សែភ្នែកស្រីផ្សេង ហើយក៏មិនចាប់អារម្មណ៍មនុស្សប្រុសដែលមើលនាងដែរ។ នាងចាប់អារម្មណ៍តែគេម្នាក់គត់ យកចិត្តគេតែម្នាក់គត់ ហើយគេក៏ទទួលបានសេចក្ដីសុខពីភរិយាក្មេងហៀរបេះដូង។

បើប្រៀបធៀបគ្នា អតីតភរិយារបស់គេជាមនុស្សស្រីទំនើង ទាមទារមិនចេះចប់មិនចេះហើយនឹងរបស់របរប្រើប្រាស់ថ្លៃៗ ប៉ុន្តែ ធីណា មិនត្រូវការរបស់ទាំងនោះ។ ធីណា ត្រូវការតែក្ដីស្រឡាញ់ ការយកចិត្តទុកដាក់ពីគេប៉ុណ្ណោះ។ នាងម៉ិកម៉ូក់ ចូលចិត្តបបោលគេដូចកូនឆ្មា ហើយបង្ហាញចេតនាច្បាស់លាស់ថានាងចូលចិត្តនៅលើគ្រែជាមួយគេ។



"ហ៊ឺ! ហ៊ឺ!" ធីណា ថ្ងួចថ្ងូរព្ញខ្លាំងៗ។

នៅខាងក្រៅមេឃភ្លឺស្រឡះ ប៉ុន្តែនៅក្នុងផ្ទះ ពួកគេបិទវាំងនន ធ្វើរឿងក្ដៅគគុកជាមួយគ្នានៅលើគ្រែទាល់តែបែកញើសជោកខ្លួន។ ថ្ងៃឈប់សម្រាករបស់ គ្រីស ជាថ្ងៃសម្រាប់គ្រួសារ នាងនិងគេដាក់ផែនការមានកូនជាមួយគ្នានៅពីរឆ្នាំក្រោយ តែពេលនេះពួកគេកំពុងស៊ែមផ្ដល់កំណើតឱ្យកូន ដើម្បីកុំឱ្យដល់ពេលពិតប្រាកដ មានភាពរអាក់រអួល។

"ងូតទឹកឱ្យបន្តិច"

ធីណា ហដៃទៅរកស្វាមី ទើបមនុស្សកាចដាក់អ្នកដទៃប្រញាប់លើកបីភរិយា ឱ្យនាងឱប.ក។

"ចង់ត្រាំទឹកក្នុងអាង"

"បាទៗ" គ្រីស ឆ្លើយតប។

ពេលនេះគេក្លាយជាទាសកររបស់ភរិយាពេញលក្ខណៈហើយ មិនថានាងត្រូវការអ្វី តួនាទីរបស់គេគឺត្រូវរកមកផ្គាប់ផ្គុននាង ដែលវាជារឿងងាយដូចបកចេក ព្រោះតម្រូវការរបស់ ធីណា គឺការដែលនាងបាននៅជិតគេ។

*ប្រពន្ធយើងគួរឱ្យស្រឡាញ់បំផុតនៅក្នុងលោក!*



Scanned by CamScanner

គំនិតបែបនេះ ធ្វើឱ្យ គ្រីស អស់សំណើចនឹងខ្លួនឯងដែរ។ គេធ្លាប់គិតថាខ្លួនឯងធុញទ្រាន់នាង មួម៉ៅដែលត្រូវមើលថែនាង ហើយមើលពេលនេះចុះ បើដាក់នាងក្នុងកាបូបស្ពាយជាប់ខ្លួនទៅនោះមកនេះបាន គេធ្វើទៅហើយ។

"ប្ដីសម្លាញ់"

"មានអី កូនឆ្មា"

"ត្រាំទឹកជាមួយគ្នា"

"ចុះបើបងមិនត្រាំ ?"

"យប់នេះមិនឱ្យរំលោភ"

"បងធ្លាប់រំលោភអូនឬ"

"មិនធ្លាប់ទេ អូនព្រមតែរហូត"

ធីណា ឆ្លើយ ហើយសើចកក្អិច បើបថ្ពាល់ស្វាមី។ នាងស្រឡាញ់គេណាស់ ដោយងឿងឆ្ងល់នឹងខ្លួនឯងដូចគ្នា ដែលស្រឡាញ់មនុស្សប្រុសម្នាក់ដល់ថ្នាក់នេះ។ នាងធ្វើតួនាទីជាមេផ្ទះ តាំងពីរៀនធ្វើដំបូងរហូតដល់ជំនាញ។

អាហារក៏ត្រូវធ្វើឱ្យឆ្ងាញ់ ព្រោះស្វាមីមកពីធ្វើការហត់នឿយ ដាំផ្កាក៏នាងត្រូវមើលការខុសត្រូវដោយផ្ទាល់។ នាងមិនបាច់ធ្វើការងារផ្សេង ព្រោះ គ្រីស រកប្រាក់ចិញ្ចឹមនាង គេមិនធ្លាប់ឱ្យនាងលាតដៃសុំប្រាក់ពីគេទាន់ គណនីប្រាក់





Scanned by CamScanner

សន្សំ ក៏គេបើកថ្មី មានឈ្មោះនាងជាម្ចាស់រួម។

ប្រាក់ខែរបស់គេ គេក៏ប្រគល់ឱ្យនាងមើលការខុសត្រូវ។ នាងដកលុយពីបញ្ជីមួយខែម្តង មានថ្លៃម្ហូបអាហារ ការចាយវាយផ្ទាល់ខ្លួន ដែល គ្រីស ប្រាប់ចំនួន និងឱ្យនាងដកដោយសេរី បើនាងចាយមិនអស់ អាចយកវាទៅដាក់ចូលបញ្ជីរួមបាន។

ʹសន្សំសំចៃទៅដល់ណា?ʹ

គ្រីស ធ្លាប់អ៊ូ ព្រោះ ធីណា ស្ទើរតែមិនប៉ះពាល់ប្រាក់ផ្ទាល់ខ្លួនក្នុងមួយខែៗ ទាំងដែលគេមិនបានស្ទិតកំណាញ់ ឬហាមឃាត់។

ʹមិនបានសន្សំសំចៃផង តែវាគ្មានអីចង់បានហ្នឹងណ៎ា អូនចង់បានតែបងនិងបានរាល់ថ្ងៃហើយʹ

នាងត្រូវការតែប៉ុណ្ណឹងពិតមែន សេចក្តីសុខរបស់នាងគឺការបានមើលថែគេ បានបបោលអង្អែលគេ ខោអាវដែលស្លៀកពាក់ គ្រីស ត្រូវតែជាអ្នកសម្រេចចិត្តទិញឱ្យ នោះហើយដែលធ្វើឱ្យមនុស្សមុខកាច ដែលមិនធ្លាប់ចាប់អារម្មណ៍រឿងមនុស្សស្រីដូចគេ អាចទិញរបស់របរប្រើប្រាស់ឱ្យភរិយាបានតាំងពីខោអាវខាងក្រៅ ដល់ឈុតក្នុង។

"ស្រួលខ្លួនដល់ហើយ"



Scanned by CamScanner

ពេលចុះទៅក្នុងអាងជាមួយគ្នា នាងក៏ប្រែខ្លួន អង្គុយច្រកកៀរ បែរមុខទៅរកស្វាមី ឱ្យដើមទ្រូងណែនក្បែរបៀតនឹងដើមទ្រូងធំទូលាយ។

"ត្រាំទឹកហើយ ធ្វើអីបន្តទៅ"

"ធ្វើអីៗគ្នា"

"ក្មេងត្រេកកាម"

គ្រីស ស្ដាបអង្អែលត្រគាករបស់ភរិយា នាងក៏សើចកក្អិច គឺនាងឆ្លងរោគត្រេកកាមពីគេ ចង់នៅជិត ចង់បៀត។

"មិនបាច់បៀតពេកទេ"

"ហេតុអី ?"

"ខ្លាចមានអារម្មណ៍"

"មនុស្សចាស់ត្រេកកាម"

"ថាអ្នកណាចាស់"

"អ្នកណាក៏មិនដឹង នៅម្ដុំៗនេះ"

ធីណា គ្រវាសម្រាមដៃ ហើយចាក់ថ្ពាល់របស់ស្វាមី ទើបត្រូវគេធ្វើមុខកាចដាក់ តែនាងមិនខ្លាច ថែមទាំងថើបថ្ពាក់គ្រើម បន្ទាប់មកក៏ប្រមៀលច្រមុះរបស់ខ្លួននឹងច្រមុះស្រួចរបស់គេ។





Scanned by CamScanner

"ចាស់ តែស្រឡាញ់អស់ពីបេះដូង ព្រោះទាំងចាស់ ទាំងសង្ហា"

"ចេះយករួចខ្លួនណាំ"

"បងសម្លាញ់"

"បាទ"

"ស្រឡាញ់អូនទេ"

"ស្រឡាញ់"

"ស្រឡាញ់អូនយូរទៀតប៉ុនណា?"

"ស្រឡាញ់ជារៀងរហូតហ្នឹង"

ពេលឆ្លើយហើយ គ្រីស ក៏ឈោងដៃយកសាប៊ូរាវមកសម្អាតរាងកាយរបស់ភរិយា ធីណា ក៏បណ្ដោយឱ្យគេដុសសាប៊ូផង ឱបថើបផង។

ថ្ងៃឈប់សម្រាកនាងនិងគេមិនធ្លាប់ប្រញាប់ប្រញាល់។ នាងគ្មានអីធ្វើច្រើនទេ ក្រៅពីធ្វើខ្លួនឱ្យស្វាមីស្រឡាញ់ ស្វាមីលង់។

**ស្រឡាញ់គ្នាជារៀងរហូតណាំ ប្ដីសម្លាញ់!**

**( ចប់ )**



Scanned by CamScanner